

ឯកសារគម្ពីរព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកដើម ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ១ ដល់ ភាគ៥០
គឺជារបស់ ឧបាសិកា កាំង ហ្គិចឈាង និងស្វាមី ព្រមទាំងបុត្រធីតា,
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត-សាវង្ស ៗ និងទុកក្នុង
គេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៗ

កែសម្រួលតាមកុំព្យូទ័រ តម្រូវឱ្យកម្មវិធីអានអេឡិចត្រូនិច
ដោយខ្ញុំព្រះករុណា ខ្ញុំបាទ ស្រុង-ចាន់ណា ៗ៕

www.5000-years.org

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# វិនយបិដក
## ចុល្លវគ្គ បឋមភាគ
## ៩

*កម្មក្ខន្ធកៈ  បារិវាសិកក្ខន្ធកៈ*

និង

*សមុច្ចយក្ខន្ធកៈ*

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០១

**ឧទ្ទិសកថា**

**យើងខ្ញុំ សូមផ្តង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។**

**ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។**

**ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។**

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្ដានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

| | | | | | |
|---|---|---|---|---|---|
| 世話人代表 | 無着　成恭 | 世話人 | 松永　然道 | 有馬　実成 |
| 事務局長 | 篠原　鋭一 | | 伊藤　佳通 | 渡井　奎一 |
| | | | 杉谷　義純 | 茂田　真澄 |
| | | | 前田　利勝 | 中島　教之 |
| | | | 永　六輔 | |

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# វិនយបិដក ចុល្លវគ្គ

## បឋមភាគ

៩

## កម្មក្ខន្ធកៈ បារិវាសិកក្ខន្ធកៈ

និង

## សមុច្ចយក្ខន្ធកៈ

ព. ស. ២៥០១

# បឋមោ ភាគោ

នមោ តស្ស ភគវតោ អរហតោ

សម្មាសម្ពុទ្ធស្ស ។

## កម្មក្ខន្ធកំ

(១) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន បណ្ឌុកលោហិតកា ភិក្ខូ អត្តនា ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា យេបិ ចញ្ញេ ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វទេន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវា ពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុស្សុតតរា ច អលមត្តតរា ច មា

# ភាគទី ១

សូមនមស្ការថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ

ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

## កម្មក្ខន្ធកៈ

(១) សម័យនោះ ព្រះសព្វញ្ញុពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង បណ្ឌុកភិក្ខុនឹងលោហិតកភិក្ខុ(១) ទាំងឡាយ ជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃទៀត ដែលជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយពាក្យយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុ៎ះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោកកល់គ្នាប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាច

---

១ ភិក្ខុពីររូបនេះនៅក្នុងពួកឆព្វគ្គិយភិក្ខុ ក្នុងអដ្ឋកថា ថា សូម្បីតែសិស្សគណរបស់ភិក្ខុពីររូបនោះ ក៏គេហៅថា បណ្ឌុកនឹងលោហិតកដែរ ។

ចស្ស ភាយិត្ថ មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។
តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច
ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។ យេ
តេ ភិក្ខូ អប្បិច្ឆា សន្តុដ្ឋា លជ្ជិនោ កុក្កុច្ចកា សិក្ខា-
កាមា តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម
បណ្ឌុកលោហិតកា ភិក្ខូ អត្តនា ភណ្ឌនការកា
កលហការកា វិវាទការកា ភស្សការកា សង្ឃេ
អធិករណការកា យេបិ ចញ្ញេ ភិក្ខូ ភណ្ឌនការកា
កលហការកា វិវាទការកា ភស្សការកា សង្ឃេ
អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វក្ខន្តិ មា
ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវា ពលវំ
បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច
ពហុស្សុតតរា ច អលមត្តតរា ច មា ចស្ស ភាយិត្ថ
មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ
ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ

ជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងកល់គ្នាក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ ។ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស មានសេចក្តីអៀនខ្មាស សេចក្តីរអែង ជាអ្នកប្រាថ្នាក្នុងសិក្ខា ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីបានជាបណ្ឌុកភិក្ខុនឹងលោហិតកភិក្ខុទាំងឡាយ ជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ ក្នុងសង្ឃដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃទៀត ដែលជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយពាក្យយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោកកល់គ្នាប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកពងវៃ ជាពហុស្សុត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងកល់គ្នាក៏ជាបក្ខពួករបស់លោកទាំង-ឡាយ ។ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹង-

ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

(២) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ បណ្ឌុកលោហិតកា ភិក្ខូ អត្តនា ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា យេបិ ចញ្ញេ ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វទេន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវា ពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុស្សុតតរា ច អលមត្តតរា ច មា ចស្ស ភាយិត្ថ មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តីតិ ។ សច្ចំ ភគវាតិ[១] ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ[២]

---

១ ឱរោបិយមរម្មពោត្ថកេសុ ឥតិសទ្ទោ ន បញ្ញាយតិ ។ ២ ឱ.ម. អននុច្ឆវិយំ ។

រឹតតែកើតធំទូលាយឡើងទៀត ៗ លំដាប់នោះ ភិក្ខុទាំងអម្បាលនោះ ក៏យកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះមានព្រះភាគ ។

(២) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បានឮថា បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុទាំងឡាយ ជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ ដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃ ដែលជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុ៎ះផ្តួលផ្តាញ់ពួកលោកបានទេ ចូរលោកពល់គ្នា ប្រឹងដែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សុត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះពួកយើងក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ ។ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្ករហេតុទាំងឡាយដែលកើតហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ ព្រះសព្វញ្ញុពុទ្ធមានព្រះភាគទ្រង់តិះដៀលថា

ភិក្ខវេ តេសំ មោឃបុរិសានំ អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា អត្តនា ភណ្ឌនការកា ។បេ។ សង្ឃេ អធិករណការកា យេបិ ចញ្ញេ ភិក្ខូ ភណ្ឌនការកា ។បេ។ សង្ឃេ អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វក្ខន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវា ពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុស្សុតតរា ច អលមត្ថតរា ច មា ចស្ស ភាយិត្ថ មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ អថខ្វេតំ[១] ភិក្ខវេ អប្បសន្នានំ ចេវ អប្បសាទាយ បសន្នានំ ច ឯកច្ចានំ អញ្ញថត្តាយាតិ ។

---

១ ឱ. ម. អថខោ តំ ។

ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងអម្បាលនោះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ ម្នាលភិក្ខុទាំងឡាយ ហេតុអ្វីបានជាមោឃបុរសទាំងអម្បាលនោះ បង្កហេតុ ។ បេ ។ បង្កអធិករណ៍ក្នុងសង្ឃដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកបង្កហេតុ ។ បេ ។ ជាអ្នកបង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោកពល់គ្នាប្រឹងជជែកឲ្យអស់ទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀតពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងពល់គ្នាក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ ។ ព្រោះហេតុនោះការបង្កហេតុទាំងឡាយដែលមិនទាន់កើតក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យកើតសេចក្ដីជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬដឹកនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមានតែដឹកនាំសេចក្ដីមិនជ្រះថ្លាឲ្យកើតដល់ពួកជនដែលមិនទាន់ជ្រះថ្លានៅឡើយ និងដឹកនាំជនទាំងឡាយខ្លះដែលជ្រះថ្លាស្រាប់ហើយឲ្យទាស់ចិត្តទៅវិញទេតើ ។

(៣) អថខោ ភគវា បណ្ឌុកលោហិតកេ[១] ភិក្ខូ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ទុប្បោសតាយ មហិច្ឆតាយ អសន្តុដ្ឋតាយ[២] សង្គណិកាយ កោសជ្ជស្ស អវណ្ណំ ភាសិត្វា អនេកបរិយាយេន សុភរតាយ សុបោសតាយ អប្បិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធុតស្ស បាសាទិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណំ ភាសិត្វា ភិក្ខូនំ តទនុច្ឆវិកំ តទនុលោមិកំ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ករោតុ ។ ឯវញ្ច បន ភិក្ខវេ កាតព្វំ ។ បឋមំ បណ្ឌុកលោហិតកា ភិក្ខូ ចោទេតព្វា ចោទេត្វា សារេតព្វា សារេត្វា អាបត្តឹ អារោបេតព្វា[៣] អាបត្តឹ អារោបេត្វា[៤] ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ

---

១ ឱ. ម. តេ ។ ២ ឱ. ម. អសន្តុដ្ឋិយា ។ ៣ ឱរោបិយមរម្មបោត្ថកេសុ រោបេតព្វា ។ ៤ ឱ. ម. រោបេត្វា ។

(៣) គ្រានោះ ព្រះមានព្រះភាគ ទ្រង់តិះដៀលបណ្ឌុកភិក្ខុនឹងលោហិតកភិក្ខុដោយអនេកបរិយាយ ហើយទ្រង់សំដែងនូវទោសនៃសភាពជាបុគ្គលដែលគេចិញ្ចឹមបានដោយក្រ នឹងថែទាំបានដោយក្រ មានសេចក្ដីប្រាថ្នាច្រើន មិនមានសេចក្ដីសន្ដោស នៅច្រឡូកច្រឡំដោយពួក មានសេចក្ដីខ្ជិលច្រអូស ទើបទ្រង់សំដែងគុណនៃសភាពជាបុគ្គលដែលគេចិញ្ចឹមបានដោយងាយ នឹងថែទាំបានដោយងាយ មានសេចក្ដីប្រាថ្នាតិច មានសេចក្ដីសន្ដោស មានចិត្តផូរផង់ កំចាត់បង់នូវកិលេស នាំឲ្យកើតសេចក្ដីជ្រះថ្លា មិនសន្សំនូវកិលេសវដ្ដ ប្រារព្ធសេចក្ដីព្យាយាម ហើយទ្រង់សំដែងនូវធម្មីកថាដ៏ល្មមសមគួរដល់កម្មនោះៗដល់ភិក្ខុទាំងឡាយ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ទើបមានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើតជ្ជនីយកម្ម[1]ដល់បណ្ឌុកភិក្ខុនឹងលោហិតកភិក្ខុចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯតជ្ជនីយកម្មនោះសង្ឃគប្បីធ្វើយ៉ាងនេះ ។ សង្ឃត្រូវចោទបណ្ឌុកភិក្ខុនឹងលោហិតកភិក្ខុជាមុន លុះចោទហើយគប្បីរំលឹក លុះរំលឹកហើយគប្បីលើកអាបត្តិឡើង លុះលើកអាបត្តិហើយ ភិក្ខុអ្នកឈ្លាសប្រតិពលគប្បីប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ខ្ញុំ បណ្ឌុកភិក្ខុ

១ កម្មដែលសង្ឃត្រូវធ្វើដល់ភិក្ខុដែលគួរគម្រាម ។

ឥមេ បណ្ឌុកលោហិតកា ភិក្ខូ អត្តនា ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា យេបិ ចញ្ញេ ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វទេន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវាពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុស្សុតតរា ច អលមត្តតរា ច មា ចស្ស ភាយិត្ថ មយម្បិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ករេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ អត្តនា ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា យេបិ ចញ្ញេ ភិក្ខូ ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វទេន្តិ មា ខោ តុម្ហេ អាយស្មន្តោ

និងលោហិតកភិក្ខុនេះជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃទៀត ដែលជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំង-ឡាយ មិនត្រូវឲ្យភិក្ខុនុះផ្ចាលផ្ចាញពួកលោកបានទេ ចូរលោកតល់គ្នា ប្រឹងដំដែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នករាងវៃ ជាពហុស្សុត ទាំងជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងពល់គ្នាក៏ជាពួករបស់លោកទាំងឡាយដែរ ។ ព្រោះហេតុនោះការបង្កហេតុទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីធ្វើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុចុះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បណ្ឌុក-ភិក្ខុនិងលោហិតកភិក្ខុនេះ ជាអ្នកបង្កហេតុ ។បេ។ បង្កអធិករណ៍ក្នុងសង្ឃដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុឯទៀតដែលជាអ្នកបង្កហេតុ ។បេ។ បង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយមិនត្រូវឲ្យភិក្ខុនុះផ្ចាលផ្ចាញពួកលោកបានទេ

ឯសោ អជេសិ ពលវា ពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុស្សុតតរា ច អល-មត្តតរា ច មា ចស្ស ភាយិត្ថ មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ករោតិ ។ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស ករ-ណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ អត្តនា ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា យេបិ ចញ្ញេ ភិក្ខូ ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វទេន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវា ពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុស្សុតតរា ច អលមត្តតរា

## កម្មក្ខន្ធក (សង្ឃធ្វើ) តជ្ជនីយកម្មដល់បណ្ឌុកភិក្ខុនឹងលោហិតកភិក្ខុ

ចូរលោកពល់គ្នាប្រឹងដដែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ទាំងជាអ្នកអង់អាចជាងភិក្ខុនោះផង ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងពល់គ្នាក៏ជាពួករបស់លោកទាំងឡាយដែរ ៗ ព្រោះហេតុនោះការបង្កហេតុទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ៗ សង្ឃធ្វើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុនឹងលោហិតកភិក្ខុ ៗ ការធ្វើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុនឹងលោហិតកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ៗ ខ្ញុំប្រកាសសេចក្ដីនេះជាគំរប់ពីរដងផង ៗ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បណ្ឌុក-ភិក្ខុនឹងលោហិតកភិក្ខុនេះជាអ្នកបង្កហេតុ ៗ បេ ៗ បង្កអធិករណ៍ក្នុងសង្ឃដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកបង្កហេតុ ៗ បេ ៗ បង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយមិនត្រូវឲ្យភិក្ខុនុ៎ះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោកពល់គ្នាប្រឹងដដែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ

ច មា ចស្ស ភាយិត្ថ មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ករោតិ ។ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស ករណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ អត្តនា ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា យេបិ ចញ្ញេ ភិក្ខូ ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វទេន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវា ពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុស្សុតតរា ច អលមត្តតរា ច មា ចស្ស ភាយិត្ថ

ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងរាល់គ្នាក៏ជាពួករបស់លោកទាំងឡាយដែរ ។ ព្រោះហេតុនោះការបង្កហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ។ សង្ឃធ្វើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ ។ ការធ្វើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុនេះជាអ្នកបង្កហេតុ ។ បេ ។ បង្កអធិករណ៍ក្នុងសង្ឃដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុឯទៀតដែលជាអ្នកបង្កហេតុ ។ បេ ។ បង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយមិនត្រូវឲ្យភិក្ខុនុះផ្ដាលផ្ដាញ់ពួកលោកបានទេ ចូរលោករាល់គ្នាប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សុត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ

មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ កណ្ហានានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច កណ្ហានានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។ សាវេជ្ជា បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ករោតិ ។ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស ករណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ កតំ សង្ឃេន បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អសម្មុខា កតំ ហោតិ អប្បដិបុច្ឆា កតំ ហោតិ អប្បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

ព្រោះយើងកប់គ្នាក៏ជាពួករបស់លោកទាំងឡាយដែរ ៗ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើង ការបង្ករហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតដុះដាលឡើងទៀត ៗ សង្ឃផ្តើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ ៗ ការផ្តើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ៗ សង្ឃបានផ្តើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុហើយ ការផ្តើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុនោះសមគួរដល់សង្ឃ ព្រោះហេតុនោះទើបសង្ឃស្ងៀម ៗ ខ្ញុំសូមចាំទុកនូវដំណើរនេះដោយអាការស្ងៀមយ៉ាងនេះ ៗ

(៤) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលសង្ឃរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ គឺកម្មដែលសង្ឃធ្វើកំបាំងមុខ ១ កម្មដែលសង្ឃធ្វើដោយការមិនសាកសួរ ១ កម្មដែលសង្ឃធ្វើដោយមិនតាមពាក្យប្តេជ្ញារបស់ភិក្ខុ ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្ម (កម្មមិនប្រកបដោយធម៌) ផង ជាអវិនយកម្ម (កម្មមិនប្រកបដោយវិន័យ) ផង ជាកម្មដែលសង្ឃរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ៗ

[៥] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុរូបសន្តញ្ច អនាបត្តិយា កតំ ហោតិ អទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ ទេសិតាយ អាបត្តិយា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុរូបសន្តញ្ច ។

[៦] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុរូបសន្តញ្ច អចោទេត្វា កតំ ហោតិ អសារេត្វា កតំ ហោតិ អាបត្តឹ អនារោបេត្វា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុរូបសន្តញ្ច ។

(៥) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយមិនមានអាបត្តិ ១ កម្មដែលធ្វើដោយអាបត្តិមិនមែនជាទេសនាគាមិនី(១) ១ កម្មដែលធ្វើដោយទេសិតាបត្តិ (អាបត្តិដែលភិក្ខុសំដែងហើយ) ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(៦) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនទាន់ចោទសិនហើយស្រាប់តែធ្វើ ១ កម្មដែលមិនទាន់រំលឹកសិនហើយស្រាប់តែធ្វើ ១ កម្មដែលមិនទាន់លើកអាបត្តិឡើងហើយស្រាប់តែធ្វើ ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

---

១ អាបត្តិដែលសំដែងមិនដាច់ អដ្ឋកថាថា បានដល់អាបត្តិពីរកង គឺ បារាជិក ១ សង្ឃាទិសេស ១ តែសារត្ថទីបនីដីកា ថា អាបត្តិដែលមិនមែនជាទេសនាគាមិនីក្នុងទីនេះសំដៅយកអាបត្តិបារាជិក តែម្យ៉ាង ព្រោះតជ្ជនីយកម្មសង្ឃធ្វើដល់ភិក្ខុដែលត្រូវអាបត្តិសង្ឃាទិសេសប៉ុណ្ណោះ មិនមែនធ្វើដល់ភិក្ខុដែលត្រូវអាបត្តិបារាជិកទេ ។

(៧) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អសម្មុខា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(៨) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អប្បដិបុច្ឆា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(៩) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អប្បដិញ្ញាយ កតំ ហោតិ អធម្មេន កតំ ហោតិ

## កម្មក្ខន្ធ ។ តជ្ជនីយកម្មជាកម្មដែលមិនត្រូវតាមធម៌

(៧) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើក្នុងទីកំបាំងមុខ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(៨) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយការមិនសាកសួរ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(៩) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយមិនតាមពាក្យប្តេជ្ញា ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១

វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(១០) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អនាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(១១) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(១២) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច

## វិនយបិដក ចុល្លវគ្គ

កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

[១០] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយមិនមានអាបត្តិ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្ម-កម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

[១១] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិន-យកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយអាបត្តិជាអទេសនាគាមិនី ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយ-កម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

[១២] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃ

ទុប្បដិវិនីតញ្ច ទេសិតាយ អាបត្តិយា កតំ ហោតិ អធម្មេ-ន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុប្បដិវិនីតញ្ច ។

(១៣) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុប្បដិវិនីតញ្ច អចោទេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុប្បដិវិនីតញ្ច ។

(១៤) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុប្បដិវិនីតញ្ច អសារេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុប្បដិវិនីតញ្ច ។

ទៀត គឺកម្មដែលធ្វើដោយទេសិតាបត្តិ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៣) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនបានចោទសិនហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៤) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនបានរំលឹកហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៥) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អាបត្តឹ អនារោបេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

អធម្មកម្ម ទ្វាទសកំ និដ្ឋិតំ ។

(១៦) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច សម្មុខា កតំ ហោតិ បដិបុច្ឆា កតំ ហោតិ បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(១៧) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អាបត្តិយា កតំ ហោតិ ទេសនាគាមិនិយា

(១៥) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនលើកអាបត្តិឡើងសិនហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

ចប់ តជ្ជនីយកម្មមានចំនួន ១២ ក្នុងអធម្មកម្ម ។

(១៦) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិនយផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ គឺកម្មដែលធ្វើក្នុងទីចំពោះមុខ ១ កម្មដែលធ្វើដោយការសាកសួរ ១ កម្មដែលធ្វើតាមពាក្យប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៧) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើតាមអាបត្តិ ១ កម្មដែលធ្វើដោយអាបត្តិជាទេសនាគាមិនី ១

អាបត្តិយា កតំ ហោតិ អទេសនាយ អាបត្តិយា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(១៨) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ចោទេត្វា កតំ ហោតិ សារេត្វា កតំ ហោតិ អាបត្តឹ អារោបេត្វា[១] កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(១៩) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច សម្មុខា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

---

១ ម. រោបេត្វា ។

### កម្មចតុក្កៈ តជ្ជនីយកម្ម ជាកម្មដែលត្រូវតាមធម៌

កម្មដែលធ្វើដោយអទេសិតាបត្តិ ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៨) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលចោទហើយទើបធ្វើ ១ កម្មដែលរំលឹកហើយទើបធ្វើ ១ កម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៩) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើចំពោះមុខ ១ កម្មដែលធ្វើតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

[២០] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច បដិបុច្ឆា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

[២១] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច បដិញ្ញាយ កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

[២២] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ

(៦០) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលសាកសួរហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្ម-កម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(៦១) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលធ្វើតាមពាក្យប្តេជ្ញា ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(៦២) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើតាមអាបត្តិ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែល

សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(២៣) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(២៤) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អទេសិតាយ អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(២៥) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច

ធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(២៣) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលធ្វើដោយអាបត្តិជាទេសនាគាមិនី ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(២៤) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលធ្វើដោយអទេសិតាបត្តិ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(២៥) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ

សុវូបសន្តញ្ច ចោទេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(២៦) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច សារេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(២៧) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អាបត្តឹ អារោបេត្វា[១] កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ តជ្ជនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

ធម្មកម្មទ្វាទសកំ[២] និដ្ឋិតំ ។

---

១ ឱ. រោបេត្វា ។ ២ ធម្មកម្មទ្វាទសកំ ។

កម្មដែលចោទហើយទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(២៦) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលរំលឹកហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង ។

(២៧) ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

ចប់តជ្ជនីយកម្មខាងបំរួន ១២ ក្នុងធម្មកម្ម ។

(២៨) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ។

(២៩) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ អធិសីលេ សីលវិបន្នោ ហោតិ អជ្ឈាចារេ អាចារវិបន្នោ ហោតិ អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ។

(៣០) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ

(២៨) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៣ គឺភិក្ខុអ្នកបង្កហេតុ បង្កជម្លោះ បង្កទាស់ទែង បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ១ ភិក្ខុពាល មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ ១ ភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះចុះ ។

(២៩) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុមានសីលវិបត្តិ[១] ក្នុងអធិសីល ១ ភិក្ខុមានអាចារវិបត្តិក្នុងអជ្ឈាចារ ១ ភិក្ខុមានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(៣០) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ ១ ភិក្ខុពោលតិះដៀលព្រះធម៌ ១ ភិក្ខុពោលតិះដៀល

---

១ ក្នុងទីឯទៀតលោកសំដៅយកអាបត្តិបារាជិកនឹងសង្ឃាទិសេស ប៉ុន្តែក្នុងទីនេះសំដៅយកអាបត្តិសង្ឃាទិសេសតែម្យ៉ាង ហេតុនេះសង្ឃមិនត្រូវធ្វើតជ្ជនីយកម្មព្រោះត្រូវអាបត្តិបារាជិកទេ សង្ឃត្រូវធ្វើតជ្ជនីយកម្មបានចំពោះតែត្រូវអាបត្តិសង្ឃាទិសេស តែម្យ៉ាងប៉ុណ្ណោះ (សារត្ថទីបនីដីកា) ។

សង្ឃស្ស អវណ្ណំ ភាសតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ។

(១១) តិណ្ណំ ភិក្ខវេ ភិក្ខូនំ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ឯកោ ភណ្ឌនការកោ ។បេ។ សង្ឃេ អធិករណការកោ ឯកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ ឯកោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ។

(១២) អបរេសំបិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ឯកោ អធិសីលេ សីលវិបន្នោ ហោតិ ឯកោ អជ្ឈាចារេ អាចារវិបន្នោ ហោតិ ឯកោ អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ ហោតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ។

ព្រះសង្ឃ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(៣១) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ ៣ ពួក គឺភិក្ខុមួយពួកជាអ្នកបង្កហេតុ ។ បេ ។ បង្កអធិករណ៍ក្នុងសង្ឃ ១ ភិក្ខុមួយពួកល្ងង់មិនឈ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ ១ ភិក្ខុមួយពួកនៅច្រឡុកច្រឡំដោយគ្រហស្ថដោយការច្រឡុកច្រឡំមិនសមគួរ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ ៣ ពួកនេះឯង ។

(៣២) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុមួយពួកមានសីលវិបត្តិក្នុងអធិសីល ១ ភិក្ខុមួយពួកមានអាចារវិបត្តិក្នុងអជ្ឈាចារ ១ ភិក្ខុមួយពួកមានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ ៣ ពួកនេះឯង ។

## កម្មក្ខន្ធកេ តិណ្ណំ ភិក្ខូនំ តជ្ជនីយកម្មករណំ

(៣៣) អបរេសំបិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ឯកោ ពុទ្ធស្ស អវណ្ណំ ភាសតិ ឯកោ ធម្មស្ស អវណ្ណំ ភាសតិ ឯកោ សង្ឃស្ស អវណ្ណំ ភាសតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ តជ្ជនីយកម្មំ ករេយ្យ ។

អាកង្ខមានឆក្កំ និដ្ឋិតំ ។

(៣៤) សង្ឃេន[១] តជ្ជនីយកម្មកតេន ភិក្ខវេ ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ ន ភិក្ខុនោវាទកសម្មុតិ សាទិតព្វា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វា យាយ អាបត្តិយា សង្ឃេន តជ្ជនីយកម្មំ កតំ ហោតិ សា អាបត្តិ ន អាបជ្ជិតព្វា អញ្ញា វា តាទិសិកា តតោ វា បាបិដ្ឋតរា កម្មំ ន គរហិតព្វំ កម្មិកា ន គរហិតព្វា ន បកតត្តស្ស ភិក្ខុនោ ឧបោសថោ ឋបេតព្វោ ន បវារណា

---

១ ឱ. សង្ឃេនាតិ ន ទិស្សតិ ។

## កម្មក្ខន្ធកៈ ការធ្វើតជ្ជនីយកម្មដល់ភិក្ខុ ៣ ពួក

(៣៣) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុពួកមួយពោលតិះដៀលព្រះពុទ្ធ ភិក្ខុពួកមួយពោលតិះដៀលព្រះធម៌ ភិក្ខុពួកមួយពោលតិះដៀលព្រះសង្ឃ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ៣ ពួកនេះឯង ។

### ចប់(តជ្ជនីយកម្ម)ដែលសង្ឃប្រាថ្នានឹងធ្វើមានចំនួន ៦ ។

(៣៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃធ្វើតជ្ជនីយកម្មហើយ ត្រូវប្រព្រឹត្តវត្តដោយប្រពៃ ។ ឯការប្រព្រឹត្តវត្តដោយប្រពៃក្នុងតជ្ជនីយកម្មនោះដូច្នេះ គឺភិក្ខុដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយនោះ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឃបានសន្មតហើយក៏គង់មិនត្រូវប្រដៅភិក្ខុនីដែរ សង្ឃបានធ្វើតជ្ជនីយកម្មព្រោះអាបត្តិណា កុំគប្បីឲ្យត្រូវអាបត្តិនោះទៀត ឬអាបត្តិដទៃប្រហែលគ្នាក្តី អាបត្តិធ្ងន់ជាងអាបត្តិមុននោះក្តី ភិក្ខុមិនត្រូវតិះដៀលតជ្ជនីយកម្ម មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើតជ្ជនីយកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណា

ឋបេតព្វា ន សវចនីយំ កាតព្វំ ន អនុវាទោ បដ្ឋបេតព្វោ ន ឱកាសោ ការេតព្វោ ន ចោទេតព្វោ ន សារេតព្វោ ន ភិក្ខូ[១] ភិក្ខូហិ សម្បយោជេតព្វន្តិ ។

តជ្ជនីយកម្មេ អដ្ឋារសវត្តំ និដ្ឋិតំ ។

(៣៩) អថខោ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ អកាសិ ។ តេ សង្ឃេន តជ្ជ-នីយកម្មកតា សម្មា វត្តន្តិ លោមំ ធាតេន្តិ នេត្ថារំ វត្តន្តិ ភិក្ខូ ឧបសង្កមិត្វា ឯវំ វទេន្តិ មយំ អាវុសោ សង្ឃេន តជ្ជនីយកម្មកតា សម្មា វត្តាម លោមំ ធា-តេម នេត្ថារំ វត្តាម កថំ នុ ខោ អម្ហេហិ បដិបជ្ជិ-តព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនី-យកម្មំ បដិប្បស្សម្ភេតុ ។

---

១ ឱ. ភិក្ខូតិ ន ទិស្សតិ ។

ដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ) មិនត្រូវទទួលនាទីជាធំក្នុងវគ្គ មិនត្រូវឲ្យធ្វើឱកាស[1] មិនត្រូវចោទគេ (ដោយវត្ថុ ឬដោយអាបត្តិ) មិនត្រូវរំលឹក (ទោសអ្នកដទៃ) មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ។

ចប់វត្ត ១៨ ក្នុងតជ្ជនីយកម្ម ។

(៣៩) លំដាប់នោះឯង សង្ឃបានធ្វើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុ នឹងលោហិតកភិក្ខុ ។ ភិក្ខុទាំងឡាយនោះដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្របកេម[2] ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម រួចក៏ចូលទៅរកភិក្ខុទាំងឡាយហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ យើងខ្ញុំដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្របកេម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្មហើយ យើងខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៀត ។ ភិក្ខុទាំងឡាយយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូររម្ងាប់តជ្ជនីយកម្មដល់បណ្ឌុកភិក្ខុនឹងលោហិតកភិក្ខុចុះ ។

---

១ ភិក្ខុដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ មិនត្រូវសូមឱកាសភិក្ខុណាមួយដែលមានទោស ដើម្បីចោទភិក្ខុនោះ ។ ២ ស្លូតសុភាពរាបទាប ។

## កម្មក្ខន្ធកេ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ

(៣៦) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ឧបសម្បាទេតិ និស្សយំ ទេតិ សាមណេរំ ឧបដ្ឋាបេតិ ភិក្ខុនោវាទកសម្មុតឹ សាទិយតិ សម្មតោបិ ភិក្ខុនិយោ ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

(៣៧) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន តជ្ជនីយកម្មំ កតំ ហោតិ តំ អាបត្តឹ អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ គរហតិ កម្មិកេ គរហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

(៣៨) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ បកតត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ បវារណំ ឋបេតិ សវចនីយំ ករោតិ អនុវាទំ បដ្ឋបេតិ ឱកាសំ ការេតិ ចោទេតិ

## កម្មក្ខន្ធកៈ តជ្ជនីយកម្មដែលសង្ឃមិនត្រូវរម្ងាប់

(៣៦) ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ គឺភិក្ខុឲ្យឧបសម្បទា ១ ភិក្ខុឲ្យនិស្ស័យ ១ ភិក្ខុឲ្យសាមណេរបម្រើខ្លួន ១ ភិក្ខុទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ ភិក្ខុដែលសង្ឃសន្មតហើយប្រៀនប្រដៅភិក្ខុនីទាំងឡាយ ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

(៣៧) ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើតជ្ជនីយកម្ម ព្រោះអាបត្តិណា ហើយត្រឡប់ត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃប្រហែលគ្នានឹងអាបត្តិមុននោះ ១ ឬអាបត្តិធ្ងន់ជាងអាបត្តិមុននោះ ១ ភិក្ខុតិះដៀលតជ្ជនីយកម្ម ១ ភិក្ខុតិះដៀលពួកភិក្ខុអ្នកធ្វើតជ្ជនីយកម្ម ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ៥ នេះទេ ។

(៣៨) ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុហាមឧបោសថរបស់ភិក្ខុជាបកតត្ត ១ ហាមបវារណារបស់ភិក្ខុជាបកតត្ត ១ ធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណណានោះ) ១ ទទួលនាទីជាធំក្នុងវត្ត ១ ភិក្ខុដែលឲ្យធ្វើឱកាស

សារេតិ ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

នប្បដិប្បស្សម្ភេតព្វអដ្ឋារសកំ និដ្ឋិតំ ។

(៣៩) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ បដិប្បស្សម្ភេតព្វំ ន ឧបសម្បាទេតិ ន និស្សយំ ទេតិ ន សាមណេរំ ឧបដ្ឋាបេតិ ន ភិក្ខុនោវាទកសម្មុតឹ សាទិយតិ សម្មតោបិ ភិក្ខុនិយោ ន ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

(៤០) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន តជ្ជនីយកម្មំ កតំ ហោតិ តំ អាបត្តឹ ន អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ ន គរហតិ កម្មិកេ ន គរហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

(ដើម្បីចោទ)១ ភិក្ខុចោទគេ ១ ភិក្ខុរំលឹកគេ ១ ភិក្ខុប្រកបពួកភិក្ខុ (ឲ្យឈ្លោះ)នឹងពួកភិក្ខុផងគ្នា ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៨ នេះទេ ។

ចប់តជ្ជនីយកម្មដែលសង្ឃមិនត្រូវរម្ងាប់មានចំនួន ១៨ ។

(៣៩) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ គឺភិក្ខុមិនឲ្យឧបសម្បទា ១ មិនឲ្យនិស្ស័យ ១ មិនឲ្យសាមណេរបម្រើខ្លួន ១ មិនទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ បើទុកជាសង្ឃសន្មតឲ្យហើយក៏គង់មិនទៅប្រដៅភិក្ខុនីទាំងឡាយ ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

(៤០) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើតជ្ជនីយកម្មព្រោះអាបត្តិណាហើយ មិនត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃប្រហែលគ្នានឹងអាបត្តិមុននោះ ១ ឬអាបត្តិធ្ងន់ជាងអាបត្តិមុននោះ ១ មិនតិះដៀលតជ្ជនីយ-កម្ម ១ មិនតិះដៀលពួកភិក្ខុអ្នកធ្វើតជ្ជនីយកម្ម ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

## កម្មក្ខន្ធកេ តជ្ជនីយកម្មប្បដិប្បស្សទ្ធិ

(៤១) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ បដិប្បស្សម្ភេតព្វំ ន បកតត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ ន បវារណំ ឋបេតិ ន សវចនីយំ ករោតិ ន អនុវាទំ បដ្ឋបេតិ ន ឱកាសំ ការេតិ ន ចោទេតិ ន សារេតិ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ភិក្ខុនោ តជ្ជនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

បដិប្បស្សម្ភេតព្វអដ្ឋារសកំ និដ្ឋិតំ ។

(៤២) ឯវញ្ច បន ភិក្ខវេ បដិប្បស្សម្ភេតព្វំ ។ តេហិ ភិក្ខវេ បណ្ឌុកលោហិតកេហិ ភិក្ខូហិ សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ មយំ ភន្តេ សង្ឃេន តជ្ជនីយកម្មកតា សម្មា វត្តាម លោមំ បាតេម នេត្ថារំ វត្តាម

## កម្មក្ខន្ធកៈ ការរម្ងាប់តជ្ជនីយកម្ម

(៤១) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុមិនហាមឧបោសថរបស់ភិក្ខុជាបកតត្ត ១ មិនហាមបវារណារបស់ភិក្ខុជាបកតត្ត ១ មិនធ្វើជាអ្នកមានមាត់ពាក្យ ១ មិនទទួលនាទីជាធំក្នុងវត្ត ១ មិនឲ្យធ្វើឱកាស (ដើម្បីចោទ) ១ មិនចោទគេ ១ មិនរំលឹកគេ ១ មិនប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៨ នេះឯង ។

ចប់តជ្ជនីយកម្មដែលសង្ឃត្រូវរម្ងាប់មានចំនួន ១៨ ។

(៤២) ម្នាលភិក្ខុទាំងឡាយ ឯតជ្ជនីយកម្មនោះសង្ឃត្រូវរម្ងាប់យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុទាំងនោះគប្បីចូលទៅរកជំនុំសង្ឃ ហើយធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ហើយសំពះបាទារបស់ភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើង និយាយយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយដែលសង្ឃធ្វើតជ្ជនីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម

តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចាមាតិ ។ ទុតិយម្បិ យាចិតព្វា ។ តតិយម្បិ យាចិតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ សង្ឃេន តជ្ជនីយកម្មកតា សម្មា វត្តន្តិ លោមំ បាតេន្តិ នេត្ថារំ វត្តន្តិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចន្តិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ បដិប្បស្សម្ភេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ សង្ឃេន តជ្ជនីយកម្មកតា សម្មា វត្តន្តិ លោមំ បាតេន្តិ នេត្ថារំ វត្តន្តិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចន្តិ ។ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ បដិប្បស្សម្ភេតិ ។ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។

ខ្ញុំព្រះករុណា ទាំងឡាយមកសូមការរម្ងាប់តជ្ជនីយកម្ម ។ គប្បីសូមជាគំរប់ពីរដងផង ។ គប្បីសូមជាគំរប់បីដងផង ។ ភិក្ខុអ្នកឆ្លាសប្រតិពលគប្បីញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុនេះ ដែលសង្ឃធ្វើតជ្ជនីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្មបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម មកសូមការរម្ងាប់តជ្ជនីយកម្ម ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុនេះ ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្មបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់តជ្ជនីយកម្ម ។ សង្ឃក៏រម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ ។ ការរម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដងផង ។

## កម្មក្ខន្ធកេ តជ្ជនីយកម្មប្បដិប្បស្សទ្ធិ

សុណាតុ មេ ភន្តេ ។បេ។ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ សង្ឃេន តជ្ជនីយកម្មកតា សម្មា វត្តន្តិ លោមំ បាតេន្តិ នេត្ថារំ វត្តន្តិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចន្តិ ។ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ បដិប្បស្សម្ភេតិ ។ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ បដិប្បស្សទ្ធំ សង្ឃេន បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

តជ្ជនីយកម្មំ បឋមំ និដ្ឋិតំ ។

## កម្មក្ខន្ធកៈ ការរម្ងាប់តជ្ជនីយកម្ម

មពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ។ បេ ។ ការរម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្ដីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុនេះ ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់ការយាររលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់តជ្ជនីយកម្ម ។ សង្ឃគួររម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ ។ ការរម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ សង្ឃបានរម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុហើយ ការរម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុគួរដល់សង្ឃ ព្រោះហេតុដូច្នោះទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះដោយអាការស្ងៀមយ៉ាងនេះ ។

**ចប់តជ្ជនីយកម្មជាបឋម ។**

(៦៣) តេន ខោ បន សមយេន អាយស្មា សេយ្យសកោ ពាលោ ហោតិ អព្យត្តោ[១] អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ អបិស្សុ ភិក្ខូ បកតត្តា[២] បរិវាសំ ទេន្តា មូលាយ បដិកស្សន្តា មានត្តំ ទេន្តា អព្ភេន្តា ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា សេយ្យសកោ ពាលោ ភវិស្សតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរិស្សតិ អននុលោមិកេហិ គិហិសំសគ្គេហិ អបិស្សុ ភិក្ខូ បកតត្តា បរិវាសំ ទេន្តា មូលាយ បដិកស្សន្តា មានត្តំ ទេន្តា អព្ភេន្តាតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

(៦៤) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ

---

១ ឱ. អព្យត្តោ ។ ២ ឱ. បកតា ។

(៤៣) សម័យនោះឯង សេយ្យសកភិក្ខុដ៏មានអាយុជាភិក្ខុល្ងង់ មិនឈ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំ ដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយជាបក-តត្តសោតក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សន ឲ្យមានត្ត ឲ្យអព្ភាន ។ ភិក្ខុទាំងឡាយឯណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីបានជាសេយ្យសកដ៏មាន អាយុជាភិក្ខុល្ងង់ មិនឈ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុ ទាំងឡាយជាបកតត្តសោតក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សន ឲ្យ មានត្ត ឲ្យអព្ភាន ។ លំដាប់នោះ ភិក្ខុទាំងអម្បាលនោះក្រាបបង្គំទូល ដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

(៤៤) ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យ ប្រជុំភិក្ខុសង្ឃហើយទ្រង់ត្រាស់សួរភិក្ខុទាំងឡាយក្នុងកាលនោះថា ម្នាល

## កម្មក្ខន្ធកេ និយស្សកម្មំ សេយ្យសកវត្ថុ

សច្ចំ កិរ ភិក្ខវេ សេយ្យសកោ ភិក្ខុ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ អបិស្សុ ភិក្ខូ បកតត្តា បរិវាសំ ទេន្តា មូលាយ បដិកស្សន្តា មានត្តំ ទេន្តា អព្ភេន្តាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ[១] ភិក្ខវេ តស្ស មោឃបុរិសស្ស អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម សោ ភិក្ខវេ មោឃបុរិសោ ពាលោ ភវិស្សតិ អព្យត្តោ អាបត្តិពហុលោ អនបទា-នោ គិហិសំសដ្ឋោ វិហរិស្សតិ អននុលោមិកេហិ គិហិ-សំសគ្គេហិ អបិស្សុ ភិក្ខូ បកតត្តា បរិវាសំ ទេន្តា មូលាយ បដិកស្សន្តា មានត្តំ ទេន្តា អព្ភេន្តា នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ សេយ្យ-សកស្ស ភិក្ខុនោ និយស្សកម្មំ ករោតុ និស្សាយ

---

១ ឱ. អននុច្ឆវិយំ ។

ភិក្ខុទាំងឡាយ ពុថា សេយ្យសកភិក្ខុជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយជាបកតត្តសោតក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សនៈ ឲ្យមានត្ត ឲ្យអព្ភាន ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសនោះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណ មិនគប្បី មិនគួរធ្វើឡើយ ម្នាលភិក្ខុទាំងឡាយ ហេតុអ្វីបានជាមោឃបុរសនោះ ជាបុគ្គលល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយជាបកតត្តសោតក៏ឲ្យបរិវាស ឲ្យមូលាយបដិកស្សនៈ ឲ្យមានត្ត ឲ្យអព្ភាន ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ មិនមែនដឹកនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ លុះទ្រង់បន្ទោសរួច ទ្រង់ធ្វើធម្មីកថាហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើនិយស្សកម្ម[១] ដល់សេយ្យសកភិក្ខុ

---

១ កម្មដែលសង្ឃត្រូវធ្វើឲ្យថយយស ។

តេ វត្តព្វន្តិ ។ ឯវញ្ច បន ភិក្ខវេ កាតព្វំ ។ បឋមំ សេយ្យសកោ ភិក្ខុ ចោទេតព្វោ ចោទេត្វា សារេតព្វោ សារេត្វា អាបត្តិ អារោបេតព្វា អាបត្តឹ អារោបេត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ សេយ្យសកោ ភិក្ខុ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ អបិស្សុ ភិក្ខូ បកតត្តា បរិភាសំ ទេន្តា មូលាយ បដិកស្សន្តា មានត្តំ ទេន្តា អព្ភេន្តា ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មំ ករេយ្យ និស្សាយ តេ វត្តព្វន្តិ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ សេយ្យសកោ ភិក្ខុ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ អបិស្សុ ភិក្ខូ បកតត្តា បរិភាសំ ទេន្តា មូលាយ បដិកស្សន្តា មានត្តំ ទេន្តា អព្ភេន្តា ។ សង្ឃោ សេយ្យសកស្ស ភិក្ខុនោ

ដោយពាក្យថា អ្នកត្រូវនៅដោយមាននិស្ស័យ[1] ។ ម្នាលភិក្ខុទាំង-ឡាយ សង្ឃគប្បីធ្វើនិយស្សកម្មយ៉ាងនេះ ។ សង្ឃត្រូវចោទសេយ្យសក-ភិក្ខុជាមុន លុះចោទហើយត្រូវរំលឹក លុះរំលឹកហើយត្រូវលើកអាបត្តិឡើង លុះលើកអាបត្តិហើយ ត្រូវភិក្ខុអ្នកឆ្លាសប្រតិពលញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សេយ្យសកភិក្ខុនេះ ជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយជាបកតត្តសោតក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សន ឲ្យមានត្ត ឲ្យអព្ភាន ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីធ្វើនិយស្សកម្មដល់សេយ្យសកភិក្ខុដោយពាក្យថា អ្នកត្រូវនៅដោយមាននិស្ស័យ (ទៀត) ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សេយ្យសកភិក្ខុនេះជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយជាបកតត្តក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សន ឲ្យមានត្ត ឲ្យអព្ភាន ។ ឥឡូវនេះសង្ឃធ្វើ

---

១ ភិក្ខុដែលល្ងង់មិនឆ្លាសនោះត្រូវតែសូមនិស្ស័យហើយនៅអាស្រ័យនឹងគ្រូអាចារ្យរបស់ខ្លួន មិនត្រូវនៅដោយនិស្ស័យមុត្តកទេ ។

## កម្មក្ខន្ធកេ និយស្សកម្មំ សេយ្យសកវត្ថុ

និយស្សកម្មំ ករោតិ និស្សាយ តេ វត្ថព្វន្តិ ។ យស្សាយស្មតោ ខមតិ សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មស្ស ករណំ និស្សាយ តេ វត្ថព្វន្តិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ សេយ្យសកោ ភិក្ខុ ពាលោ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ អបិស្សុ ភិក្ខូ បកតត្តា បរិវាសំ ទេន្តា មូលាយ បដិកស្សន្តា មានត្តំ ទេន្តា អព្ភេន្តា ។ សង្ឃោ សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មំ ករោតិ និស្សាយ តេ វត្ថព្វន្តិ ។ យស្សាយស្មតោ ខមតិ សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មស្ស ករណំ និស្សាយ តេ វត្ថព្វន្តិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ។ បេ ។ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ

និយស្សកម្មដល់សេយ្យសកភិក្ខុដោយពាក្យថា អ្នកត្រូវនៅដោយមាននិស្ស័យ(ទៀត) ។ ការធ្វើនិយស្សកម្មដល់សេយ្យសកភិក្ខុដោយពាក្យថា អ្នកត្រូវនៅដោយមាននិស្ស័យ (ទៀត) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សេយ្យសកភិក្ខុនេះ ជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយជាបកតត្តសោតក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សនឲ្យមានត្តឲ្យអព្ភាន ។ ឥឡូវនេះសង្ឃធ្វើនិយស្សកម្មដល់សេយ្យសកភិក្ខុដោយពាក្យថា អ្នកត្រូវនៅដោយមាននិស្ស័យ (ទៀត) ។ ការធ្វើនិយស្សកម្មដល់សេយ្យសកភិក្ខុដោយពាក្យថា អ្នកត្រូវនៅដោយមាននិស្ស័យ (ទៀត) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ។បេ។ លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ

ភាសេយ្យ ។ កតំ សង្ឃេន សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មំ និស្សាយ តេ វត្ថព្វន្តិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤៥) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អសម្មុខា កតំ ហោតិ អប្បដិបុច្ឆា កតំ ហោតិ អប្បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(៤៦) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អនាបត្តិយា កតំ ហោតិ អទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ ទេសិតាយ អាបត្តិយា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

ត្រូវនិយាយឡើង ។ សង្ឃបានធ្វើនិយស្សកម្មដល់សេយ្យសកភិក្ខុដោយពាក្យថា អ្នកត្រូវនៅដោយមាននិស្ស័យ (ទៀត) ដូច្នេះ គួរដល់សង្ឃហើយ ព្រោះហេតុនោះទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះដោយអាការស្ងៀមយ៉ាងនេះ ។

(៤៥) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលសង្ឃរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ គឺកម្មដែលសង្ឃធ្វើកំបាំងមុខ ១ កម្មដែលមិនសាកសួរហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើដោយមិនតាមពាក្យប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(៤៦) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយអនាបត្តិ ១ កម្មដែលធ្វើដោយអាបត្តិមិនមែនជាទេសនាគាមិនី ១ កម្មដែលធ្វើដោយទេសិតាបត្តិ ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

## កម្មក្ខន្ធកេ និយស្សកម្មំ អធម្មកម្មំ

(៤៧) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អចោទេត្វា កតំ ហោតិ អសារេត្វា កតំ ហោតិ អាបត្តឹ អនារោបេត្វា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(៤៨) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អសម្មុខា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(៤៩) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អប្បដិបុច្ឆា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ

កម្មក្ខន្ធកៈ និយស្សកម្ម ជាកម្មដែលមិនត្រូវតាមធម៌

(៤៧) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនទាន់ចោទហើយស្រាប់តែធ្វើ ១ កម្មដែលមិនទាន់រំលឹកហើយស្រាប់តែធ្វើ ១ កម្មដែលមិនទាន់លើកអាបត្តិឡើងហើយធ្វើ ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(៤៨) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើកំបាំងមុខ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(៤៩) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនទាន់សាកសួរហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ

តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(៥០) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អប្បដិញ្ញាយ កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិន-យកម្មញ្ច ទុវូបសន្តញ្ច ។

(៥១) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អនាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តី-ហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(៥២) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អទេសនាគាមិនិយា អាបត្តិយា កតំ

និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(៩០) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយមិនតាមពាក្យប្តេជ្ញា ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(៩១) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយអនាបត្តិ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលសង្ឃរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(៩២) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយអាបត្តិមិនមែនជាទេសនាគាមិនី ១ កម្មដែលធ្វើ

ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(៥៣) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ទេសិតាយ អាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(៥៤) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អចោទេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

មិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយនិយស្ស-កម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

[៩៣] ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយទេសិតាបត្តិ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

[៩៤] ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនទាន់ចោទហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្ម-កម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(៥៥) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អសារេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(៥៦) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អាបត្តឹ អនារោបេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

អធម្មកម្មទ្វាទសកំ និដ្ឋិតំ ។

(៥៧) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច

(៥៥) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិន័យកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនទាន់រំលឹកហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិន័យកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(៥៦) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិន័យកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនទាន់លើកអាបត្តិឡើងហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាអធម្មកម្មផង ជាអវិន័យកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

ចប់និយស្សកម្មមានចំនួន ១២ ក្នុងអធម្មកម្ម ។

(៥៧) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិន័យកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ គឺកម្មដែល

សម្មុខា កតំ ហោតិ បដិបុច្ឆា កតំ ហោតិ បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(៥៨) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អាបត្តិយា កតំ ហោតិ ទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ អទេសិតាយ អាបត្តិយា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(៥៩) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ចោទេត្វា កតំ ហោតិ សារេត្វា កតំ ហោតិ អាបត្តឹ អារោបេត្វា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

ធ្វើចំពោះមុខ ១ កម្មដែលសាកសួរហើយទើបធ្វើ១ កម្មដែលធ្វើតាមពាក្យប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(៤៨) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលធ្វើតាមអាបត្តិ១ កម្មដែលធ្វើដោយអាបត្តិជាទេសនាគាមិនី១ កម្មដែលធ្វើដោយអទេសិតាបត្តិ ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្ម-កម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(៤៩) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលចោទហើយទើបធ្វើ១ កម្មដែលរំលឹកហើយទើបធ្វើ ១ កម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្ម-កម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(៦០) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច សម្មុខា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(៦១) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច បដិបុច្ឆា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(៦២) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច បដិញ្ញាយ កតំ ហោតិ ធម្មេន កតំ ហោតិ

[៦០] ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលធ្វើចំពោះមុខ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

[៦១] ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលសាកសួរហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

[៦២] ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើតាមពាក្យប្តេជ្ញា ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែល

សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(៦៣) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(៦៤) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(៦៥) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច

ធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(៦៣) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើតាមអាបត្តិ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(៦៤) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយអាបត្តិជាទេសនាគាមិនី ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(៦៥) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត

សុវូបសន្តញ្ច អនេសិតាយ អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(៦៦) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ចោទេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(៦៧) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច សារេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

គឺកម្មដែលធ្វើដោយអទេសិតាបត្តិ ១ កម្មដែលធ្វើខុសតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(៦៦) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលចោទហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(៦៧) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលរំលឹកហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

### កម្មក្ខន្ធកេ តិអង្គសមន្នាគតភិក្ខុនោ និយស្សកម្មករណំ

(៦៨) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អាបត្តឹ អារោបេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ និយស្សកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

### ធម្មកម្មេ ទ្វាទសកំ និដ្ឋិតំ ។

(៦៩) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ និយស្សកម្មំ ករេយ្យ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ និយស្សកម្មំ ករេយ្យ ។

## កម្មក្ខន្ធកៈ ការធ្វើនិយស្សកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣

(៦៨) ម្នាលភិក្ខុទាំងឡាយ និយស្សកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកប ដោយអង្គ ៣ នេះឯង ។

ចប់និយស្សកម្មមានចំនួន ១២ ក្នុងធម្មកម្ម ។

(៦៩) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើ និយស្សកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺភិក្ខុជាអ្នកបង្កហេតុ បង្ក ជំលោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ ១ ជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ ១ ជាភិក្ខុនៅច្រឡូក ច្រឡំដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរ ១ ម្នាលភិក្ខុទាំង ឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្មដល់ភិក្ខុដែលប្រកប ដោយអង្គ ៣ នេះឯង ។

(៧០) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ និយស្សកម្មំ ករេយ្យ អធិសីលេ សីលវិបន្នោ ហោតិ អជ្ឈាចារេ អាចារវិបន្នោ ហោតិ អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ និយស្សកម្មំ ករេយ្យ ។

(៧១) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ និយស្សកម្មំ ករេយ្យ ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ និយស្សកម្មំ ករេយ្យ ។

(៧២) តិណ្ណំ ភិក្ខវេ ភិក្ខូនំ អាកង្ខមានោ សង្ឃោ និយស្សកម្មំ ករេយ្យ ឯកោ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ឯកោ ពាលោ ហោតិ

(៧០) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្ស-កម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុមានសីលវិបត្តិក្នុងអធិសីល ១ ភិក្ខុមានអាចារវិបត្តិក្នុងអជ្ឈាចារ ១ ភិក្ខុមានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិ ១ ម្នាលភិក្ខុទាំងឡាយ បើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(៧១) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្ស-កម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ ១ ពោលតិះដៀលព្រះធម៌ ១ ពោលតិះដៀលព្រះសង្ឃ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(៧២) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្ស-កម្មដល់ភិក្ខុ ៣ ពួក គឺភិក្ខុអ្នកបង្កហេតុ បង្កជំលោះ បង្កវិវាទ បង្កតិរច្ឆាន-កថា បង្កអធិករណ៍ក្នុងសង្ឃពួក ១ ភិក្ខុល្ងង់មិនឆ្លាស មានអាបត្តិច្រើន

អព្យត្តោ អាបត្តិពហុលោ អនបទានោ ឯកោ គិហិសំ-
សដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ
ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ
សង្ឃោ និយស្សកម្មំ ករេយ្យ ។

(៧៣) អបរេសំបិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខ-
មានោ សង្ឃោ និយស្សកម្មំ ករេយ្យ ឯកោ អធិ-
សីលេ សីលវិបន្នោ ហោតិ ឯកោ អជ្ឈាចារេ អា-
ចារវិបន្នោ ហោតិ ឯកោ អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ
ហោតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខ-
មានោ សង្ឃោ និយស្សកម្មំ ករេយ្យ ។

(៧៤) អបរេសំបិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខ-
មានោ សង្ឃោ និយស្សកម្មំ ករេយ្យ ឯកោ ពុទ្ធស្ស
អវណ្ណំ ភាសតិ ឯកោ ធម្មស្ស អវណ្ណំ ភាសតិ ឯកោ
សង្ឃស្ស អវណ្ណំ ភាសតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ
ភិក្ខូនំ អាកង្ខមានោ សង្ឃោ និយស្សកម្មំ ករេយ្យ ។

**អាកង្ខមានចតុក្កំ និដ្ឋិតំ ។**

មិនមានការកំណត់អាបត្តិពួក ១ ភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្មដល់ភិក្ខុ ៣ ពួកនេះឯង ។

(៧៣) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្មដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុមានសីលវិបត្តិក្នុងអធិសីលពួក ១ ភិក្ខុមានអាចារវិបត្តិក្នុងអជ្ឈាចារពួក ១ ភិក្ខុមានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្មដល់ភិក្ខុ ៣ ពួកនេះឯង ។

(៧៤) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្មដល់ភិក្ខុទាំងឡាយ ៣ ពួកដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធពួក ១ ពោលតិះដៀលព្រះធម៌ពួក ១ ពោលតិះដៀលព្រះសង្ឃពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្មដល់ភិក្ខុទាំង ៣ ពួកនេះឯង ។

ចប់និយស្សកម្មដែលសង្ឃប្រាថ្នានឹងធ្វើមានចំនួន ៦ ។

(៧៥) និយស្សកម្មកតេន ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ ន ភិក្ខុនោវាទកសម្មតិ សាទិតព្វា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វា យាយ អាបត្តិយា សង្ឃេន និយស្សកម្មំ កតំ ហោតិ សា អាបត្តិ ន អាបជ្ជិតព្វា អញ្ញា វា តាទិសិកា តតោ វា បាបិដ្ឋតរា កម្មំ ន គរហិតព្វំ កម្មិកា ន គរហិតព្វា ន បកតត្តស្ស ភិក្ខុនោ ឧបោសថោ ឋបេតព្វោ ន បវារណា ឋបេតព្វា ន សវចនីយំ កាតព្វំ ន អនុវាទោ បដ្ឋបេតព្វោ ន ឱកាសោ ការេតព្វោ ន ចោទេតព្វោ ន សារេតព្វោ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វន្តិ ។

និយស្សកម្មេ អដ្ឋារសវត្តំ និដ្ឋិតំ ។

(៧៦) អថខោ សង្ឃោ សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មំ អកាសិ និស្សាយ តេ វត្ថព្វន្តិ ។ សោ

(៧៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃបានធ្វើនិយស្សកម្មហើយ ត្រូវប្រព្រឹត្តវត្តដោយប្រពៃ ។ ឯការប្រព្រឹត្តិវត្តដោយប្រពៃក្នុងនិយស្សកម្មនោះដូច្នេះ គឺភិក្ខុមិនត្រូវឲ្យឧបសម្បទា ១ មិនត្រូវឲ្យនិស្ស័យ ១ មិនត្រូវឲ្យសាមណេរបម្រើខ្លួន ១ មិនត្រូវទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ បើទុកជាសង្ឃសន្មតឲ្យហើយ ក៏មិនត្រូវទៅប្រដៅពួកភិក្ខុនីឡើយ ១ និយស្សកម្មដែលសង្ឃធ្វើព្រោះអាបត្តិណា ភិក្ខុកុំឲ្យត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃប្រហែលគ្នានឹងអាបត្តិមុននោះ ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ ១ មិនត្រូវតិះដៀលនិយស្សកម្ម ១ មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម ១ មិនត្រូវហាមឧបោសថរបស់ភិក្ខុជាបកតត្ត ១ មិនត្រូវហាមបវារណា (របស់ភិក្ខុជាបកតត្ត) ១ មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ) ១ មិនត្រូវទទួលនាទីជាធំក្នុងវត្ត ១ មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) ១ មិនត្រូវចោទគេ ១ មិនត្រូវរំលឹកគេ ១ មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុ ១ ៗ

ចប់វត្ត ១៨ ក្នុងនិយស្សកម្ម ។

(៧៦) លំដាប់នោះ សង្ឃបានធ្វើនិយស្សកម្មដល់សេយ្យសកភិក្ខុដោយពាក្យថា លោកត្រូវនៅដោយមាននិស្ស័យ (ទៀត) ៗ សេយ្យសក-

សង្ឃេន និយស្សកម្មកតោ កល្យាណមិត្តេ សេវមានោ ភជមានោ បយិរុបាសមានោ ឧទ្ទិសាបេន្តោ បរិបុច្ឆន្តោ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ បណ្ឌិតោ វិយត្តោ មេធាវី លជ្ជី កុក្កុច្ចកោ សិក្ខាកាមោ សោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ ភិក្ខូ ឧបសង្កមិត្វា ឯវំ វទតិ អហំ អាវុសោ សង្ឃេន និយស្សកម្មកតោ សម្មា វត្តាមិ លោមំ បាតេមិ នេត្ថារំ វត្តាមិ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

(៧៧) តេនហិ ភិក្ខវេ សង្ឃោ សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មំ បដិប្បស្សម្ភេតុ ។ បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ និយស្សកម្មំ ន បដិប្បស្សម្ភេតព្វំ ឧបសម្បាទេតិ និស្សយំ ទេតិ សាមណេរំ ឧបដ្ឋាបេតិ ភិក្ខុនោវាទកសម្មតឹ សាទិយតិ

ភិក្ខុដែលសង្ឃបានធ្វើនិយស្សកម្មហើយនោះ ក៏សេពគប់ចូលទៅអង្គុយជិតពួកភិក្ខុជាកល្យាណមិត្តសូមរៀនបាលីនិងអដ្ឋកថា ក៏បានជាពហុស្សូត ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក អ្នកទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត វាងវៃ មានបញ្ញា មានសេចក្ដីខ្មាស មានសេចក្ដីរអែងប្រាថ្នាក្នុងសិក្ខា សេយ្យសកភិក្ខុនោះ ក៏ប្រព្រឹត្តដោយប្រពៃ ទាំងសម្ងបកោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម ហើយក៏ចូលទៅរកភិក្ខុទាំងឡាយនិយាយពាក្យយ៉ាងនេះថា ម្នាលលោកទាំងឡាយដ៏មានអាយុ ខ្ញុំដែលសង្ឃធ្វើនិយស្សកម្មហើយបានប្រព្រឹត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្មហើយ ខ្ញុំត្រូវប្រតិបត្តិដូចម្ដេចទៀត ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។

(៧៧) ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះសង្ឃចូររម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុចុះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គទាំងឡាយ ៥ គឺភិក្ខុឲ្យឧបសម្បទា ១ ភិក្ខុឲ្យនិស្ស័យ ១ ភិក្ខុឲ្យសាមណេរបម្រើខ្លួន ១ ភិក្ខុទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១

សម្មតោបិ ភិក្ខុនិយោ ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ និយស្សកម្មំ ន បដិប្បស្សម្ភេតព្វំ ។

(៧៨) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ និយស្សកម្មំ ន បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន និយស្សកម្មំ កតំ ហោតិ តំ អាបត្តឹ អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ គរហតិ កម្មិកេ គរហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ និយស្សកម្មំ ន បដិប្បស្សម្ភេតព្វំ ។

(៧៩) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ និយស្សកម្មំ ន បដិប្បស្សម្ភេតព្វំ បកតត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ បវារណំ ឋបេតិ សវចនីយំ ករោតិ អនុវាទំ បដ្ឋបេតិ ឱកាសំ ការេតិ ចោទេតិ សារេតិ ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ភិក្ខុនោ និយស្សកម្មំ ន បដិប្បស្សម្ភេតព្វំ ។

នប្បដិប្បស្សម្ភេតព្វអដ្ឋារសកំ និដ្ឋិតំ ។

ភិក្ខុដែលសង្ឃសន្មតឲ្យហើយ ក៏នៅតែទៅប្រដៅភិក្ខុនីទាំងឡាយ ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ ឡើយ ។

(៧៨) ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើនិយស្សកម្មព្រោះអាបត្តិណាហើយត្រឡប់ត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃប្រហែលនឹងអាបត្តិមុននោះ ១ ឬអាបត្តិធ្ងន់ជាងអាបត្តិនោះ ១ តិះដៀលនិយស្សកម្ម ១ តិះដៀលពួកភិក្ខុអ្នកធ្វើនិយស្សកម្ម ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះទេ ។

(៧៩) ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុហាមឧបោសថរបស់ភិក្ខុជាបកតត្ត ១ ហាមបវារណារបស់ភិក្ខុជាបកតត្ត ១ ធ្វើជាអ្នកមានមាត់ពាក្យ ១ ទទួលនាទីជាធំក្នុងវត្ត ១ ឲ្យធ្វើឱកាស(ដើម្បីចោទ) ១ ចោទគេ ១ រំលឹកគេ ១ ប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៨នេះទេ ។

ចប់និយស្សកម្មមានចំនួន ១៨ ដែលសង្ឃមិនត្រូវរម្ងាប់ ។

## កម្មក្ខន្ធកេ បដិប្បស្សម្ភេតព្វនិយស្សកម្មំ

(៨០) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ និយស្សកម្មំ បដិប្បស្សម្ភេតព្វំ ។ ន ឧបសម្បាទេតិ ។ បេ ។

(៨១) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ និយស្សកម្មំ បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន និយស្សកម្មំ កតំ ហោតិ តំ អាបត្តឹ នាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ ន គរហតិ កម្មិកេ ន គរហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ និយស្សកម្មំ បដិប្បស្សម្ភេតព្វំ ។

(៨២) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ និយស្សកម្មំ បដិប្បស្សម្ភេតព្វំ ន បកតត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ ន បវារណំ ឋបេតិ ន សវចនីយំ ករោតិ ន អនុវាទំ បដ្ឋបេតិ ន ឱកាសំ ការេតិ ន ចោទេតិ ន សារេតិ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ភិក្ខុនោ និយស្សកម្មំ បដិប្បស្សម្ភេតព្វំ ។

**បដិប្បស្សម្ភេតព្វអដ្ឋារសកំ និដ្ឋិតំ ។**

## កម្មក្ខន្ធក និយស្សកម្មដែលសង្ឃត្រូវរម្ងាប់

(៨០) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ គឺភិក្ខុមិនឲ្យឧបសម្បទា ១ ។ បេ ។

(៨១) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឃបានធ្វើនិយស្សកម្មព្រោះអាបត្តិណា ហើយមិនត្រឡប់ត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃប្រហែលនឹងអាបត្តិមុននោះ ១ ឬអាបត្តិធ្ងន់ជាងអាបត្តិមុននោះ ១ មិនតិះ-ដៀលនិយស្សកម្ម ១ មិនតិះដៀលពួកភិក្ខុអ្នកធ្វើនិយស្សកម្ម ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

(៨២) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុមិនហាមឧបោសថរបស់ភិក្ខុជាបកតត្ត ១ មិនហាមបវារណារបស់ភិក្ខុជាបកតត្ត ១ មិនធ្វើឲ្យជាអ្នកមានមាត់ពាក្យ ១ មិនទទួលនាទីជាធំក្នុងវត្ត ១ មិនឲ្យធ្វើឱកាស ( ដើម្បីចោទ ) ១ មិនចោទគេ ១ មិនរំលឹកគេ ១ មិនប្រកបពួកភិក្ខុ ( ឲ្យឈ្លោះ ) នឹងពួកភិក្ខុ ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គទាំង ៨ នេះឯង ។

ចប់និយស្សកម្មមានចំនួន ១៨ ដែលសង្ឃត្រូវរម្ងាប់ ។

## វិនយបិដកេ ចុល្លវគ្គោ

(៨៣) ឯវញ្ច បន ភិក្ខវេ បដិប្បស្សម្ភេតព្វំ ។ តេន ភិក្ខវេ សេយ្យសកេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ សង្ឃេន និយស្សកម្មកតោ សម្មា វត្តាមិ លោមំ បាតេមិ នេត្ថារំ វត្តាមិ និយស្សកម្មស្ស បដិប្បស្សទ្ធិំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា ។ តតិយម្បិ យាចិតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ សេយ្យសកោ ភិក្ខុ សង្ឃេន និយស្សកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ និយស្សកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មំ បដិប្បស្សម្ភេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ សេយ្យសកោ ភិក្ខុ សង្ឃេន និយស្សកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ និយស្សកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ សង្ឃោ សេយ្យសកស្ស

(៨៣) ម្នាលភិក្ខុទាំងឡាយ ឯនិយស្សកម្មនោះ សង្ឃត្រូវរម្ងាប់យ៉ាងនេះ ៗ ម្នាលភិក្ខុទាំងឡាយ សេយ្យសកភិក្ខុនោះគប្បីចូលទៅរកជំនុំសង្ឃ ហើយធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ហើយសំពះបាទារបស់ភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើង និយាយពាក្យយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណាដែលសង្ឃបានធ្វើនិយស្សកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្របពេម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម ខ្ញុំសូមការរម្ងាប់និយស្សកម្ម ៗ គប្បីសូមជាគំរប់ពីរដងផង ៗ គប្បីសូមជាគំរប់បីដងផង ៗ ភិក្ខុអ្នកឆ្លាសប្រតិពលគប្បីញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សេយ្យសកភិក្ខុនេះដែលសង្ឃធ្វើនិយស្សកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្របពេម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់និយស្សកម្ម ៗ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុនោះចុះ ៗ នេះជាញត្តិ ៗ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតសេយ្យសកភិក្ខុនេះដែលសង្ឃបានធ្វើនិយស្សកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្របពេម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួន

ភិក្ខុនោ និយស្សកម្មំ បដិប្បស្សម្ភេតិ ។ យស្សាយស្ម-
តោ ខមតិ សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មស្ស
បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ
ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ
មេ ភន្តេ សង្ឃោ អយំ សេយ្យសកោ ភិក្ខុ សង្ឃេន
និយស្សកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ
វត្តតិ និយស្សកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ សង្ឃោ
សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មំ បដិប្បស្សម្ភេ-
តិ ។ យស្សាយស្មតោ ខមតិ សេយ្យសកស្ស ភិក្ខុនោ
និយស្សកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស
នក្ខមតិ សោ ភាសេយ្យ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។
សុណាតុ មេ ភន្តេ សង្ឃោ អយំ សេយ្យសកោ ភិក្ខុ
សង្ឃេន និយស្សកម្មកតោ សម្មា វត្តតិ លោមំ បា-
តេតិ នេត្ថារំ វត្តតិ និយស្សកម្មស្ស បដិប្បស្សទ្ធឹ យាច-
តិ ។ សង្ឃោ សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មំ
បដិប្បស្សម្ភេតិ ។ យស្សាយស្មតោ ខមតិ សេយ្យ-
សកស្ស ភិក្ខុនោ និយស្សកម្មស្ស បដិប្បស្សទ្ធិ

## កម្មក្ខន្ធក ការរម្ងាប់និយស្សកម្ម

ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់និយស្សកម្ម ។ សង្ឃរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុ ។ ការរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សេយ្យសកភិក្ខុនេះដែលសង្ឃធ្វើនិយស្សកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់និយស្សកម្ម ។ សង្ឃរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុ ។ ការរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សេយ្យសកភិក្ខុនេះដែលសង្ឃបានធ្វើនិយស្សកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោមប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់និយស្សកម្ម ។ សង្ឃរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុ ។ ការរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មាន

សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ បដិប្បស្សទ្ធំ សង្ឃេន សេយ្យសកស្ស ភិក្ខុនោ និយស្សកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

និយស្សកម្មំ ទុតិយំ និដ្ឋិតំ ។

(៨៤) តេន ខោ បន សមយេន អស្សជិបុនព្វសុកា នាម ភិក្ខូ កីដាគិរិស្មឹ អាវាសិកា ហោន្តិ អលជ្ជិនោ បាប-ភិក្ខូ ។ តេ ឯវរូបំ អនាចារំ អាចរន្តិ មាលាវច្ឆំ រោបេន្តិបិ រោបាបេន្តិបិ សិញ្ចន្តិបិ សិញ្ចាបេន្តិបិ ឱចិនន្តិបិ ឱចិ-នាបេន្តិបិ គន្ថេន្តិបិ គន្ថាបេន្តិបិ ឯកតោវណ្ដិកមាលំ ករោន្តិបិ ការាបេន្តិបិ ឧភតោវណ្ដិកមាលំ ករោន្តិបិ ការាបេន្តិបិ មញ្ជរិកំ ករោន្តិបិ ការាបេន្តិបិ វិធូតិកំ[១] ករោន្តិបិ ការាបេន្តិបិ វដំសកំ ករោន្តិបិ ការាបេន្តិបិ អាវេឡំ ករោន្តិបិ ការាបេន្តិបិ ឧរច្ឆទំ ករោន្តិបិ ការា-បេន្តិបិ តេ កុលិត្ថីនំ កុលធីតានំ កុលកុមារីនំ កុល-សុណ្ហានំ កុលទាសីនំ ឯកតោវណ្ដិកមាលំ ហរន្តិបិ

១ មរម្មបោត្ថកេ វិធូតិកន្តិ លិខិតំ ។

អាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ សង្ឃបានរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុហើយ ការរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុគួរដល់សង្ឃហើយ ព្រោះហេតុនោះទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្ដីនេះដោយអាការស្ងៀមយ៉ាងនេះ ។

ចប់និយស្សកម្មជាគំរប់ពីរ ។

[៨៤] សម័យនោះឯង ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក ជាចៅអាវាសទៀបកីដាគិរីជនបទ ជាភិក្ខុលាមកឥតខ្មាស ។ ភិក្ខុទាំងនោះប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះ គឺដាំកូនឈើផ្កាដោយខ្លួនឯងខ្លះ ឲ្យគេដាំខ្លះ ស្រោចខ្លួនឯងខ្លះ ឲ្យគេស្រោចខ្លះ បេះខ្លួនឯងខ្លះ ឲ្យគេបេះខ្លះ ក្រងខ្លួនឯងខ្លះ ឲ្យគេក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើចាក់រំលេចទងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើសម្រាប់ស៊កក្នុងបំពង់ខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុនោះនាំយកផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំយក

### កម្មក្ខន្ធកេ បព្វាជនីយកម្មំ អស្សជិបុនព្វសុកវត្ថុ

ការាបេន្តិបិ ឧភតោវណ្ដិកមាលំ ករោន្តិបិ ការាបេន្តិបិ មញ្ជរិកំ ករោន្តិបិ ការាបេន្តិបិ វិធូតិកំ ករោន្តិបិ ការាបេន្តិបិ វដំសកំ ករោន្តិបិ ការាបេន្តិបិ អាវេឡំ ករោន្តិបិ ការាបេន្តិបិ ឧរច្ឆទំ ករោន្តិបិ ការាបេន្តិបិ តេ កុលិត្ថីហិ កុលធីតាហិ កុលកុមារីហិ កុលសុណ្ហាហិ កុលទាសីហិ សទ្ធឹ ឯកភាជនេបិ ភុញ្ជន្តិ ឯកថាលកេបិ បិវន្តិ ឯកាសនេបិ និសីទន្តិ ឯកមញ្ចេបិ តុវដ្ដេន្តិ ឯកត្ថរណាបិ តុវដ្ដេន្តិ ឯកបាវុរណាបិ តុវដ្ដេន្តិ ឯកត្ថរណបាវុរណាបិ តុវដ្ដេន្តិ វិកាលេបិ ភុញ្ជន្តិ មជ្ជម្បិ បិវន្តិ មាលាគន្ធវិលេបនម្បិ ធារេន្តិ នច្ចន្តិបិ គាយន្តិបិ វាទេន្តិបិ លាសេន្តិបិ នច្ចន្តិយាបិ នច្ចន្តិ នច្ចន្តិយាបិ គាយន្តិ នច្ចន្តិយាបិ វាទេន្តិ នច្ចន្តិយាបិ លាសេន្តិ គាយន្តិយាបិ នច្ចន្តិ

ទៅខ្លះ យកផ្កាកម្រងដែលមានទងតាំងពីរខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំយកផ្កាឈើតាក់រំលេចទងទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំយកផ្កាឈើសម្រាប់សិកក្នុងបំពង់ទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំយកផ្កាកម្រងសម្រាប់ប្រដាប់ក្បាលទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំយកផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំយកផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ ដើម្បីស្រីនៃត្រកូល ដើម្បីធីតានៃត្រកូល ដើម្បីកុមារីនៃត្រកូល ដើម្បីស្រីជាកូនប្រសានៃត្រកូល ដើម្បីទាសីនៃត្រកូលទាំងឡាយ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុទាំងនោះឆាន់ភោជនក្នុងភាជនមួយជាមួយនឹងស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល នឹងទាសីនៃត្រកូលទាំងឡាយខ្លះ ផឹកទឹកក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់ជាមួយគ្នាខ្លះ ដេកលើកម្រាលនឹងដណ្តប់ជាមួយគ្នាខ្លះ ឆាន់ភោជនក្នុងវេលាវិកាលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រងគ្រឿងក្រអូបនឹងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ

គាយន្តិយាបិ គាយន្តិ គាយន្តិយាបិ វាទេន្តិ គាយន្តិយាបិ លាសេន្តិ វាទេន្តិយាបិ នច្ចន្តិ វាទេន្តិយាបិ គាយន្តិ វាទេន្តិយាបិ វាទេន្តិ វាទេន្តិយាបិ លាសេន្តិ លាសេន្តិយាបិ នច្ចន្តិ លាសេន្តិយាបិ គាយន្តិ លាសេន្តិយាបិ វាទេន្តិ លាសេន្តិយាបិ លាសេន្តិ អដ្ឋបទេបិ កីឡន្តិ ទសបទេបិ កីឡន្តិ អាកាសេបិ កីឡន្តិ បរិហារបថេបិ កីឡន្តិ សន្តិកាយបិ កីឡន្តិ ខលិកាយបិ កីឡន្តិ ឃដិកាយបិ[១] កីឡន្តិ សលាកហត្ថេនបិ កីឡន្តិ អក្ខេនបិ កីឡន្តិ បង្គចីរេនបិ[២] កីឡន្តិ វង្កកេនបិ កីឡន្តិ មោក្ខចិកាយបិ កីឡន្តិ ចិង្គុលកេនបិ កីឡន្តិ បត្តាឡ្ហកេនបិ កីឡន្តិ រថកេនបិ កីឡន្តិ ធនុកេនបិ កីឡន្តិ អក្ខរិកាយបិ កីឡន្តិ មនេសិកាយបិ កីឡន្តិ យថាវជ្ជេនបិ កីឡន្តិ ហត្ថិស្មិម្បិ សិក្ខន្តិ អស្សស្មិម្បិ សិក្ខន្តិ រថស្មិម្បិ សិក្ខន្តិ ធនុស្មិម្បិ សិក្ខន្តិ ថរុស្មិម្បិ សិក្ខន្តិ ហត្ថិស្សបិ បុរតោ ធាវន្តិ អស្សស្សបិ បុរតោ ធាវន្តិ រថស្សបិ បុរតោ ធាវន្តិ ធាវន្តិបិ អាធាវន្តិបិ

---

១ ឱ. ម. ឃដិកេនបិ ។ ២ ឱ. ម. បង្គចិរេនបិ ។

ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ កែក្រាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីកំពុងកែក្រាយខ្លះ លេងបាស្កាមានក្រឡា៨[១]ខ្លះ លេងបាស្កាមានក្រឡា១០[២]ខ្លះ លេងបាស្កាក្នុងអាកាស[៣]ខ្លះ លេងវាងផ្លូវដែលខ្លួនគូរកង[៤]ខ្លះ លេងផ្លាត់គ្រាប់(មានគ្រួសជាដើម)ខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ លេងអង្គញ់ខ្លះ លេងផ្លុំស្លឹកខ្លះ លេងកូននង្គ័លខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងកល់ដីខ្សាច់(បាយឡុកបាយឡ)ខ្លះ លេងរថតូចៗខ្លះ លេងធ្នូតូចៗខ្លះ លេងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ លេងទាយចិត្ត(ស្តូបចង់)ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់វិជ្ជាដំរីខ្លះ ហាត់វិជ្ជាសេះខ្លះ ហាត់វិជ្ជារថខ្លះ ហាត់វិជ្ជាធ្នូខ្លះ ហាត់ដង (មានដងដាវជាដើម)ខ្លះ ស្ទុះរត់ពីមុខដំរីខ្លះ ស្ទុះរត់ពីមុខសេះខ្លះ ស្ទុះរត់ពីមុខរថខ្លះ ស្ទុះរត់ទៅខ្លះ ស្ទុះរត់មកខ្លះ

---

១ ចត្រង្គមានក្រឡា ៨ ។ ២ ចត្រង្គមានក្រឡា ១០ ។ ន័យខ្លះប្រែថាបាយខុំ ។ ៣ ចត្រង្គគ្មានក្ដារ លេងតែមាត់ទទេ ។ ៤ ប្រហែលជាលេងបិទមុខបិទពួន ។

ឧស្សេឡ្ហេន្តិបិ[១] អប្ផោដេន្តិបិ[២] និព្ពុជ្ឈន្តិបិ មុដ្ឋីហិបិ យុជ្ឈន្តិ រង្គមជ្ឈេបិ សង្ឃាដឹ បត្ថរិត្វា នច្ចន្តឹ[៣] ឯវំ វទេន្តិ ឥធ ភគិនិ នច្ចស្សូតិ នលាដិកំបិ ទេន្តិ វិវិធំបិ អនាចារំ អាចរន្តិ ។

[៨៥] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ កាសីសុ វស្សំ វុត្ថោ សាវត្ថឹ គច្ឆន្តោ ភគវន្តំ ទស្សនា-យ យេន កីដាគិរិ តទវសរិ ។ អថ ខោ សោ ភិក្ខុ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កីដាគិរឹ បិណ្ឌាយ បាវិសិ បាសាទិកេន អភិក្កន្តេន បដិក្កន្តេន អាលោកិតេន វិលោកិតេន សម្មិញ្ជិតេន បសារិតេន ឱក្ខិត្តចក្ខុ ឥរិយាបថសម្បន្នោ ។ មនុស្សា តំ ភិក្ខុំ បស្សិត្វា ឯវមាហំសុ ក្វាយំ អពលពលោ វិយ មន្ទ-មន្ទោ វិយ ភាកុដិកភាកុដិកោ វិយ កោ ឥមស្ស ឧបគតស្ស បិណ្ឌកំបិ ទស្សតិ អម្ហាកំ បន អយ្យា អស្សជិបុនព្វសុកា សណ្ហា សខិលា សុខសម្ភាសា មិហិតបុព្វង្គមា ឯហិស្វាគតវាទិនោ អព្ភាកុដិកា

១ ម. ឧស្សេឡេន្តិ ។ ២ ឱ. អប្ផោឋេន្តិ ។ ៣ ឱ. នច្ចកឹ ។ ម. នច្ចកី ។

ស្រែកហៅខ្លះ ទះដៃខ្លះ ចំបាប់គ្នាខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្តាលរោងរាំ ហើយនិយាយនឹងស្រីដែលកំពុងរាំ យ៉ាងនេះថា ម្នាលប្អូនស្រី នាងចូររាំក្នុងទីនេះ មើលដូច្នេះខ្លះ ដាក់ម្រាមដៃលើថ្ងាសខ្លួន នឹងថ្ងាសស្រីវិញខ្លះ ប្រព្រឹត្តអនាចារផ្សេងៗខ្លះ (ក្រៅអំពីនេះទៅទៀត) ។

[៨៥] សម័យនោះឯង មានភិក្ខុមួយរូបចាំវស្សាក្នុងដែនកាសី រួចហើយទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ ក៏ដើរសំ-ដៅទៅកិដាគិរីជនបទ ។ លុះវេលាព្រឹកឡើង ភិក្ខុនោះក៏ស្លៀកស្បង់ ប្រដាប់ដោយបាត្រនិងចីវរ ដើរចូលទៅកាន់កិដាគិរីជនបទ ដើម្បីបិណ្ឌបាត មានភ្នែកសង្រួម មានឥរិយាបថបវរំទំ ឈានដើរទៅមុខ ឬថយក្រោយ ក្រឡេកមើលទៅមុខ ឬមើលចំហៀង បត់ដៃចូល ឬលាចេញ គួរឲ្យកើតសេចក្តីជ្រះថ្លា ។ មនុស្សទាំងឡាយឃើញភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា លោកអ្វីនេះ ដូចជាសង្រួមហួស ដូចជាទន់ល្វន់ពេក ដូចជាមុខស្រពោនពេក អ្នកណានឹងឲ្យដុំបាយដល់លោកនេះ ដែលចូលទៅរក (គេនោះ) ចំណែកអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុជាម្ចាស់យើង ពោលពាក្យផ្អែម ពោលពាក្យពីរោះ ពោលពាក្យជាសុខ មានញញឹមញញែមជាមុន តែងនិយាយថា អ្នកចូរមក អ្នកមកល្អហើយ មានមុខមិនស្រពោន

ឧត្តានមុខា បុព្វភាសិនោ តេសំ ខោ នាម បិណ្ឌោ ទា-តព្វោតិ ។ អទ្ទសា ខោ អញ្ញតរោ ឧបាសកោ តំ ភិក្ខុំ កិដាគិរិស្មឹ បិណ្ឌាយ ចរន្តំ ទិស្វាន យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ អភិវាទេត្វា ឯត-ទវោច អបិ ភន្តេ បិណ្ឌោ លព្ភតីតិ ។ ន ខោ អាវុសោ បិណ្ឌោ លព្ភតីតិ ។ ឯហិ ភន្តេ ឃរំ គមិស្សាមាតិ ។ អថខោ សោ ឧបាសកោ តំ ភិក្ខុំ ឃរំ នេត្វា ភោ-ជេត្វា ឯតទវោច កហំ ភន្តេ អយ្យោ គមិស្សតីតិ ។ សាវត្ថឹ ខោ អហំ អាវុសោ គមិស្សាមិ ភគវន្តំ ទស្ស-នាយាតិ ។ តេនហិ ភន្តេ មម វចនេន ភគវតោ បាទេ សិរសា វន្ទាហិ[១] ឯវញ្ច វទេហិ ទុដ្ឋោ ភន្តេ កិដាគិរិស្មឹ អាវាសោ អស្សជិបុនព្វសុកា នាម កិដាគិរិស្មឹ អាវា-សិកា អលជ្ជិនោ បាបភិក្ខូ តេ ឯវរូបំ អនាចារំ អាចរន្តិ

១ ម. វន្ទ ។

មានមុខងើប តែងនិយាយមុន យើងគួរប្រគេនដុំបាយដល់លោកម្ចាស់អស់នោះ ។ ឧបាសកម្នាក់បានឃើញភិក្ខុនោះត្រាច់ទៅបិណ្ឌបាតក្នុងកិដាគិរីជនបទ លុះឃើញហើយក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំភិក្ខុនោះហើយនិយាយយ៉ាងនេះថា សូមមេត្តាប្រោសលោកម្ចាស់បានបង្អាន់ខ្លះដែរឬ ។ ភិក្ខុនោះប្រាប់ថា អាវុសោ បង្អាន់អាត្មាមិនទាន់បានទេ ។ ឧបាសកនោះនិយាយថា សូមមេត្តាប្រោសសូមលោកម្ចាស់និមន្តមក យើងនឹងនាំគ្នាទៅផ្ទះ ។ ទើបឧបាសកនោះនាំភិក្ខុនោះទៅផ្ទះឲ្យឆាន់ស្រេចហើយ ក៏បានសួរដូច្នេះថា សូមមេត្តាប្រោស លោកម្ចាស់នឹងនិមន្តទៅក្នុងទីណាទៀត ។ ភិក្ខុនោះប្រាប់ថា អាវុសោ អាត្មានឹងទៅក្រុងសាវត្ថីដើម្បីគាល់ព្រះដ៏មានព្រះភាគ ។ ឧបាសកនោះផ្តាំថា សូមមេត្តាប្រោស បើដូច្នោះសូមលោកម្ចាស់ថ្វាយបង្គំព្រះបាទាព្រះដ៏មានព្រះភាគដោយត្បូងតាមពាក្យរបស់ខ្ញុំផង ម្យ៉ាងទៀត សូមលោកម្ចាស់ក្រាបបង្គំទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស អាវាសក្នុងកិដាគិរីជនបទខូចហើយ ដ្បិតភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក ជាចៅអាវាសក្នុងកិដាគិរីជនបទ ជាភិក្ខុលាមកឥតខ្មាស ភិក្ខុទាំងពីររូបនោះប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះ

មាលាវច្ឆំ រោបេន្តិបិ រោបាបេន្តិបិ សិញ្ចន្តិបិ សិញ្ចាបេន្តិបិ ឱចិនន្តិបិ ឱចិនាបេន្តិបិ គន្ថេន្តិបិ គន្ថាបេន្តិបិ ឯកតោវណ្ដិកមាលំ ករោន្តិបិ ការាបេន្តិបិ ឧភតោវណ្ដិកមាលំ ករោន្តិបិ ការាបេន្តិបិ មញ្ជរិកំ ករោន្តិបិ ការាបេន្តិបិ វិធូតិកំ ករោន្តិបិ ការាបេន្តិបិ វដំសកំ ករោន្តិបិ ការាបេន្តិបិ អាវេឡំ ករោន្តិបិ ការាបេន្តិបិ ឧរច្ឆទំ ករោន្តិបិ ការាបេន្តិបិ តេ កុលិត្ថីនំ កុលធីតានំ កុលកុមារីនំ កុលសុណ្ហានំ កុលទាសីនំ ឯកតោវណ្ដិកមាលំ ហរន្តិបិ ហារាបេន្តិបិ ឧភតោវណ្ដិកមាលំ ហរន្តិបិ ហារាបេន្តិបិ មញ្ជរិកំ ហរន្តិបិ ហារាបេន្តិបិ វិធូតិកំ ហរន្តិបិ ហារាបេន្តិបិ វដំសកំ ហរន្តិបិ ហារាបេន្តិបិ អាវេឡំ ហរន្តិបិ ហារាបេន្តិបិ ឧរច្ឆទំ ហរន្តិបិ ហារាបេន្តិបិ តេ កុលិត្ថីហិ កុលធីតាហិ កុលកុមារីហិ កុលសុណ្ហាហិ កុលទាសីហិ សទ្ធឹ

## កម្មក្ខន្ធក បព្វាជនីយកម្ម រឿងអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ

គឺដាំកូនឈើផ្កាខ្លួនឯងខ្លះ ឲ្យគេដាំខ្លះ ស្រោចខ្លួនឯងខ្លះ ឲ្យគេស្រោចខ្លះ បេះខ្លួនឯងខ្លះ ឲ្យគេបេះខ្លះ ក្រងខ្លួនឯងខ្លះ ឲ្យគេក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើចាក់រំលេចទងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើដែលដោតជាបង្កោមខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុនោះនាំយកផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំផ្កាកម្រងមានទងទាំងពីរខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាឈើចាក់រំលេចទងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាឈើសម្រាប់ស៊កក្នុងបំពង់ទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ក្បាលទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ ដើម្បីស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយ ភិក្ខុទាំងនោះឆាន់ភោជនក្នុងភាជនមួយជាមួយនឹងស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូល

ឯកភាជនេបិ ភុញ្ជន្តិ ឯកថាលកេបិ បិវន្តិ ឯកាសនេបិ និសីទន្តិ ឯកមញ្ចេបិ តុវដ្ដេន្តិ ឯកត្ថរណាបិ តុវដ្ដេន្តិ ឯកបាវុរណាបិ តុវដ្ដេន្តិ ឯកត្ថរណបាវុរណាបិ តុវដ្ដេន្តិ វិកាលេបិ ភុញ្ជន្តិ មជ្ជំបិ បិវន្តិ មាលាគន្ធវិលេបនំបិ ធារេន្តិ នច្ចន្តិបិ គាយន្តិបិ វាទេន្តិបិ លាសេន្តិបិ នច្ចន្តិយាបិ នច្ចន្តិ នច្ចន្តិយាបិ គាយន្តិ នច្ចន្តិយាបិ វាទេន្តិ នច្ចន្តិយាបិ លាសេន្តិ គាយន្តិយាបិ នច្ចន្តិ គាយន្តិយាបិ គាយន្តិ គាយន្តិយាបិ វាទេន្តិ គាយន្តិយាបិ លាសេន្តិ វាទេន្តិយាបិ នច្ចន្តិ វាទេន្តិយាបិ គាយន្តិ វាទេន្តិយាបិ វាទេន្តិ វាទេន្តិយាបិ លាសេន្តិ លាសេន្តិយាបិ នច្ចន្តិ លាសេន្តិយាបិ គាយន្តិ លាសេន្តិយាបិ វាទេន្តិ លាសេន្តិយាបិ លាសេន្តិ អដ្ឋបទេបិ កីឡន្តិ ទសបទេបិ កីឡន្តិ អាកាសេបិ កីឡន្តិ បរិហារបថេបិ កីឡន្តិ សន្តិកាយបិ កីឡន្តិ ខលិកាយបិ កីឡន្តិ ឃដិកាយបិ កីឡន្តិ សលាកហត្ថេនបិ

តាំងឡាយខ្លះ ផឹកវកក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់ជាមួយគ្នាខ្លះ ដេកលើកម្រាលនឹងដណ្តប់ជាមួយគ្នាខ្លះ ឆាន់ភោជនក្នុងវេលាវិកាលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រងគ្រឿងក្រអូបនិងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ កែ-ក្រាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ កែក្រាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីកំពុងកែក្រាយខ្លះ លេងបាស្កាមានក្រឡា ៨ ខ្លះ លេងបា-ស្កាមានក្រឡា ១០ ខ្លះ លេងបាស្កាក្នុងអាកាសខ្លះ លេងរាំងផ្លូវដែលខ្លួនគូរពេញខ្លះ លេងផ្ទាត់គ្រាប់ (មានគ្រួសជាដើម) ខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហឹងខ្លះ លេងរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ

## កម្មក្ខន្ធកេ បព្វាជនីយកម្មំ អស្សជិបុនព្វសុកវត្ថុ

កីឡន្តិ អក្ខេនបិ កីឡន្តិ បង្គចីរេនបិ[១] កីឡន្តិ វង្កកេនបិ កីឡន្តិ មោក្ខចិកាយបិ កីឡន្តិ ចិង្គុល-កេនបិ កីឡន្តិ បត្តាឡ្ហកេនបិ កីឡន្តិ រថកេនបិ កីឡន្តិ ធនុកេនបិ កីឡន្តិ អក្ខរិកាយបិ កីឡន្តិ មនេសិកាយបិ កីឡន្តិ យថាវជ្ជេនបិ កីឡន្តិ ហត្ថិ-ស្មឹបិ សិក្ខន្តិ អស្សស្មឹបិ សិក្ខន្តិ រថស្មឹបិ សិក្ខន្តិ ធនុស្មឹបិ សិក្ខន្តិ ថរុស្មឹបិ សិក្ខន្តិ ហត្ថិស្សបិ បុរ-តោ ធាវន្តិ អស្សស្សបិ បុរតោ ធាវន្តិ រថស្សបិ បុរ-តោ ធាវន្តិ ធាវន្តិបិ អាធាវន្តិបិ ឧស្សេឡ្ហេន្តិបិ អប្ផោ-ដេន្តិបិ[២] និព្ពុជ្ឈន្តិបិ មុដ្ឋីហិបិ យុជ្ឈន្តិ រង្គមជ្ឈេបិ[៣] សង្ឃាដឹ បត្ថរិត្វា នច្ចកឹ ឯវំ វទន្តិ ឥធ ភគិនិ នច្ចស្សូតិ នលាដិកម្បិ ទេន្តិ វិវិធម្បិ អនាចារំ អាចរន្តិ យេបិ តេ កុលេ មនុស្សា បុព្វេ សទ្ធា អហេសុំ ប-សន្នា តេបិ ឯតរហិ អស្សទ្ធា អប្បសន្នា យានិបិ តា-និ សង្ឃស្ស បុព្វេ ទានបថានិ តានិបិ ឯតរហិ ឧ-បច្ឆិន្នានិ រិញ្ចន្តិ បេសលា ភិក្ខូ និវសន្តិ បាបភិក្ខូ

---

១ ឱ. បង្គចិរេនបិ ។ ២ ឱ. អប្បោឋេន្តិបិ ។ ៣ ឱ. រង្គមជ្ឈំ ។

លេងអង្គញ់ខ្លះ លេងផ្ទុំស្លឹកខ្លះ លេងកូនទង្គ័លខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងកាល់ដីខ្សាច់ខ្លះ លេងរថតូចៗខ្លះ លេងធ្នូតូចៗខ្លះ លេងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ លេងទាយចិត្ត (ស្គុចចង់) ខ្លះ លេងកំប៉ុងត្រាប់គេខ្លះ ហាត់វិជ្ជាដំរីខ្លះ ហាត់វិជ្ជាសេះខ្លះ ហាត់វិជ្ជារថខ្លះ ហាត់វិជ្ជាធ្នូខ្លះ ហាត់ដង (មានដងដាវជាដើម) ខ្លះ ស្ទុះរត់ពីមុខដំរីខ្លះ ស្ទុះរត់ពីមុខសេះខ្លះ ស្ទុះរត់ពីមុខរថខ្លះ ស្ទុះរត់ទៅខ្លះ ស្ទុះរត់មកខ្លះ ស្រែកហៅខ្លះ ទះដៃខ្លះ ចំបាប់គ្នាខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្តាលរោងរាំ ហើយនិយាយនឹងស្រីដែលកំពុងរាំយ៉ាងនេះថា ម្នាលប្អូនស្រី នាងចូររាំក្នុងទីនេះមើលដូច្នេះខ្លះ ដាក់ម្រាមដៃលើថ្ងាសខ្លួននឹងថ្ងាសស្រីរបាំខ្លះ ប្រព្រឹត្តអនាចារផ្សេងៗ (ក្រៅអំពីនេះទៅទៀត) ខ្លះ បពិត្រព្រះអង្គដ៏ចំរើន ក៏មនុស្សទាំងឡាយឯណាដែលធ្លាប់មានសទ្ធាជ្រះថ្លាមកពីមុន ឥឡូវនេះមនុស្សទាំងនោះត្រឡប់ជាគ្មានសទ្ធាគ្មានសេចក្តីជ្រះថ្លាទៅវិញ លំអានទានទាំងឡាយឯណា (ដែលគេធ្លាប់ធ្វើ) ដល់សង្ឃមកពីមុន ឥឡូវនេះលំអានទានទាំងនោះគេក៏ផ្តាច់អស់ហើយ ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ក៏នាំគ្នារត់ចេញ នៅតែពួកភិក្ខុដែលលាមក សូមទ្រង់ព្រះមេត្តាប្រោស

សាធុ ភន្តេ ភគវា កីដាគិរឹ ភិក្ខូ បហិណេយ្យ យថាយំ កីដាគិរិស្មឹ អាវាសោ សណ្ឋហេយ្យាតិ ។ ឯវមាវុសោតិ ខោ សោ ភិក្ខុ តស្ស ឧបាសកស្ស បដិស្សុណិត្វា(១) ឧដ្ឋាយាសនា យេន សាវត្ថី តេន បក្កាមិ អនុបុព្វេន យេន សាវត្ថី ជេតវនំ អនាថបិណ្ឌិកស្ស អារាមោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[៨៦] អាចិណ្ណំ ខោ បនេតំ ពុទ្ធានំ ភគវន្តានំ អាគន្តុកេហិ ភិក្ខូហិ សទ្ធឹ បដិសម្មោទិតុំ ។ អថខោ ភគវា តំ ភិក្ខុំ ឯតទវោច កច្ចិ ភិក្ខុ ខមនីយំ កច្ចិ យាបនីយំ កច្ចិ អប្បកិលមថេន អទ្ធានំ អាគតោ កុតោ ច ត្វំ ភិក្ខុ អាគច្ឆសីតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា អប្បកិលមថេន ចាហំ ភន្តេ អទ្ធានំ អាគតោ ឥធាហំ ភន្តេ កាសីសុ វស្សំវុត្ថោ សាវត្ថឹ អាគច្ឆន្តោ ភគវន្តំ ទស្សនាយ យេន កីដាគិរិ តទវសរឹ

១ ឱ. បដិស្សុត្វា ។

ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះដ៏មានព្រះភាគទ្រង់បញ្ជូនភិក្ខុទាំងឡាយទៅកិដាគិរីជនបទ ដើម្បីឲ្យអាវាសក្នុងកិដាគិរីជនបទនេះបានស្ថិតស្ថេរ (តទៅ) ។ ភិក្ខុនោះទទួលពាក្យបណ្ដាំឧបាសកនោះថា អើអាវុសោ ហើយក្រោកចាកអាសនចៀសចេញទៅកាន់ក្រុងសាវត្ថី ហើយបានចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋី ឯក្រុងសាវត្ថីដោយលំដាប់ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។

(៨៦) ក៏ការទទួលរាក់ទាក់ជាមួយនឹងពួកភិក្ខុជាអាគន្តុកនេះ ជាទំនៀមរបស់ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទាំងឡាយ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរភិក្ខុនោះដូច្នេះថា ម្នាលភិក្ខុ អ្នកល្មមអត់ទ្រាំបានទេឬ អ្នកល្មមប្រព្រឹត្តទៅបានទេឬ អ្នកមកតាមផ្លូវឆ្ងាយមិនសូវលំបាកទេឬ ម្នាលភិក្ខុ ចុះអ្នកមកអំពីទីណា ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គល្មមអត់ទ្រាំទៅបាន បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គល្មមប្រព្រឹត្តទៅបាន បពិត្រព្រះអង្គដ៏ចំរើន មួយវិញទៀត ខ្ញុំព្រះអង្គមកតាមផ្លូវឆ្ងាយមិនសូវលំបាកទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនៅចាំវស្សាក្នុងដែនកាសីរួចហើយ មកក្រុងសាវត្ថីដើម្បីគាល់ព្រះអង្គក្នុងទីនេះ បានដើរសំដៅមកកិដាគិរីជនបទ បពិត្រព្រះអង្គដ៏ចំរើន

អថាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមា-
ទាយ កីដាគិរឹ បិណ្ឌាយ បាវិសឹ អទ្ទសា ខោ មំ ភន្តេ
អញ្ញតរោ ឧបាសកោ កីដាគិរិស្មឹ បិណ្ឌាយ ចរន្តំ
ទិស្វាន យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ
អភិវាទេត្វា ឯតទវោច អបិ ភន្តេ បិណ្ឌោ លព្ភតីតិ
ន ខោ អាវុសោ បិណ្ឌោ លព្ភតីតិ ឯហិ ភន្តេ ឃរំ
គមិស្សាមាតិ អថខោ ភន្តេ សោ ឧបាសកោ មំ ឃរំ
នេត្វា ភោជេត្វា ឯតទវោច កហំ ភន្តេ អយ្យោ គ-
មិស្សតីតិ សាវត្ថឹ ខោ អហំ អាវុសោ គមិស្សាមិ ភគវន្តំ
ទស្សនាយាតិ តេនហិ ភន្តេ មម វចនេន ភគវតោ
បាទេ សិរសា វន្ទាហិ ឯវញ្ច វទេហិ ទុដ្ឋោ ភន្តេ
កីដាគិរិស្មឹ អាវាសោ អស្សជិបុនព្វសុកានាម កីដា-
គិរិស្មឹ អាវាសិកា អលជ្ជិនោ បាបភិក្ខូ តេ ឯវរូបំ
អនាចារំ អាចរន្តិ មាលាវច្ឆំ រោបេន្តិបិ រោបាបេន្តិបិ

## កម្មក្ខន្ធក បញ្ញាជនីយកម្ម រឿងអស្សជិភិក្ខុនឹងបុនព្វសុកភិក្ខុ

លុះវេលាព្រឹកឡើង ខ្ញុំព្រះអង្គស្លៀកស្បង់ហើយប្រដាប់ដោយបាត្រចីវរ ចូលទៅកាន់កិដាគិរីជនបទដើម្បីបិណ្ឌបាត្រ បពិត្រព្រះអង្គដ៏ចំរើន មានឧបាសកម្នាក់បានឃើញខ្ញុំព្រះអង្គកំពុងត្រាច់ទៅបិណ្ឌបាត្រក្នុងកិដាគិរីជនបទ លុះឃើញហើយក៏ចូលមករកខ្ញុំព្រះអង្គ លុះចូលមកហើយថ្វាយបង្គំខ្ញុំព្រះអង្គហើយបានសួរដូច្នេះថា សូមមេត្តាប្រោសលោកម្ចាស់បានចង្ហាន់ខ្លះដែរឬ ខ្ញុំព្រះអង្គប្រាប់ថា ម្នាលអាវុសោ ចង្ហាន់អាត្មាមិនទាន់បានទេ ឧបាសកនោះនិយាយថា សូមមេត្តាប្រោស សូមលោកម្ចាស់និមន្តមក យើងនឹងនាំគ្នាទៅផ្ទះ ។ បពិត្រព្រះអង្គដ៏ចំរើន លុះឧបាសកនោះនាំខ្ញុំព្រះអង្គទៅផ្ទះឲ្យឆាន់ស្រេចហើយបានសួរដូច្នេះថា សូមមេត្តាប្រោស លោកម្ចាស់នឹងនិមន្តទៅក្នុងទីណា ខ្ញុំព្រះអង្គប្រាប់ថា អាវុសោ អាត្មានឹងទៅក្រុងសាវត្ថីដើម្បីគាល់ព្រះដ៏មានព្រះភាគ ឧបាសកនោះក៏ផ្តាំថា សូមមេត្តាប្រោស បើដូច្នោះសូមលោកម្ចាស់ថ្វាយបង្គំព្រះបាទាព្រះដ៏មានព្រះភាគដោយត្បូងតាមពាក្យរបស់ខ្ញុំ ម្យ៉ាងទៀតសូមលោកម្ចាស់ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន អាវាសក្នុងកិដាគិរីជនបទខូចហើយ ព្រោះភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុកជាចោរអាវាសក្នុងកិដាគិរីជនបទជាភិក្ខុលាមកមិនមានសេចក្តីអៀនខ្មាស ភិក្ខុទាំងនោះប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះ គឺដាំកូនឈើផ្កាខ្លួនឯងខ្លះ ឲ្យគេដាំខ្លះ ។ បេ ។

។ បេ ។ ឥមំបិ អនាចារំ អាចរន្តិ យេបិ តេ ភន្តេ មនុស្សា បុព្វេ សទ្ធា អហេសុំ បសន្នា តេបិ ឯតរហិ អស្សទ្ធា អប្បសន្នា យានិបិ តានិ សង្ឃស្ស បុព្វេ ទានបថានិ តានិបិ ឯតរហិ ឧបច្ឆិន្នានិ រិញ្ចន្តិ បេសលា ភិក្ខូ និវសន្តិ បាបភិក្ខូ សាធុ ភន្តេ ភគវា កីដាគិរឹ ភិក្ខូ បហិណេយ្យ យថាយំ កីដាគិរិស្មឹ អាវាសោ សណ្ឋាហេយ្យាតិ ឥតោ អហំ ភគវា អាគច្ឆាមីតិ ។

(៨៧) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ អស្សជិបុនព្វសុកា នាម កីដាគិរិស្មឹ អាវាសិកា អលជ្ជិនោ បាបភិក្ខូ តេ ឯវរូបំ អនាចារំ អាចរន្តិ មាលាវច្ឆំ រោបេន្តិបិ រោបាបេន្តិបិ ។ បេ ។ ឥមំបិ អនាចារំ អាចរន្តិ យេបិ តេ មនុស្សា បុព្វេ សទ្ធា អហេសុំ បសន្នា តេបិ ឯតរហិ អស្សទ្ធា អប្បសន្នា យានិបិ តានិ សង្ឃស្ស បុព្វេ ទានបថានិ

ប្រព្រឹត្តអនាចារផ្សេង ៗ (ក្រៅអំពីនេះទៅទៀត) ខ្លះ បពិត្រព្រះអង្គដ៏ចំរើន ពួកមនុស្សណា ដែលធ្លាប់មានសទ្ធាជ្រះថ្លាមកពីមុន ឥឡូវនេះមនុស្សទាំងនោះក៏ត្រឡប់ជាគ្មានសទ្ធាជ្រះថ្លាទៅវិញ លំពេនទានទាំងឡាយឯណា (ដែលគេធ្លាប់ធ្វើ) ដល់សង្ឃមកពីមុន ឥឡូវនេះលំអានទានទាំងនោះគេក៏ផ្តាច់អស់ទៅ ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ក៏ខ្ចាត់-ភាត់ចេញអស់ នៅតែពួកភិក្ខុដែលលាមក បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះដ៏មានព្រះភាគជាម្ចាស់បញ្ជូនពួកភិក្ខុទៅកាន់កិដាគិរីជនបទ ដើម្បីឲ្យអាវាសក្នុងកិដាគិរីជនបទនេះបានតាំងនៅខ្ជាប់ខ្ជួនដូចដែលវិញ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទើបនឹងមកអំពីទីនោះ ។

(៨៧) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថាអស្សជិភិក្ខុនឹងបុនព្វសុកភិក្ខុជាចៅអាវាសក្នុងកិដាគិរីជនបទ ជាភិក្ខុអលជ្ជីលាមក ភិក្ខុទាំងនោះប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះ គឺដាំកូនឈើផ្កាខ្លួនឯងខ្លះ ឲ្យគេដាំខ្លះ ។ បេ ។ ប្រព្រឹត្តអនាចារមានប្រការផ្សេង ៗ (ក្រៅអំពីនេះទៅទៀត) ខ្លះ ពួកមនុស្សណា ធ្លាប់មានសទ្ធាជ្រះថ្លាមកពីមុន ឥឡូវនេះមនុស្សទាំងនោះក៏បាត់សទ្ធាជ្រះថ្លាទៅវិញ លំអានទាន

តានិបិ ឯតរហិ ឧបច្ឆិន្នានិ រិញ្ចន្តិ បេសលា ភិក្ខូ និវសន្តិ បាបភិក្ខូតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ ភិក្ខវេ តេសំ មោឃបុរិសានំ ។បេ។ កថញ្ហិ នាម តេ ភិក្ខវេ មោឃបុរិសា ឯវរូបំ អនាចារំ អាចរិស្សន្តិ មាលាវច្ឆំ រោបេស្សន្តិបិ រោបាបេស្សន្តិបិ សិញ្ចិស្សន្តិបិ សិញ្ចាបេស្សន្តិបិ ឱចិនិស្សន្តិបិ ឱចិនាបេស្សន្តិបិ គន្ថិស្សន្តិបិ គន្ថាបេស្សន្តិបិ ឯកតោវណ្ដិកមាលំ ករិស្សន្តិបិ ការាបេស្សន្តិបិ ឧភតោវណ្ដិកមាលំ ករិស្សន្តិបិ ការាបេស្សន្តិបិ មញ្ជរិកំ ករិស្សន្តិបិ ការាបេស្សន្តិបិ វិធុតិកំ ករិស្សន្តិបិ ការាបេស្សន្តិបិ វដំសកំ ករិស្សន្តិបិ ការាបេស្សន្តិបិ អាវេឡំ ករិស្សន្តិបិ ការាបេស្សន្តិបិ ឧរច្ឆទំ ករិស្សន្តិបិ ការាបេស្សន្តិបិ តេ កុលិត្ថីនំ កុលធីតានំ កុលកុមារីនំ កុលសុណ្ហានំ កុលទាសីនំ ឯកតោវណ្ដិកមាលំ ហរិស្សន្តិបិ ហរាបេស្សន្តិបិ ឧភតោវណ្ដិកមាលំ ហរិស្សន្តិបិ

ទាំងឡាយឯណា (ដែលគេធ្លាប់ធ្វើ) ដល់សង្ឃក្នុងកាលមុន ឥឡូវនេះ លំអានទានទាំងនោះគេក៏ផ្តាច់អស់ហើយ ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ក៏ខ្ចាត់ខ្ចាត់ចេញអស់ នៅតែពួកភិក្ខុដែលលាមក (សេចក្តីនេះ) ជាពិតមែនឬ ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើនៃមោឃបុរសទាំងនោះមិនសមគួរទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះមិនសមបើនឹងប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះ គឺដាំកូនឈើខ្លួនឯងខ្លះ ឲ្យគេដាំខ្លះ ស្រោចខ្លួនឯងខ្លះ ឲ្យគេស្រោចខ្លះ បេះខ្លួនឯងខ្លះ ឲ្យគេបេះខ្លះ ក្រងខ្លួនឯងខ្លះ ឲ្យគេក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើចាក់រំលេចទងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើសម្រាប់ស៊កក្នុងបំពង់ខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុនោះនាំផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងដែលមានទងទាំងពីរខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ

ការាបេស្សន្តិបិ មញ្ជរិកំ ករិស្សន្តិបិ ការាបេស្សន្តិបិ វិធុតិកំ ករិស្សន្តិបិ ការាបេស្សន្តិបិ វដំសកំ ករិស្សន្តិបិ ការាបេស្សន្តិបិ អាវេឡំ ករិស្សន្តិបិ ការាបេស្សន្តិបិ ឧរច្ឆទំ ករិស្សន្តិបិ ការាបេស្សន្តិបិ តេ កុលិត្ថិយា កុលធីតាយ កុលកុមារិយា កុលសុណ្ហាយ កុលទាសិយា សទ្ធឹ ឯកភាជនេបិ ភុញ្ជិស្សន្តិ ឯកថាលកេបិ បិវិស្សន្តិ ឯកាសនេបិ និសីទិស្សន្តិ ឯកមញ្ចេបិ តុវដ្ដិស្សន្តិ ឯកត្ថរណាបិ តុវដ្ដិស្សន្តិ ឯកបាវុរណាបិ តុវដ្ដិស្សន្តិ ឯកត្ថរណបាវុរណាបិ តុវដ្ដិស្សន្តិ វិកាលេបិ ភុញ្ជិស្សន្តិ មជ្ជំបិ បិវិស្សន្តិ មាលាគន្ធវិលេបនំបិ ធារេស្សន្តិ នច្ចិស្សន្តិបិ គាយិស្សន្តិបិ វាទេស្សន្តិបិ លាសេស្សន្តិបិ នច្ចន្តិយាបិ នច្ចិស្សន្តិ នច្ចន្តិយាបិ គាយិស្សន្តិ នច្ចន្តិយាបិ វាទេស្សន្តិ នច្ចន្តិយាបិ លាសេស្សន្តិ គាយន្តិយាបិ នច្ចិស្សន្តិ គាយន្តិយាបិ គាយិស្សន្តិ គាយន្តិយាបិ វាទេស្សន្តិ គាយន្តិយាបិ

## វិនយបិដក ចុល្លវគ្គ

នាំផ្កាឈើតាក់តែលេបចទង់ទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាឈើសម្រាប់ស៊កក្នុងបំពង់ទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ក្បាលទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ ដើម្បីស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយ ភិក្ខុទាំងនោះឆាន់ភោជនក្នុងភាជនមួយជាមួយនឹងស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល នឹងទាសីនៃត្រកូលទាំងឡាយខ្លះ ផឹកទឹកក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់សំពត់ជាមួយគ្នាខ្លះ ដេកលើកម្រាលដណ្តប់សំពត់ជាមួយគ្នាខ្លះ ឆាន់ភោជនក្នុងវេលាវិកាលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រងគ្រឿងក្រអូបនឹងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ កៃក្រាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ កៃក្រាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ កៃក្រាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ

## កម្មក្ខន្ធកេ បព្វាជនីយកម្មំ អស្សជិបុនព្វសុកវត្ថុ

លាសេន្តិ វាទេន្តិយាបិ នច្ចន្តិ វាទេន្តិយាបិ គាយន្តិ វាទេន្តិយាបិ វាទេន្តិ វាទេន្តិយាបិ លាសេន្តិ លាសេន្តិយាបិ នច្ចន្តិ លាសេន្តិយាបិ គាយន្តិ លាសេន្តិយាបិ វាទេន្តិ លាសេន្តិយាបិ លាសេន្តិ អដ្ឋបទេបិ កីឡន្តិ ទសបទេបិ កីឡន្តិ អាកាសេបិ កីឡន្តិ បរិហារបថេបិ កីឡន្តិ សន្តិកាយបិ កីឡន្តិ ខលិកាយបិ កីឡន្តិ ឃដិកាយបិ កីឡន្តិ សលាកហត្ថេនបិ កីឡន្តិ អក្ខេនបិ កីឡន្តិ បង្គចីរេនបិ កីឡន្តិ វង្កកេនបិ កីឡន្តិ មោក្ខចិកាយបិ កីឡន្តិ ចិង្គុលកេនបិ កីឡន្តិ បត្តាឡ្ហកេនបិ កីឡន្តិ រថកេនបិ កីឡន្តិ ធនុកេនបិ កីឡន្តិ អក្ខរិកាយបិ កីឡន្តិ មនេសិកាយបិ កីឡន្តិ យថាវជ្ជេនបិ កីឡន្តិ ហត្ថិស្មិម្បិ សិក្ខន្តិ អស្សស្មិម្បិ សិក្ខន្តិ រថស្មិម្បិ សិក្ខន្តិ ធនុស្មិម្បិ សិក្ខន្តិ ថរុស្មិម្បិ សិក្ខន្តិ ហត្ថិស្សបិ បុរតោ ធាវន្តិ អស្សស្សបិ បុរតោ ធាវន្តិ រថស្សបិ បុរតោ ធាវន្តិ ធាវន្តិបិ

កម្មក្ខន្ធក បញ្ញាជនីយកម្ម រឿងអស្សជិភិក្ខុនឹងបុនព្វសុកភិក្ខុ

រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីកំពុងកែ-ក្រាយខ្លះ លេងបាស្កាមានក្រឡា ៨ ខ្លះ លេងបាស្កាមានក្រឡា ១០ ខ្លះ លេងបាស្កាក្នុងអាកាសខ្លះ លេងផ្លូវដែលខ្លួនគូរវង់ខ្លះ លេងផ្ទាត់គ្រាប់ (មានគ្រួសជាដើម) ខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ លេងអង្គុញខ្លះ លេងផ្លុំស្លឹកខ្លះ លេងកូននង្គ័លតូចខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងវាល់ដីខ្សាច់ខ្លះ លេងរថតូច ៗ ខ្លះ លេងធ្នូតូច ៗ ខ្លះ លេងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ លេងទាយចិត្ត (ស្តួចចង់) ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់វិជ្ជាដំរីខ្លះ ហាត់វិជ្ជាសេះខ្លះ ហាត់វិជ្ជារថខ្លះ ហាត់វិជ្ជាធ្នូខ្លះ ហាត់ដង (មានដងដាវជាដើម) ខ្លះ ស្ទុះរត់ពីមុខដំរីខ្លះ ស្ទុះរត់ពីមុខសេះខ្លះ ស្ទុះរត់ពីមុខរថខ្លះ ស្ទុះរត់ទៅខ្លះ ស្ទុះរត់មកខ្លះ ស្រែកហ៊ោខ្លះ

អាធាវិស្សន្តិបិ ឧស្សេឡេស្សន្តិបិ អប្ផោដេស្សន្តិបិ(១) និពុជ្ឈិស្សន្តិបិ មុដ្ឋីហិបិ យុជ្ឈិស្សន្តិ រង្គមជ្ឈេបិ សង្ឃា-ដឹ បត្ថរិត្វា នច្ចកឹ ឯវំ វក្ខន្តិ ឥធ ភគិនិ នច្ចស្សូតិ នលាដិកំបិ ទស្សន្តិ វិវិធំបិ អនាចារំ អាចរិស្សន្តិ យេបិ តេ មនុស្សា បុព្វេ សទ្ធា អហេសុំ បសន្នា តេបិ ឯតរហិ អស្សទ្ធា អប្បសន្នា យានិបិ តានិ សង្ឃស្ស បុព្វេ ទាន-បថានិ តានិបិ ឯតរហិ ឧបច្ឆិន្នានិ រិញ្ចន្តិ បេសលា ភិក្ខូ និវសន្តិ បាបភិក្ខូ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា សារីបុត្ត-មោគ្គល្លានេ អាមន្តេសិ គច្ឆថ តុម្ហេ សារីបុត្តា កិដា-គិរឹ គន្ត្វា អស្សជិបុនព្វសុកានំ ភិក្ខូនំ កិដាគិរិស្មា បព្វាជនីយកម្មំ ករោថ តុម្ហាកំ ឯតេ សទ្ធិវិហារិកាតិ ។ កថំ មយំ ភន្តេ អស្សជិបុនព្វសុកានំ ភិក្ខូនំ កិដា-គិរិស្មា បព្វាជនីយកម្មំ ករោម ចណ្ឌា ច(២) តេ ភិក្ខូ

១ ឱ ឧស្សេឡិស្សន្តិបិ អប្ផោដិស្សន្តិបិ ។ ២ ឥធ ចសទ្ទោ ឧភេបិ យមរម្មបោត្ថកេសុ ន ទិស្សតិ ។

ទះដៃខ្លះ ចំបាប់គ្នាខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្តាលពេនរាំហើយ និយាយនឹងស្រីដែលកំពុងរាំយ៉ាងនេះថា ម្នាលប្អូនស្រី នាងចូររាំក្នុងទីនេះ មើលដូច្នេះខ្លះ ដាក់ម្រាមដៃលើថ្ងាសខ្លួននឹងថ្ងាសស្រីរបាំខ្លះ ប្រព្រឹត្តអនាចារផ្សេងៗ(ក្រៅអំពីនេះទៅទៀត)ខ្លះ ក៏ពួកមនុស្សណា ធ្លាប់មានសទ្ធាជ្រះថ្លាមកអំពីមុន ឥឡូវនេះមនុស្សទាំងនោះត្រឡប់ជាគ្មានសទ្ធាជ្រះថ្លាទៅវិញ លំអានទានទាំងឡាយឯណា(ដែលគេធ្លាប់ធ្វើ)ដល់សង្ឃក្នុងកាលមុន ឥឡូវនេះលំអានទានទាំងនោះគេក៏ផ្តាច់អស់ទៅហើយ ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ក៏ខ្លាត់ភ្លាត់ចេញអស់ នៅតែពួកភិក្ខុលាមក ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថារួចត្រាស់ហៅព្រះសារីបុត្តនឹងព្រះមោគ្គល្លានមកថា ម្នាលសារីបុត្តនឹងមោគ្គល្លាន ចូរអ្នកទាំងឡាយទៅកិដាគិរីជនបទ ហើយធ្វើបព្វាជនីយកម្ម[1] ដល់ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុក ( ឲ្យចេញ ) ពីកិដាគិរីជនបទចេញ ( ដ្បិត ) ភិក្ខុទាំងនុ៎ះជាសទ្ធិវិហារិករបស់អ្នកទាំងឡាយស្រាប់ហើយ ។ ព្រះសារីបុត្តនឹងព្រះមោគ្គល្លានក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំនឹងធ្វើបព្វាជនីយកម្មដល់ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុក

---

១ កម្មដែលសង្ឃត្រូវបណ្តេញឬបំបរបង់ភិក្ខុដែលមានទោសឲ្យចេញពីទីអាវាស ។

ផរុសាតិ ។ តេនហិ តុម្ហេ សារីបុត្តា ពហុកេហិ ភិក្ខូហិ សទ្ធឹ គច្ឆថាតិ ។ ឯវំ ភន្តេតិ ខោ សារីបុត្តមោគ្គល្លានា ភគវតោ បច្ចស្សោសុំ ។

(៨៨) ឯវញ្ច បន ភិក្ខវេ កាតព្វំ ។ បឋមំ អស្សជិបុនព្វសុកា ភិក្ខូ ចោទេតព្វា ចោទេត្វា សារេតព្វា សារេត្វា អាបត្តឹ អារោបេតព្វា អាបត្តឹ អារោបេត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ អស្សជិបុនព្វសុកា ភិក្ខូ កុលទូសកា បាបសមាចារា ឥមេសំ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ច ឥមេហិ ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ អស្សជិបុនព្វសុកានំ ភិក្ខូនំ កីដាគិរិស្មា បព្វាជនីយកម្មំ ករេយ្យ នាស្សជិបុនព្វសុកេហិ ភិក្ខូហិ កីដាគិរិស្មឹ វត្ថព្វន្តិ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ

(ឲ្យចេញ) ចាកកិដាគិរីជនបទដូចម្ដេចបាន ព្រោះភិក្ខុទាំងនោះសុទ្ធតែជាមនុស្សកាចរឹងរូសណាស់ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្តមោគ្គល្លាន បើដូច្នោះ ចូរអ្នកទាំងឡាយទៅជាមួយនឹងពួកភិក្ខុច្រើនរូបចុះ ។ ព្រះសារីបុត្តនឹងព្រះមោគ្គល្លានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។

(៨៨) ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឯបញ្ញាជនីយកម្មនេះសង្ឃត្រូវធ្វើយ៉ាងនេះ ។ ត្រូវចោទភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុកជាមុន លុះចោទហើយ ត្រូវរំលឹក លុះរំលឹកហើយ ត្រូវលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុដែលឈ្លាសប្រតិពល ត្រូវផ្ដៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ (ដ្បិត) ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុកនេះជាអ្នកទ្រុស្តត្រកូល ជាអ្នកមានមារយាទអាក្រក់ មារយាទអាក្រក់របស់ភិក្ខុទាំងនេះ គេក៏បានឃើញ បានឮ ទាំងពួកត្រកូលដែលភិក្ខុទាំងនេះទ្រុស្តហើយ គេក៏បានឃើញ បានឮដែរ ។ បើបញ្ញាជនីយកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើបញ្ញាជនីយកម្មដល់ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរីជនបទថា ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរីជនបទទេ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន

សង្ឃោ ឥមេ អស្សជិបុនព្វសុកា ភិក្ខូ កុលទូសកា បាបសមាចារា ឥមេសំ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ច ឥមេហិ ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ សង្ឃោ អស្សជិបុនព្វសុកានំ ភិក្ខូនំ កីដាគិរិស្មា បព្វាជនីយកម្មំ ករោតិ ន អស្សជិបុនព្វសុកេហិ ភិក្ខូហិ កីដាគិរិស្មឹ វត្ថព្វន្តិ ។ យស្សាយស្មតោ ខមតិ អស្សជិបុនព្វសុកានំ ភិក្ខូនំ កីដាគិរិស្មា បព្វាជនីយកម្មស្ស ករណំ ន អស្សជិបុនព្វសុកេហិ ភិក្ខូហិ កីដាគិរិស្មឹ វត្ថព្វន្តិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ អស្សជិបុនព្វសុកា ភិក្ខូ កុលទូសកា បាបសមាចារា ឥមេសំ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ច ឥមេហិ ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ សង្ឃោ អស្សជិបុនព្វសុកានំ ភិក្ខូនំ កីដាគិរិស្មា បព្វាជនីយកម្មំ ករោតិ ន អស្សជិបុនព្វសុកេហិ ភិក្ខូហិ កីដាគិរិស្មឹ វត្ថព្វន្តិ ។

សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) ភិក្ខុឈ្មោះអស្សជិនិងភិក្ខុឈ្មោះបុនព្វសុកនេះជាអ្នកទ្រុស្តត្រកូលមានមារយាទអាក្រក់ មារយាទអាក្រក់របស់ភិក្ខុទាំងនេះគេក៏បានឃើញ បានឮ ទាំងពួកត្រកូលដែលភិក្ខុទាំងនេះទ្រុស្តហើយគេក៏បានឃើញ បានឮដែរ ៗ (ឥឡូវ) សង្ឃធ្វើបព្វាជនីយកម្មដល់ភិក្ខុឈ្មោះអស្សជិនិងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរីជនបទថា ភិក្ខុឈ្មោះអស្សជិនិងភិក្ខុឈ្មោះបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរីជនបទទេ ។ ការធ្វើបព្វាជនីយកម្មដល់ភិក្ខុឈ្មោះអស្សជិនិងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរីជនបទថា ភិក្ខុឈ្មោះអស្សជិនិងភិក្ខុឈ្មោះបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរីជនបទទេ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏-មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) ភិក្ខុឈ្មោះអស្សជិនិងភិក្ខុឈ្មោះបុនព្វសុកនេះជាអ្នកទ្រុស្តត្រកូល ជាអ្នកមានមារយាទអាក្រក់ មារយាទអាក្រក់របស់ភិក្ខុទាំងនេះគេក៏បានឃើញ បានឮ ទាំងពួកត្រកូលដែលភិក្ខុទាំងនេះទ្រុស្តហើយ គេក៏បានឃើញ បានឮដែរ ៗ សង្ឃធ្វើបព្វាជនីយកម្មដល់ភិក្ខុឈ្មោះអស្សជិនិងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ចាកកិដាគិរីជនបទថា ភិក្ខុឈ្មោះអស្សជិនិងភិក្ខុឈ្មោះបុនព្វសុកមិនត្រូវ

យស្សាយស្មតោ ខមតិ អស្សជិបុនព្វសុកានំ ភិក្ខូនំ កិដាគិរិស្មា បព្វាជនីយកម្មស្ស ករណំ នអស្សជិបុនព្វសុកេហិ ភិក្ខូហិ កិដាគិរិស្មឹ វត្ថព្វន្តិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ អស្សជិបុនព្វសុកា ភិក្ខូ កុលទូសកា បាបសមាចារា ឥមេសំ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ច ឥមេហិ ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ សង្ឃោ អស្សជិបុនព្វសុកានំ ភិក្ខូនំ កិដាគិរិស្មា បព្វាជនីយកម្មំ ករោតិ នអស្សជិបុនព្វសុកេហិ ភិក្ខូហិ កិដាគិរិស្មឹ វត្ថព្វន្តិ ។ យស្សាយស្មតោ ខមតិ អស្សជិបុនព្វសុកានំ ភិក្ខូនំ កិដាគិរិស្មា បព្វាជនីយកម្មស្ស ករណំ នអស្សជិបុនព្វសុកេហិ ភិក្ខូហិ កិដាគិរិស្មឹ វត្ថព្វន្តិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ កតំ សង្ឃេន

## កម្មវត្ថុ ការធ្វើបព្វាជនិយកម្ម

នៅក្នុងកិដាគិរីជនបទនេះ ។ ការធ្វើបព្វាជនីយកម្មដល់ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរីជនបទថា ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរីជនបទនេះដូច្នេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុកនេះ ជាអ្នកទ្រុស្តត្រកូល ជាអ្នកមានមារយាទអាក្រក់ មារយាទអាក្រក់របស់ភិក្ខុទាំងនេះ គេក៏បានឃើញ បានឮ ទាំងពួកត្រកូលដែលភិក្ខុទាំងនេះទ្រុស្តហើយ គេក៏បានឃើញ បានឮដែរ ។ សង្ឃធ្វើបព្វាជនីយកម្មដល់ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរីជនបទថា ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរីជនបទនេះ ។ ការធ្វើបព្វាជនីយកម្មដល់ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរីជនបទថា ភិក្ខុឈ្មោះអស្សជិនឹងភិក្ខុឈ្មោះបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរីជនបទដូច្នេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។

អស្សជិបុនព្វសុកានំ ភិក្ខូនំ កិដាគិរិស្មា បព្វាជនីយ-
កម្មំ ន អស្សជិបុនព្វសុកេហិ ភិក្ខូហិ កិដាគិរិស្មិំ វត្ថព្វន្តិ
ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៨៩] តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ បព្វាជ-
នីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូប-
សន្តញ្ច អសម្មុខា កតំ ហោតិ អប្បដិបុច្ឆា កតំ ហោតិ
អប្បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តី-
ហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ អធម្មកម្មញ្ច
ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

[៩០] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ
បព្វាជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច
ទុវូបសន្តញ្ច អនាបត្តិយា កតំ ហោតិ អទេសនាគាមិនិ-
យា អាបត្តិយា កតំ ហោតិ ទេសិតាយ អាបត្តិយា
កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នា-
គតំ បព្វាជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយ-
កម្មញ្ច ទុវូបសន្តញ្ច ។

សង្ឃបានធ្វើបព្វាជនីយកម្មដល់ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរីជនបទថា ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរីជនបទគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ។

(៨៩) ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ គឺកម្មដែលសង្ឃធ្វើក្នុងទីកំបាំងមុខ ១ កម្មដែលធ្វើដោយមិនសាកសួរ ១ កម្មដែលធ្វើមិនតាមពាក្យប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គទាំង ៣ នេះឯង ។

(៩០) ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយមិនមានអាបត្តិ ១ កម្មដែលធ្វើដោយអាបត្តិជាអទេសនាគាមិនី ១ កម្មដែលធ្វើដោយអាបត្តិដែលភិក្ខុសំដែងហើយ ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គទាំង ៣ នេះឯង ។

[៩១] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អចោទេត្វា កតំ ហោតិ អសារេត្វា កតំ ហោតិ អាបត្តឹ អនារោបេត្វា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ ។ បេ ។

[៩២] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។ អសម្មុខា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។ អប្ប-ដិបុច្ឆា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។ អប្បដិញ្ញាយ កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។ អនាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។ អទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។ ទេសិតាយ អាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។ អចោទេត្វា កតំ

## កម្មត្តិក បញ្ចានន្តរិយកម្មជាកម្មដែលមិនត្រូវតាមធម៌

(៩១) ម្នាលភិក្ខុទាំងឡាយ បញ្ចានន្តរិយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនទាន់បានចោទហើយស្រាប់តែធ្វើ ១ កម្មដែលមិនទាន់បានរំលឹកហើយស្រាប់តែធ្វើ ១ កម្មដែលមិនទាន់បានលើកអាបត្តិឡើងហើយស្រាប់តែធ្វើ ១ ម្នាលភិក្ខុទាំងឡាយ ។បេ។

(៩២) ម្នាលភិក្ខុទាំងឡាយ បញ្ចានន្តរិយកម្ម ប្រកបដោយអង្គ ៣ ដទៃទៀត ។បេ។ គឺកម្មដែលធ្វើកំបាំងមុខ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ បញ្ចានន្តរិយកម្ម ប្រកបដោយអង្គទាំង៣នេះឯង ។បេ។ កម្មដែលធ្វើដោយមិនបានសាកសួរ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ។បេ។ កម្មដែលធ្វើមិនតាមពាក្យប្តេជ្ញា ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ។បេ។ កម្មដែលធ្វើដោយមិនមានអាបត្តិ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ។បេ។ កម្មដែលធ្វើដោយអាបត្តិជាអទេសនាគាមិនី ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ។បេ។ កម្មដែលធ្វើដោយអាបត្តិដែលភិក្ខុសំដែងហើយ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ។បេ។

ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។ អសារេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។ អាបត្តិ អនារោបេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

អធម្មកម្ម ទ្វាទសកំ និដ្ឋិតំ ។

(៩៣) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច សម្មុខា កតំ ហោតិ បដិបុច្ឆា កតំ ហោតិ បដិញ្ញាយ កតំ ហោតិ ។ បេ ។

(៩៤) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អាបត្តិយា កតំ ហោតិ ទេសនាគាមិ-

កម្មដែលមិនទាន់បានចោទហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ។បេ។ កម្មដែលមិនទាន់រំលឹកហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើជាពួក ១ ។បេ។ កម្មដែលមិនទាន់លើកអាបត្តិឡើងហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់អាក្រក់ផង ប្រកបដោយអង្គទាំង ៣ នេះឯង ។

ចប់ បព្វាជនីយកម្មមានចំនួន១២ក្នុងអធម្មកម្ម ។

(៩៣) ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ គឺកម្មដែលធ្វើក្នុងទីចំពោះមុខ ១ កម្មដែលធ្វើដោយការសាកសួរ ១ កម្មដែលធ្វើតាមពាក្យប្តេជ្ញា ១ ។បេ។

(៩៤) ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយអាបត្តិ ១ កម្មដែលធ្វើដោយអាបត្តិជាទេសនាគាមិនី ១

និយា អាបត្តិយា កតំ ហោតិ អទេសិតាយ អាបត្តិយា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

[៩៥] អបរេហិបិ ។ បេ ។ អចោទេត្វា កតំ ហោតិ អសារេត្វា កតំ ហោតិ អាបត្តឹ អនារោបេត្វា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។

[៩៦] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច សម្មុខា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ធម្មកម្មញ្ច ។ បេ ។

[៩៧] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។ បដិញ្ញាយ កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។

កម្មដែលធ្វើដោយអាបត្តិដែលភិក្ខុមិនបានសំដែង ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គទាំង ៣ នេះឯង ។

(៩៥) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលចោទហើយទើបធ្វើ ១ កម្មដែលរំលឹកហើយទើបធ្វើ ១ កម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មប្រកបដោយអង្គទាំង ៣ នេះឯង ។ បេ ។

(៩៦) ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មជាធម្មកម្មផង ជាវិនយ-កម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលធ្វើក្នុងទីចំពោះមុខ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មប្រកបដោយអង្គទាំង ៣ នេះឯងជាធម្មកម្មផង ។ បេ ។

(៩៧) ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មប្រកបដោយអង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយការសាកសួរ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មប្រកបដោយអង្គទាំង ៣ នេះឯង ។ បេ ។

(៩៨) អបរេហិបិ ។ បេ ។ បដិញ្ញាយ កាតំ ហោតិ ធម្មេន កាតំ ហោតិ សមគ្គេន កាតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ធម្មកម្មញ្ចេវ ។ បេ ។

(៩៩) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។ អាបត្តិយា កាតំ ហោតិ ធម្មេន កាតំ ហោតិ សមគ្គេន កាតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។

(១០០) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។ ទេសនាគាមិនិយា អាបត្តិយា កាតំ ហោតិ ធម្មេន កាតំ ហោតិ សមគ្គេន កាតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។

(១០១) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។ អទេសិតាយ អាបត្តិយា កាតំ ហោតិ ធម្មេន កាតំ ហោតិ សមគ្គេន កាតំ ហោតិ.

(៩៨) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើតាមពាក្យប្តេជ្ញា ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មប្រកបដោយអង្គទាំង ៣ នេះឯងជាធម្មកម្មផង ។ បេ ។

(៩៩) ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មប្រកបដោយអង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើតាមអាបត្តិ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយ-កម្មប្រកបដោយអង្គទាំង ៣ នេះឯង ។ បេ ។

(១០០) ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មប្រកបដោយអង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើតាមអាបត្តិជាទេសនាគាមិនី ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មប្រកបដោយអង្គទាំង ៣ នេះឯង ។ បេ ។

(១០១) ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មប្រកបដោយអង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយអាបត្តិដែលភិក្ខុមិនបានសំដែង ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១

ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនី-យកម្មំ ។ បេ ។

[១០២] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។ ចោទេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។

[១០៣] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។ សារេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនីយកម្មំ ។ បេ ។

[១០៤] អបរេហិបិ ។ បេ ។ អាបត្តឹ អារោបេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បព្វាជនី-យកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូ-បសន្តញ្ច ។

ធម្មកម្មេ ទ្វាទសកំ និដ្ឋិតំ ។

កម្មចតុក្ក បញ្ញាជនីយកម្មជាកម្មដែលត្រូវតាមធម៌

ម្នាលភិក្ខុទាំងឡាយ បញ្ញាជនីយកម្មប្រកបដោយអង្គទាំង៣នេះឯង ។ល។

(១០២) ម្នាលភិក្ខុទាំងឡាយ បញ្ញាជនីយកម្មប្រកបដោយអង្គ ៣ ដទៃទៀត ។ល។ គឺកម្មដែលចោទហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ បញ្ញាជនីយកម្មប្រកបដោយអង្គទាំង ៣ នេះឯង ។ល។

(១០៣) ម្នាលភិក្ខុទាំងឡាយ បញ្ញាជនីយកម្មប្រកបដោយអង្គ ៣ ដទៃទៀត ។ល។ គឺកម្មដែលរំលឹកហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ បញ្ញាជនីយកម្មប្រកបដោយអង្គទាំង ៣ នេះឯង ។ល។

(១០៤) អង្គទាំងឡាយ ៣ ដទៃទៀត ។ល។ គឺកម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ ១ កម្មដែលធ្វើត្រូវតាមធម៌ ១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ បញ្ញាជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គទាំង ៣ នេះឯង ។

ចប់ បញ្ញាជនីយកម្មមានចំនួន ១២ ក្នុងធម្មកម្ម ។

(១០៥) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

(១០៦) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ អធិសីលេ សីលវិបន្នោ ហោតិ អជ្ឈាចារេ អាចារវិបន្នោ ហោតិ អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

(១០៧) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ

## វិនយបិដក ចុល្លវគ្គ

(១០៥) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺភិក្ខុជាអ្នកបង្កហេតុ បង្កជំលោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ ១ ភិក្ខុល្ងង់ មិនឆ្លាស ត្រូវអាបត្តិច្រើន ឥតមានការកំណត់អាបត្តិ ១ ភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៣ នេះឯង ។

(១០៦) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គទាំងឡាយ ៣ ដទៃទៀត គឺភិក្ខុមានសីលវិបត្តិក្នុងអធិសីល ១ មានអាចារវិបត្តិក្នុងអជ្ឈាចារ ១ មានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(១០៧) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុពោលពាក្យ

ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

(១០៨) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ កាយិកេន ទវេន សមន្នាគតោ ហោតិ វាចសិកេន ទវេន សមន្នាគតោ ហោតិ កាយិកវាចសិកេន ទវេន សមន្នាគតោ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

(១០៩) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ កាយិកេន អនាចារេន សមន្នាគតោ ហោតិ វាចសិកេន អនាចារេន សមន្នាគតោ ហោតិ កាយិកវាចសិកេន អនាចារេន សមន្នាគតោ ហោតិ ឥមេហិ

តិះដៀលព្រះពុទ្ធ ១ ពោលពាក្យតិះដៀលព្រះធម៌ ១ ពោលពាក្យតិះដៀលព្រះសង្ឃ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបញ្ញាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(១០៨) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបញ្ញាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុប្រកបដោយការល្បែងតាមកាយទ្វារ ១ ប្រកបដោយការល្បែងតាមវចីទ្វារ ១ ប្រកបដោយការល្បែងតាមកាយទ្វារនិងវចីទ្វារ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបញ្ញាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(១០៩) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបញ្ញាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុប្រកបដោយអនាចារផ្លូវកាយ[១] ១ ប្រកបដោយអនាចារផ្លូវវាចា ១ ប្រកបដោយអនា-

---

១ ការល្មើសនឹងសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តក្នុងកាយទ្វារ ហៅថាអនាចារផ្លូវកាយ (អដ្ឋកថា) ។

ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

(១១០) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ កាយិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ វាចសិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ កាយិកវាចសិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

(១១១) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ កាយិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ វាចសិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ កាយិកវាចសិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

(១១០) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ កាយិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ វាចសិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ កាយិកវាចសិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

(១១១) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ កាយិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ វាចសិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ កាយិកវាចសិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

ដោយផ្លូវកាយវាចា ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(១១០) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជ-នីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុប្រកបដោយការបៀតបៀនសិក្ខាបទ(១) ដោយផ្លូវកាយ ១ ភិក្ខុប្រកបដោយការបៀតបៀន (សិក្ខាបទ) ដោយផ្លូវវាចា ១ ភិក្ខុប្រកបដោយការបៀតបៀន(សិក្ខាបទ) ទាំងផ្លូវកាយទាំងផ្លូវវាចា ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(១១១) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជ-នីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុប្រកបដោយមិច្ឆាជីវៈផ្លូវកាយ(២) ១ ប្រកបដោយមិច្ឆាជីវៈផ្លូវវាចា(៣) ១ ប្រកបដោយមិច្ឆាជីវៈទាំងផ្លូវកាយទាំងផ្លូវវាចា ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

---

១ ការបៀតបៀនបានខាងឯការបំផ្លាញ ពង្រេច ដោយមិនប្រឹងសិក្សាសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តក្នុងកាយទ្វារ ។ ២ មិច្ឆាជីវៈផ្លូវកាយ បានដល់ការចិញ្ចឹមជីវិតមានទស្សប្រេងស្លថ្នាំអរិដ្ឋជាដើម ដោយអំណាចអនេសនាមានវេជ្ជកម្មដែលទ្រង់ហាមជាដើម ។ ៣ មិច្ឆាជីវៈផ្លូវវាចា បានដល់ទទួលនឹងប្រាប់ដំណឹងរបស់ពួកគ្រហស្ថជាដើម (ទូត) ។

[១១២] តិណ្ណំ ភិក្ខវេ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ឯកោ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ឯកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ ឯកោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

[១១៣] អបរេសម្បិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ឯកោ អធិសីលេ សីលវិបន្នោ ហោតិ ឯកោ អជ្ឈាចារេ អាចារវិបន្នោ ហោតិ ឯកោ អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ ហោតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

[១១៤] អបរេសម្បិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ឯកោ ពុទ្ធស្ស អវណ្ណំ ភាសតិ ឯកោ ធម្មស្ស អវណ្ណំ

## កម្មក្ខន្ធក ការធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួក

(១១២) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួក គឺភិក្ខុអ្នកបង្កហេតុ បង្កជំលោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃពួក ១ ភិក្ខុល្ងង់មិនឆ្លាស ត្រូវអាបត្តិច្រើនឥតមានការកំណត់អាបត្តិពួក ១ ភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួកនេះឯង ។

(១១៣) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុមានសីលវិបត្តិក្នុងអធិសីលពួក ១ មានអាចារវិបត្តិក្នុងអជ្ឈាចារពួក ១ មានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួកនេះឯង ។

(១១៤) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុពោលពាក្យតិះដៀលព្រះពុទ្ធពួក ១ ពោលពាក្យតិះដៀលព្រះធម៌ពួក ១ ពោលពាក្យតិះដៀល

ភាសតិ ឯកោ សង្ឃស្ស អវណ្ណំ ភាសតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

(១១៥) អបរេសម្បិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ឯកោ កាយិកេន ទវេន សមន្នាគតោ ហោតិ ឯកោ វាចសិកេន ទវេន សមន្នាគតោ ហោតិ ឯកោ កាយិកវាចសិកេន ទវេន សមន្នាគតោ ហោតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

(១១៦) អបរេសម្បិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ឯកោ កាយិកេន អនាចារេន សមន្នាគតោ ហោតិ ឯកោ វាចសិកេន អនាចារេន សមន្នាគតោ ហោតិ ឯកោ កាយិកវាចសិកេន អនាចារេន សមន្នាគតោ ហោតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

ព្រះសង្ឃពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំង ៣ ពួកនេះឯង ។

(១១៥) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុប្រកបដោយការល្បែងតាមកាយទ្វារពួក ១ ប្រកបដោយការល្បែងតាមវចីទ្វារពួក ១ ប្រកបដោយការល្បែងតាមកាយទ្វារនឹងវចីទ្វារពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួកនេះឯង ។

(១១៦) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុប្រកបដោយអនាចារផ្លូវកាយពួក ១ ប្រកបដោយអនាចារផ្លូវវាចាពួក ១ ប្រកបដោយអនាចារទាំងផ្លូវកាយទាំងផ្លូវវាចាពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាគប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួកនេះឯង ។

### កម្មក្ខន្ធកេ តិណ្ណំ ភិក្ខូនំ បព្វាជនីយកម្មករណំ

[១១៧] អបរេសម្បិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ឯកោ កាយិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ ឯកោ វាចសិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ ឯកោ កាយិកវាចសិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

[១១៨] អបរេសម្បិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ឯកោ កាយិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ ឯកោ វាចសិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ ឯកោ កាយិកវាចសិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

អាកង្ខមានចតុក្កំ និដ្ឋិតំ ។

## កម្មក្ខន្ធកេ តិណ្ណំ ភិក្ខូនំ បព្វាជនីយកម្មករណំ

[១១៧] អបរេសម្បិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ឯកោ កាយិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ ឯកោ វាចសិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ ឯកោ កាយិកវាចសិកេន ឧបឃាតិកេន សមន្នាគតោ ហោតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

[១១៨] អបរេសម្បិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ឯកោ កាយិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ ឯកោ វាចសិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ ឯកោ កាយិកវាចសិកេន មិច្ឆាជីវេន សមន្នាគតោ ហោតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បព្វាជនីយកម្មំ ករេយ្យ ។

អាកង្ខមានចុទ្ទសកំ និដ្ឋិតំ ។

## កម្មក្ខន្ធក ការធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួក

(១១៧) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុប្រកបដោយការបៀតបៀន (សិក្ខាបទ) តាមផ្លូវកាយពួក ១ ប្រកបដោយការបៀតបៀន (សិក្ខាបទ) តាមផ្លូវវាចាពួក ១ ប្រកបដោយការបៀតបៀន (សិក្ខាបទ) ទាំងផ្លូវកាយ ទាំងផ្លូវវាចាពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំង ៣ ពួកនេះឯង ។

(១១៨) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុប្រកបដោយមិច្ឆាជីវផ្លូវកាយពួក ១ ប្រកបដោយមិច្ឆាជីវផ្លូវវាចាពួក ១ ប្រកបដោយមិច្ឆាជីវទាំងផ្លូវកាយ ទាំងផ្លូវវាចាពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំង ៣ នេះឯង ។

ចប់ បព្វាជនីយកម្មមាន ១៤ ដែលសង្ឃប្រាថ្នា (នឹងធ្វើក៏ធ្វើបាន) ។

(១១៩) បព្វាជនីយកម្មកតេន ភិក្ខវេ ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ ន ភិក្ខុនោវាទកសម្មុតិ សាទិតព្វា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វា យាយ អាបត្តិយា សង្ឃេន បព្វាជនីយកម្មំ កតំ ហោតិ សា អាបត្តិ ន អាបជ្ជិតព្វា អញ្ញា វា តាទិសិកា តតោ វា បាបិដ្ឋតរា កម្មំ ន គរហិតព្វំ កម្មិកា ន គរហិតព្វា ន បកតត្តស្ស ភិក្ខុនោ ឧបោសថោ ឋបេតព្វោ ន បវារណា ឋបេតព្វា ន សវចនីយំ កាតព្វំ ន អនុវាទោ បដ្ឋបេតព្វោ ន ឱកាសោ ការេតព្វោ ន ចោទេតព្វោ ន សារេតព្វោ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វន្តិ ។

បព្វាជនីយកម្មេ អដ្ឋារសវត្តំ[១] និដ្ឋិតំ ។

---

១ អដ្ឋារសកន្តិបិ កត្ថចិ បោត្ថកេ ទិស្សតិ ។

(១១៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃធ្វើបព្វាជនីយកម្ម ហើយត្រូវប្រព្រឹត្តវត្តដោយប្រពៃ ។ ឯការប្រព្រឹត្តិវត្តដោយប្រពៃក្នុងបព្វាជនីយកម្មនោះដូច្នេះ គឺភិក្ខុដែលសង្ឃបានធ្វើបព្វាជនីយកម្មហើយ នោះមិនត្រូវឲ្យឧបសម្បទា ១ មិនត្រូវឲ្យនិស្ស័យ ១ មិនត្រូវឲ្យសាមណេរបម្រើខ្លួន១ មិនត្រូវទទួលការសន្មតិខ្លួនប្រដៅភិក្ខុនី១ ទុកជាសង្ឃសន្មតឲ្យហើយក៏មិនត្រូវប្រដៅពួកភិក្ខុនី ១ សង្ឃបានធ្វើបព្វាជនីយកម្ម ព្រោះអាបត្តិណាហើយ មិនឲ្យត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃទៀត ដែលប្រហែលនឹងអាបត្តិនោះ ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ ១ មិនត្រូវតិះដៀលកម្ម១ មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម១ មិនត្រូវហាមឧបោសថរបស់ភិក្ខុជាបកតត្ត១ មិនត្រូវហាមបវារណារបស់ភិក្ខុជាបកតត្ត១ មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ) ១ មិនត្រូវទទួលនាទីជាធំក្នុងវត្ត១ មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនត្រូវចោទ (ភិក្ខុដទៃ)១ មិនត្រូវរំលឹក (ភិក្ខុដទៃ)១ មិនត្រូវប្រកបពួកភិក្ខុ(ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ។

ចប់ វគ្គ ១៨ ក្នុងបព្វាជនីយកម្ម ។

[១២០] អថខោ សារីបុត្តមោគ្គល្លានប្បមុខោ ភិក្ខុសង្ឃោ កីដាគិរឹ គន្ត្វា អស្សជិបុនព្វសុកានំ ភិក្ខូនំ កីដាគិរិស្មា បព្វាជនីយកម្មំ អកាសិ នាស្សជិបុនព្វសុកេហិ(១) ភិក្ខូហិ កីដាគិរិស្មឹ វត្ថព្វន្តិ ។ តេ សង្ឃេន បព្វាជនីយកម្មកតា ន សម្មា វត្តន្តិ ន លោមំ បាតេន្តិ ន នេត្ថារំ វត្តន្តិ ភិក្ខូ ន ខមាបេន្តិ អក្កោសន្តិ បរិភាសន្តិ ឆន្ទគាមិតា ទោសគាមិតា មោហគាមិតា ភយគាមិតា បាបេន្តិ បក្កមន្តិបិ វិព្ភមន្តិបិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អស្សជិបុនព្វសុកា ភិក្ខូ សង្ឃេន បព្វាជនីយកម្មកតា ន សម្មា វត្តិស្សន្តិ ន លោមំ បាតេស្សន្តិ ន នេត្ថារំ វត្តិស្សន្តិ ភិក្ខូ ន ខមាបេស្សន្តិ អក្កោសិស្សន្តិ បរិភាសិស្សន្តិ ឆន្ទគាមិតា ទោសគាមិតា មោហគាមិតា ភយគាមិតា បាបេស្សន្តិ បក្កមិស្សន្តិបិ វិព្ភមិស្សន្តិបីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

---

១ ឱ. ម. អស្សជិបុនព្វសុកេហិ ។

## កម្មក្ខន្ធក ការធ្វើបព្វាជនីយកម្មដល់អស្សជិភិក្ខុនឹងបុនព្វសុកភិក្ខុ

(១២០) គ្រានោះ ភិក្ខុសង្ឃមានព្រះសារីបុត្តនឹងព្រះមោគ្គល្លានជាប្រធានបានទៅកាន់កិដាគិរីជនបទ ហើយធ្វើបព្វាជនីយកម្ម (បណ្តេញ) ពួកអស្សជិភិក្ខុនឹងបុនព្វសុកភិក្ខុ (ឲ្យចេញ) អំពីកិដាគិរីជនបទ ដោយពាក្យថា ពួកអស្សជិភិក្ខុនឹងបុនព្វសុកភិក្ខុមិនត្រូវនៅក្នុងកិដាគិរីជនបទទេ ។ ភិក្ខុអម្បាលនោះ កាលបើសង្ឃបានធ្វើបព្វាជនីយកម្មហើយ ក៏មិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្ងបរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញបាកកម្ម មិនបានឲ្យភិក្ខុទាំងឡាយអត់ទោស ហើយត្រឡប់ជាជេរប្រទេចបន្ទោសការកសង្ឃវិញថា សង្ឃលំអៀងដោយសេចក្តីស្រឡាញ់ លំអៀងដោយសេចក្តីស្អប់ លំអៀងដោយសេចក្តីល្ងង់ លំអៀងដោយសេចក្តីខ្លាច ភិក្ខុទាំងនោះក៏ចេញទៅខ្លះ សឹកទៅខ្លះ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកអស្សជិភិក្ខុនឹងបុនព្វសុកភិក្ខុដែលសង្ឃបានធ្វើបព្វាជនីយកម្មហើយ មិនសមបើនឹងមិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្ងបរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញបាកកម្ម នឹងមិនបានឲ្យភិក្ខុទាំងឡាយអត់ទោស ត្រឡប់ជាជេរប្រទេចបន្ទោសការកសង្ឃថា សង្ឃលំអៀងដោយសេចក្តីស្រឡាញ់ លំអៀងដោយសេចក្តីស្អប់ លំអៀងដោយសេចក្តីល្ងង់ លំអៀងដោយសេចក្តីខ្លាច ហើយភិក្ខុទាំងនោះក៏ចេញទៅខ្លះ សឹកទៅខ្លះ ។ ទើបភិក្ខុទាំងនោះយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។

(១២១) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ ប-
ករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ
កិរ ភិក្ខវេ អស្សជិបុនព្វសុកា ភិក្ខូ សង្ឃេន បព្វា-
ជនីយកម្មកតា ន សម្មា វត្តន្តិ ន លោមំ បាតេន្តិ
ន នេត្ថារំ វត្តន្តិ ភិក្ខូ ន ខមាបេន្តិ អក្កោសន្តិ បរិភា-
សន្តិ ឆន្ទគាមិតា ទោសគាមិតា មោហគាមិតា ភយគា-
មិតា បាបេន្តិ បក្កមន្តិបិ វិព្ភមន្តិបីតិ ។ សច្ចំ ភគវាតិ ។
វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ ភិក្ខវេ តេសំ មោឃបុរិ-
សានំ ។ បេ ។ កថំ ហិ នាម តេ ភិក្ខវេ មោឃបុ-
រិសា សង្ឃេន បព្វាជនីយកម្មកតា ន សម្មា វត្តិ-
ស្សន្តិ ន លោមំ បាតេស្សន្តិ ន នេត្ថារំ វត្តិស្សន្តិ
ភិក្ខូ ន ខមាបេស្សន្តិ អក្កោសិស្សន្តិ បរិភាសិ-
ស្សន្តិ ឆន្ទគាមិតា ទោសគាមិតា មោហគាមិតា

(១៦១) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំង-ឡាយ ឮថាអស្សជិភិក្ខុនឹងបុនព្វសុកភិក្ខុដែលសង្ឃបានធ្វើបព្វាជនីយកម្ម ហើយ មិនព្រមប្រព្រឹត្តវត្តដោយប្រពៃ មិនសម្មបរោម មិនប្រព្រឹត្តវត្តគួរ ដល់កិរិយារលាស់ខ្លួនចេញចាកកម្ម នឹងមិនបានឲ្យភិក្ខុទាំងឡាយអត់ ទោស ត្រឡប់ជាជេរប្រទេចបន្ទោសការកសង្ឃថា សង្ឃលំអៀងដោយ សេចក្ដីស្រឡាញ់ លំអៀងដោយសេចក្ដីស្អប់ លំអៀងដោយសេចក្ដីល្ងង់ លំអៀងដោយសេចក្ដីខ្លាច ហើយភិក្ខុទាំងនោះក៏ចេញទៅខ្លះ សឹកទៅខ្លះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុ ទាំងឡាយ អំពើរបស់មោឃបុរសទាំងនោះមិនសមគួរទេ ។បេ។ ម្នាលភិក្ខុ ទាំងឡាយ មោឃបុរសទាំងនោះដែលសង្ឃបានធ្វើបព្វាជនីយកម្មហើយ មិនសមបើនឹងមិនព្រមប្រព្រឹត្តវត្តដោយប្រពៃ មិនសម្មបរោម មិនប្រព្រឹត្ត វត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្មនឹងមិនបានឲ្យភិក្ខុទាំងឡាយអត់ ទោស ត្រឡប់ជាជេរប្រទេចបន្ទោសការកសង្ឃថា សង្ឃលំអៀងដោយ សេចក្ដីស្រឡាញ់ លំអៀងដោយសេចក្ដីស្អប់ លំអៀងដោយសេចក្ដីល្ងង់

ភយតាមិតា ទាបេស្សន្តិ បក្កាមិស្សន្តិបិ វិព្ភមិស្សន្តិបិ ឥទំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេន-ហិ ភិក្ខវេ សង្ឃោ បព្វាជនីយកម្មំ បដិប្បស្សម្ភេតុ ។

(១២២) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បព្វាជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ឧបសម្បា-ទេតិ និស្សយំ ទេតិ សាមណេរំ ឧបដ្ឋាបេតិ ភិក្ខុនោ-វាទកសម្មុតឹ សាទិយតិ សម្មតោបិ ភិក្ខុនិយោ ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បព្វាជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

(១២៣) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគ-តស្ស ភិក្ខុនោ បព្វាជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន បព្វាជនីយកម្មំ កតំ ហោតិ តំ អាបត្តឹ អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ គរហតិ កម្មិកេ គរហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បព្វាជនី-យកម្មំ ន បដិប្បស្សម្ភេតព្វំ ។

លំអៀងដោយសេចក្តីខ្លាច ហើយភិក្ខុទាំងនោះចេញទៅខ្លះ សឹកទៅខ្លះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះ-ថ្លាទេ ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូររម្ងាប់បព្វាជ-នីយកម្មចេញ ។

[១២២] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ គឺភិក្ខុឲ្យឧបសម្បទា ១ ឲ្យនិស្ស័យ ១ ឲ្យសាមណេរបម្រើខ្លួន ១ ទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ សង្ឃសន្មតឲ្យហើយទៅប្រដៅពួកភិក្ខុនី ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ ។

[១២៣] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឃបានធ្វើបព្វា-ជនីយកម្មព្រោះអាបត្តិណា ហើយត្រឡប់ត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃដែលប្រហែលគ្នានឹងអាបត្តិមុននោះ ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ ១ តិះដៀលកម្ម ១ តិះដៀលពួកភិក្ខុអ្នកធ្វើកម្ម ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះទេ ។

[១២៤] អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បព្វាជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ បកតត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ បវារណំ ឋបេតិ សវចនីយំ ករោតិ អនុវាទំ បដ្ឋបេតិ ឱកាសំ ការេតិ ចោទេតិ សារេតិ ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បព្វាជនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

**បព្វាជនីយកម្មេ នប្បដិប្បស្សម្ភេតព្វអដ្ឋារសកំ និដ្ឋិតំ ។**

[១២៥] បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បព្វាជនីយកម្មំ បដិប្បស្សម្ភេតព្វំ ន ឧបសម្បាទេតិ ន និស្សយំ ទេតិ ន សាមណេរំ ឧបដ្ឋាបេតិ ន ភិក្ខុនោវាទកសម្មុតឹ សាទិយតិ សម្មតោបិ ភិក្ខុនិយោ ន ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បព្វាជនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

[១២៦] អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បព្វាជនីយកម្មំ បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន បព្វាជនីយកម្មំ កតំ ហោតិ តំ

[១៦៤] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុហាមឧបោសថដល់ភិក្ខុជាបកតត្ត ១ ភិក្ខុហាមបវារណាដល់ភិក្ខុជាបកតត្ត ១ ភិក្ខុធ្វើជាអ្នកមានទាត់ពាក្យ (ក្នុងអធិករណ៍នោះ) ១ ភិក្ខុទទួលនាទីជាធំក្នុងវគ្គ ១ ភិក្ខុឲ្យផ្ដើមឱកាស (ដើម្បីចោទ) ១ ភិក្ខុចោទគេ ១ ភិក្ខុរំលឹកគេ ១ ភិក្ខុប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយ-កម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៨ នេះទេ ។

ចប់ វគ្គ ១៨ ដែលសង្ឃមិនត្រូវរម្ងាប់ក្នុងបព្វាជនីយកម្ម ។

[១៦៥] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ គឺភិក្ខុមិនបានឲ្យឧបសម្បទា ១ មិនបានឲ្យនិស្ស័យ ១ មិនបានឲ្យសាមណេរបម្រើខ្លួន ១ មិនទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ ទុកជាសង្ឃសន្មតហើយក៏មិនបានទៅប្រដៅពួកភិក្ខុនី ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុប្រកបដោយអង្គទាំង ៥ នេះឯង ។

[១៦៦] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឃបានធ្វើបព្វាជ-នីយកម្មព្រោះអាបត្តិណា ហើយ មិនបានត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិ

អាបត្តឹ អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ ន គរហតិ កម្មិកេ ន គរហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បព្វាជនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

(១៤៧) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បព្វាជនីយកម្មំ បដិប្បស្សម្ភេតព្វំ ន បកត-ត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ ន បវារណំ ឋបេតិ ន សវចនីយំ ករោតិ ន អនុវាទំ បដ្ឋបេតិ ន ឱកាសំ ការេតិ ន ចោទេតិ ន សារេតិ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នា-គតស្ស ភិក្ខុនោ បព្វាជនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

**បព្វាជនីយកម្មេ បដិប្បស្សម្ភេតព្វអដ្ឋារសកំ និដ្ឋិតំ ។**

(១៤៨) ឯវញ្ច បន ភិក្ខវេ បដិប្បស្សម្ភេតព្វំ ។ តេន ភិក្ខវេ បព្វាជនីយកម្មកតេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ សង្ឃេន បព្វាជនីយ-

ដទៃដែលប្រហែលគ្នានឹងអាបត្តិមុននោះ ១ ឬអាបត្តិធ្ងន់ជាងអាបត្តិមុននោះ ១ មិនបានតិះដៀលកម្ម ១ មិនបានតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គទាំង ៥ នេះឯង ។

(១២៧) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុមិនបានហាមឧបោសថដល់ភិក្ខុជាបកតត្ត ១ មិនបានហាមបវារណាដល់ភិក្ខុជាបកតត្ត ១ មិនបានធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ) ១ មិនបានទទួលនាទីជាធំក្នុងវត្ត ១ មិនឲ្យធ្វើឱកាស (ដើម្បីចោទ) ១ មិនបានចោទគេ ១ មិនបានរំលឹកគេ ១ មិនបានប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុដែលប្របកដោយអង្គទាំង ៨ នេះឯង ។

**ចប់ វត្ត ១៨ ដែលសង្ឃត្រូវរម្ងាប់ក្នុងបព្វាជនីយកម្ម ។**

(១២៨) ម្នាលភិក្ខុទាំងឡាយ ឯបព្វាជនីយកម្មនោះ សង្ឃត្រូវរម្ងាប់យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃបានធ្វើបព្វាជនីយកម្មហើយនោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើសំពត់ឧត្តរាសង្គឆៀងស្មា ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលី ឡើងពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសង្ឃបានធ្វើ

កម្មកតោ សម្មា វត្តាមិ លោមំ បាតេមិ នេត្ថារំ វត្តាមិ បព្វាជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា ។ តតិយម្បិ យាចិតព្វា ។ ព្យត្តេន(១) ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សង្ឃេន បព្វាជនីយ-កម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បព្វាជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ បព្វាជនីយកម្មំ បដិប្បស្សម្ភេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សង្ឃេន បព្វាជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បព្វាជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ បព្វាជនី-យកម្មំ បដិប្បស្សម្ភេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ បព្វាជនីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

---

១ ឱ. វ្យត្តេន ។

បព្វាជនីយកម្មហើយ ព្រមប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្រុបរោមនឹងប្រ-
ព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់បព្វាជនី-
យកម្ម ៗ ភិក្ខុនោះត្រូវសូមអស់វារពីរដងផង ៗ ភិក្ខុនោះត្រូវសូមអស់វារបី
ដងផង ៗ ភិក្ខុដែលឈ្លាសប្រតិពលគប្បីញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះ
សង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតភិក្ខុឈ្មោះនេះសង្ឃបានធ្វើបព្វាជនី-
យកម្មហើយ ព្រមប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្រុបរោម នឹងប្រព្រឹត្តវត្ត
គួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់បព្វាជនីយកម្ម ៗ
បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់បព្វាជនីយកម្មដល់
ភិក្ខុឈ្មោះនេះចុះ ៗ នេះជាញត្តិ ៗ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃ
ស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះសង្ឃបានធ្វើបព្វាជនីយកម្មហើយ ព្រមប្រព្រឹត្តវត្ត
ដោយប្រពៃ ទាំងសម្រុបរោម បានប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួន
ចេញចាកកម្មហើយ មកសូមការរម្ងាប់បព្វាជនីយកម្ម ៗ សង្ឃរម្ងាប់បព្វា-
ជនីយកម្មដល់ភិក្ខុឈ្មោះនេះ ៗ ការរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុឈ្មោះនេះ
គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិន
គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោល

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សង្ឃេន បដិសារណីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បដិសារណីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្សម្ភេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ បដិសារណីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ បដិប្បស្សទ្ធំ សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ បដិសារណីយកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

បដិសារណីយកម្មំ តតិយំ និដ្ឋិតំ ។

(១២៩) តេន ខោ បន សមយេន អាយស្មា សុធម្មោ មច្ឆិកាសណ្ឌេ ចិត្តស្ស គហបតិនោ អាវាសិកោ ហោតិ នវកម្មិកោ ធុវភត្តិកោ ។ យទា ចិត្តោ គហបតិ សង្ឃំ វា គណំ វា បុគ្គលំ វា និមន្តេតុកាមោ ហោតិ[១] ន អាយស្មន្តំ សុធម្មំ អនបលោកេត្វា សង្ឃំ វា គណំ វា

១ ឥតោ បរំ មរម្មពោត្ថកេ តទាសទ្ទោ បញ្ញាយតិ ។

ឡើង ៗ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដងផង ៗ បេ ៗ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង ៗ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះសង្ឃបានធ្វើបព្វាជនីយកម្មហើយ ព្រមប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម នឹងប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់បព្វាជនីយកម្ម ៗ សង្ឃរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុឈ្មោះនេះ ៗ ការរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ៗ សង្ឃបានរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុឈ្មោះនេះ ការរម្ងាប់បព្វាជនីយកម្មនេះគួរដល់សង្ឃ ព្រោះហេតុនោះទើបសង្ឃស្ងៀម ៗ ខ្ញុំសូមចាំទុកសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ៗ

ចប់បព្វាជនីយកម្មទី ៣ ៗ

[១២៩] សម័យនោះឯង សុធម្មភិក្ខុដ៏មានអាយុជាចៅអាវាសរបស់ចិត្តគហបតិដ៏តនគរមច្ឆិកាសណ្ឌ ជាអ្នកប្រកបការកសាង ជាអ្នកមានធុវភត្ត (ជាអ្នកដែលគហបតិទំនុកបម្រុងដោយនិច្ចភត្ត) ៗ កាលណាចិត្តគហបតិត្រូវការនឹងនិមន្តសង្ឃក្តី គណក្តី បុគ្គលក្តី តែមិនទាន់បានប្រាប់សុធម្មភិក្ខុ (ជាមុន) ហើយមិនហ៊ាននិមន្តសង្ឃ ឬគណ ឬបុគ្គលឡើយ ៗ គ្រានោះ

បុគ្គលំ ភ និមន្តេតិ ។ តេន ខោ បន សមយេន សម្ព-ហុលា ថេរា ភិក្ខូ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាមោគ្គល្លានោ អាយស្មា ច មហាកច្ចានោ អា-យស្មា ច មហាកោដ្ឋិតោ អាយស្មា ច មហាកប្បិនោ អាយស្មា ច មហាចុន្ទោ អាយស្មា ច អនុរុទ្ធោ អាយស្មា ច រេវតោ អាយស្មា ច ឧបាលិ អាយស្មា ច អានន្ទោ អាយស្មា ច រាហុលោ កាសីសុ ចារិកញ្ចរមានា យេន មច្ឆិកាសណ្ឌោ តទវសរុំ ។

(១៣០) អស្សោសិ ខោ ចិត្តោ គហបតិ ថេរា កិរ ភិក្ខូ មច្ឆិកាសណ្ឌំ អនុប្បត្តាតិ ។ អថខោ ចិត្តោ គហ-បតិ យេន ថេរា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា ថេរេ ភិក្ខូ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ចិត្តំ គហបតឹ អាយស្មា សារីបុត្តោ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ ចិត្តោ គហបតិ អាយស្មតា សារីបុត្តេន ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្ប-ហំសិតោ ថេរេ ភិក្ខូ ឯតទវោច អធិវាសេន្តុ មេ ភន្តេ

ពួកភិក្ខុដែលជាថេរច្រើនរូប គឺព្រះសារីបុត្តដ៏មានអាយុ១ ព្រះមហាមោគ្គ-ល្លានដ៏មានអាយុ១ ព្រះមហាកច្ចានដ៏មានអាយុ១ ព្រះមហាកោដ្ឋិតដ៏មានអាយុ១ ព្រះមហាកប្បិនដ៏មានអាយុ១ ព្រះមហាចុន្ទដ៏មានអាយុ១ ព្រះអនុរុទ្ធដ៏មានអាយុ១ ព្រះរេវតដ៏មានអាយុ១ ព្រះឧបាលិដ៏មានអាយុ១ ព្រះអានន្ទដ៏មានអាយុ១ ព្រះរាហុលដ៏មានអាយុ១ នាំគ្នាទៅកាន់ចារិកក្នុងដែនកាសី ក៏បានទៅដល់នគរមច្ឆិកាសណ្ឌ ។

(១៣០) ចិត្តគហបតិបានឮដំណឹងថា ភិក្ខុជាថេរទាំងឡាយបានមកដល់នគរមច្ឆិកាសណ្ឌហើយ ។ លំដាប់នោះ ចិត្តគហបតិក៏បានចូលទៅរកភិក្ខុជាថេរទាំងឡាយ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំភិក្ខុជាថេរទាំងឡាយហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះចិត្តគហបតិអង្គុយនៅក្នុងទីដ៏សមគួរហើយ ព្រះសារីបុត្តដ៏មានអាយុក៏បានពន្យល់ឲ្យយល់ ឲ្យសមាទាន ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ ចិត្តគហបតិ កាលបើព្រះសារីបុត្តដ៏មានអាយុបានពន្យល់ឲ្យយល់ ឲ្យសមាទាន ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏បាននិយាយនឹងភិក្ខុជាថេរទាំងឡាយដោយពាក្យដូច្នេះថា បពិត្រព្រះថេរទាំងឡាយដ៏ចំរើន

ថេរា ស្វាតនាយ អាគន្តុកភត្តន្តិ ។ អធិវាសេសុំ ខោ តេ[១] ថេរា ភិក្ខូ តុណ្ហីភាវេន ។

(១៣១) អថខោ ចិត្តោ គហបតិ ថេរានំ ភិក្ខូនំ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ថេរេ ភិក្ខូ អភិវាទេត្វា បទក្ខិណំ កត្វា យេនាយស្មា សុធម្មោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សុធម្មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ ចិត្តោ គហបតិ អាយស្មន្តំ សុធម្មំ ឯតទវោច អធិវាសេតុ មេ ភន្តេ អយ្យោ សុធម្មោ ស្វាតនាយ ភត្តំ សទ្ធឹ ថេរេហីតិ ។ អថខោ អាយស្មា សុធម្មោ បុព្វេ ខ្វាយំ ចិត្តោ គហបតិ យទា សង្ឃំ វា គណំ វា បុគ្គលំ វា និមន្តេតុកាមោ ន មំ អនបលោកេត្វា សង្ឃំ វា គណំ វា បុគ្គលំ វា និមន្តេតិ សោទានិ មំ អនបលោកេត្វា ថេរេ ភិក្ខូ និមន្តេសិ ទុដ្ឋោទានាយំ ចិត្តោ គហបតិ អនបេក្ខោ វិរត្តរូបោ មយីតិ ចិត្តំ គហបតឹ ឯតទវោច អលំ គហបតិ នាធិវាសេមីតិ ។ ទុតិយម្បិ ខោ ចិត្តោ គហបតិ អាយស្មន្តំ សុធម្មំ ឯតទវោច អធិវាសេតុ មេ ភន្តេ អយ្យោ សុធម្មោ

១ ឧភោបិយមម្មបោត្ថកេសុ តេសទ្ទោ ន ទិស្សតិ ។

## កម្មក្ខន្ធក បដិសារណីយកម្ម រឿងសុធម្មភិក្ខុ

សូមព្រះថេរទាំងឡាយទទួលអាគន្តុកភត្តរបស់ខ្ញុំព្រះករុណាក្នុងថ្ងៃស្អែក ។ ភិក្ខុជាថេរទាំងនោះក៏បានទទួលនិមន្តដោយសភាពស្ងៀម ។

(១៣១) លំដាប់នោះ ចិត្តគហបតិដឹងថា ភិក្ខុជាថេរទាំងឡាយនិមន្តហើយ ក៏ក្រោកឡើងចាកអាសនៈ ថ្វាយបង្គំភិក្ខុជាថេរទាំងឡាយ ធ្វើប្រទក្សិណហើយក៏ដើរចូលទៅរកសុធម្មភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏បានថ្វាយបង្គំសុធម្មភិក្ខុដ៏មានអាយុហើយ ឈរក្នុងទីដ៏សមគួរ ។ លុះចិត្តគហបតិបានឈរក្នុងទីដ៏សមគួរហើយ ក៏បាននិយាយនឹងសុធម្មភិក្ខុដ៏មានអាយុដូច្នេះថា បពិត្រលោកដ៏ចំរើន សូមលោកសុធម្មភិក្ខុជាម្ចាស់ទទួលភត្តរបស់ខ្ញុំក្នុងថ្ងៃស្អែកជាមួយនឹងព្រះថេរទាំងឡាយ ។ លំដាប់នោះ សុធម្មភិក្ខុដ៏មានអាយុគិតថា គ្រាមុន ៗ ចិត្តគហបតិនេះ កាលណាត្រូវការនិមន្តសង្ឃក្តី គណក្តី បុគ្គលក្តីតែមិនទាន់បានប្រាប់អាត្មាអញ (ជាមុន) ហើយ មិនហ៊ាននិមន្តសង្ឃឬគណ ឬបុគ្គលទេ ឥឡូវនេះគាត់មិនបានប្រាប់អាត្មាអញ (ជាមុន) ហើយមកនិមន្តភិក្ខុជាថេរទាំងឡាយ ឥឡូវនេះ ចិត្តគហបតិនេះខឹងមិនអាឡោះអាល័យនឿយណាយចាកអាត្មាអញហើយ (គិតដូច្នេះហើយ) ទើបតបទៅចិត្តគហបតិដោយពាក្យដូច្នេះថា នែគហបតិ កុំឡើយ អាត្មាមិនទទួលនិមន្តទេ ។ ចិត្តគហបតិបានអង្វរសុធម្មភិក្ខុដ៏មានអាយុជាគំរប់ពីរដងដោយពាក្យដូច្នេះ បពិត្រលោកដ៏ចំរើន សូម

ស្វាតនាយ ភត្តំ សទ្ធឹ ថេរេហីតិ ។ អលំ គហបតិ ណាធិវាសេមីតិ ។ ទុតិយម្បិ ខោ ចិត្តោ គហបតិ អាយស្មន្តំ សុធម្មំ ឯតទវោច អធិវាសេតុ មេ ភន្តេ អយ្យោ សុធម្មោ ស្វាតនាយ ភត្តំ សទ្ធឹ ថេរេហីតិ ។ អលំ គហបតិ ណាធិវាសេមីតិ ។ អថខោ ចិត្តោ គហបតិ កឹ មេ ករិស្សតិ អយ្យោ សុធម្មោ អធិវាសេន្តោ វា អនធិវាសេន្តោ វាតិ អាយស្មន្តំ សុធម្មំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

(១៣២) អថខោ ចិត្តោ គហបតិ តស្សា រត្តិយា អច្ចយេន ថេរានំ ភិក្ខូនំ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេសិ ។ អថខោ អាយស្មា សុធម្មោ យន្នូនាហំ ចិត្តស្ស គហបតិនោ ថេរានំ ភិក្ខូនំ បដិយត្តំ បស្សេយ្យន្តិ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ចិត្តស្ស គហបតិនោ និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ ចិត្តោ គហបតិ យេនាយស្មា សុធម្មោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សុធម្មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ចិត្តំ គហបតឹ

លោកសុធម្មភិក្ខុជាម្ចាស់ទទួលភត្តរបស់ខ្ញុំក្នុងថ្ងៃព្រឹកស្អែក ជាមួយនឹងព្រះថេរទាំងឡាយ ។ សុធម្មភិក្ខុតបថា នែគហបតិកុំឡើយ អាត្មាមិនទទួលនិមន្តទេ ។ ចិត្តគហបតិបានអង្វរសុធម្មភិក្ខុដ៏មានអាយុជាគំរប់ពីដង ដោយពាក្យដូច្នេះថា បពិត្រលោកដ៏ចំរើន សូមលោកសុធម្មភិក្ខុជាម្ចាស់ទទួលភត្តរបស់ខ្ញុំក្នុងថ្ងៃព្រឹកស្អែកជាមួយនឹងព្រះថេរទាំងឡាយ ។ សុធម្មភិក្ខុតបថា នែគហបតិ កុំឡើយ អាត្មាមិនទទួលនិមន្តទេ ។ លំដាប់នោះ ចិត្តគហបតិគិតថា លោកសុធម្មភិក្ខុជាម្ចាស់ ទោះទទួលនិមន្តក្តី មិនទទួលនិមន្តក្តី នឹងមានប្រយោជន៍អ្វីដល់អាត្មាអញ ហើយក៏ថ្វាយបង្គំសុធម្មភិក្ខុដ៏មានអាយុធ្វើប្រទក្សិណហើយដើរចេញទៅ ។

(១៣២) លុះកន្លងរាត្រីនោះទៅ ចិត្តគហបតិក៏តាក់តែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដើម្បីភិក្ខុជាថេរៈទាំងឡាយ ។ លំដាប់នោះ សុធម្មភិក្ខុដ៏មានអាយុគិតថា គួរតែអាត្មាអញទៅមើលគ្រឿងសក្ការដែលចិត្តគហបតិតាក់តែងដល់ភិក្ខុជាថេរទាំងឡាយ ហើយក៏ស្លៀកស្បង់ប្រដាប់ដោយបាត្រនឹងចីវរអំពីព្រឹកព្រហាមចូលទៅកាន់លំនៅរបស់ចិត្តគហបតិ លុះចូលទៅដល់ហើយក៏អង្គុយលើអាសនដែលគេតែងតាំងទុក ។ ឯចិត្តគហបតិក៏បានចូលទៅរកសុធម្មភិក្ខុដ៏មានអាយុ លុះចូលទៅដល់ ក៏ថ្វាយបង្គំសុធម្មភិក្ខុដ៏មានអាយុហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះចិត្តគហបតិអង្គុយ

អាយស្មា សុធម្មោ ឯតទវោច បហូតំ ខោ តេ ឥទំ គហបតិ ខាទនីយំ ភោជនីយំ បដិយត្តំ ឯកា ច ខោ ឥធ នត្ថិ យទិទំ តិលសង្គុឡិកាតិ ។ ពហុម្ហិ វត ភន្តេ[១] ពុទ្ធវចនេ វិជ្ជមានេ អយ្យេន សុធម្មេន យទេវ កិញ្ចិ ភាសិតំ យទិទំ តិលសង្គុឡិកាតិ ភូតបុព្វំ ភន្តេ ទក្ខិណាបថកា វាណិជា បុរត្ថិមំ ជនបទំ អគមំសុ តេ[២] វាណិជា[៣] តតោ កុក្កុដឹ អានេសុំ អថខោ សា ភន្តេ កុក្កុដី កាកេន សទ្ធឹ សំវាសំ កប្បេសិ សា បោតកំ ជនេសិ យទា ខោ សោ ភន្តេ កុក្កុដបោតកោ កាកវស្សំ វស្សិតុកាមោ ហោតិ កាកកុក្កុដីតិ[៤] វស្សតិ យទា កុក្កុដវស្សំ វស្សិតុកាមោ ហោតិ កុក្កុដីកាកាតិ[៥] វស្សតិ ឯវមេវ ខោ ភន្តេ ពហុម្ហិ ពុទ្ធវចនេ វិជ្ជមានេ អយ្យេន សុធម្មេន យទេវ កិញ្ចិ ភាសិតំ យទិទំ

១ ឥតោ បរំ ឱរោបិយមរម្មបោត្ថកេសុ រតនេតិ សព្វត្ថ អត្ថិ ។ ២ ឱ ម. តេតិ សព្វត្ថ ន បញ្ញាយតិ ។ ៣ ឥតោ បរំ ឱ. ម. បោត្ថកេសុ វាណិជ្ជាយាតិ សព្វត្ថ អត្ថិ ។ ៤ ឱ កុក្កុដិកាតិ ។ ម កាកកុក្កុដាតិ ។ ៥ កាកាតិ ។ ម. កុក្កុដកាតិ ។

## កម្មក្ខន្ធក បដិសារណីយកម្ម រឿងសុធម្មភិក្ខុ

ក្នុងទីសមគួរហើយ សុធម្មភិក្ខុក៏បាននិយាយពាក្យនេះថា ម្នាលគហបតិ ខាទនីយភោជនីយាហារដែលអ្នកតាក់តែងនេះបរិបូណ៌ណាស់ហើយ មានតែក្នុងទីនេះគ្មាននំក្រាបល្ងមួយមុខប៉ុណ្ណោះ ។ ចិត្តគហបតិតបថា សូមមេត្តាប្រោស បើព្រះពុទ្ធវចនមានច្រើនម៉្លេះតើ (ចុះក៏) លោកម្ចាស់សុធម្មពោលពាក្យតែបន្តិចបន្តួចថា នំក្រាបល្ងវិញ សូមមេត្តាប្រោស ធ្លាប់មានរឿងមកហើយថា មានពួកពាណិជនៅស្រុកទក្ខិណាបថបានទៅកាន់បុរត្ថិមជនបទ ពាណិជទាំងនោះនាំយកមេមាន់ពីបុរត្ថិមជនបទនោះមក សូមមេត្តាប្រោស ឯមេមាន់នោះបានរួមសំវាសជាមួយនឹងក្អែក មេមាន់នោះក៏កើតកូន សូមមេត្តាប្រោស កាលណាកូនមាន់នោះចង់ស្រែកជាសំឡេងក្អែក វាក៏ស្រែកថា កាកាកុក្កុដី (ក្អែកមាន់) កាលណាបើចង់ស្រែកជាសំឡេងមាន់ វាក៏ស្រែកថា កុក្កុដីកាកា (មាន់ក្អែក) យ៉ាងណាមិញ សូមមេត្តាប្រោស បើពុទ្ធវចនមានច្រើនដល់ម្លេះ (ចុះក៏) លោកម្ចាស់សុធម្មពោលពាក្យបន្តិចបន្តួចថា នំក្រាបល្ងវិញ ក៏យ៉ាងនេះឯង ។

តិលសង្គុឡិកាតិ ។ អក្កោសសិ មំ ត្វំ គហបតិ បរិភាសសិ មំ ត្វំ គហបតិ ឯសោ តេ គហបតិ អាវាសោ តម្ហា អាវាសា(១) បក្កមិស្សាមីតិ ។ នាហំ ភន្តេ អយ្យំ សុធម្មំ អក្កោសាមិ ន(២) បរិភាសាមិ វសតុ ខោ(៣) ភន្តេ អយ្យោ សុធម្មោ មច្ឆិកាសណ្ឌេ រម្មណីយេ អម្ពាដកវនេ(៤) អហំ អយ្យស្ស សុធម្មស្ស ឧស្សុក្កំ ករិស្សាមិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ ទុតិយម្បិ ខោ អាយស្មា សុធម្មោ ចិត្តំ គហបតឹ ឯតទវោច អក្កោសសិ មំ ត្វំ គហបតិ បរិភាសសិ មំ ត្វំ គហបតិ ឯសោ តេ គហបតិ អាវាសោ តម្ហា អាវាសា បក្កមិស្សាមីតិ ។ នាហំ ភន្តេ អយ្យំ សុធម្មំ អក្កោសាមិ ន បរិភាសាមិ វសតុ ខោ ភន្តេ អយ្យោ សុធម្មោ មច្ឆិកាសណ្ឌេ រម្មណីយេ អម្ពាដកវនេ អហំ អយ្យស្ស

---

១ សព្វត្ថិទំ តម្ហា អាវាសាតិ ទ្វយំ ឱ. ម. បោត្ថកេសុ ន ទិស្សតិ ។ ២ ឥធ ន សទ្ទោ ឱ. ម. បោត្ថកេសុ នត្ថិ ។ ៣ ខោ សទ្ទោ ឱ. ម. បោត្ថកេសុ នត្ថិ ។ ៤ ឱ. ម. បោត្ថកេសុ រម្មណីយំ អម្ពាដកវនន្តិ វចនំ ទ្វយំ ។

សុធម្មភិក្ខុឆ្លើយថា ម្នាលគហបតិ អ្នកឯងដេរអាត្មា អ្នកឯងផ្តាសាអាត្មា ម្នាលគហបតិ ទុះអាវាសរបស់អ្នកឯង អាត្មាមុខជាដើរចេញពីអាវាសនោះហើយ ៗ ចិត្តគហបតិនិយាយតបថា សូមមេត្តាប្រោស ខ្ញុំមិនបានដេរ មិនបានផ្តាសាលោកម្ចាស់សុធម្មទេ សូមមេត្តាប្រោស សូមលោកម្ចាស់សុធម្មគង់ក្នុងវត្តអម្ពាដកវ័នជារមណីយស្ថានជិតនគរមច្ឆិកាសណ្ឌចុះ ខ្ញុំនឹងធ្វើសេចក្តីខ្វល់ខ្វាយដល់លោកម្ចាស់សុធម្មដោយចីវរបិណ្ឌបាតសេនាសន និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ៗ សុធម្មភិក្ខុក៏មានអាយុបាននិយាយពាក្យនេះនឹងចិត្តគហបតិជាគំរប់ពីរដងទៀតថា ម្នាលគហបតិ អ្នកឯងដេរអាត្មា ម្នាលគហបតិ អ្នកឯងផ្តាសាអាត្មា ម្នាលគហបតិ ទុះអាវាសរបស់អ្នក អាត្មាមុខជាដើរចេញពីអាវាសនោះហើយ ៗ ចិត្តគហបតិក៏តបថា សូមមេត្តាប្រោស ខ្ញុំមិនបានដេរ មិនបានផ្តាសាលោកម្ចាស់សុធម្មទេ សូមមេត្តាប្រោស សូមលោកម្ចាស់សុធម្មគង់នៅក្នុងវត្តអម្ពាដកវ័នជារមណីយស្ថានជិតនគរមច្ឆិកាសណ្ឌចុះ ខ្ញុំនឹងធ្វើសេចក្តីខ្វល់-

សុធម្មស្ស ឧស្សុក្កំ ការិស្សាមិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ ទុតិយម្បិ ខោ អាយស្មា សុធម្មោ ចិត្តំ គហបតឹ ឯតទវោច អក្កោសសិ មំ ត្វំ គហបតិ បរិភាសសិ មំ ត្វំ គហបតិ ឯសោ តេ គហបតិ អាវាសោ តម្ហា អាវាសា បក្កមិស្សាមីតិ ។ កហំ ភន្តេ អយ្យោ សុធម្មោ គមិស្សតីតិ ។ សាវត្ថឹ ខោ អហំ គហបតិ គមិស្សាមិ ភគវន្តំ ទស្សនាយាតិ ។ តេនហិ ភន្តេ យញ្ច អត្តនា ភណិតំ យញ្ច មយា ភណិតំ តំ សព្វំ ភគវតោ អារោចេហិ អនច្ឆរិយំ(១) ខោ បនេតំ ភន្តេ យំ អយ្យោ សុធម្មោ បុនទេវ មច្ឆិកាសណ្ឌំ បច្ចាគច្ឆេយ្យាតិ ។

(១៣៣) អថខោ អាយស្មា សុធម្មោ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន សាវត្ថី តេន បក្កាមិ អនុបុព្វេន យេន សាវត្ថី ជេតវនំ អនាថបិណ្ឌិកស្ស អារាមោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ

១ អច្ឆរិយន្តិ លិខិតំ ។

ថ្វាយដល់លោកម្ចាស់សុធម្មដោយចីវរបិណ្ឌបាតសេនាសន និងភេសជ្ជ-បរិក្ខារជាបច្ច័យដល់មនុស្សឈឺ ។ សុធម្មភិក្ខុដ៏មានអាយុបាននិយាយពាក្យនេះនឹងចិត្តគហបតិជាគំរប់បីដងទៀតថា ម្នាលគហបតិ អ្នកឯងជេរអាត្មា ម្នាលគហបតិ អ្នកឯងផ្ដាសាអាត្មា ម្នាលគហបតិ ទុះអាវាសរបស់អ្នក អាត្មាមុខជាដើរចេញពីអាវាសនោះហើយ ។ ចិត្តគហបតិសួរថា សូមមេត្តាប្រោស ចុះលោកម្ចាស់សុធម្មនឹងនិមន្តទៅកន្លែងឯណា ។ សុធម្មភិក្ខុប្រាប់ថា ម្នាលគហបតិ អាត្មានឹងទៅកាន់ក្រុងសាវត្ថីដើម្បីគាល់ព្រះដ៏មានព្រះភាគ ។ ចិត្តគហបតិផ្ដាំថា សូមមេត្តាប្រោស បើដូច្នោះ ពាក្យណាដែលលោកម្ចាស់បានពោលក្ដី ពាក្យណាដែលខ្ញុំបានពោលក្ដី សូមលោកម្ចាស់ (នាំយក) ពាក្យនោះទៅក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ឲ្យសព្វគ្រប់ផងចុះ សូមមេត្តាប្រោស បើលោកម្ចាស់សុធម្មត្រឡប់មកកាន់នគរមច្ឆិកាសណ្ឌវិញ ដោយហេតុឯណា ហេតុនោះមិនជាអស្ចារ្យទេ ។

(១៣៣) គ្រានោះ សុធម្មភិក្ខុដ៏មានអាយុក៏បានរៀបចំទុកដាក់សេ-នាសនស្រេចហើយ នាំយកបាត្រនឹងចីវរចេញទៅកាន់ក្រុងសាវត្ថី ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគឯវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថីដោយលំដាប់ លុះចូលទៅដល់ហើយបានថ្វាយបង្គំព្រះដ៏-មានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសុធម្មភិក្ខុអង្គុយក្នុងទីដ៏-

អាយស្មា សុធម្មោ យញ្ច អត្តនា កថិតំ យញ្ច ចិត្តេន គហបតិនា កថិតំ តំ សព្វំ ភគវតោ អារោចេសិ ។

(១៣៤) វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ[1] មោឃបុរិស អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម ត្វំ មោឃបុរិស ចិត្តំ គហបតឹ សទ្ធំ បសន្នំ ទាយកំ ការកំ សង្ឃុបដ្ឋាកំ ហីនេន ខុំសេស្សសិ ហីនេន វម្ភេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ។ បេ ។ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មំ ករោតុ ចិត្តោ តេ គហបតិ ខមាបេតព្វោ ។ ឯវញ្ច បន ភិក្ខវេ កាតព្វំ ។ បឋមំ សុធម្មោ ភិក្ខុ ចោទេតព្វោ ចោទេត្វា សារេតព្វោ សារេត្វា អាបត្តិំ អារោបេតព្វោ អាបត្តឹ អារោបេត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ សុធម្មោ ភិក្ខុ ចិត្តំ គហបតឹ សទ្ធំ បសន្នំ ទាយកំ ការកំ សង្ឃុបដ្ឋាកំ ហីនេន ខុំសេតិ ហីនេន វម្ភេតិ ។ យទិ

---

១ ឱ. អននុច្ឆវិយំ ។

សមគួរហើយ ក៏(នាំយក)ពាក្យដែលខ្លួនពោល នឹងពាក្យដែលចិត្តគហបតិពោលនោះក្រាបបង្គំទូលព្រះដ៏មានព្រះភាគសព្វគ្រប់ ។

(១៣៤) ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស អំពើនេះមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈមិនគប្បី មិនគួរធ្វើទេ ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងដេរចិត្តគហបតិដែលមានសទ្ធាជ្រះថ្លា ជាទាយក ជាកប្បិយការក ជាឧបដ្ឋាកសង្ឃដោយពាក្យថោកទាប នឹងដៀលត្មះដោយពាក្យថោកទាបសោះ ម្នាលមោឃបុរស អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់តិះដៀលហើយ ។ បេ ។ ក៏ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើបដិសារណីយកម្មដល់សុធម្មភិក្ខុដោយពាក្យថា លោកត្រូវសូមទោសនឹងគហបតិ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្មនោះសង្ឃត្រូវធ្វើយ៉ាងនេះ ។ សង្ឃត្រូវចោទសុធម្មភិក្ខុជាមុន លុះចោទហើយត្រូវរំលឹក លុះរំលឹកហើយត្រូវលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុអ្នកឆ្លាសប្រតិពលត្រូវញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតសុធម្មភិក្ខុនេះដេរចិត្តគហបតិ ដែលជាអ្នកមានសទ្ធាជ្រះថ្លា ជាទាយក ជាកប្បិយការក ជាឧបដ្ឋាកសង្ឃដោយពាក្យ

## កម្មក្ខន្ធកេ បដិសារណីយកម្មំ សុធម្មភិក្ខុវត្ថុ

សង្ឃស្ស បត្តកល្លំ សង្ឃោ សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មំ ករេយ្យ ចិត្តោ តេ គហបតិ ខមាបេតព្វោ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ សុធម្មោ ភិក្ខុ ចិត្តំ គហបតឹ សទ្ធំ បសន្នំ ទាយកំ ការកំ សង្ឃុបដ្ឋាកំ ហីនេន ខុំសេតិ ហីនេន វម្ភេតិ ។ សង្ឃោ សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មំ ករោតិ ចិត្តោ តេ គហបតិ ខមាបេតព្វោតិ ។ យស្សាយស្មតោ ខមតិ សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មស្ស ករណំ ចិត្តោ តេ គហបតិ ខមាបេតព្វោតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ សុធម្មោ ភិក្ខុ ចិត្តំ គហបតឹ សទ្ធំ បសន្នំ ទាយកំ ការកំ សង្ឃុបដ្ឋាកំ ហីនេន ខុំសេតិ ហីនេន វម្ភេតិ ។ សង្ឃោ សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មំ ករោតិ ចិត្តោ តេ គហបតិ ខមាបេតព្វោតិ ។ យស្សាយស្មតោ ខមតិ សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មស្ស ករណំ ចិត្តោ តេ គហបតិ

## កម្មក្ខន្ធក បដិសារណីយកម្ម រឿងសុធម្មភិក្ខុ

ថោកទាប និងដៀលត្មះដោយពាក្យថោកទាប ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើបដិសារណីយកម្មដល់សុធម្មភិក្ខុដោយពាក្យថា លោកត្រូវសូមទោសនឹងចិត្តគហបតិ ។ នេះជាវាចាប្រកាសឲ្យសង្ឃដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតសុធម្មភិក្ខុនេះជេរចិត្តគហបតិ ដែលជាអ្នកមានសទ្ធាជ្រះថ្លា ជាទាយក ជាកប្បិយការក ជាឧបដ្ឋាកសង្ឃដោយពាក្យថោកទាប និងដៀលត្មះដោយពាក្យថោកទាប ។ សង្ឃធ្វើបដិសារណីយកម្មដល់សុធម្មភិក្ខុដោយពាក្យថា លោកត្រូវសូមទោសនឹងចិត្តគហបតិ ។ ការធ្វើបដិសារណីយកម្មដល់សុធម្មភិក្ខុដោយពាក្យថា លោកត្រូវសូមទោសនឹងចិត្តគហបតិ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតសុធម្មភិក្ខុនេះជេរចិត្តគហបតិ ដែលជាអ្នកមានសទ្ធាជ្រះថ្លា ជាទាយក ជាកប្បិយការក ជាឧបដ្ឋាកសង្ឃដោយពាក្យថោកទាប និងដៀលត្មះដោយពាក្យថោកទាប ។ ឥឡូវសង្ឃធ្វើបដិសារណីយកម្មដល់សុធម្មភិក្ខុដោយពាក្យថា លោកត្រូវសូមទោសនឹងចិត្តគហបតិ ។ ការធ្វើបដិសារណីយកម្មដល់

ខមាបេតព្វោតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ កតំ សង្ឃេន សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មំ ចិត្តោ តេ គហបតិ ខមាបេតព្វោតិ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(១៣៥) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អសម្មុខា កតំ ហោតិ អប្បដិបុច្ឆា កតំ ហោតិ អប្បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(១៣៦) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អនាបត្តិយា កតំ ហោតិ អទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ ទេសិតាយ

សុធម្មភិក្ខុដោយពាក្យថា លោកត្រូវសូមទោសនឹងចិត្តគហបតិដូច្នេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ បដិសារណីយកម្ម សង្ឃបានធ្វើដល់សុធម្មភិក្ខុដោយពាក្យថា លោកត្រូវសូមទោសនឹងចិត្តគហបតិដូច្នេះគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(១៣៥) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលសង្ឃរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ គឺកម្មដែលធ្វើក្នុងទីកំបាំងមុខ ១ កម្មដែលធ្វើដោយមិនបានសាកសួរ ១ កម្មដែលធ្វើមិនតាមប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៣៦) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយមិនមានអាបត្តិ ១ កម្មដែលធ្វើដោយអា-

អាបត្តិយា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(១៣៧) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អចោទេត្វា កតំ ហោតិ អសារេត្វា កតំ ហោតិ អាបត្តឹ អនារោបេត្វា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(១៣៨) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អសម្មុខា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ ។បេ។

បត្តិជាអទេសនាគាមិនី ១ កម្មដែលធ្វើដោយអាបត្តិដែលភិក្ខុបានសំដែងហើយ ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៣៧) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនបានចោទហើយស្រាប់តែធ្វើ ១ កម្មដែលមិនរំលឹកហើយស្រាប់តែធ្វើ ១ កម្មដែលមិនលើកអាបត្តិឡើងហើយស្រាប់តែធ្វើ ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៣៨) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើក្នុងទីកំបាំងមុខ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ប្រកបដោយអង្គ ៣ នេះឯង ។ បេ ។

[១៣៩] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អប្បដិបុច្ឆា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

[១៤០] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អប្បដិញ្ញាយ កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

[១៤១] អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អនាបត្តិយា កតំ ហោតិ

(១៣៩) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយមិនបានសាកសួរ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៤០) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើមិនតាមបដិញ្ញា (របស់ភិក្ខុ) ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៤១) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលសង្ឃរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយមិនមានអាបត្តិ ១ កម្មដែល

## កម្មក្ខន្ធកេ បដិសារណីយកម្មំ អធម្មកម្មំ

អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(១៤២) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ។ បេ ។

(១៤៣) អបរេហិបិ ។ បេ ។ ទេសិតាយ អាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ។ បេ ។

(១៤៤) អបរេហិបិ ភិក្ខវេ ។ បេ ។ អចោទេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

ធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៤២) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺ កម្មដែលធ្វើដោយអាបត្តិជាអទេសនាគាមិនី ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ។ បេ ។

(១៤៣) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយអាបត្តិដែលភិក្ខុសំដែងហើយ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្ម ។ បេ ។ ប្រកបដោយអង្គ ៣ នេះឯង ។

(១៤៤) ម្នាលភិក្ខុទាំងឡាយ អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលមិនចោទហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៦៥) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អសារេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(១៦៦) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ។ បេ ។ អាបត្តឹ អនារោបេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

បដិសារណីយកម្មេ អធម្មកម្មទ្វាទសកំ និដ្ឋិតំ ។

(១៦៧) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ បដិសារណីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច

(១៤៥) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលមិនរំលឹកហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៤៦) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ។ បេ ។ ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលសង្ឃមិនលើកអាបត្តិឡើងហើយស្រាប់តែធ្វើ ១ កម្មដែលធ្វើមិនត្រូវតាមធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

ចប់អធម្មកម្មមានចំនួន ១២ ក្នុងបដិសារណីយកម្ម ។

(១៤៧) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ គឺកម្ម

សុវូបសន្តញ្ច សម្មុខា កតំ ហោតិ បដិបុច្ឆា កតំ ហោតិ បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(១៤៨) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អាបត្តិយា កតំ ហោតិ ទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ អទេសិតាយ អាបត្តិយា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(១៤៩) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ចោទេត្វា កតំ ហោតិ សារេត្វា កតំ ហោតិ អាបត្តឹ អារោបេត្វា កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ។បេ។

ដែលធ្វើចំពោះមុខ ១ កម្មដែលធ្វើដោយការសាកសួរ ១ កម្មដែលធ្វើតាមពាក្យប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៨៨) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយអាបត្តិ ១ កម្មដែលធ្វើដោយអាបត្តិជាទេសនាគាមិនី ១ កម្មដែលធ្វើតាមអាបត្តិដែលភិក្ខុមិនបានសំដែង ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៨៩) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលចោទហើយទើបធ្វើ ១ កម្មដែលរំលឹកហើយទើបធ្វើ ១ កម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ។ បេ ។ ប្រកបដោយអង្គ ៣ នេះឯង ។

(១៨០) អបរេហិបិ ភិក្ខវេ ។ បេ ។ សម្មុខា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ ។ បេ ។

(១៨១) អបរេហិបិ ភិក្ខវេ ។ បេ ។ បដិបុច្ឆា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ ។ បេ ។

(១៨២) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ។ បេ ។ បដិញ្ញាយ កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ ។ បេ ។

(១៨៣) អបរេហិបិ ភិក្ខវេ ។ បេ ។ អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ ។ បេ ។

(១៩០) ម្នាលភិក្ខុទាំងឡាយ អង្គ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើចំពោះមុខ ១ កម្មដែលធ្វើតាមធម៌ ១ កម្មដែលធ្វើដោយសេចក្ដីព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ។ បេ ។ ប្រកបដោយអង្គ ៣ នេះឯង ។

(១៩១) ម្នាលភិក្ខុទាំងឡាយ អង្គ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយការសាកសួរ ១ កម្មដែលធ្វើតាមធម៌ ១ កម្មដែលធ្វើដោយសេចក្ដីព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ។ បេ ។ ប្រកបដោយអង្គ ៣ នេះឯង ។

(១៩២) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្មប្រកបដោយអង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើតាមពាក្យប្ដេជ្ញា ១ កម្មដែលធ្វើតាមធម៌ ១ កម្មដែលធ្វើដោយសេចក្ដីព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំង-ឡាយ បដិសារណីយកម្ម ។ បេ ។ ប្រកបដោយអង្គ ៣ នេះឯង ។

(១៩៣) ម្នាលភិក្ខុទាំងឡាយ អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយអាបត្តិ ១ កម្មដែលធ្វើតាមធម៌ ១ កម្មដែលធ្វើដោយសេចក្ដីព្រមព្រៀងគ្នា ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ។ បេ ។ ប្រ-កបដោយអង្គ ៣ នេះឯង ។

(១៨៤) អបរេហិបិ ភិក្ខវេ ។បេ។ ទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ។បេ។

(១៨៥) អបរេហិបិ ភិក្ខវេ ។បេ។ អទេសិតាយ អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ ។បេ។

(១៨៦) អបរេហិបិ ភិក្ខវេ ។បេ។ ចោទេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ ។បេ។

(១៨៧) អបរេហិបិ ភិក្ខវេ ។បេ។ សារេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(១៨៨) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អាបត្តឹ អារោបេត្វា កតំ ហោតិ ធម្មេន

## កម្មក្ខន្ធក បដិសារណីយកម្ម ជាកម្មដែលត្រូវតាមធម៌

(១៩៤) ម្នាលភិក្ខុទាំងឡាយ អង្គ ៣ ដទៃទៀត ។បេ។ គឺកម្មដែលធ្វើដោយអាបត្តិជាទេសនាគាមិនី ១ កម្មដែលធ្វើតាមធម៌ ១ កម្មដែលធ្វើដោយសេចក្តីព្រមព្រៀង ១ ។បេ។

(១៩៥) ម្នាលភិក្ខុទាំងឡាយ អង្គ ៣ ដទៃទៀត ។បេ។ គឺកម្មដែលធ្វើដោយអាបត្តិដែលភិក្ខុមិនបានសំដែង ១ កម្មដែលធ្វើតាមធម៌ ១ កម្មដែលធ្វើដោយសេចក្តីព្រមព្រៀង ១ ម្នាលភិក្ខុទាំងឡាយ ។បេ។

(១៩៦) ម្នាលភិក្ខុទាំងឡាយ អង្គ ៣ ដទៃទៀត ។បេ។ គឺកម្មដែលចោទហើយទើបធ្វើ ១ កម្មដែលធ្វើតាមធម៌ ១ កម្មដែលធ្វើដោយសេចក្តីព្រមព្រៀង ១ ម្នាលភិក្ខុទាំងឡាយ ។បេ។

(១៩៧) ម្នាលភិក្ខុទាំងឡាយ អង្គ ៣ ដទៃទៀត ។បេ។ គឺកម្មដែលរំលឹកហើយទើបធ្វើ ១ កម្មដែលធ្វើតាមធម៌ ១ កម្មដែលធ្វើដោយសេចក្តីព្រមព្រៀង ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៩៨) ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ ១ កម្មដែលធ្វើតាមធម៌ ១

កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បដិសារណីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

បដិសារណីយកម្មេ ធម្មកម្មទ្វាទសកំ និដ្ឋិតំ ។

(១៥៩) បញ្ចហង្គេហិ[១] ភិក្ខវេ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ ករេយ្យ គិហីនំ អលាភាយ បរិសក្កតិ គិហីនំ អនត្ថាយ បរិសក្កតិ គិហីនំ អនាវាសាយ[២] បរិសក្កតិ គិហី អក្កោសតិ បរិភាសតិ គិហី គិហីហិ ភេទេតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ ករេយ្យ ។

(១៦០) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ ករេយ្យ គិហីនំ ពុទ្ធស្ស អវណ្ណំ ភាសតិ គិហីនំ ធម្មស្ស អវណ្ណំ ភាសតិ គិហីនំ សង្ឃស្ស អវណ្ណំ ភាសតិ

---

១ ឱ. បញ្ចហិ ភិក្ខវេ អង្គេហិ ។ ២ ឱ. ម. អភាសាយ ។

កម្មដែលធ្វើដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ បដិសារ-ណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

ចប់ ធម្មកម្មមាន ១២ ក្នុងបដិសារណីយកម្ម ។

(១៥៩) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិ-សារណីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ គឺភិក្ខុព្យាយាមមិនឲ្យពួកគ្រហស្ថបានលាភ ១ ព្យាយាមមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ១ ព្យាយាមមិនឲ្យពួកគ្រហស្ថបានលំនៅ ១ ជេរប្រទេចពួកគ្រហស្ថ ១ បំបែកពួកគ្រហស្ថឲ្យបែកបាក់ពួកគ្រហស្ថ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង[១] ។

(១៦០) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិ-សារណីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធចំពោះ(មុខ)ពួកគ្រហស្ថ១ ពោលតិះដៀលព្រះធម៌ចំពោះ(មុខ)ពួកគ្រហស្ថ១ ពោលតិះដៀលព្រះសង្ឃចំពោះ(មុខ)ពួកគ្រហស្ថ១

---

១ អដ្ឋកថា ថា សូម្បីប្រកបដោយអង្គ ១ ក៏គប្បីធ្វើបដិសារណីយកម្មដែរ ។

គិហី ហីនេន ខុំសេតិ គិហី ហីនេន វម្ភេតិ គិហីនំ ធម្មិកំ បដិស្សវំ ន សច្ចាបេតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ ករេយ្យ ។

(១៦១) បញ្ចន្នំ ភិក្ខវេ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ ករេយ្យ ឯកោ គិហីនំ អលាភាយ បរិសក្កតិ ឯកោ គិហីនំ អនត្ថាយ បរិសក្កតិ ឯកោ គិហីនំ អនាវាសាយ បរិសក្កតិ ឯកោ គិហី អក្កោសតិ បរិភាសតិ ឯកោ គិហី គិហីហិ ភេទេតិ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ ករេយ្យ ។

(១៦២) អបរេសំបិ ភិក្ខវេ បញ្ចន្នំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ ករេយ្យ ឯកោ គិហីនំ ពុទ្ធស្ស អវណ្ណំ ភាសតិ ឯកោ គិហីនំ ធម្មស្ស អវណ្ណំ ភាសតិ ឯកោ គិហីនំ សង្ឃស្ស អវណ្ណំ ភាសតិ ឯកោ គិហី ហីនេន ខុំសេតិ គិហី ហីនេន វម្ភេតិ

ជេរពួកគ្រហស្ថដោយពាក្យថោកទាប ១ ដៀលត្មះពួកគ្រហស្ថដោយពាក្យថោកទាប ១ ទទួលពាក្យប្ដេជ្ញាប្រកបដោយធម៌អំពីពួកគ្រហស្ថហើយ ត្រឡប់ជាមិនធ្វើឲ្យពិតតាមពាក្យប្ដេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

(១៦១) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្មដល់ភិក្ខុ ៥ ពួក គឺភិក្ខុមួយពួកព្យាយាមមិនឲ្យពួកគ្រហស្ថបានលាភ ១ មួយពួកព្យាយាមមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ១ មួយពួកព្យាយាមមិនឲ្យពួកគ្រហស្ថបានលំនៅ ១ មួយពួកជេរប្រទេចពួកគ្រហស្ថ ១ មួយពួកបំបែកពួកគ្រហស្ថ (ឲ្យបែក) ចាកពួកគ្រហស្ថ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្មដល់ភិក្ខុ ៥ ពួកនេះឯង ។

(១៦២) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្មដល់ភិក្ខុ ៥ ពួកដទៃទៀត គឺភិក្ខុមួយពួកពោលតិះដៀលព្រះពុទ្ធចំពោះ(មុខ)ពួកគ្រហស្ថ ១ មួយពួកពោលតិះដៀលព្រះធម៌ចំពោះ(មុខ)ពួកគ្រហស្ថ ១ មួយពួកពោលតិះដៀលព្រះសង្ឃចំពោះ(មុខ)ពួកគ្រហស្ថ ១ មួយពួកជេរពួកគ្រហស្ថដោយពាក្យថោកទាប ១ មួយពួកដៀល

ឯកោ គិហីនំ ធម្មិកំ បដិស្សវំ ន សច្ចាបេតិ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ ករេយ្យ ។

អាកង្ខមានចតុបញ្ចកំ និដ្ឋិតំ ១

(១៦៣) បដិសារណីយកម្មកតេន ភិក្ខវេ ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បា-ទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋា-បេតព្វោ ន ភិក្ខុនោវាទកសម្មុតិ សាទិតព្វា សម្ម-តេនបិ ភិក្ខុនិយោ ន ឱវទិតព្វា យាយ អាបត្តិយា សង្ឃេន បដិសារណីយកម្មំ កតំ ហោតិ សា អាបត្តិ ន អាបជ្ជិតព្វា អញ្ញា វា តាទិសិកា តតោ វា បាបិដ្ឋតរា កម្មំ ន គរហិតព្វំ កម្មិកា ន គរហិតព្វា ន បក-តត្តស្ស ភិក្ខុនោ ឧបោសថោ ឋបេតព្វោ ន បវារណា

ត្នះពួកគ្រហស្ថដោយពាក្យជេរកទាប ១ មួយពួកទទួលពាក្យប្តេជ្ញាប្រកប ដោយធម៌អំពីពួកគ្រហស្ថហើយ ត្រឡប់ជាមិនធ្វើឲ្យពិតតាមពាក្យ ប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសា-រណីយកម្មដល់ភិក្ខុ ៥ ពួកនេះឯង ៗ

ចប់បដិសារណីយកម្មមានប្រាំ ៗ បួនលើក (ម្តង) ដែលសង្ឃប្រាថ្នា (នឹងធ្វើក៏ធ្វើបាន) ។

(១៦៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃបានធ្វើបដិសារណី-យកម្មហើយ គួរប្រព្រឹត្តវត្តដោយត្រឹមត្រូវ ៗ ឯការប្រព្រឹត្តិវត្តដោយត្រឹមត្រូវក្នុងបដិសារណីយកម្មនោះដូច្នេះ គឺភិក្ខុនោះមិនត្រូវឲ្យឧបសម្បទា ១ មិនត្រូវឲ្យនិស្ស័យ ១ មិនត្រូវឲ្យសាមណេរបម្រើខ្លួន ១ មិនត្រូវទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ ទុកជាសង្ឃបានសន្មតហើយក៏មិនត្រូវប្រដៅភិក្ខុនីទាំងឡាយ ១ សង្ឃបានធ្វើបដិសារណីយកម្មព្រោះអាបត្តិណា ភិក្ខុមិនគប្បីត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃប្រហែលគ្នានឹងអាបត្តិនោះ ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ ១ ភិក្ខុនោះមិនត្រូវតិះ-ដៀលកម្ម ១ មិនត្រូវតិះដៀលភិក្ខុដែលធ្វើកម្ម ១ មិនត្រូវហាមឧបោសថដល់ភិក្ខុជាបកតត្ត ១ មិនត្រូវហាមបវារណា ដល់ភិក្ខុជាបកតត្ត ១

ឋបេតព្វា ន សវចនីយំ កាតព្វំ ន អនុវាទោ បដ្ឋបេតព្វោ ន ឱកាសោ ការេតព្វោ ន ចោទេតព្វោ ន សារេតព្វោ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វន្តិ ។

បដិសារណីយកម្មេ អដ្ឋារសវត្តំ និដ្ឋិតំ ។

[១៦៤] អថខោ សង្ឃោ សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មំ អកាសិ ចិត្តោ តេ គហបតិ ខមាបេតព្វោតិ ។ សោ សង្ឃេន បដិសារណីយកម្មកតោ មច្ឆិកាសណ្ឌំ គន្ត្វា មង្កុភូតោ នាសក្ខិ ចិត្តំ គហបតឹ ខមាបេតុំ ។ សោ[១] បុន ទេវ សាវត្ថឹ បច្ចាគច្ឆិ ។ ភិក្ខូ ឯវមាហំសុ ខមាបិតោ តយា អាវុសោ សុធម្ម[២] ចិត្តោ គហបតីតិ ។ ឥធាហំ អាវុសោ មច្ឆិកាសណ្ឌំ គន្ត្វា មង្កុភូតោ នាសក្ខឹ ចិត្តំ គហបតឹ ខមាបេតុន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ សុធម្មស្ស ភិក្ខុនោ អនុទូតំ ទេតុ

---

១ អយំ សោសទ្ទោ ឱ. ប. បោត្ថកេសុ ន ទិស្សតិ ។ ២ អយំ អាវុសោ សុធម្មសទ្ទោ ឱ. បោត្ថកេសុ ន ទិស្សតិ ។

## កម្មក្ខន្ធក វិធីញុំាងសុធម្មភិក្ខុដ៏មានអាយុឲ្យសូមខមាទោស

មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ)១ មិនត្រូវទទួលនាទីជាធំក្នុងវត្ត១ មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនត្រូវចោទគេ១ មិនត្រូវរំលឹកគេ១ មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ។

ចប់វត្ត ១៨ ក្នុងបដិសារណីយកម្ម ។

(១៦៤) គ្រានោះ សង្ឃបានធ្វើបដិសារណីយកម្មដល់សុធម្មភិក្ខុថា លោកត្រូវសូមទោសនឹងចិត្តគហបតិ ។ សុធម្មភិក្ខុនោះកាលបើសង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏ទៅកាន់នគរមច្ឆិកាសណ្ឌ បែជាអៀនអន់មិនអាចនឹងសូមទោសចិត្តគហបតិឡើយ ។ លោកក៏ត្រឡប់មកក្រុងសាវត្ថីវិញ ។ ភិក្ខុទាំងឡាយនិយាយយ៉ាងនេះថា នែអាវុសោសុធម្ម លោកបានសូមទោសនឹងចិត្តគហបតិហើយឬ ។ សុធម្មភិក្ខុឆ្លើយថា នែអាវុសោទាំងឡាយ ខ្ញុំបានចេញអំពីទីនេះទៅដល់នគរមច្ឆិកាសណ្ឌហើយ ក៏មានសេចក្ដីអៀនអន់មិនអាចសូមទោសនឹងចិត្តគហបតិឡើយ ។ ភិក្ខុទាំងនោះបានក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃឲ្យអនុទូត[1]ដល់

---

១ ភិក្ខុជាអ្នកទទួលបម្រើរបស់សង្ឃ ដែលត្រូវចាត់ឲ្យទៅតាមពិនិត្យមើលការឬជួយសូមទោស គឺជាអ្នកដំណាងសង្ឃ ។

ចិត្តំ គហបតឹ ខមាបេតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ យាចិត្វា ព្យត្តេន ភិក្ខុនា បដិ-ពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សុធម្មស្ស ភិក្ខុនោ អនុទូតំ ទទេយ្យ ចិត្តំ គហបតឹ ខមា-បេតុំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សុធម្មស្ស ភិក្ខុនោ អនុទូតំ ទេតិ ចិត្តំ គហបតឹ ខមាបេតុំ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សុធម្មស្ស ភិក្ខុនោ អនុទូតស្ស ទានំ ចិត្តំ គហបតឹ ខមាបេតុំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ សុធម្មស្ស ភិក្ខុនោ អនុទូតោ ចិត្តំ គហបតឹ ខមាបេតុំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(១៦៨) តេន ភិក្ខវេ សុធម្មេន ភិក្ខុនា អនុទូតេន ភិក្ខុនា សទ្ធឹ មច្ឆិកាសណ្ឌំ គន្ត្វា ចិត្តោ គហបតិ

សុធម្មភិក្ខុដើម្បីសូមទោសនឹងចិត្តគហបតិ ។ ម្នាលភិក្ខុទាំងឡាយ (ភិក្ខុជាអនុទូតនោះ) សង្ឃត្រូវប្រគល់យ៉ាងនេះ ។ សង្ឃត្រូវសូមភិក្ខុជាមុន លុះសូមហើយត្រូវភិក្ខុដែលឈ្លាសប្រតិពលប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើបដិសារណីយកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវប្រគល់ភិក្ខុឈ្មោះនេះឲ្យជាអនុទូតរបស់សុធម្មភិក្ខុ ដើម្បីសូមទោសនឹងចិត្តគហបតិចុះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃប្រគល់ភិក្ខុឈ្មោះនេះឲ្យជាអនុទូតរបស់សុធម្មភិក្ខុ ដើម្បីសូមទោសនឹងចិត្តគហបតិ ។ ការប្រគល់ភិក្ខុឈ្មោះនេះឲ្យជាអនុទូតរបស់សុធម្មភិក្ខុ ដើម្បីទៅសូមទោសនឹងចិត្តគហបតិ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ សង្ឃបានប្រគល់ភិក្ខុឈ្មោះនេះឲ្យជាអនុទូតរបស់សុធម្មភិក្ខុ ដើម្បីនឹងសូមទោសចិត្តគហបតិហើយ ការប្រគល់អនុទូតនោះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ។

(១៦៥) ម្នាលភិក្ខុទាំងឡាយ សុធម្មភិក្ខុនោះត្រូវទៅនគរមច្ឆិកាសណ្ឌជាមួយនឹងភិក្ខុជាអនុទូត ហើយសូមទោសនឹងចិត្តគហបតិថា ម្នាល

ខមាបេតព្វោ ខម គហបតិ បសាទេមិ តន្តិ ឯវញ្ចេ វុច្ចមានោ ខមតិ ឥច្ចេតំ កុសលំ ។ នោ ចេ ខមតិ អនុទូតេន ភិក្ខុនា វត្តព្វោ ខម គហបតិ ឥមស្ស ភិក្ខុនោ បសាទេតិ តន្តិ ឯវញ្ចេ វុច្ចមានោ ខមតិ ឥច្ចេតំ កុសលំ ។ នោ ចេ ខមតិ អនុទូតេន ភិក្ខុនា វត្តព្វោ ខម គហបតិ ឥមស្ស ភិក្ខុនោ អហន្តំ បសាទេមីតិ ឯវញ្ចេ វុច្ចមានោ ខមតិ ឥច្ចេតំ កុសលំ ។ នោ ចេ ខមតិ អនុទូតេន ភិក្ខុនា វត្តព្វោ ខម គហបតិ ឥមស្ស ភិក្ខុនោ សង្ឃស្ស វចនេនាតិ ឯវញ្ចេ វុច្ចមានោ ខមតិ ឥច្ចេតំ កុសលំ ។ នោ ចេ ខមតិ អនុទូតេន ភិក្ខុនា សុធម្មំ ភិក្ខុំ ចិត្តស្ស គហបតិនោ ទស្សនូបចារំ អវិជហាបេត្វា សវនូបចារំ អវិជហាបេត្វា ឯកំសំ ឧត្តរាសង្គំ ការាបេត្វា ឧក្កុដិកំ និសីទាបេត្វា អញ្ជលឹ បគ្គណ្ហាបេត្វា សា អាបត្តិ ទេសាបេតព្វាតិ ។

គហបតិ អ្នកចូរអត់ទោស ម្នាលគហបតិ អាត្មាឲ្យអ្នកជ្រះថ្លា (វិញ) បើសុធម្មភិក្ខុនោះនិយាយយ៉ាងនេះ ចិត្តគហបតិក៏បានព្រមអត់ទោសឲ្យ ការអត់ទោសឲ្យយ៉ាងនេះជាការល្អ ។ បើចិត្តគហបតិមិនព្រមអត់ទោសឲ្យទេ ត្រូវភិក្ខុជាអនុទូតជួយនិយាយថា ម្នាលចិត្តគហបតិ អ្នកចូរអត់ទោសដល់ភិក្ខុនេះចុះ ភិក្ខុនេះនឹងឲ្យអ្នកជ្រះថ្លាវិញ បើភិក្ខុជាអនុទូតនិយាយយ៉ាងនេះហើយ ចិត្តគហបតិក៏អត់ទោសឲ្យ ការព្រមអត់ទោសឲ្យយ៉ាងនេះជាការល្អ ។ បើចិត្តគហបតិមិនព្រមអត់ទោសឲ្យទេ ត្រូវភិក្ខុជាអនុទូតនិយាយថា ម្នាលចិត្តគហបតិ អ្នកចូរអត់ទោសដល់ភិក្ខុនេះចុះ អាត្មានឹងឲ្យអ្នកជ្រះថ្លាវិញ បើភិក្ខុជាអនុទូតនិយាយយ៉ាងនេះហើយ ចិត្តគហបតិក៏ព្រមអត់ទោសឲ្យ ការព្រមអត់ទោសឲ្យយ៉ាងនេះជាការល្អ ។ បើចិត្តគហបតិនោះមិនព្រមអត់ទោសឲ្យទេ ត្រូវភិក្ខុជាអនុទូតនិយាយទៀតថា ម្នាលចិត្តគហបតិ អ្នកចូរអត់ទោសដល់ភិក្ខុនេះ តាមពាក្យរបស់សង្ឃចុះ បើភិក្ខុជាអនុទូតនិយាយយ៉ាងនេះ ចិត្តគហបតិក៏ព្រមអត់ទោសឲ្យ ការព្រមអត់ទោសឲ្យយ៉ាងនេះជាការល្អ។ បើចិត្តគហបតិមិនព្រមអត់ទោសឲ្យទេ ត្រូវភិក្ខុជាអនុទូតកុំឲ្យសុធម្មភិក្ខុលះទីឧបចារដែលមើលឃើញ កុំឲ្យលះទីឧបចារដែលស្តាប់ឮ របស់ចិត្តគហបតិឡើយ ហើយឲ្យធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាងរួចឲ្យអង្គុយច្រហោងផ្គងអញ្ជលីហើយឲ្យសំដែងអាបត្តិនោះចេញ ។

[១៦៦] អថខោ អាយស្មា សុធម្មោ អនុទូតេន ភិក្ខុនា សទ្ធឹ មច្ឆិកាសណ្ឌំ គន្ត្វា ចិត្តំ គហបតឹ ខមាបេសិ ។ សោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ ភិក្ខូ ឧបសង្កមិត្វា ឯវំ វទេតិ អហំ អាវុសោ សង្ឃេន បដិសារណីយកម្មកតោ សម្មា វត្តាមិ លោមំ បាតេមិ នេត្ថារំ វត្តាមិ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្សម្ភេតុ ។

[១៦៧] បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ ន បដិប្បស្សម្ភេតព្វំ ឧបសម្បាទេតិ និស្សយំ ទេតិ សាមណេរំ ឧបដ្ឋាបេតិ ភិក្ខុនោវាទកសម្មុតឹ សាទិយតិ សម្មតោបិ ភិក្ខុនិយោ ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

[១៦៦] វេលានោះ ឯសុធម្មភិក្ខុដ៏មានអាយុក៏បានទៅកាន់នគរមច្ឆិកាសណ្ឌជាមួយនឹងភិក្ខុជាអនុទូតហើយសូមទោសចិត្តគហបតី ។ សុធម្មភិក្ខុនោះព្រមប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម រួចចូលទៅរកភិក្ខុទាំងឡាយហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាអ្នកដែលសង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្មហើយ ខ្ញុំត្រូវប្រតិបត្តិដូចម្តេច (ទៀត) ។ ភិក្ខុទាំងនោះបានក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូររម្ងាប់បដិសារណីយកម្មរបស់សុធម្មភិក្ខុចុះ ។

[១៦៧] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បដិសារណីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៥ គឺភិក្ខុឲ្យឧបសម្បទា ១ ឲ្យនិស្ស័យ ១ ឲ្យសាមណេរបម្រើខ្លួន ១ ទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ ដែលសង្ឃបានសន្មតហើយក៏ទៅប្រដៅពួកភិក្ខុនី ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បដិសារណីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ ៥នេះទេ ។

(១៦៨) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ ន បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន បដិសារណីយកម្មំ កតំ ហោតិ តំ អាបត្តឹ អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ គរហតិ កម្មិកេ គរហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

(១៦៩) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ ន បដិប្បស្សម្ភេតព្វំ បកតត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ បវារណំ ឋបេតិ សវចនីយំ ករោតិ អនុវាទំ បដ្ឋបេតិ ឱកាសំ ការេតិ ចោទេតិ សារេតិ ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

បដិសារណីយកម្មេ នប្បដិប្បស្សម្ភេតព្វអដ្ឋារសកំ និដ្ឋិតំ ។

កម្មក្ខន្ធកៈ បដិសារណីយកម្មដែលសង្ឃមិនត្រូវរម្ងាប់

(១៦៨) ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បដិសារណីយ-កម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឃបានធ្វើបដិសារណីយកម្មព្រោះអាបត្តិណា នៅតែត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃដែលប្រហែលគ្នានឹងអាបត្តិនោះ ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ ១ តិះដៀលកម្ម ១ តិះដៀលពួកភិក្ខុដែលធ្វើកម្ម ១ ម្នាលភិក្ខុទាំង-ឡាយ សង្ឃមិនត្រូវរម្ងាប់បដិសារណីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះទេ ។

(១៦៩) ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បដិសារណីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុហាមឧបោសថដល់ភិក្ខុជាបកតត្ត ១ ហាមបវារណាដល់ភិក្ខុជាបកតត្ត ១ ធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិក-រណនោះ) ១ ទទួលនាទីជាធំក្នុងវត្ត ១ ឲ្យធ្វើឱកាស (ដើម្បីចោទ) ១ ចោទ ១ រំលឹក ១ ប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បដិសារណីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៨ នេះទេ ។

ចប់អង្គមានចំនួន ១៨ ដែលសង្ឃមិនត្រូវរម្ងាប់ក្នុងបដិសារណីយកម្ម ។

(១៧០) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្សម្ភេតព្វំ ន ឧបសម្បាទេតិ ន និស្សយំ ទេតិ ន សាមណេរំ ឧបដ្ឋាបេតិ ន ភិក្ខុនោវាទកសម្មុតឹ សាទិយតិ សម្មតោបិ ភិក្ខុនិយោ ន ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្សម្ភេតព្វំ ។

(១៧១) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន បដិសារណីយកម្មំ កតំ ហោតិ តំ អាបត្តឹ ន អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ ន គរហតិ កម្មិកេ ន គរហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្សម្ភេតព្វំ ។

(១៧២) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្សម្ភេតព្វំ ន បកតត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ ន បវារណំ

(១៧០) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បដិសារណីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ គឺភិក្ខុមិនបានឲ្យឧបសម្បទា ១ មិនបានឲ្យនិស្ស័យ ១ មិនបានឲ្យសាមណេរបម្រើខ្លួន ១ មិនបានទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ ដែលសង្ឃបានសន្មតហើយក៏មិនប្រដៅភិក្ខុនី ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បដិសារណីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

(១៧១) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បដិសារណីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឃបានធ្វើបដិសារណីយកម្មព្រោះអាបត្តិណា ហើយមិនបានត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃប្រហែលគ្នានឹងអាបត្តិនោះ ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ ១ មិនបានតិះដៀលកម្ម ១ មិនបានតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បដិសារណីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

(១៧២) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បដិសារណីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុមិនបានហាមឧបោសថដល់ភិក្ខុជាបកតត្ត ១ មិនបានហាមបវារណាដល់ភិក្ខុជាបកតត្ត ១ មិនបានធ្វើជាអ្នកមានមាត់ពាក្យ

ឋបេតិ ន សវចនីយំ ករោតិ ន អនុវាទំ បដ្ឋបេតិ ន ឱកាសំ ការេតិ ន ចោទេតិ ន សារេតិ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្សម្ភេតព្វំ ។

បដិសារណីយកម្មេ បដិប្បស្សម្ភេតព្វអដ្ឋារសកំ និដ្ឋិតំ ។

(១៧៣) ឯវញ្ច បន ភិក្ខវេ បដិប្បស្សម្ភេតព្វំ ។ តេនហិ[1] ភិក្ខវេ សុធម្មេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ សង្ឃេន បដិសារណីយកម្មកតោ សម្មា វត្តាមិ លោមំ បាតេមិ នេត្ថារំ វត្តាមិ បដិសារណីយកម្មស្ស បដិប្បស្សទ្ធឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា ។ តតិយម្បិ យាចិតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ សុធម្មោ ភិក្ខុ សង្ឃេន បដិសារណីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ

---

១ ហិសទ្ទោ ឱ ពោត្ថកេ ន ទិស្សតិ ។

(ក្នុងអធិករណ៍នោះ) ១ មិនបានទទួលនាទីជាធំក្នុងវត្ត ១ មិនបានឲ្យធ្វើឱកាស (ដើម្បីចោទ) ១ មិនបានចោទគេ ១ មិនបានរំលឹក ១ មិនបានប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងភិក្ខុផងគ្នា ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បដិសារណីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៨ នេះឯង ។

ចប់អង្គមានចំនួន ១៨ ដែលសង្ឃត្រូវរម្ងាប់ក្នុងបដិសារណីយកម្ម ។

(១៧៣) ម្នាលភិក្ខុទាំងឡាយ ឯបដិសារណីយកម្មនោះ សង្ឃត្រូវរម្ងាប់យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះសុធម្មភិក្ខុត្រូវចូលទៅរកសង្ឃហើយ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាងរួចថ្វាយបង្គំបាទារបស់ភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលី និយាយយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាអ្នកដែលសង្ឃបានធ្វើបដិសារណី-យកម្មរួចហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយាលោះចេញចាកកម្ម មកសូមការរម្ងាប់បដិសារណីយកម្ម ។ ភិក្ខុនោះត្រូវសូមជាគំរប់ពីរដងផង ។ ត្រូវសូមជាគំរប់បីដងផង ។ ភិក្ខុដែលឆ្លាសប្រតិពល ត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សុធម្មភិក្ខុនេះ សង្ឃបានធ្វើបដិសារណីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់

នេត្ថារំ វត្តតិ បដិសារណីយកម្មស្ស បដិប្បស្សទ្ធឹ
យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ សុធម្ម-
ស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្សម្ភេយ្យ ។
ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ
សុធម្មោ ភិក្ខុ សង្ឃេន បដិសារណីយកម្មកតោ
សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បដិសា-
រណីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ សង្ឃោ
សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្ស-
ម្ភេតិ ។ យស្សាយស្មតោ ខមតិ សុធម្មស្ស ភិក្ខុនោ
បដិសារណីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស
យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ
ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ
អយំ សុធម្មោ ភិក្ខុ សង្ឃេន បដិសារណីយ-
កម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ
បដិសារណីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ សង្ឃោ
សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្សម្ភេតិ ។
យស្សាយស្មតោ ខមតិ សុធម្មស្ស ភិក្ខុនោ បដិសារ-

កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់បដិសារណីយកម្ម ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវរម្ងាប់បដិសារណីយកម្មដល់សុធម្មភិក្ខុចេញ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សុធម្មភិក្ខុនេះ សង្ឃបានធ្វើបដិសារណីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្រុបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់បដិសារណីយកម្ម ។ សង្ឃរម្ងាប់បដិសារណីយកម្មដល់សុធម្មភិក្ខុ ។ ការរម្ងាប់បដិសារណីយកម្មដល់សុធម្មភិក្ខុគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សុធម្មភិក្ខុនេះ សង្ឃបានធ្វើបដិសារណីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្រុបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់បដិសារណីយកម្ម ។ សង្ឃរម្ងាប់បដិសារណីយកម្មដល់សុធម្មភិក្ខុ ។ ការរម្ងាប់បដិសារណីយកម្មដល់សុធម្មភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោក

ណីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ សុធម្មោ ភិក្ខុ សង្ឃេន បដិសារណីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បដិសារណីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ សង្ឃោ សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មំ បដិប្បស្សម្ភេតិ ។ យស្សាយស្មតោ ខមតិ សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ បដិប្បស្សទ្ធំ សង្ឃេន សុធម្មស្ស ភិក្ខុនោ បដិសារណីយកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

បដិសារណីយកម្មំ ចតុត្ថំ និដ្ឋិតំ ។

(១៧៤) តេន សមយេន ពុទ្ធោ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មា ឆន្នោ អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តឹ បស្សិតុំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ

ដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សុធម្មភិក្ខុនេះ សង្ឃបានធ្វើបដិសារណីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបពេម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់បដិសារណីយកម្ម ។ សង្ឃរម្ងាប់បដិសារណីយកម្មដល់សុធម្មភិក្ខុ ។ ការរម្ងាប់បដិសារណីយកម្មដល់សុធម្មភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ សង្ឃបានរម្ងាប់បដិសារណីយកម្មដល់សុធម្មភិក្ខុហើយ ការរម្ងាប់បដិសារៈណីយកម្មដល់សុធម្មភិក្ខុនេះគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ចប់ បដិសារណីយកម្មទី ៤ ។

(១៧៤) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងឃោសិតារាមជិតក្រុងកោសម្ពី ។ វេលានោះឯង ឆន្នភិក្ខុដ៏មានអយុត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញនូវអាបត្តិឡើយ ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស

ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឆន្នោ អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆិស្សតិ អាបត្តឹ បស្សិតុន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

(១៧៥) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ឆន្នោ ភិក្ខុ អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តឹ បស្សិតុន្តិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ[១] ។ បេ ។ កថំ ហិ នាម សោ ភិក្ខវេ មោឃបុរិសោ អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆិស្សតិ អាបត្តឹ បស្សិតុំ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ។ បេ ។ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ ករោតុ អសម្ភោគំ សង្ឃេន ។ ឯវញ្ច បន ភិក្ខវេ កាតព្វំ ។ បឋមំ ឆន្នោ ភិក្ខុ ចោទេតព្វោ ចោទេត្វា

---

១ អននុច្ឆវិកន្តិ កត្ថចិ បោត្ថកេ ន ទិស្សតិ ។

តិះដៀល បន្តុះបង្អាប់ថា មិនសមបើឆន្នដ៏មានអាយុត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិសោះ ។ ទើបភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។

(១៧៤) ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃក្នុងវេលានោះ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បានឮថាឆន្នភិក្ខុត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ការនេះមិនសមគួរទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មិនសមបើមោឃបុរសនោះត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះនឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើងក៏ទេ ។ បេ ។ លុះទ្រង់បន្ទោសរួច ។ បេ ។ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំង-ឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯឧក្ខេបនីយកម្មនោះ សង្ឃត្រូវធ្វើយ៉ាងនេះ ។ សង្ឃត្រូវចោទឆន្នភិក្ខុជាមុន លុះចោទហើយត្រូវរំលឹក លុះរំលឹកហើយ

សារេតព្វោ សារេត្វា អាបត្តិ អារោបេតព្វា អាបត្តឹ អារោបេត្វា ព្យត្តេន[១] ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឆន្នោ ភិក្ខុ អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តឹ បស្សិតុំ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ ករេយ្យ អសម្ភោគំ សង្ឃេន ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឆន្នោ ភិក្ខុ អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តឹ បស្សិតុំ ។ សង្ឃោ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ ករោតិ អសម្ភោគំ សង្ឃេន ។ យស្សាយស្មតោ ខមតិ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មស្ស ករណំ អសម្ភោគំ សង្ឃេន សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឆន្នោ ភិក្ខុ អាបត្តឹ អាបជ្ជិត្វា

---

១ ឱ. អាបត្តិ រោបេតព្វា អាបត្តឹ រោបេត្វា វ្យត្តេន ។

## កម្មក្ខន្ធក ការធ្វើឧក្ខេបនីយកម្មដល់ឆន្នភិក្ខុ

ត្រូវលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុដែលឆ្លាសប្រតិពល ត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិឡើយ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើឧក្ខេបនីយកម្ម គឺកុំឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុចុះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះត្រូវអាបត្តិហើយមិនប្រាថ្នានឹងឃើញអាបត្តិទេ ។ សង្ឃក៏ធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុ ។ ការធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិទេ ។

ន ឥច្ឆតិ អាបត្តឹ បស្សិតុំ ។ សង្ឃោ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ ករោតិ អសម្ភោគំ សង្ឃេន ។ យស្សាយស្មតោ ខមតិ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មស្ស ករណំ អសម្ភោគំ សង្ឃេន សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ កតំ សង្ឃេន ឆន្នស្ស ភិក្ខុនោ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ អសម្ភោគំ សង្ឃេន ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ អាវាសបរម្បរញ្ច ភិក្ខវេ សំសថ ឆន្នោ ភិក្ខុ សង្ឃេន[1] អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មកតោ អសម្ភោគំ សង្ឃេនាតិ ។

(១៧៦) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អសម្មុខា កតំ ហោតិ អប្បដិបុច្ឆា កតំ ហោតិ អប្បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ

---

១ ឥធ សង្ឃេនាតិ សទ្ទោ ឧភោបិយមរម្មបោត្ថកេសុ ន ទិស្សតិ ។

សង្ឃក៏ធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិដល់ឆន្នភិក្ខុ ។ ការធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិដល់ឆន្នភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ សង្ឃបានធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃព្រោះមិនឃើញអាបត្តិដល់ឆន្នភិក្ខុហើយ ការធ្វើឧក្ខេបនីយកម្មដល់ឆន្នភិក្ខុនេះ គួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រាប់គ្នាក្នុងអាវាសត ៗ ទៅថា ឆន្នភិក្ខុ សង្ឃបានធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិហើយ ។

(១៧៦) ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្មព្រោះមិនឃើញអាបត្តិ ដែលជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ គឺកម្មដែលធ្វើក្នុងទីកំបាំងមុខ ១ កម្មដែលធ្វើដោយមិនបានសាកសួរ ១ កម្មដែលធ្វើដោយមិនតាមពាក្យប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្មព្រោះមិន

អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុរូបសន្តញ្ច ។

(១៧៧) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុរូបសន្តញ្ច អនាបត្តិយា កតំ ហោតិ អទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ ទេសិតាយ អាបត្តិយា កតំ ហោតិ ។ បេ ។

(១៧៨) អបរេហិបិ ។ បេ ។ អចោទេត្វា កតំ ហោតិ អសារេត្វា កតំ ហោតិ អាបត្តឹ អនារោបេត្វា កតំ ហោតិ ។ បេ ។

(១៧៩) អបរេហិបិ ។ បេ ។ អសម្មុខា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។

(១៨០) អបរេហិបិ ។ បេ ។ អប្បដិបុច្ឆា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ ។ បេ ។

ឃើញអាបត្តិ ដែលជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

(១៧៧) ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដែលជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយគ្មានអាបត្តិ ១ កម្មដែលធ្វើដោយអាបត្តិមិនមែនជាទេសនាគាមិនី ១ កម្មដែលធ្វើដោយអាបត្តិដែលភិក្ខុសំដែងហើយ ១ ។ បេ ។

(១៧៨) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលមិនបានចោទហើយស្រាប់តែធ្វើ ១ កម្មដែលមិនបានរំលឹកហើយស្រាប់តែធ្វើ ១ កម្មដែលមិនបានលើកអាបត្តិឡើងហើយស្រាប់តែធ្វើ ១ ។ បេ ។

(១៧៩) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើក្នុងទីកំបាំងមុខ ១ កម្មដែលធ្វើមិនប្រកបដោយធម៌ ១ កម្មដែលធ្វើដោយពួក ១ ។ បេ ។

(១៨០) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយមិនបានសាកសួរ ១ កម្មដែលធ្វើមិនប្រកបដោយធម៌ ១ កម្មដែលធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ ។ បេ ។

(១៨១) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ។ បេ ។ អប្បដិញ្ញាយ កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។

(១៨២) អបរេហិបិ ។ បេ ។ អនាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។

(១៨៣) អបរេហិបិ ។ បេ ។ អទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។

(១៨៤) អបរេហិបិ ។ បេ ។ ទេសិតាយ អាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។

(១៨៥) អបរេហិបិ ។ បេ ។ អចោទេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។

(១៨៦) អបរេហិបិ ។ បេ ។ អសារេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។

(២៥៧) អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មកតេន ភិក្ខវេ ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ ន ភិក្ខុនោវាទកសម្មុតិ សាទិតព្វា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វា យាយ អាបត្តិយា សង្ឃេន អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ កតំ ហោតិ សា អាបត្តិ ន អាបជ្ជិតព្វា

## កម្មក្ខន្ធក ការប្រព្រឹត្តដោយប្រពៃក្នុងឧក្ខេបនីយកម្ម

(២៥៦) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ ពួក ១ ពោលតិះដៀលព្រះធម៌ ពួក ១ ពោលតិះដៀលព្រះសង្ឃ ពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុ ៣ ពួក នេះឯង ។

### ចប់វត្ថុមានចំនួន ៦ ដែលសង្ឃប្រាថ្នា (នឹងធ្វើក៏ធ្វើបាន) ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ។

(២៥៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃបានធ្វើឧក្ខេបនីយកម្មហើយ ព្រោះមិនសំដែងអាបត្តិចេញ ត្រូវប្រព្រឹត្តដោយប្រពៃ ។ ការប្រព្រឹត្តដោយប្រពៃ ក្នុងឧក្ខេបនីយកម្មនោះដូច្នេះ គឺភិក្ខុនោះមិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ទុកជាសង្ឃបានសន្មតហើយ ក៏មិនត្រូវប្រដៅភិក្ខុនីដែរ ភិក្ខុនោះដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញចំពោះអាបត្តិណា កុំឲ្យត្រូវអាបត្តិនោះទៀត

អញ្ញា វា តាទិសិកា តតោ វា បាបិដ្ឋតរា កម្មំ ន គរហិតព្វំ កម្មិកា ន គរហិតព្វា ន បកតត្តស្ស ភិក្ខុនោ អភិវា-ទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អាសនាភិហារោ សេយ្យាភិហារោ បាទោទកំ បាទបីឋំ បាទកឋលិកំ បត្តចីវរប្បដិគ្គហណំ នហានេ បិដ្ឋិបរិកម្មំ សាទិតព្វំ ន បកតត្តោ ភិក្ខុ សីលវិបត្តិយា អនុទ្ធំសេតព្វោ ន អាចារវិបត្តិយា អនុទ្ធំសេតព្វោ ន ទិដ្ឋិវិបត្តិយា អនុទ្ធំសេ-តព្វោ ន អាជីវវិបត្តិយា អនុទ្ធំសេតព្វោ ន ភិក្ខុ ភិក្ខូហិ ភេទេតព្វោ ន គិហិទ្ធជោ ធារេតព្វោ ន តិត្ថិយទ្ធជោ ធារេតព្វោ ន តិត្ថិយា សេវិតព្វា ភិក្ខូ សេវិតព្វា ភិក្ខុ-សិក្ខា សិក្ខិតព្វា ន បកតត្តេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អនាវាសេ វត្ថព្វំ ន ឯ-កច្ឆន្នេ អាវាសេ វា អនាវាសេ វា វត្ថព្វំ បកតត្តំ ភិក្ខុំ ទិស្វា អាសនា វុដ្ឋាតព្វំ ន បកតត្តោ ភិក្ខុ អាសាទេ-តព្វោ អន្តោ វា ពហិ វា ន បកតត្តស្ស ភិក្ខុនោ ឧបោសថោ ឋបេតព្វោ ន បវារណា ឋបេតព្វា

ឬអាបត្តិឯទៀតប្រហែលនឹងអាបត្តិនោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុដែលធ្វើកម្ម មិនត្រូវត្រេកអរនឹងការសំពះ ការក្រោកទទួល ការធ្វើអញ្ជលិ សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកលាងជើង តាំងទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រនឹងចីវរ ការដុសក្អែលខ្នងក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្ត មិនត្រូវចោទភិក្ខុជាបកតត្ត ដោយសីលវិបត្តិ មិនត្រូវចោទដោយអាចារវិបត្តិ មិនត្រូវចោទដោយទិដ្ឋិវិបត្តិ មិនត្រូវចោទដោយអាជីវវិបត្តិ មិនត្រូវបំបែកពួកភិក្ខុ (ឲ្យបែក) ចាកភិក្ខុផងគ្នា មិនត្រូវទ្រទ្រង់ទង់ជ័យរបស់គ្រហស្ថ មិនត្រូវទ្រទ្រង់ទង់ជ័យរបស់តិរ្ថិយ មិនត្រូវសេពគប់នឹងតិរ្ថិយ ត្រូវតែគប់រកពួកភិក្ខុ ត្រូវតែសិក្សាសិក្ខារបស់ភិក្ខុ មិនត្រូវនៅក្នុងអាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងទីមិនមែនជាអាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាសឬទីមិនមែនជាអាវាសដែលមានដម្បូលមួយជាមួយនឹងភិក្ខុជាបកតត្ត បើឃើញភិក្ខុជាបកតត្តមកហើយ ត្រូវតែក្រោកឡើងចាកអាសន មិនត្រូវរុករានភិក្ខុជាបកតត្ត ខាងក្នុងឬខាងក្រៅ(វិហារ) មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណាដល់ភិក្ខុ

ន សវចនីយំ កាតព្វំ ន អនុវាទោ បដ្ឋបេតព្វោ ន ឱកាសោ ការេតព្វោ ន ចោទេតព្វោ ន សារេតព្វោ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វន្តិ ។

អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មេ តេចត្តាឡីសវត្តំ និដ្ឋិតំ ។

[២៥៨] អថខោ សង្ឃោ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ អកាសិ អសម្ភោគំ សង្ឃេន ។ សោ សង្ឃេន អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មកតោ តម្ហា អាវាសា អញ្ញំ អាវាសំ អគមាសិ ។ តត្ថ ភិក្ខូ នេវ អភិវាទេសុំ ន បច្ចុដ្ឋេសុំ ន អញ្ជលិកម្មំ ន សាមីចិកម្មំ អកំសុ ន សក្ការឹសុ ន គរុការឹសុ ន មានេសុំ ន បូជេសុំ ។ សោ ភិក្ខូហិ អសក្ករិយមានោ អគរុករិយមានោ អមានិយមានោ អបូជិយមានោ អសក្ការបកតោ តម្ហាបិ អាវាសា អញ្ញំ អាវាសំ អគមាសិ ។ តត្ថបិ ភិក្ខូ នេវ អភិវាទេសុំ ន បច្ចុដ្ឋេសុំ ន អញ្ជលិកម្មំ ន សាមីចិកម្មំ អកំសុ

ជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ) មិនត្រូវទទួលនាទីជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទគេ មិនត្រូវរំលឹកគេ មិនត្រូវញុះញង់ពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ។

ចប់វគ្គ ៤៣ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ។

(២៥៨) គ្រានោះ សង្ឃបានធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ ។ ឆន្នភិក្ខុនោះ លុះត្រូវសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញហើយ ក៏ចេញអំពីអាវាសនោះ ទៅកាន់អាវាសឯទៀត ។ ពួកភិក្ខុក្នុងអាវាសនោះក៏មិនថ្វាយបង្គំ មិនក្រោកទទួល មិនធ្វើអញ្ជលិកម្ម មិនធ្វើសាមីចិកម្ម មិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជាឡើយ ។ ឆន្នភិក្ខុនោះកាលដែលពួកភិក្ខុមិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជា គ្មាននរណាធ្វើសក្ការហើយ ក៏ចេញអំពីអាវាសនោះទៅកាន់អាវាសដទៃ ។ ពួកភិក្ខុក្នុងអាវាសនោះ ក៏មិនថ្វាយបង្គំ មិនក្រោកទទួល មិនធ្វើអញ្ជលិកម្ម មិនធ្វើ

ន សក្ការឹសុ ន គរុការឹសុ ន មានេសុំ ន បូជេសុំ ។
សោ ភិក្ខុហិ អសក្ការិយមានោ អគរុការិយមានោ
អមានិយមានោ អបូជិយមានោ អសក្ការបកតោ តម្ហាបិ
អាវាសា អញ្ញំ អាវាសំ អគមាសិ ។ តត្ថបិ ភិក្ខូ
នេវ អភិវាទេសុំ ន បច្ចុដ្ឋេសុំ ន អញ្ជលិកម្មំ ន
សាមីចិកម្មំ អកំសុ ន សក្ការឹសុ ន គរុការឹសុ ន
មានេសុំ ន បូជេសុំ ។ សោ ភិក្ខុហិ អសក្ការិយមានោ
អគរុការិយមានោ អមានិយមានោ អបូជិយមានោ
អសក្ការបកតោ បុនទេវ កោសម្ពឹ បច្ចាគញ្ឆិ ។
សោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ ភិក្ខូ
ឧបសង្កមិត្វា ឯវំ វទេតិ អហំ អាវុសោ សង្ឃេន
អាបត្តិយា អប្បដិកម្មេ ឧក្ខេបនិយកម្មកតោ សម្មា
វត្តាមិ លោមំ បាតេមិ នេត្ថារំ វត្តាមិ កថំ នុ ខោ
មយា បដិបជ្ជិតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ
អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ ឆន្នស្ស ភិក្ខុនោ
អាបត្តិយា អប្បដិកម្មេ ឧក្ខេបនិយកម្មំ បដិប្បស្ស-
ម្ភេតុ ។

សាមីចិកម្ម មិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជាទៀតដែរ ។ ឆន្នភិក្ខុនោះ កាលបើពួកភិក្ខុមិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជា គ្មាននរណាធ្វើសក្ការហើយ ក៏ចេញអំពីអាវាសនោះទៅកាន់អាវាសដទៃទៀត ។ ពួកភិក្ខុក្នុងអាវាសនោះ ក៏មិនថ្វាយបង្គំ មិនក្រោកទទួល មិនធ្វើអញ្ជលិកម្ម មិនធ្វើសាមីចិកម្ម មិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជាដែរ ។ ឆន្នភិក្ខុនោះ កាលដែលពួកភិក្ខុមិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជា គ្មាននរណាធ្វើសក្ការហើយ ក៏ត្រឡប់មកក្រុងកោសម្ពីវិញ ។ ឆន្នភិក្ខុក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្បុបកោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម ហើយចូលទៅរកភិក្ខុទាំងឡាយ និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញហើយ ក៏បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្បុបកោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម តើខ្ញុំគប្បីប្រតិបត្តិដូចម្តេចទៀត ។ ពួកភិក្ខុនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះសង្ឃចូររម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុចុះ ។

(២៥៩) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ឧបសម្បាទេតិ និស្សយំ ទេតិ សាមណេរំ ឧបដ្ឋាបេតិ ភិក្ខុនោវាទកសម្មុតឹ សាទិយតិ សម្មតោបិ ភិក្ខុនិយោ ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

(២៦០) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ន បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ កតំ ហោតិ តំ អាបត្តឹ អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ គរហតិ កម្មិកេ គរហតិ ។បេ។

(២៦១) អបរេហិបិ ។បេ។ បកតត្តស្ស ភិក្ខុនោ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អាសនាភិហារំ សាទិយតិ ។បេ។

[២៥៩] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនគប្បីរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ គឺភិក្ខុឲ្យឧបសម្បទា ១ ឲ្យនិស្ស័យ ១ ឲ្យសាមណេរបម្រើខ្លួន ១ ទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ ទុកជាសង្ឃសន្មតហើយនៅតែប្រដៅពួកភិក្ខុនី ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះទេ ។

[២៦០] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ចំពោះអាបត្តិណាហើយ នៅតែត្រូវអាបត្តិនោះទៀត ១ ឬត្រូវអាបត្តិដទៃប្រហែលអាបត្តិនោះ ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ ១ តិះដៀលកម្ម ១ តិះដៀលពួកភិក្ខុដែលធ្វើកម្ម ១ ។ បេ ។

[២៦១] អង្គ ៥ ដទៃទៀត ។ បេ ។ គឺភិក្ខុត្រេកអរនឹងការសំពះ ១ ការក្រោកទទួល ១ អញ្ជលិកម្ម ១ សាមីចិកម្ម ១ ការនាំអាសនមកឲ្យ ១ របស់ភិក្ខុជាបកតត្ត ។ បេ ។

[២៦២] អបរេហិបិ ។ បេ ។ បកតត្តស្ស ភិក្ខុនោ សេយ្យាភិហារំ បាទោទកំ បាទបីឋំ បាទកឋលិកំ បត្ត-ចីវរប្បដិគ្គហណំ នហានេ បិដ្ឋិបរិកម្មំ សាទិយតិ ។ បេ ។

[២៦៣] អបរេហិបិ ។ បេ ។ បកតត្តំ ភិក្ខុំ សីលវិបត្តិយា អនុទ្ធំសេតិ អាចារវិបត្តិយា អនុទ្ធំសេតិ ទិដ្ឋិវិបត្តិយា អនុទ្ធំសេតិ អាជីវវិបត្តិយា អនុទ្ធំសេតិ ភិក្ខុ ភិក្ខូហិ ភេទេតិ ។ បេ ។

[២៦៤] អបរេហិបិ ។ បេ ។ គិហិទ្ធជំ ធារេតិ តិត្ថិយទ្ធជំ ធារេតិ តិត្ថិយេ សេវតិ ន ភិក្ខូ សេវតិ ភិក្ខុសិក្ខាយ ន សិក្ខតិ ។ បេ ។

[២៦៥] អបរេហិបិ ។ បេ ។ បកតត្តេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាវាសេ វសតិ ឯកច្ឆន្នេ អនាវាសេ វសតិ ឯកច្ឆន្នេ អាវាសេ វា អនាវាសេ វា វសតិ បកតត្តំ ភិក្ខុំ ទិស្វា អាសនា ន វុដ្ឋាតិ បកតត្តំ ភិក្ខុំ

(២៦២) អង្គ ៥ ដទៃទៀត ។បេ។ គឺភិក្ខុត្រេកអរនឹងការនាំទីដេកមកឲ្យ ១ ទឹកសម្រាប់លាងជើង ១ តាំងសម្រាប់ទ្រជើង ១ វត្ថុសម្រាប់ជូតជើង ១ ការទទួលបាត្រនិងចីវរ ១ ការដុសខ្នងក្នុងវេលាងូតទឹក ១ របស់ភិក្ខុជាបកតត្ត ។បេ។

(២៦៣) អង្គ៥ដទៃទៀត ។បេ។ គឺភិក្ខុចោទភិក្ខុជាបកតត្តដោយសីលវិបត្តិ១ ចោទដោយអាចារវិបត្តិ១ ចោទដោយទិដ្ឋិវិបត្តិ១ ចោទដោយអាជីវវិបត្តិ១ បំបែកពួកភិក្ខុ (ឲ្យបែកបាក) ពួកភិក្ខុផងគ្នា១ ។បេ។

(២៦៤) អង្គ៥ដទៃទៀត ។បេ។ គឺភិក្ខុទ្រទ្រង់ទង់ជ័យរបស់គ្រហស្ថ១ ទ្រទ្រង់ទង់ជ័យរបស់តិរ្ថិយ១ សេពគប់ពួកតិរ្ថិយ១ មិនសេពគប់ពួកភិក្ខុ១ មិនសិក្សាសិក្ខារបស់ភិក្ខុ១ ។បេ។

(២៦៥) អង្គ៥ដទៃទៀត ។បេ។ គឺភិក្ខុនៅក្នុងអាវាសដែលមានដំបូលមួយ ១ នៅក្នុងទីមិនមែនជាអាវាសដែលមានដំបូលមួយ១ នៅក្នុងអាវាសឬទីមិនមែនអាវាសដែលមានដំបូលមួយ ជាមួយនឹងភិក្ខុជាបកតត្ត១ ឃើញភិក្ខុជាបកតត្តហើយ មិនក្រោកចាកអាសនៈ១ រុករានភិក្ខុជាបកតត្ត

អាសាទេតិ អញ្ញោ វា ពាហិ វា ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

(២៦៦) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ន បដិប្បស្សម្ភេតព្វំ បកតត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ បវារណំ ឋបេតិ សវចនីយំ ករោតិ អនុវាទំ បដ្ឋបេតិ ឱកាសំ ការេតិ ចោទេតិ សារេតិ ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេប-នីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មេ នប្បដិប្បស្សម្ភេតព្វតេចត្តាឡីសកំ និដ្ឋិតំ ។

(២៦៧) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតព្វំ ន ឧបសម្បាទេតិ ន និស្សយំ ទេតិ ន សាមណេរំ ឧបដ្ឋាបេតិ ន ភិក្ខុនោវាទកសម្មុតឹ

ខាងក្នុងឬខាងក្រៅ(វិហារ)១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ ។

(៦៦៦) ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៨ គឺភិក្ខុឃាត់ឧបោសថដល់ភិក្ខុជាបកតត្តៈ១ ឃាត់បវារណា១ ជាអ្នកមានមាត់ពាក្យ(ក្នុងអធិករណ៍នោះ)១ ទទួលនាទីជាធំក្នុងវត្ត១ ឲ្យធ្វើឱកាស (ដើម្បីចោទ)១ ចោទគេ១ រំលឹកគេ១ ប្រកបពួកភិក្ខុ(ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៨នេះទេ ។

ចប់វត្ត ៤៣ ដែលសង្ឃមិនត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ។

(៦៦៧) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ គឺភិក្ខុមិនឲ្យឧបសម្បទា១ មិនឲ្យនិស្ស័យ១ មិនឲ្យសាមណេរបម្រើខ្លួន១ មិនទទួល

សាធិយតិ សម្មតោបិ ភិក្ខុនិយោ ន ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

(២៦៨) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគ-តស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ កតំ ហោតិ តំ អាបត្តឹ អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ ន គរហតិ កម្មិកេ ន គរហតិ ។ បេ ។

(២៦៩) អបរេហិបិ ។ បេ ។ ន បកតត្តស្ស ភិក្ខុនោ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អាស-នាភិហារំ សាទិយតិ ។ បេ ។

(២៧០) អបរេហិបិ ។ បេ ។ ន បកតត្តស្ស ភិក្ខុនោ សេយ្យាភិហារំ បាទោទកំ បាទបីឋំ បាទកឋលិកំ បត្ត-ចីវរប្បដិគ្គហណំ នហានេ បិដ្ឋិបរិកម្មំ សាទិយតិ ។ បេ ។

ការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ បើទុកជាសង្ឃសន្មតហើយ ក៏មិនប្រដៅពួកភិក្ខុនី ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

(២៦៨) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ បំពោះអាបត្តិណា មិនត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃដែលប្រហែលនឹងអាបត្តិនោះ ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ ១ មិនតិះដៀលកម្ម ១ មិនតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម ១ ។ បេ ។

(២៦៩) អង្គ ៥ ដទៃទៀត ។ បេ ។ គឺភិក្ខុមិនត្រេកអរនឹងអភិវាទនកម្ម ១ បច្ចុដ្ឋានកម្ម ១ អញ្ជលិកម្ម ១ សាមីចិកម្ម ១ ការនាំអាសនមកឲ្យ ១ របស់ភិក្ខុជាបកតត្ត ។ បេ ។

(២៧០) អង្គ ៥ ដទៃទៀត ។ បេ ។ គឺភិក្ខុមិនត្រេកអរនឹងការនាំទីដេកមកឲ្យ ១ ទឹកសម្រាប់លាងជើង ១ តាំងទ្រជើង នឹងរត្រុសម្រាប់ជូតជើង ១ ការទទួលបាត្រនឹងចីវរ ១ ការដុសខ្នងក្នុងវេលាស្រង់ទឹក ១ របស់ភិក្ខុជាបកតត្ត ។ បេ ។

(២៧១) អបរេហិបិ ។ បេ ។ ន បកតត្តំ ភិក្ខុំ សីលវិបត្តិយា អនុទ្ធំសេតិ ន អាចារវិបត្តិយា អនុទ្ធំសេតិ ន ទិដ្ឋិវិបត្តិយា អនុទ្ធំសេតិ ន អាជីវវិបត្តិយា អនុទ្ធំសេតិ ន ភិក្ខូ ភិក្ខូហិ ភេទេតិ ។ បេ ។

(២៧២) អបរេហិបិ ។ បេ ។ ន គិហិទ្ធជំ ធារេតិ ន តិត្ថិយទ្ធជំ ធារេតិ ន តិត្ថិយេ សេវតិ ភិក្ខូ សេវតិ ភិក្ខុសិក្ខាយ សិក្ខតិ ។ បេ ។

(២៧៣) អបរេហិបិ ។ បេ ។ ន បកតត្តេន ភិក្ខុនា សទ្ធិំ ឯកច្ឆន្នេ អាវាសេ វសតិ ន ឯកច្ឆន្នេ អនាវាសេ វសតិ ន ឯកច្ឆន្នេ អាវាសេ វា អនាវាសេ វា វសតិ បកតត្តំ ភិក្ខុំ ទិស្វា អាសនា វុដ្ឋាតិ ន បកតត្តំ ភិក្ខុំ អាសាទេតិ អន្តោ វា ពហិ វា ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

(២៧៤) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ

(២៧១) អង្គ ៥ ដទៃទៀត ។ បេ ។ គឺភិក្ខុមិនចោទភិក្ខុជាបកតត្ត ដោយសីលវិបត្តិ ១ មិនចោទដោយអាចារវិបត្តិ ១ មិនចោទដោយទិដ្ឋិវិបត្តិ ១ មិនចោទដោយអាជីវវិបត្តិ ១ មិនបំបែកពួកភិក្ខុ (ឲ្យបែក) ចាកពួកភិក្ខុផងគ្នា ១ ។ បេ ។

(២៧២) អង្គ ៥ ដទៃទៀត ។ បេ ។ គឺភិក្ខុមិនទ្រទ្រង់ទង់ជ័យរបស់គ្រហស្ថ ១ មិនទ្រទ្រង់ទង់ជ័យរបស់តិរ្ថិយ ១ មិនសេពគប់ពួកតិរ្ថិយ ១ សេពគប់តែពួកភិក្ខុ ១ សិក្សាសិក្ខារបស់ភិក្ខុ ១ ។ បេ ។

(២៧៣) អង្គ ៥ ដទៃទៀត ។ បេ ។ គឺភិក្ខុមិននៅក្នុងអាវាសដែលមានដំបូលមួយ ១ មិននៅក្នុងទីមិនមែនជាអាវាសដែលមានដំបូលមួយ ១ មិននៅក្នុងទីជាអាវាសឬមិនមែនជាអាវាសដែលមានដំបូលមួយ ១ ជាមួយនឹងភិក្ខុជាបកតត្ត ឃើញភិក្ខុជាបកតត្តហើយ ក្រោកចាកអាសនៈ ១ មិនរុករានភិក្ខុជាបកតត្តខាងក្នុងឬខាងក្រៅ (វិហារ) ១ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

(២៧៤) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុមិនឃាត់

បដិប្បស្សម្ភេតព្វំ ន បកតត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ ន បវារណំ ឋបេតិ ន សវចនីយំ ករោតិ ន អនុវាទំ បដ្ឋបេតិ ន ឱកាសំ ការេតិ ន ចោទេតិ ន សារេតិ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋារសហិ សមន្នាគតស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មេ បដិប្បស្សម្ភេតព្វតេចត្តាឡីសកំ និដ្ឋិតំ ។

(២៧៨) ឯវញ្ច បន ភិក្ខវេ បដិប្បស្សម្ភេតព្វំ ។ តេន ភិក្ខវេ ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ សង្ឃេន អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មកតោ សម្មា វត្តាមិ លោមំ បាតេមិ នេត្ថារំ វត្តាមិ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា ។

ឧបោសថដល់ភិក្ខុជាបកតត្ត ១ មិនឃាត់បវារណាដល់ភិក្ខុជាបកតត្ត ១ មិនធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ) ១ មិនទទួលនាទីជាធំក្នុងវត្ត ១ មិនឲ្យធ្វើឱកាស (ដើម្បីចោទ) ១ មិនចោទ ១ មិនរំលឹក ១ មិនប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ ៨ នេះឯង ។

ចប់វគ្គ ៤៣ ដែលសង្ឃត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ។

(២៧៩) ម្នាលភិក្ខុទាំងឡាយ ឯឧក្ខេបនីយកម្មនោះសង្ឃត្រូវរម្ងាប់យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ឆន្នភិក្ខុនោះត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើងនិយាយយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ។ ឆន្នភិក្ខុគប្បីសូមជាគំរប់ពីរដងផង ។

តតិយម្បិ យាចិតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឆន្នោ ភិក្ខុ សង្ឃេន អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឆន្នោ ភិក្ខុ សង្ឃេន អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ សង្ឃោ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតិ ។ យស្សាយស្មតោ ខមតិ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។បេ។ តតិយម្បិ

គប្បីសូមជាគំរប់បីដងផង ។ ភិក្ខុដែលឈ្លាសប្រតិពលត្រូវប្រកាសឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ឆន្នភិក្ខុនេះសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយាលោស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ឆន្នភិក្ខុនេះសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយាលោស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ។ សង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ ។ ការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីនិយាយឡើង ។ ខ្ញុំប្រកាសសេចក្ដីនេះជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំប្រកាស

ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឆន្នោ ភិក្ខុ សង្ឃេន អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ សង្ឃោ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតិ ។ យស្សាយស្មតោ ខមតិ ឆន្នស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ បដិប្បស្សទ្ធំ សង្ឃេន ឆន្នស្ស ភិក្ខុនោ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ឆដ្ឋំ និដ្ឋិតំ ។

[២៧៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន

សេចក្តីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងស្ងប់រោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ។ សង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ ។ ការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញដល់ឆន្ន-ភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីនិយាយឡើង ។ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ សង្ឃបានរម្ងាប់ដល់ឆន្នភិក្ខុហើយ ការរម្ងាប់ឧក្ខេបនីយកម្មនោះ គួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ចប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាគំរប់ ៦ ។

[២៣៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុ

ខោ បន សមយេន អរិដ្ឋស្ស នាម ភិក្ខុនោ គទ្ធពាធិបុព្វស្ស[1] ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ អស្សោសុំ ខោ សម្ពហុលា ភិក្ខូ អរិដ្ឋស្ស កិរ នាម ភិក្ខុនោ គទ្ធពាធិបុព្វស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ អថ ខោ តេ ភិក្ខូ យេន អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ[2] តេនុបសង្កមឹសុ ឧបសង្កមិត្វា អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ឯតទវោចុំ សច្ចំ កិរ តេ អាវុសោ អរិដ្ឋ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។

---

១ ឱរោបិយពោត្ថកេ គទ្ធពាធិបុព្វស្សាតិ បាឋោ ភវតិ ។ ២ ឱ. ពោត្ថកេ គទ្ធពាធិបុព្វោតិ បាឋោ ។

ឈ្មោះអរិដ្ឋជាកូននៃត្រកូលអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើងថា យើងដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណាដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា តែងធ្វើសេចក្តីអន្តរាយបានយ៉ាងណា ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ។ ភិក្ខុទាំងឡាយជាច្រើនរូបបានឮដំណឹងថា ភិក្ខុឈ្មោះអរិដ្ឋ ជាកូននៃត្រកូលអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើងដូច្នេះថា យើងដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណាដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា តែងធ្វើសេចក្តីអន្តរាយបានយ៉ាងណា ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ ។ គ្រានោះឯង ភិក្ខុទាំងនោះចូលទៅរកអរិដ្ឋភិក្ខុដែលជាកូននៃត្រកូលអ្នកសម្លាប់ត្មាត លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងអរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាតថា ម្នាលអាវុសោអរិដ្ឋ ឮថាអ្នកឯងមានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើងដូច្នេះថា យើងដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណាដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា តែងធ្វើសេចក្តីអន្តរាយបានយ៉ាងណា ធម៌ទាំងនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ពិតមែនឬ ។ អរិដ្ឋភិក្ខុ

ឯវំ ព្យា ខោ[១] អហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ មា អាវុសោ អរិដ្ឋ ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ អរិដ្ឋ អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ បដិសេវតោ អន្តរាយាយ អប្បស្សាទា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបា-យាសា អាទីនវោ ឯត្ថ ភិយ្យោ អដ្ឋិកង្កលុបមា[២] កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ មំសបេសុបមា កាមា វុត្តា ភគវតា ។ បេ ។ តិណុក្កុបមា កាមា វុត្តា ភគវតា ។ បេ ។ អង្គារកាសុបមា កាមា វុត្តា ភគវតា ។ បេ ។

---

១ ឯវញ្ច ខោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ អដ្ឋិកង្កលូបមាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ឆ្លើយថា ម្នាលអាវុសោ យើងដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងថា ធម៌ទាំងឡាយឯណាដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ ដូច្នោះមែន ៗ ភិក្ខុទាំងឡាយនោះនិយាយថា ម្នាលអាវុសោអរិដ្ឋ លោកកុំពោលយ៉ាងនេះ លោកកុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រោះថាព្រះដ៏មានព្រះភាគមិនមែនទ្រង់ត្រាស់ដូច្នេះទេ ម្នាលអាវុសោអរិដ្ឋ ធម៌ទាំងឡាយដែលធ្វើសេចក្តីអន្តរាយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយដោយអនេកបរិយាយ ឯធម៌ទាំងឡាយនោះអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពមែន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយមានសេចក្តីត្រេករាយតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានច្រើន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយមានឧបមាដោយរាងឆ្អឹង មានសេចក្តីទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានច្រើន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើងស្មៅ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយមានឧបមាដោយរណ្តៅរងើកភ្លើង ។បេ។

កម្មក្ខន្ធកេ អរិដ្ឋភិក្ខុវត្ថុ កាមាទីនវកថា

សុបិនកុបមា កាមា វុត្តា ភគវតា ។ បេ ។ យាចិ-
តកុបមា កាមា វុត្តា ភគវតា ។ បេ ។ រុក្ខផ-
លុបមា កាមា វុត្តា ភគវតា ។ បេ ។ អសិសូនុបមា
កាមា វុត្តា ភគវតា ។ បេ ។ សត្តិសូលុបមា កាមា
វុត្តា ភគវតា ។ បេ ។ សប្បសិរុបមា កាមា វុត្តា ភគ-
វតា ពហុទុក្ខា ពហូទាយាសា អាទីនវោ ឯត្ថ ភិយ្យោ-
តិ ។ ឯវំបិ ខោ អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ តេហិ
ភិក្ខូហិ វុច្ចមានោ តថេវ តំ ទាបកំ ទិដ្ឋិគតំ ថាមសា
បរាមស្ស អភិនិវិស្ស វោហរតិ ឯវំ ព្យា ខោ អហំ អា-
វុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ
អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ
នាលំ អន្តរាយាយាតិ ។ យតោ ច ខោ តេ ភិក្ខូ
នាសក្ខឹសុ អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ឯតស្មា
ទាបកា ទិដ្ឋិគតា វិវេចេតុំ ។ អថខោ តេ ភិក្ខូ

## កម្មក្ខន្ធក រឿងអរិដ្ឋភិក្ខុ និយាយអំពីទោសរបស់កាម

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយមានឧបមាដោយយល់សប្តិ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយមានឧបមាដោយរបស់ខ្ចីគេ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយមានឧបមានដោយកំបិតនឹងជ្រញ់ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយមានឧបមាដោយលំពែងនឹងដែកស្រួច ។ បេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ ។ បេ ។ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានច្រើន ៗ អរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាត កាលដែលពួកភិក្ខុទាំងនោះនិយាយដាស់តឿនយ៉ាងនេះហើយ ក៏នៅតែប្រកាន់ទិដ្ឋិលាមកនោះដោយមាំ ហើយនិយាយយ៉ាងនេះដដែលថា ម្នាលអាវុសោ យើងដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយបានយ៉ាងណា ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពបានទេ ដូច្នោះមែន ។ ពួកភិក្ខុនោះមិនអាចនឹងដោះអរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាត ឲ្យរួចចាកទិដ្ឋិដ៏លាមកនោះបាន ។ លំដាប់នោះ ពួកភិក្ខុ

យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតោ ឯតមត្ថំ អារោចេសុំ ។

(២៧៧) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ បដិបុច្ឆិ សច្ចំ កិរ តេ អរិដ្ឋ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ កស្ស នុ ខោ នាម ត្វំ មោឃបុរិស មយា ឯវំ ធម្មំ ទេសិតំ អាជានាសិ ននុ មយា មោឃបុរិស អនេកបរិយាយេន អន្តរាយិកា ធម្មា វុត្តា

ទាំងនោះចូលទៅក្រាបបង្គំគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

(២៧៧) ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់អរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាតក្នុងកាលនោះថា ម្នាលអរិដ្ឋ ឮថា ទិដ្ឋិលាមកមានសភាពដូច្នេះ កើតឡើងដល់អ្នកឯងថា យើងដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងថា ធម៌ទាំងឡាយឯណាដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាធ្វើសេចក្តីអន្តរាយបានយ៉ាងណា ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពបានទេ ពិតមែនឬ ។ អរិដ្ឋភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណាដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយបានយ៉ាងណា ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពបានទេ ដូច្នោះមែន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោឃបុរស អ្នកឯងដឹងច្បាស់នូវធម៌ដែលតថាគតសំដែងហើយយ៉ាងនេះ អំពីអ្នកណា ម្នាលមោឃបុរស ធម៌ទាំងឡាយដែលធ្វើសេចក្តីអន្តរាយ តថាគតសំដែងហើយដោយអនេកបរិយាយ

អលញ្ច បន តេ បដិសេវតោ អន្តរាយាយ អប្បស្សាទា កាមា វុត្តា មយា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អដ្ឋិកង្កលូបមា កាមា វុត្តា មយា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ មំសបេសូបមា កាមា វុត្តា មយា ។បេ។ តិណុក្កូបមា កាមា វុត្តា មយា ។បេ។ អង្គារកាសូបមា កាមា វុត្តា មយា ។បេ។ សុបិនកូបមា កាមា វុត្តា មយា ។បេ។ យាចិតកូបមា កាមា វុត្តា មយា ។បេ។ រុក្ខផលូបមា កាមា វុត្តា មយា ។បេ។ អសិសូនូបមា កាមា វុត្តា មយា ។បេ។ សត្តិសូលូបមា កាមា វុត្តា មយា ។បេ។ សប្បសិរូបមា កាមា វុត្តា មយា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អថ ច បន ត្វំ មោឃបុរិស អត្តនា ទុគ្គហិតេន ទិដ្ឋិ-គតេន អម្ហេ ចេវ អព្ភាចិក្ខសិ អត្តានញ្ច ខណសិ

មិនមែនទេឬ ឯធម៌ទាំងនោះអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពពិតមែន តថាគតសំដែងថា កាមទាំងឡាយមានសេចក្តីរីករាយតិច មានសេចក្តីទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានច្រើន តថាគតសំដែងថា កាមទាំងឡាយមានឧបមាដោយរាងឆ្អឹង ។បេ។ មានសេចក្តីទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានច្រើន តថាគតសំដែងថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ។បេ។ តថាគតសំដែងថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើងស្មៅ ។បេ។ តថាគតសំដែងថា កាមទាំងឡាយមានឧបមាដោយរណ្តៅរងើកភ្លើង ។បេ។ តថាគតសំដែងថា កាមទាំងឡាយមានឧបមាដោយយល់សប្តិ ។បេ។ តថាគតសំដែងថា កាមទាំងឡាយមានឧបមាដោយរបស់ខ្ចីគេ ។ បេ ។ តថាគតសំដែងថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ ។ បេ ។ តថាគតសំដែងថា កាមទាំងឡាយមានឧបមាដោយកំបិតនឹងជ្រញ់ ។ បេ ។ តថាគតសំដែងថា កាមទាំងឡាយមានឧបមាដោយលំពែងនឹងដែកស្រួច ។បេ។ តថាគតសំដែងថាកាមទាំងឡាយមានឧបមាដោយក្បាលពស់ ។បេ។ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានច្រើន ម្នាលមោឃបុរស បើដូច្នោះអ្នកឯងឈ្មោះថាពោលបង្កាច់តថាគតផង គាស់រំលើងខ្លួនឯងផង

ពហុញ្ច អបុញ្ញំ បសវសិ តំ ហិ តេ មោឃបុរិស ភវិស្សតិ ទីឃរត្តំ អហិតាយ ទុក្ខាយ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ វិគរហិត្វា ។ បេ ។ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ អរិដ្ឋស្ស ភិក្ខុនោ គទ្ធពាធិបុព្វស្ស បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករោតុ អសម្ភោគំ សង្ឃេន ។

(២៧៨) ឯវញ្ច បន ភិក្ខវេ កាតព្វំ បឋមំ អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ ចោទេតព្វោ ចោទេត្វា សារេតព្វោ សារេត្វា អាបត្តិំ អារោបេតព្វា អាបត្តឹ អារោបេត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អរិដ្ឋស្ស ភិក្ខុនោ គទ្ធពា-ធិបុព្វស្ស ឯវរូបំ បាបកំ[១] ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរា-យិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ

១ ឱ. បាបិកំ ។

សោយបាបជាច្រើនផង ដោយទិដ្ឋិដែលខ្លួនប្រកាន់ខុស ម្នាលមោឃបុរស ទិដ្ឋិដែលអ្នកប្រកាន់ខុសនោះនឹងប្រព្រឹត្តទៅដើម្បីទុក្ខ មិនមែនជាប្រយោជន៍ដល់អ្នកឯង អស់កាលដ៏វែង ម្នាលមោឃបុរស អំពើនោះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាស្រាប់ហើយឲ្យរឹតរឹងតែជ្រះថ្លាឡើងទេ ។ បេ ។ លុះទ្រង់តិះដៀលហើយ ។ បេ ។ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុ ជាកូននៃត្រកូលអ្នកសម្លាប់ត្មាត ។

(២៧៨) ម្នាលភិក្ខុទាំងឡាយ ឯឧក្ខេបនីយកម្មនោះសង្ឃត្រូវធ្វើយ៉ាងនេះ សង្ឃត្រូវចោទអរិដ្ឋភិក្ខុដែលជាកូននៃត្រកូលអ្នកសម្លាប់ត្មាតជាមុនសិន លុះចោទហើយត្រូវរំលឹក លុះរំលឹកហើយ ត្រូវលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុដែលឈ្លាសប្រតិពល ត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ទិដ្ឋិដ៏លាមកមានសភាពយ៉ាងនេះកើតឡើងដល់អរិដ្ឋភិក្ខុ ជាកូននៃត្រកូល អ្នកសម្លាប់ត្មាត ដូច្នេះថា យើងដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណាដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយបានយ៉ាងណា ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយ

អន្តរាយាយាតិ ។ សោ តំ ទិដ្ឋឹ នប្បដិនិស្សជ្ជតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ អរិដ្ឋស្ស ភិក្ខុនោ គទ្ធពាធិបុព្វស្ស បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ អសម្ភោគំ សង្ឃេន ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អរិដ្ឋស្ស ភិក្ខុនោ គទ្ធពាធិបុព្វស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ សោ តំ ទិដ្ឋឹ នប្បដិនិស្សជ្ជតិ[១] ។ សង្ឃោ អរិដ្ឋស្ស ភិក្ខុនោ គទ្ធពាធិបុព្វស្ស បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករោតិ អសម្ភោគំ សង្ឃេន ។ យស្សាយស្មតោ ខមតិ អរិដ្ឋស្ស ភិក្ខុនោ គទ្ធពាធិបុព្វស្ស បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មស្ស ករណំ អសម្ភោគំ សង្ឃេន សោ តុណ្ហស្ស យស្ស នក្ខមតិ

---

១ ម. ន បដិនិស្សជ្ជតិ ។

ដល់បុគ្គលអ្នកសេពគេ ៗ អរិដ្ឋភិក្ខុនោះមិនលះបង់ទិដ្ឋិនោះសោះ ៗ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុដែលជាកូននៃត្រកូលអ្នកសម្លាប់ត្មាត ៗ នេះជាញត្តិ ៗ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងដល់អរិដ្ឋ-ភិក្ខុ ជាកូននៃត្រកូលអ្នកសម្លាប់ត្មាតដូច្នេះថា យើងដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណាដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយបានយ៉ាងណា ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពគេ ៗ អរិដ្ឋភិក្ខុនោះក៏មិនលះបង់ទិដ្ឋិនោះសោះ ៗ សង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុជាកូននៃត្រកូលជាអ្នកសម្លាប់ត្មាត ៗ ការធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាត គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា

សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ អរិដ្ឋស្ស ភិក្ខុនោ គទ្ធពាធិបុព្វស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ សោ តំ ទិដ្ឋឹ នប្បដិនិស្សជ្ជតិ ។ សង្ឃោ អរិដ្ឋស្ស ភិក្ខុនោ គទ្ធពាធិបុព្វស្ស បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនិយកម្មំ ករោតិ អសម្ភោគំ សង្ឃេន ។ យស្សាយស្មតោ ខមតិ អរិដ្ឋស្ស ភិក្ខុនោ គទ្ធពាធិបុព្វស្ស បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនិយកម្មស្ស ករណំ អសម្ភោគំ សង្ឃេន សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ កតំ សង្ឃេន អរិដ្ឋស្ស ភិក្ខុនោ គទ្ធពាធិបុព្វស្ស បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនិយកម្មំ អសម្ភោគំ សង្ឃេន ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ

លោកដ៏មានអាយុអង្គនោះគប្បីនិយាយឡើង ៗ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដងផង ៗ បេ ៗ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង ៗ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ទិដ្ឋិដ៏លាមកមានសភាពយ៉ាងនេះ កើតឡើងដល់អរិដ្ឋភិក្ខុ ជាកូននៃត្រកូលអ្នកសម្លាប់ត្មាតដូច្នេះថា យើងដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណាដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយបានយ៉ាងណា ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ៗ អរិដ្ឋភិក្ខុនោះមិនលះបង់ទិដ្ឋិនោះចេញទេ ៗ សង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃដល់អរិដ្ឋភិក្ខុជាកូននៃត្រកូលជាអ្នកសម្លាប់ត្មាត ៗ ការធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិលាមក គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាត គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ៗ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ៗ បានធ្វើដល់អរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាតហើយ ការធ្វើឧក្ខេបនីយកម្មនោះគួរដល់សង្ឃ ហេតុនោះបានជាសង្ឃស្ងៀម ៗ ខ្ញុំចាំទុកនូវដំណើរនេះ

ធារយាមីតិ ។ អាវាសបរម្បរញ្ច ភិក្ខវេ សំសថ អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ សង្ឃេន(១) បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតោ អសម្ភោគំ សង្ឃេនាតិ ។

(២៧៩) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច អសម្មុខា កតំ ហោតិ អប្បដិបុច្ឆា កតំ ហោតិ អប្បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ អធម្មកម្មញ្ច ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

(២៨០) អបរេហិបិ ។ បេ ។ អនាបត្តិយា កតំ ហោតិ អទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ ទេសិតាយ អាបត្តិយា កតំ ហោតិ ។ បេ ។

(២៨១) អបរេហិបិ ។ បេ ។ អចោទេត្វា កតំ ហោតិ អសារេត្វា កតំ ហោតិ អាបត្តិ អនារោបេត្វា កតំ ហោតិ ។ បេ ។

---

១ ឧភោបិ យមរម្មជោត្តកេសុ ឥទំ សង្ឃេនាតិ សទ្ទោ ន ទិស្សតិ ។

ដោយអាការស្មៀមនៅយ៉ាងនេះ ៗ ម្នាលភិក្ខុទាំងឡាយ មួយ៉ាងទៀតអ្នកទាំងឡាយចូរប្រាប់គ្នាក្នុងអាវាសត ៗ ទៅថា អរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាត សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិដ៏លាមក គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃហើយ ៗ

(២៧៩) ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ គឺកម្មដែលធ្វើក្នុងទីកំបាំងមុខ ១ ធ្វើដោយមិនបានសាកសួរ ១ ធ្វើដោយមិនតាមពាក្យប្តេជ្ញា ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ៗ

(២៨០) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយគ្មានអាបត្តិ ១ ធ្វើដោយអាបត្តិមិនមែនជាទេសនាគាមិនី ១ ធ្វើដោយអាបត្តិដែលសំដែងរួចហើយ ១ ។ បេ ។

(២៨១) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលមិនចោទហើយស្រាប់តែធ្វើ ១ មិនរំលឹកហើយស្រាប់តែធ្វើ ១ មិនលើកអាបត្តិឡើងហើយស្រាប់តែធ្វើ ១ ។ បេ ។

(២៨២) អបរេហិបិ ។ បេ ។ អសម្មុខា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ។ បេ ។

(២៨៣) អបរេហិបិ ។ បេ ។ អប្បដិបុច្ឆា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ។ បេ ។

(២៨៤) អបរេហិបិ ។ បេ ។ អប្បដិញ្ញាយ កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ។ បេ ។

(២៨៥) អបរេហិបិ ។ បេ ។ អនាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ។ បេ ។

(២៨៦) អបរេហិបិ ។ បេ ។ អទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ។ បេ ។

[២៨២] អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើកន្លងទីកំបាំងមុខ ១ ធ្វើមិនត្រូវតាមធម៌ ១ ធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ ទុក្កបទនីយកម្មប្រកបដោយអង្គ ៣ នេះឯង ។ បេ ។

[២៨៣] អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយមិនបានសាកសួរ ១ ធ្វើមិនត្រូវតាមធម៌ ១ ធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ ទុក្កបទនីយកម្មប្រកបដោយអង្គ ៣ នេះឯង ។ បេ ។

[២៨៤] អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយមិនតាមពាក្យប្តេជ្ញា ១ ធ្វើមិនត្រូវតាមធម៌ ១ ធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ ទុក្កបទនីយកម្មប្រកបដោយអង្គ ៣ នេះឯង ។ បេ ។

[២៨៥] អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយគ្មានអាបត្តិ ១ ធ្វើមិនត្រូវតាមធម៌ ១ ធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ ទុក្កបទនីយកម្មប្រកបដោយអង្គនេះឯង ។ បេ ។

[២៨៦] អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយអាបត្តិមិនមែនជាទេសនាគាមិនី ១ ធ្វើមិនត្រូវតាមធម៌ ១ ធ្វើដោយពួក ១ ។ បេ ។

(២៨៧) អបរេហិបិ ។បេ។ ទេសិតាយ អាបត្តិយា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ ។បេ។

(២៨៨) អបរេហិបិ ។បេ។ អចោទេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ។បេ។

(២៨៩) អបរេហិបិ ។បេ។ អសារេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ។បេ។

(២៩០) អបរេហិបិ ។បេ។ អាបត្តឹ អនារោបេត្វា កតំ ហោតិ អធម្មេន កតំ ហោតិ វគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ អធម្មកម្មញ្ចេវ ហោតិ អវិនយកម្មញ្ច ទុវូបសន្តញ្ច ។

បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មេ អធម្មកម្មទ្វាទសកំ និដ្ឋិតំ ។

កម្មក្ខន្ធក ឧក្ខេបនីយកម្មជាកម្មដែលមិនត្រូវតាមធម៌

(២៨៧) អង្គ ៣ ដទៃទៀត ។បេ។ គឺកម្មដែលធ្វើដោយអាបត្តិដែលសំដែងរួចហើយ ១ ធ្វើមិនត្រូវតាមធម៌ ១ ធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ ៣ នេះឯង ។បេ។

(២៨៨) អង្គ ៣ ដទៃទៀត ។បេ។ គឺកម្មដែលមិនចោទហើយស្រាប់តែធ្វើ១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ ៣ នេះឯង ។បេ។

(២៨៩) អង្គ ៣ ដទៃទៀត ។បេ។ គឺកម្មដែលមិនរំលឹកហើយស្រាប់តែធ្វើ១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ ៣ នេះឯង ។បេ។

(២៩០) អង្គ ៣ ដទៃទៀត ។បេ។ គឺកម្មដែលមិនលើកអាបត្តិឡើងហើយស្រាប់តែធ្វើ ១ ធ្វើមិនត្រូវតាមធម៌ ១ ធ្វើដោយពួក ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ នេះឯង ។

ចប់អធម្មកម្ម ១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ។

(២៩១) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតំ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច សម្មុខា កតំ ហោតិ បដិបុច្ឆា កតំ ហោតិ បដិញ្ញាយ កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

(២៩២) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ធម្មកម្មញ្ចេវ ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច អាបត្តិយា កតំ ហោតិ ទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ អទេសិតាយ អាបត្តិយា កតំ ហោតិ ។ បេ ។

(២៩៣) អបរេហិបិ ។ បេ ។ ចោទេត្វា កតំ ហោតិ សារេត្វា កតំ ហោតិ អាបត្តឹ អារោបេត្វា កតំ ហោតិ ។ បេ ។

(២៩១) ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ គឺកម្មដែលធ្វើក្នុងទីចំពោះមុខ១ សួរហើយទើបធ្វើ១ ធ្វើតាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំង-ឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

(២៩២) ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មប្រកបដោយធម៌ផង ប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ ដទៃទៀត គឺកម្មដែលធ្វើដោយមានអាបត្តិ១ ធ្វើដោយអាបត្តិជាទេសនាគាមិនី១ ធ្វើដោយអាបត្តិដែលមិនទាន់សំដែង១ ។បេ។

(២៩៣) អង្គ ៣ ដទៃទៀត ។បេ។ គឺកម្មដែលចោទហើយទើបធ្វើ១ រំលឹកហើយទើបធ្វើ១ លើកអាបត្តិឡើងហើយទើបធ្វើ១ ។បេ។

(២៩៤) អបរេហិបិ ។ បេ ។ សម្មុខា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ។ បេ ។

(២៩៥) អបរេហិបិ ។ បេ ។ បដិបុច្ឆា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ ។ បេ ។

(២៩៦) អបរេហិបិ ។ បេ ។ បដិញ្ញាយ កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ ។ បេ ។

(២៩៧) អបរេហិបិ ។ បេ ។ អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ ។ បេ ។

(២៩៨) អបរេហិបិ ។ បេ ។ ទេសនាគាមិនិយា អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ។ បេ ។

## កម្មក្ខន្ធក ឧក្ខេបនីយកម្មជាកម្មដែលត្រូវតាមធម៌

(៤៩៤) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើកន្លងចំពោះមុខ ១ ធ្វើដោយធម៌ ១ ធ្វើដោយសេចក្តីព្រមព្រៀង ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្មប្រកបដោយអង្គ ៣ នេះឯង ។ បេ ។

(៤៩៥) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលបញ្ជាក់ហើយទើបធ្វើ ១ ធ្វើត្រូវតាមធម៌ ១ ធ្វើដោយសេចក្តីព្រមព្រៀង ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្មប្រកបដោយអង្គ ៣ នេះឯង ។ បេ ។

(៤៩៦) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើតាមពាក្យប្តេជ្ញា ១ ធ្វើត្រូវតាមធម៌ ១ ធ្វើដោយសេចក្តីព្រមព្រៀង ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្មប្រកបដោយអង្គ ៣ នេះឯង ។ បេ ។

(៤៩៧) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយមានអាបត្តិ ១ ធ្វើត្រូវតាមធម៌ ១ ធ្វើដោយសេចក្តីព្រមព្រៀង ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្មប្រកបដោយអង្គ ៣ នេះឯង ។ បេ ។

(៤៩៨) អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយអាបត្តិជាទេសនាគាមិនី ១ ធ្វើត្រូវតាមធម៌ ១ ធ្វើដោយសេចក្តីព្រមព្រៀង ១ ។ បេ ។

(២៩៩) អបរេហិបិ ។ បេ ។ អទេសិតាយ អាបត្តិយា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ។ បេ ។

(៣០០) អបរេហិបិ ។ បេ ។ ចោទេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ ។ បេ ។

(៣០១) អបរេហិបិ ។ បេ ។ សារេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ ។ បេ ។

(៣០២) អបរេហិបិ ។ បេ ។ អាបត្តឹ អារោបេត្វា កតំ ហោតិ ធម្មេន កតំ ហោតិ សមគ្គេន កតំ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតំ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ធម្មកម្មញ្ច ហោតិ វិនយកម្មញ្ច សុវូបសន្តញ្ច ។

បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មេ ធម្មកម្មទ្វាទសកំ និដ្ឋិតំ ។

[២៩៩] អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលធ្វើដោយអាបត្តិដែលមិនទាន់សំដែង ១ ធ្វើត្រូវតាមធម៌ ១ ធ្វើដោយសេចក្តីព្រម-ព្រៀង ១ ។ បេ ។

[៣០០] អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលចោទហើយទើបធ្វើ ១ ធ្វើត្រូវតាមធម៌ ១ ធ្វើដោយសេចក្តីព្រមព្រៀង ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្មប្រកបដោយអង្គ ៣ នេះឯង ។ បេ ។

[៣០១] អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលរំលឹកហើយទើបធ្វើ ១ ធ្វើត្រូវតាមធម៌ ១ ធ្វើដោយសេចក្តីព្រមព្រៀង ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្មប្រកបដោយអង្គ ៣ នេះឯង ។ បេ ។

[៣០២] អង្គ ៣ ដទៃទៀត ។ បេ ។ គឺកម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ ១ ធ្វើត្រូវតាមធម៌ ១ ធ្វើដោយសេចក្តីព្រមព្រៀង ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ ៣ នេះឯង ។

ចប់កម្មប្រកបដោយធម៌មានចំនួន ១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ។

(៣០៣) តីហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ ។

(៣០៤) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ អធិសីលេ សីលវិបន្នោ ហោតិ អជ្ឈាចារេ អាចារវិបន្នោ ហោតិ អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ ហោតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ ។

## កម្មក្ខន្ធក ការធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣

(៣០៣) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ គឺភិក្ខុអ្នកធ្វើការបង្កហេតុ អ្នកធ្វើការជម្លោះ អ្នកធ្វើការទាស់ទែង អ្នកធ្វើតិរច្ឆានកថា អ្នកធ្វើអធិករណក្នុងសង្ឃ ១ ជាមនុស្សល្ងង់ មិនឆ្លាស ច្រើនទៅដោយអាបត្តិ មិនមានការកំណត់អាបត្តិ ១ នៅច្រឡូកច្រឡំដោយគ្រហស្ថដោយការច្រឡូកច្រឡំមិនសមគួរ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នាក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(៣០៤) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុវិបត្តិចាកសីលក្នុងអធិសីល ១ វិបត្តិចាកអាចារក្នុងអជ្ឈាចារ ១ វិបត្តិចាកទិដ្ឋិក្នុងអតិទិដ្ឋិ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(៣០៥) អបរេហិបិ ភិក្ខវេ តីហង្គេហិ សមន្នាគ-
តស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បាបិកាយ ទិដ្ឋិ-
យា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ ពុទ្ធស្ស
អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស
អវណ្ណំ ភាសតិ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នា-
គតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បាបិកាយ
ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ ។

(៣០៦) តិណ្ណំ ភិក្ខវេ ភិក្ខូនំ អាកង្ខមានោ
សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនី-
យកម្មំ ករេយ្យ ឯកោ ភណ្ឌនការកោ ហោតិ ក-
លហការកោ វិវាទការកោ ភស្សការកោ សង្ឃេ
អធិករណការកោ ឯកោ ពាលោ ហោតិ អព្យត្តោ
អាបត្តិពហុលោ អនបទានោ ឯកោ គិហិសំសដ្ឋោ វិហ-
រតិ អននុលោមិកេហិ គិហិសំសគ្គេហិ ឥមេសំ ខោ
ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បាបិកាយ
ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ ។

(៣០៥) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ ១ ពោលតិះដៀលព្រះធម៌ ១ ពោលតិះដៀលព្រះសង្ឃ ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ នេះឯង ។

(៣០៦) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុ ៣ ពួក គឺភិក្ខុជាអ្នកធ្វើការបង្កហេតុ ជាអ្នកធ្វើការជម្លោះ ជាអ្នកធ្វើសេចក្ដីទាស់ទែង ជាអ្នកធ្វើតិរច្ឆានកថា ជាអ្នកធ្វើអធិករណ៍ក្នុងសង្ឃពួក ១ ល្ងង់ មិនឆ្លាស ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិពួក ១ នៅច្របូកច្របល់ដោយគ្រហស្ថដោយការច្របូកច្របល់មិនសមគួរពួក ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុ ៣ ពួកនេះឯង ។

(៣០៧) អបរេសម្បិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ ឯកោ អធិសីលេ សីលវិបន្នោ ហោតិ ឯកោ អជ្ឈាចារេ អាចារវិបន្នោ ហោតិ ឯកោ អតិទិដ្ឋិយា ទិដ្ឋិវិបន្នោ ហោតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ ។

(៣០៨) អបរេសម្បិ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ ឯកោ ពុទ្ធស្ស អវណ្ណំ ភាសតិ ឯកោ ធម្មស្ស អវណ្ណំ ភាសតិ ឯកោ សង្ឃស្ស អវណ្ណំ ភាសតិ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភិក្ខូនំ អាកង្ខមានោ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករេយ្យ ។

បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មេ អាកង្ខមានឆក្កំ និដ្ឋិតំ ។

## កម្មក្ខន្ធក ការធ្វើឧក្ខេបនីយកម្មដល់ភិក្ខុ ៣ ពួក

(៣០៧) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុវិបត្តិចាកសីលក្នុងអធិសីលពួក១ វិបត្តិចាកអាចារក្នុងអជ្ឈាចារពួក១ វិបត្តិចាកទិដ្ឋិក្នុងអតិទិដ្ឋិពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុទាំង ៣ ពួកនេះឯង ។

(៣០៨) ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុ ៣ ពួកដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធពួក១ ពោលតិះដៀលព្រះធម៌ពួក១ ពោលតិះដៀលព្រះសង្ឃពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុទាំង ៣ ពួកនេះឯង ។

ចប់កម្មមានចំនួន ៦ លើកដែលសង្ឃប្រាថ្នា (នឹងធ្វើក៏ធ្វើបាន) ក្នុងឧក្ខេបនីយកម្ម
ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ។

(៣០៩) បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតេន ភិក្ខវេ ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ ន ភិក្ខុនោវាទកសម្មុតិ សាទិតព្វា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វា យាយ អាបត្តិយា សង្ឃេន បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ កតំ ហោតិ សា អាបត្តិ ន អាបជ្ជិតព្វា អញ្ញា វា តាទិសិកា តតោ វា បាបិដ្ឋតរា កម្មំ ន គរហិតព្វំ កម្មិកា ន គរហិតព្វា ន បកតត្តស្ស ភិក្ខុនោ ឧបោសថោ ឋបេតព្វោ ន បវារណា ឋបេតព្វា ន សវចនីយំ កាតព្វំ ន អនុវាទោ បដ្ឋបេតព្វោ ន ឱកាសោ ការេតព្វោ ន ចោទេតព្វោ ន សារេតព្វោ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វន្តិ ។

បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មេ អដ្ឋារសវត្តំ និដ្ឋិតំ ។

(៣០៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃបានធ្វើឧក្ខេបនិយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញហើយ ត្រូវប្រព្រឹត្តវត្តដោយប្រពៃ ។ ការប្រព្រឹត្តិវត្តដោយប្រពៃ ក្នុងឧក្ខេបនីយកម្មនោះដូច្នេះ គឺមិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវឲ្យទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឃសន្មតរួចហើយ ក៏មិនត្រូវប្រដៅភិក្ខុនី សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចំពោះអាបត្តិណា កុំឲ្យត្រូវអាបត្តិនោះទៀត ឬអាបត្តិដទៃដែលប្រហែលនឹងអាបត្តិនោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុដែលធ្វើកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណាដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យក្នុងអធិករណនោះ មិនត្រូវទទួលនាទីជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទ មិនត្រូវរំលឹក មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ។

**ចប់វត្ត ១៨ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ។**

(៣១០) អថខោ សង្ឃោ អរិដ្ឋស្ស ភិក្ខុនោ គន្ធពាធិបុព្វស្ស បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ អកាសិ អសម្ភោគំ សង្ឃេន ។ សោ សង្ឃេន បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតោ វិព្ភមិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អរិដ្ឋោ ភិក្ខុ គន្ធពាធិបុព្វោ សង្ឃេន បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតោ វិព្ភមិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

(៣១១) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា[1] ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ អរិដ្ឋោ ភិក្ខុ គន្ធពាធិបុព្វោ សង្ឃេន បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតោ វិព្ភមតីតិ[2] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម សោ ភិក្ខវេ មោឃបុរិសោ សង្ឃេន បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្ម-

១ ឯត្ថន្តរេ តេតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ. វិព្ភមីតិ ។

## កម្មក្ខន្ធក អរិដ្ឋភិក្ខុដែលសង្ឃបានធ្វើឧក្ខេបនីយកម្មព្រោះមិនលះបង់ទិដ្ឋិអាក្រក់

(៣១០) គ្រានោះ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុដែលជាកូននៃត្រកូលអ្នកសម្លាប់ត្មាត ។ អរិដ្ឋភិក្ខុនោះលុះសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ហើយ ក៏សឹកចេញទៅ ។ ពួកភិក្ខុទាំងឡាយឯណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា អរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាត សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ មិនគួរនឹងសឹកសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។

(៣១១) ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់ពួកភិក្ខុក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ឮថាអរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាត សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ហើយក៏សឹកចេញទៅ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសនោះដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់

កាតោ វិក្កមិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតុ ។

(៣១២) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ឧបសម្បាទេតិ និស្សយំ ទេតិ សាមណេរំ ឧបដ្ឋាបេតិ ភិក្ខុនោវាទកសម្មតឹ សាទិយតិ សម្មតោបិ ភិក្ខុនិយោ ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

(៣១៣) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ន បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ

មិនសមគួរនឹងសឹកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើងទេ ។ បេ ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះចូរសង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិដ៏អាក្រក់ ។

(៣១២) ម្នាលភិក្ខុទាំងឡាយ សង្ឃមិនគប្បីរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុឲ្យឧបសម្បទា ១ ឲ្យនិស្ស័យ ១ ឲ្យសាមណេរបម្រើខ្លួន ១ ទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ បើទុកជាសង្ឃសន្មតរួចហើយ ក៏នៅតែប្រដៅពួកភិក្ខុនី ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គទាំង ៨ នេះទេ ។

(៣១៣) ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ ៨ ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ

ឧក្ខេបនីយកម្មំ កតំ ហោតិ តំ អាបត្តឹ អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ គរហតិ កម្មិកេ គរហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

(៣១៦) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ន បដិប្បស្សម្ភេតព្វំ បកតត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ បវារណំ ឋបេតិ សវចនីយំ ករោតិ អនុវាទំ បដ្ឋបេតិ ឱកាសំ ការេតិ ចោទេតិ សារេតិ ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ន បដិប្បស្សម្ភេតព្វំ ។

បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មេ នបដិប្បស្សម្ភេតព្វអដ្ឋារសកំ និដ្ឋិតំ ។

បំពោះអាបត្តិណា នៅតែត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃដែលប្រ-ហែលគ្នានឹងអាបត្តិនោះ ១ ឬអាបត្តិដែលធ្ងន់ជាងនោះ ១ តិះដៀលកម្ម ១ តិះដៀលពួកភិក្ខុអ្នកធ្វើកម្ម ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះទេ ។

(៣១៤) ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ដល់ភិក្ខុដែលប្រកបដោយអង្គ គឺភិក្ខុដែលហាមឧបោសថដល់ភិក្ខុជាបកតត្ត១ ហាមបវារណា១ ធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ)១ ទទួលនាទីជាធំក្នុងវត្ត១ ឲ្យធ្វើឱកាស (ដើម្បីចោទ)១ ចោទ១ រំលឹក១ ប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ដល់ភិក្ខុដែលប្រកបដោយអង្គ ៨ នេះទេ ។

ចប់អង្គមានចំនួន ១៨ ដែលសង្ឃមិនត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ហើយ ។

(៣១៥) បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតព្វំ ន ឧបសម្បាទេតិ ន និស្សយំ ទេតិ ន សាមណេរំ ឧបដ្ឋាបេតិ ន ភិក្ខុនោវាទកសម្មុតឹ សាទិយតិ សម្មតោបិ ភិក្ខុនិយោ ន ឱវទតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

(៣១៦) អបរេហិបិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតព្វំ យាយ អាបត្តិយា សង្ឃេន បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ កតំ ហោតិ តំ អាបត្តឹ ន អាបជ្ជតិ អញ្ញំ វា តាទិសិកំ តតោ វា បាបិដ្ឋតរំ កម្មំ ន គរហតិ កម្មិកេ ន គរហតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

(៣១៥) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ គឺភិក្ខុមិនឲ្យឧបសម្បទា ១ មិនឲ្យនិស្ស័យ ១ មិនឲ្យសាមណេរបម្រើខ្លួន ១ មិនទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ ទុកជាសង្ឃសន្មតហើយក៏មិនប្រដៅភិក្ខុនីទាំងឡាយ ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

(៣១៦) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចំពោះអាបត្តិណា ហើយមិនត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃដែលប្រហែលគ្នានឹងអាបត្តិនោះ ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ ១ មិនតិះដៀលកម្ម ១ មិនតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង ។

(៣១៧) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតព្វំ ន បកតត្តស្ស ភិក្ខុនោ ឧបោសថំ ឋបេតិ ន បវារណំ ឋបេតិ ន សវចនីយំ ករោតិ ន អនុវាទំ បដ្ឋបេតិ ន ឱកាសំ ការេតិ ន ចោទេតិ ន សារេតិ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតព្វំ ។

បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មេ បដិប្បស្សម្ភេតព្វអដ្ឋារសកំ និដ្ឋិតំ ។

(៣១៨) ឯវញ្ច បន ភិក្ខវេ បដិប្បស្សម្ភេតព្វំ តេន ភិក្ខវេ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ

កម្មក្ខន្ធក ការរម្ងាប់ឧក្ខេបនីយកម្ម

[៣១៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ដល់ភិក្ខុដែលប្រកបដោយអង្គ ៨ គឺភិក្ខុមិនហាមឧបោសថដល់ភិក្ខុជាបកតត្ត ១ មិនហាមបវារណា ១ មិនធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ) ១ មិនទទួលនាទីជាធំក្នុងវត្ត ១ មិនឲ្យធ្វើឱកាស (ដើម្បីចោទ) ១ មិនចោទ ១ មិនរំលឹក ១ មិនប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ដល់ភិក្ខុដែលប្រកបដោយអង្គ ៨ នេះឯង ។

ចប់អង្គមានចំនួន ១៨ ដែលសង្ឃត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ។

[៣១៨] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្មនោះសង្ឃត្រូវរម្ងាប់យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញនោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង សំពះបាទារបស់ភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង

បក្កន្តោ ឯវមស្ស វចនីយោ អហំ ភន្តេ សង្ឃេន
បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្ម-
កតោ សម្មា វត្តាមិ លោមំ បាតេមិ នេត្ថារំ វត្តាមិ
បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយ-
កម្មស្ស បដិប្បស្សទ្ធឹ យាចាមីតិ ។ ទុតិយម្បិ យាចិ-
តព្វា ។ តតិយម្បិ យាចិតព្វា ។ ព្យត្តេន ភិក្ខុនា
បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ
សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សង្ឃេន បាបិកាយ
ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតោ សម្មា
វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បាបិកាយ ទិដ្ឋិយា
អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធឹ យា-
ចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស
ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេប-
នីយកម្មំ បដិប្បស្សម្ភេយ្យ ។ ឯសា ញត្តិ ។ សុណាតុ
មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សង្ឃេន បា
បិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតោ
សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បាបិកាយ

ផ្គងអញ្ជលីឡើងនិយាយពាក្យយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់រួចហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ។ គប្បីសូបជាគំរប់ពីរដងផង ។ គប្បីសូមជាគំរប់បីដងផង ។ ភិក្ខុអ្នកឆ្លាសប្រតិពលគប្បីញាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញដល់ភិក្ខុឈ្មោះនេះចុះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់

ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។បេ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សង្ឃេន បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ

ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ។ សង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញដល់ភិក្ខុឈ្មោះនេះ ។ ការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ។ ភិក្ខុឈ្មោះនេះ សង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញហើយ បានប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្ងបរោម ប្រព្រឹត្តត្រូវគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ។ សង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញដល់ភិក្ខុឈ្មោះនេះ ។ ការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា

សោ ភាសេយ្យ ។ បដិប្បស្សទ្ធំ សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

**បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ សត្តមំ និដ្ឋិតំ ។**

**កម្មក្ខន្ធកំ និដ្ឋិតំ បឋមំ ។**

**ឥមម្ហិ ខន្ធកេ វត្ថូ សត្ត ។**

តស្សុទ្ទានំ

(៣១៩) បណ្ឌុកលោហិតកា ភិក្ខូ
សយំ ភណ្ឌនការកា
តាទិសេ ឧបសង្កម្ម
ឧស្សាហឹសុ ច ភណ្ឌនេ
អនុប្បន្នានិ ជាយន្តិ
ឧប្បន្នានិបិ វឌ្ឍរេ[១]
អប្បិច្ឆា បេសលា ភិក្ខូ

---

១ ឱ. បវឌ្ឍន្តិ ។

លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ សង្ឃបានរម្ងាប់ដល់ភិក្ខុឈ្មោះនេះហើយ ការរម្ងាប់ឧក្ខេបនីយកម្មនោះគួរដល់សង្ឃ ព្រោះហេតុនោះទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ។

ចប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញជាគំរប់ ៣ ។

ចប់កម្មក្ខន្ធក ជាបឋម ។

ក្នុងខន្ធកនេះមាន ៧ រឿង ។

ឧទ្ទាននៃកម្មក្ខន្ធកនោះគឺ

[ ៣១៩ ] រឿងបណ្ឌុកភិក្ខុនឹងលោហិតកភិក្ខុជាអ្នកធ្វើការបង្កហេតុដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុជាអ្នកធ្វើការបង្កហេតុដូចគ្នាដែរ ហើយក៏នាំគ្នាប្រឹងប្រែងក្នុងការបង្កហេតុការបង្កហេតុទាំងឡាយ ដែលមិនទាន់កើតក៏កើតឡើង ដែលកើតឡើងហើយក៏ចំរើនឡើង ពួកភិក្ខុអ្នកមានសីលជាទី

កម្មក្ខន្ធកេ ខន្ធកគាថា

ឧជ្ឈាយន្តិ បរីសតោ(១)
សទ្ធម្មដ្ឋិតិកោ ពុទ្ធោ
សយម្ភូ អគ្គបុគ្គលោ
អាណាបេសិ តជ្ជនីយំ(២)
កម្មំ សាវត្ថិយំ ជិនោ ។
អសម្មុខាប្បដិបុច្ឆា
អប្បដិញ្ញាយ កតញ្ច យំ
អនាបត្តិ អទេសនេ
ទេសិតាយ កតញ្ច យំ
អចោទេត្វា អសារេត្វា
អនារោបេត្វា(៣) ច យំ កតំ
អសម្មុខា អធម្មេន
វគ្គេនាបិ ច យំ កតំ(៤)
អប្បដិបុច្ឆា អធម្មេន
វគ្គេនាបិ ច យំ កតំ(៥)

---

១ ឱ. បរស្សកោ ។ ម. បរស្សតោ ។ ២ ឱ. តជ្ជនីយ ។ ៣ ឱ. អរោបេត្វា ។
៤ ឱ. ម. វគ្គេន ចាបិ យំ កតំ ។ ៥ ឱ. ម. បុន វគ្គេន យំ កតំ ។

ស្រឡាញ់មានសេចក្តីប្រាថ្នាតិច ក៏ពោលទោសក្នុងកណ្តាលបរិសទ្យ ព្រះពុទ្ធដ៏ប្រសើរជាព្រះសយម្ភូជាអគ្គបុគ្គល ទ្រង់ប្រាថ្នាការស្ថិតស្ថេរនៃព្រះសទ្ធម្ម ទើបទ្រង់បង្គាប់ឲ្យធ្វើតជ្ជនីយកម្មជិតក្រុងសាវត្ថី ។ តជ្ជនីយកម្មឯណាដែលសង្ឃធ្វើក្នុងទីកំបាំងមុខ ធ្វើដោយការមិនសាកសួរ ធ្វើដោយមិនតាមពាក្យប្តេជ្ញា ១ តជ្ជនីយកម្មឯណាដែលសង្ឃធ្វើដោយគ្មានអាបត្តិ ដោយអាបត្តិមិនមែនជាទេសនាគាមិនី ដោយអាបត្តិដែលសំដែងរួចហើយ ១ តជ្ជនីយកម្មឯណាដែលសង្ឃមិនចោទហើយស្រាប់តែធ្វើ មិនរំលឹកហើយស្រាប់តែធ្វើ មិនលើកអាបត្តិឡើងហើយស្រាប់តែធ្វើ ១ តជ្ជនីយកម្មឯណាដែលសង្ឃធ្វើក្នុងទីកំបាំងមុខ ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក ១ តជ្ជនីយកម្មឯណាដែលសង្ឃធ្វើដោយមិនបានសាកសួរ ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក ១ តជ្ជនីយកម្មឯណាដែលសង្ឃធ្វើ

អប្បដិញ្ញាយ អធម្មេន
វគ្គេនាបិ ច យំ កតំ[១]
អនាបត្តិយា[២] អធម្មេន
វគ្គេនាបិ ច យំ កតំ[៣]
អទេសនាគាមិនិយា
អធម្មវគ្គមេវ ច
ទេសិតាយ អធម្មេន
វគ្គេនាបិ តថេវ ច
អចោទេត្វា អធម្មេន
វគ្គេនាបិ តថេវ ច
អសារេត្វា អធម្មេន
វគ្គេនាបិ តថេវ ច
អនាកោបេត្វា[៤] អធម្មេន
វគ្គេនាបិ តថេវ ច

---

១ ឱ. ម. វគ្គេន ចាបិ យំ កតំ ។ ២ ឱ. អនាបត្តិ ។ ៣ ឱ. ម. វគ្គេន ចាបិ យំ កតំ ។ ៤ ឱ. អកោបេត្វា ។

ដោយមិនតាមពាក្យប្តេជ្ញា ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក ១
តជ្ជនីយកម្មឯណាដែលសង្ឃធ្វើដោយគ្មានអាបត្តិ ធ្វើមិនត្រូវ
តាមធម៌ ធ្វើដោយពួក ធ្វើដោយអាបត្តិមិនមែនជាទេសនា-
គាមិនី ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក ១ (តជ្ជនីយកម្ម
ទាំងនោះហាត់ជាអធម្មកម្ម ជាអវិនយកម្ម) តជ្ជនីយកម្មដែល
សង្ឃធ្វើដោយអាបត្តិដែលសំដែងហើយ ធ្វើមិនត្រូវតាមធម៌
ធ្វើដោយពួក ក៏ហាត់ជាអធម្មកម្ម ជាអវិនយកម្មដូចគ្នាដែរ
តជ្ជនីយកម្មដែលសង្ឃមិនបានចោទហើយស្រាប់តែធ្វើ ធ្វើ
មិនត្រូវតាមធម៌ ធ្វើដោយពួក ក៏ដូចគ្នាដែរ កម្មដែលសង្ឃ
មិនបានរំលឹកហើយស្រាប់តែធ្វើ ធ្វើមិនត្រូវតាមធម៌ ធ្វើដោយ
ពួក ក៏ដូចគ្នាដែរ កម្មដែលសង្ឃមិនបានលើកអាបត្តិឡើង
ហើយស្រាប់តែធ្វើ ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក ក៏ដូច

កម្មក្ខន្ធកៈ ខន្ធកគាថា

កណ្ហភរនយោនេវ
សុក្កាភរំ វិជាតិយា(១) ។
សង្ឃោ អាកង្ខមានោ វ(២)
យស្ស ត្ថុជ្ជនីយំ ការេ
ភណ្ឌនំ ពាលោ សំសគ្គោ
អធិសីលេ(៣) អជ្ឈាចារេ
អតិទិដ្ឋិយា វិបន្នស្ស
សង្ឃោ តជ្ជនីយំ ការេ ។
ពុទ្ធធម្មស្ស សង្ឃស្ស
អវណ្ណំ យោ ច ភាសតិ ។
តិណ្ណន្នម្បិ ច កិច្ចានំ
សង្ឃោ តជ្ជនីយំ ការេ
ភណ្ឌនការកោ ឋកោ
ពាលោ សំសគ្គវិស្សុតោ ។
អធិសីលេ អជ្ឈាចារេ
តថេវ អតិទិដ្ឋិយា

---

១ ឱ. ម. សុក្កាភិរម្ប ជាតិយំ ។ ២ ឱ. ម. ច ។ ៣ ឱ. អធិសីលំ ។

គ្នាដែរ បណ្ឌិតគប្បីដឹងសុក្កករ (ករនៃកម្មស គឺចំណែកខាងកម្មត្រូវ) តាមទំនងនៃកណ្ហករ (ករនៃកម្មខ្មៅ គឺចំណែកខាងកម្មខុស)។ នោះចុះ ៗ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយ-កម្មដល់ភិក្ខុដែលជាអ្នកបង្កហេតុ ល្ងង់ នៅច្រឡូកច្រឡំដោយគ្រហស្ថ សង្ឃគប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុមានសីលវិបត្តិក្នុងអធិសីល មានអាចារវិបត្តិក្នុងអជ្ឈាចារ មានទិដ្ឋិវិបត្តិក្នុងអតិ-ទិដ្ឋិ ៗ នឹងភិក្ខុដែលពោលតិះដៀលព្រះពុទ្ធព្រះធម៌ព្រះសង្ឃ សង្ឃគប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ ៣ ពួកទៀត គឺភិក្ខុអ្នកធ្វើនូវការបង្កហេតុពួក ១ ល្ងង់ពួក ១ នៅច្រឡូកច្រឡំដោយគ្រហស្ថពួក១ ៗ ភិក្ខុមានសីលវិបត្តិក្នុងអធិសីលពួក១ មានអាចារវិបត្តិក្នុងអជ្ឈាចារពួក ១ មានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិពួក ១

ពុទ្ធធម្មស្ស សង្ឃស្ស

អវណ្ណំ យោ ច ភាសតិ ។

តជ្ជនីយកម្មកតោ

ឯវំ សម្មានុវត្តនា

ឧបសម្បទា និស្សយោ

សាមណេរឧបដ្ឋនា

ភិក្ខុនោវាទកសម្មតោ

ន ការេ តជ្ជនីកតោ[១]

នាបជ្ជេ តញ្ច អាបត្តឹ

តាទិសញ្ច តតោ បរំ

កម្មញ្ច កម្មិកេ ចេវ[២]

ន គរហេ តថាវិធោ

ឧបោសថំ បវារណំ

បកតត្តស្ស ន ដ្ឋបេ[៣]

ន[៤] សវចនីយំ អនុវាទោ[៥]

---

១ ឱវាទសម្មតេនាតិ ន ករេ តជ្ជនិកតោ ។ ២ ឱ. ម. ចាបិ ។ ៣ ឱ. ន ឋបេ ។ ៤ ឱ. ម. ពោត្ថកេសុ អយំ ខណ្ឌោ ន ទិស្សតិ ។ ៥ ឱ. ម. សវចនិអនុវាទោ ។

(សង្ឃគប្បីធ្វើតជ្ជនីយកម្ម) ដូចគ្នាដែរ ទឹងភិក្ខុដែលពោលតិះដៀលព្រះពុទ្ធពួក ១ ព្រះធម៌ពួក ១ ព្រះសង្ឃពួក ១ ។ ភិក្ខុដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយត្រូវប្រព្រឹត្តវត្តដោយប្រពៃយ៉ាងនេះ គឺភិក្ខុដែលសង្ឃធ្វើតជ្ជនីយកម្មហើយ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឃសន្មតហើយ ក៏មិនត្រូវប្រដៅភិក្ខុនីឡើយ មិនឲ្យត្រូវអាបត្តិនោះទៀត ឬអាបត្តិដែលប្រហែលនឹងអាបត្តិមុននោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណាដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ មិនត្រូវទទួលនាទីជាធំក្នុងវត្ត

កម្មក្ខន្ធកេ ឧទ្ទានគាថា

ឱកាសោ ចោទនេន ច
សារណំ សម្បយោគញ្ច
ន ការេយ្យ តថាវិធោ ។
ឧបសម្បទា និស្សយោ[១]
សាមណេរឧបដ្ឋនា
ឱវាទកសម្មត្តេនាបិ
បញ្ចហង្គេហិ សម្មតិ[២] ។
យញ្ចាបជ្ជតិ អាបត្តឹ[៣]
តាទិសញ្ច តតោ បរំ
កម្មញ្ច កម្មិកេ ចាបិ
គរហន្តោ ន សម្មតិ ។
ឧបោសថំ បវារណំ
សវចនីយានុវាទោ
ឱកាសោ ចោទនញ្ចេវ
សារណា សម្បយោជនា

១ ឱ. ឧបសម្បទនិស្សយោ ។ ២ ឱ. បញ្ចអង្គោ ន សម្មតិ ។ ម. បញ្ចអង្គេន សម្មតិ ។
៣ ឱ. តំ អាបជ្ជតាបត្តឹ ០ ។

មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទ មិនត្រូវរំលឹក មិនត្រូវប្រកបពួកភិក្ខុឲ្យឈ្លោះគ្នា ៗ តជ្ជនីយកម្ម (មិន) រម្ងាប់ដោយអង្គទាំងឡាយ ៥ គឺភិក្ខុឲ្យឧបសម្បទា ឲ្យនិស្ស័យ ឲ្យសាមណេរបម្រើខ្លួន ទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឃសន្មតហើយក៏ទៅប្រដៅភិក្ខុនី ៗ តជ្ជនីយកម្មមិនរម្ងាប់ (ដោយអង្គ ៥ ដទៃទៀត) គឺភិក្ខុនៅតែត្រូវអាបត្តិនោះ ឬអាបត្តិដែលប្រហែលនឹងអាបត្តិមុននោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ តិះដៀលកម្ម តិះដៀលពួកភិក្ខុអ្នកធ្វើកម្ម ៗ ភិក្ខុឯណាប្រកបដោយអង្គ ៨ នេះ គឺហាមឧបោសថ ហាមបវារណា ធ្វើជាអ្នកមានមាត់ពាក្យ ទទួលនាទីជាធំក្នុងវត្ត ឲ្យធ្វើឱកាស (ដើម្បីចោទ) ចោទ រំលឹក

ឥមេហដ្ឋង្គេហិ យោ យុត្តោ
តជ្ជនា នូបសម្មតិ[១] ។
កណ្ហាភារនយេនេវ
សុក្កភារំ វិជានិយា[២] ។
ពាលោ អាបត្តិពហុលោ
សំសដ្ឋាបិ ច សេយ្យសោ
និយស្សកម្មំ សម្ពុទ្ធោ
អាណាបេសិ មហាមុនិ ។
កីដាគិរិស្មឹ ទ្វេ ភិក្ខូ
អស្សជិបុនព្វសុកា
អនាចារម្បិ វិវិធំ
អាចរឹសុ អសញ្ញតា
បព្វាជនីយំ សម្ពុទ្ធោ
កម្មំ សាវត្ថិយំ ជិនោ ។
មច្ឆិកាសណ្ឌេ សុធម្មោ
ចិត្តស្សាវាសិកោ អហុ

---

១ ឱ. នុបសម្មតិ ។ ២ ឱ សុក្កភារម្បិ វិជានិយា ។

ប្រកបពួកភិក្ខុឲ្យឈ្លោះគ្នា តជ្ជនីយកម្មរបស់ភិក្ខុនោះមិនរម្ងាប់ឡើយ ។ បណ្ឌិតគប្បីដឹងសុក្កវារតាមទំនងនៃកណ្ហវារចុះ ។ រឿងសេយ្យសកភិក្ខុ ជាភិក្ខុល្ងង់ មានអាបត្តិច្រើន នៅច្រឡូកច្រឡំដោយគ្រហស្ថ ទើបព្រះសម្ពុទ្ធមហាមុនីទ្រង់បង្គាប់ឲ្យធ្វើនិយស្សកម្ម ។ រឿងភិក្ខុពីររូបឈ្មោះអស្សជិនិងបុនព្វសុក នៅក្នុងកិដាគិរីជនបទ ជាអ្នកមិនសង្រួម ប្រព្រឹត្តអនាចារផ្សេងៗ ទើបព្រះសម្ពុទ្ធជិនស្រី (ទ្រង់បង្គាប់ឲ្យធ្វើ) បព្វាជនីយកម្មជិតក្រុងសាវត្ថី ។ រឿងសុធម្មភិក្ខុនៅក្នុងអាវាស

### កម្មក្ខន្ធកេ ឧទ្ទានគាថា

ជាតិវាទេន ខុំសេតិ
សុធម្មោ ចិត្តុបាសកំ
បដិសារណីយំ កម្មំ
អាណាបេសិ តថាគតោ ។
កោសម្ពិយំ ឆន្នំ ភិក្ខុំ
និច្ឆន្តាបត្តិ បស្សិតុំ ។
អទស្សនេ ឧក្ខិបិតុំ
អាណាបេសិ ជិនុត្តមោ ។
ឆន្នោ តំយេវ អាបត្តឹ
បដិកាតុំ ន ឥច្ឆតិ
ឧក្ខេបនាប្បដិកម្មេ
អាណាបេសិ វិនាយកោ ។
បាបទិដ្ឋិ អរិដ្ឋស្ស
អាសិ អញ្ញាណនិស្សិតា

របស់ចិត្តគហបតិក្នុងនគរមច្ឆិកាសណ្ឌ សុធម្មភិក្ខុនោះដេរចិត្តគហបតិជាឧបាសក ដោយពាក្យតិះដៀលដល់ជាតិ ទើបព្រះតថាគតទ្រង់បង្គាប់ឲ្យធ្វើបដិសារណីយកម្ម ។ រឿងឆន្នភិក្ខុក្នុងក្រុងកោសម្ពី (ត្រូវអាបត្តិហើយ) ក៏មិនប្រាថ្នានឹងឃើញអាបត្តិ ។ ទើបព្រះជិនស្រីដ៏ឧត្តមទ្រង់បង្គាប់ឲ្យធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ។ ឆន្នភិក្ខុក៏មិនប្រាថ្នានឹងសំដែងអាបត្តិនោះឡើយ ព្រះសម្ពុទ្ធជានាយកដ៏វិសេសទ្រង់បង្គាប់ឲ្យធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ។ រឿងអរិដ្ឋភិក្ខុមានទិដ្ឋិដ៏លាមក ព្រោះអាស្រ័យសេចក្ដីមិនដឹង

ទិដ្ឋិអប្បដិនិស្សគ្គេ
ឧក្ខេបំ ជិនភាសិតំ ។
និយស្សកម្មំ បព្វជ្ជំ[១]
តថេវ បដិសារណី ។
អទស្សនាប្បដិកម្មេ
អនិស្សគ្គេ ច ទិដ្ឋិយា
ឧភណាចារុបយាតី
មិច្ឆាអាជីវមេវ ច
បព្វាជនីយកម្មម្ហិ
អតិរេកបទា ឥមេ ។
អលាភាវណ្ណា ទ្វេ បញ្ច
ទ្វេ បញ្ចកាតិនាមកា[២]
បដិសារណីយកម្មម្ហិ[៣]
អតិរេកបទា ឥមេ ។

---

១ ឱ. បព្វាជំ ។ ២ ឱ. អលាភាវណ្ណទ្វេបញ្ច ទ្វេបញ្ចកោ តិនាមកោ ។ ៣ ឱ. បដិសារនិកម្មម្ហិ ។

ព្រះជិនស្រីទ្រង់ត្រាស់ឲ្យធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ។ ទ្រង់បង្គាប់ឲ្យធ្វើនិយស្សកម្ម បព្វាជនីយកម្ម និងបដិសារណីយកម្ម ព្រោះហេតុដូចគ្នាដែរ ។ (ឧក្ខេបនីយកម្ម) ព្រោះមិនឃើញអាបត្តិ ១ មិនសំដែងអាបត្តិ ១ មិនលះទិដ្ឋិអាក្រក់ ១ ល្បែង ១ មារយាទមិនសមគួរ ១ ការបៀតបៀន ១ មិច្ឆាអាជីវ ១ ទាំងនេះជាអតិរេកបទក្នុងបព្វាជនីយកម្ម ។ អង្គ ៩ គឺភិក្ខុព្យាយាមមិនឲ្យគ្រហស្ថបានលាភ និងពោលទោសព្រះរតនត្រ័យ (ជាដើម) មាន ២ លើក មានឈ្មោះថាទ្វេបញ្ចក ទាំងនេះជាអតិរេកបទក្នុងបដិសារណីយកម្ម ។

កម្មក្ខន្ធកេ ខន្ធកគាថា

តជ្ជនីយំ និយស្សញ្ច[១]
ទុវេ កម្មានិ សាទិសា[២] ។
បព្វជ្ជា[៣] បដិសារី ច
ទ្វជ្ជឱដារិត្តកា[៤]
តយោ ឧក្ខេបនីយកម្មា[៥]
សទិសា តេ វិភត្តិតោ
តជ្ជនីយនយេនាបិ
សេសំ កម្មំ[៦] វិជានិយាតិ ។

---

១ ឱ. និស្សយញ្ច ។ ២ ឱ. ទុវេ កម្មេសុ សទិសំ ។ ៣ ឱ. បព្វាជា ។ ៤ ឱ. ម. បដិសារិ ច នត្ថិ បទាតិរិត្តតា ។ ៥ ឱ. ម. ឧក្ខេបនា កម្មា ។ ៦ ឱ. សេសកម្មំ ។

## កម្មក្ខន្ធក ឧទ្ទានគាថា

មួយវិញទៀត កម្មទាំងឡាយពីរ គឺតជ្ជនីយកម្ម១ និយស្សកម្ម១ មានលក្ខណដូចគ្នា ។ មួយវិញទៀត កម្មទាំងឡាយពីរ គឺបព្វាជនីយកម្ម១ បដិសារណីយកម្ម១ មានអង្គ៨ខ្វះ ថយពី៨ខ្វះ មិនលើសពី៨ឡើយ ឧក្ខេបនីយកម្ម៣ នោះប្រហែលៗគ្នា ដោយការបែកកម្មដ៏សេស អ្នកប្រាជ្ញគប្បីដឹងតាមទំនងនៃតជ្ជនីយកម្ម (នោះចុះ) ។

# បារិវាសិកក្ខន្ធកំ

(៣២០) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន បារិវាសិកា ភិក្ខូ សាទិយន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អាសនាភិហារំ សេយ្យាភិហារំ បាទោទកំ បាទបីឋំ បាទកឋលិកំ បត្តចីវរប្បដិគ្គហណំ នហានេ បិដ្ឋិបរិកម្មំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម បារិវាសិកា ភិក្ខូ សាទិយិស្សន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អាសនាភិហារំ សេយ្យាភិហារំ បាទោទកំ បាទបីឋំ បាទកឋលិកំ បត្តចីវរប្បដិគ្គហណំ នហានេ បិដ្ឋិបរិកម្មន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

# បារិវាសិកក្ខន្ធក

[៣៦០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់គង់នៅក្នុងជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុអ្នកនៅបរិវាស(១) តែងទទួលត្រេកអរចំពោះអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រនឹងចីវរ ការដុសក្អែលក្នុងវេលាស្រង់ទឹក របស់ភិក្ខុជាបកតត្តទាំងឡាយ ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុអ្នកនៅបរិវាសមិនសមបើនឹងត្រេកអរចំពោះអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រនឹងចីវរ ការដុសក្អែលក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយសោះ ។ ទើបភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

---

១ បរិវាសមាន ៤ យ៉ាង គឺអប្បដិច្ឆន្នបរិវាស ១ បដិច្ឆន្នបរិវាស ១ សុទ្ធន្តបរិវាស ១ សមោធានបរិវាស ១ ។ ឯអប្បដិច្ឆន្នបរិវាសនោះបានសំដែងរួចហើយក្នុងមហាខន្ធកនៃមហាវគ្គ ចំណែកបរិវាស ៣ ទៀតនោះមានសេចក្តីពិស្តារក្នុងសមុច្ចយក្ខន្ធក ។

[៣៤៧] អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ បារិវាសិកា ភិក្ខុ សាទិយន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អាសនាភិហារំ សេយ្យាភិហារំ បាទោទកំ បាទបីឋំ បាទកឋលិកំ បត្តចីវរប្បដិគ្គហណំ នហានេ បិដ្ឋិបរិកម្មន្តិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ បារិវាសិកា ភិក្ខុ សាទិយិស្សន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អាសនាភិហារំ សេយ្យាភិហារំ បាទោទកំ បាទបីឋំ បាទកឋលិកំ បត្តចីវរប្បដិគ្គហណំ នហានេ បិដ្ឋិបរិកម្មំ ។ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សាទិតព្វំ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ

(៣២១) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកភិក្ខុអ្នកនៅបរិវាសត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រនិងចីវរ ការដុសក្អែលក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកនៅបរិវាស មិនសមបើនឹងត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រនិងចីវរ ការដុសក្អែលក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយទេ ។ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរិតតែជ្រះថ្លាឡើងទេ ។ បេ ។ លុះទ្រង់បន្ទោសរួចហើយទើបទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅបរិវាសមិនត្រូវត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម

អញ្ជលិកម្មំ សាមីចិកម្មំ អាសនាភិហារកេ សេយ្យាភិហារកេ(១) បាទោទកំ បាទបីឋំ បាទកឋលិកំ បត្តចីវរប្បដិគ្គហណំ នហានេ បិដ្ឋិបរិកម្មំ យោ សាទិយេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ បារិវាសិកានំ ភិក្ខូនំ មិថុ យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អាសនាភិហារំ សេយ្យាភិហារំ បាទោទកំ បាទបីឋំ បាទកឋលិកំ បត្តចីវរប្បដិគ្គហណំ នហានេ បិដ្ឋិបរិកម្មំ ។ អនុជានាមិ ភិក្ខវេ បារិវាសិកានំ ភិក្ខូនំ បញ្ច យថាវុឌ្ឍំ ឧបោសថំ បវារណំ វស្សិកសាដិកំ ឱណោជនំ ភត្តញ្ច(២) ។ តេនហិ ភិក្ខវេ បារិវាសិកានំ ភិក្ខូនំ វត្តំ បញ្ញាបេស្សាមិ យថា បារិវាសិកេហិ ភិក្ខូហិ វត្តិតព្វំ ។

---

១ កត្ថចិ បោត្ថកេ អាសនាភិហារំ សេយ្យាភិហារន្តិ ទិស្សតិ ។ ២ អយំ ចសទ្ទោ ឧភោបិយមរម្មបោត្ថកេសុ ន ទិស្សតិ ។

អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រនឹងចីវរ ការដុសក្អែលក្នុងវេលាងូតទឹករបស់ភិក្ខុទាំងឡាយជាបកតត្តទេ ភិក្ខុឯណាត្រេកអរ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអ្នកនៅបរិវាស(ត្រេកអរ)នឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រនឹងចីវរ ការដុសក្អែលក្នុងវេលាងូតទឹកនៃគ្នានឹងគ្នា គឺភិក្ខុដែលនៅបរិវាសដូចគ្នា តាមលំដាប់ភិក្ខុចាស់(ខ្ចី)បាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបោសថ១ បវារណា១ ការទទួលវស្សិកសាដក១ ការលះបង់ភត្ត[1]១ ការទទួលភត្ត[2]១ ទាំង៥យ៉ាង ដល់ភិក្ខុអ្នកនៅបរិវាសទាំងឡាយ តាមលំដាប់ភិក្ខុចាស់(ខ្ចី) ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្តដល់ពួកភិក្ខុអ្នកនៅបរិវាស តាមទំនងដែលភិក្ខុអ្នកនៅបរិវាសត្រូវប្រព្រឹត្ត ។

---

១ លំដាប់ភត្តមានឧទ្ទេសភត្តជាដើម ដែលសង្ឃត្រូវចែកឲ្យដល់ខ្លួនក្នុងថ្ងៃនេះ ហើយខ្លួនក៏លះបង់ភត្តនោះ គឺប្រាប់ឲ្យចែកដល់ភិក្ខុដទៃសិន ចំណែកខ្លួននឹងសូមទទួលក្នុងថ្ងៃតទៅ ។

២ ទទួលចែកភត្តដែលខ្លួនត្រូវបានតាមលំដាប់វស្សាបាន ។

## បារិវាសិកក្ខន្ធកេ បារិវាសិកស្ស សម្មាវត្តនា

(៣២២) បារិវាសិកេន ភិក្ខវេ ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ ន ភិក្ខុនោវាទកសម្មុតិ សាទិតព្វា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វា យាយ អាបត្តិយា សង្ឃេន បរិវាសោ ទិន្នោ ហោតិ សា អាបត្តិ ន អាបជ្ជិតព្វា អញ្ញា វា តាទិសិកា តតោ វា បាបិដ្ឋតរា កម្មំ ន គរហិតព្វំ កម្មិកា ន គរហិតព្វា ន បកតត្តស្ស ភិក្ខុនោ ឧបោសថោ ឋបេតព្វោ ន បវារណា ឋបេតព្វា ន សវចនីយំ កាតព្វំ

(៣៤៤) ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ (ភិក្ខុអ្នកនៅបរិវាស) ត្រូវប្រព្រឹត្តវត្តដោយប្រពៃ ។ ការប្រព្រឹត្តិវត្តដោយប្រពៃក្នុងការនៅបរិវាសនោះដូច្នេះ គឺភិក្ខុដែលនៅបរិវាសនោះមិនត្រូវឲ្យឧបសម្បទា[1] ១ មិនត្រូវឲ្យនិស្ស័យ[2] ១ មិនត្រូវឲ្យសាមណេរបម្រើខ្លួន[3] ១ មិនត្រូវទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី ១ បើទុកជាសង្ឃសន្មតហើយ ក៏មិនត្រូវប្រដៅភិក្ខុនី ១ សង្ឃឲ្យបរិវាសចំពោះអាបត្តិណា មិនឲ្យត្រូវអាបត្តិនោះទៀត ១ ឬអាបត្តិដទៃប្រហែលគ្នានឹងអាបត្តិនោះ ១ ឬត្រូវអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ ១ មិនត្រូវតិះដៀលកម្ម ១ មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម ១ មិនត្រូវហាមឧបោសថដល់ភិក្ខុជាបកតត្ត ១ មិនត្រូវហាមបវារណា ១ មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ) ១ មិនត្រូវទទួលនាទីជាធំក្នុងវត្ត ១ មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) ១

---

១ អដ្ឋកថា ថា មិនត្រូវធ្វើជាឧបជ្ឈាយ៍ឲ្យឧបសម្បទាដល់កុលបុត្ត ប៉ុន្តែបើបានដាក់វត្តហើយ នឹងឲ្យឧបសម្បទាក៏គួរ ។ មិនត្រូវធ្វើជាអាចារ្យសូត្រកម្មវាចា កាលបើគ្មានភិក្ខុដទៃ ភិក្ខុនោះបានដាក់វត្តហើយសូត្រកម្មវាចាក៏គួរ ។ ២ មិនត្រូវឲ្យនិស្ស័យដល់ភិក្ខុជាអាគន្តុក ភិក្ខុឯណាបានកាន់និស្ស័យទៅហើយត្រូវប្រាប់ភិក្ខុអស់នោះថា ខ្ញុំធ្វើវិន័យកម្ម ត្រូវលោកកាន់យកនិស្ស័យក្នុងសំណាក់ព្រះថេរឯណោះចុះ កុំមកធ្វើវត្តដល់ខ្ញុំឡើយ វេលាចូលស្រុកកុំមកតាមខ្ញុំឡើយ ។ បើបានហាមយ៉ាងនេះហើយគេនៅតែធ្វើនោះ បារិវាសិកភិក្ខុមិនត្រូវអាបត្តិទេ ។ ៣ មិនត្រូវទទួលសាមណេរឯទៀត ទុកជាសាមណេរដែលខ្លួនបំបួសហើយក៏ត្រូវហាមថា ខ្ញុំធ្វើវិន័យកម្ម កុំមកធ្វើវត្តដល់ខ្ញុំឡើយ ។ បើបានហាមយ៉ាងនេះហើយ សាមណេរអស់នោះនៅតែធ្វើ បារិវាសិកភិក្ខុនោះមិនត្រូវអាបត្តិឡើយ ។

ន អនុវាទោ បដ្ឋបេតព្វោ ន ឱកាសោ ការេតព្វោ ន ចោទេតព្វោ ន សារេតព្វោ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វំ ។

(៣២៣) ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា បកតត្តស្ស ភិក្ខុនោ បុរតោ គន្តព្វំ ន បុរតោ និសីទិតព្វំ យោ ហោតិ សង្ឃស្ស អាសនបរិយន្តោ សេយ្យាបរិយន្តោ វិហារបរិយន្តោ សោ តស្ស បទាតព្វោ[១] តេន ច សោ សាទិតព្វោ ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា បកតត្តេន ភិក្ខុនា បុរេសមណេន វា បច្ឆាសមណេន វា កុលានិ ឧបសង្កមិតព្វានិ ន អារញ្ញិកង្គំ សមាទិតព្វំ ន បិណ្ឌបាតិកង្គំ សមាទិតព្វំ ន ច តប្បច្ចយា បិណ្ឌបាតោ នីហរាបេតព្វោ មា មំ ជានឹសូតិ ។

---

១ ឱ. ទាតព្វោ ។

មិនត្រូវចោទគេ ១ មិនត្រូវរំលឹកគេ ១ មិនត្រូវបែកបពួកភិក្ខុ(ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ១ ។

(៣២៣) ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវដើរមុខ មិនត្រូវអង្គុយមុខភិក្ខុជាបកតត្ត ទីឱកាសឯណាដែលជាទីបំផុតនៃទីអង្គុយ ជាទីបំផុតនៃទីដេក (គ្រែឬតាំងដែលអាក្រក់ជាងគេ) ជាទីបំផុតនៃលំនៅ (លំនៅដែលអាក្រក់ជាងគេ) របស់សង្ឃ ។ ត្រូវប្រគល់ឲ្យឱកាសនោះដល់បារិវាសិកភិក្ខុនោះ បារិវាសិកភិក្ខុនោះត្រូវត្រេកអរចំពោះឱកាសនោះ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ(មិនត្រូវធ្វើ) ភិក្ខុជាបកតត្តឲ្យជាបុរេសមណ (សមណដើរមុខ) ឬបច្ឆាសមណ(សមណដើរក្រោយ) ចូលទៅកាន់ត្រកូលទាំងឡាយទេ មិនត្រូវសមាទានអារញ្ញិកធុតង្គ មិនត្រូវសមាទានបិណ្ឌបាតិកធុតង្គ មិនត្រូវឲ្យគេនាំចង្ហាន់បិណ្ឌបាតមក (ដើម្បីខ្លួន) ព្រោះបច្ច័យនោះដោយគិតថា ជនទាំងឡាយកុំដឹង (រឿង)អញឡើយ[១] ។

---

១ បារិវាសិកភិក្ខុគិតថា អញនឹងអង្គុយឆាន់ក្នុងវត្តនេះហើយបើនឹងកប់រាត្រីទាំងឡាយ កាលបើអញចេញទៅបិណ្ឌបាតនឹងប្រទះភិក្ខុក្នុងស្រុក កាលបើអញមិនប្រាប់នឹងដាច់រាត្រី បារិវាសិកភិក្ខុនោះមិនត្រូវឲ្យគេនាំចង្ហាន់បិណ្ឌបាតមកដើម្បីខ្លួនដោយហេតុនេះឯង ។ ទុកជាប្រើឲ្យសាមណេរចំអិនហើយឆាន់ក្នុងវត្តដោយអធ្យាស្រ័យថា កុំឲ្យអ្នកណាមួយដឹងសោះឡើយ ដូច្នេះក៏មិនបាន បារិវាសិកភិក្ខុនោះត្រូវតែចូលទៅបិណ្ឌបាតក្នុងស្រុក ។

(៣២៤) ចារិកសិកេន កិត្តាវ កិត្តុជា អាកុន្ទុ-
កេន អាពេចេតព្ អាកន្ទុកស្ស អាពេចេតព្ ឱហោ-
សថេ អាពេចេតព្ បក់រឈាយ អាពេចេតព្ សថេ
កិលាដោ ហោតិ ឱ្យតេជបំ អាពេចាបេតព្ ។

(៣២៥) ន កិត្តាវ ចារិកសិកេន កិត្តុជា
សកិត្តុកា អាកសា អកិត្តុកោ អាកសោ តន្ទុញោ
អញ្ញមញ្ញ បកតន្ទុន អញ្ញមញ្ញ អន្ទុកយា ន កិត្តាវ
ចារិកសិកេន កិត្តុជា សកិត្តុកា អាកសា អកិត្តុកោ
អជាកសោ តន្ទុញោ អញ្ញមញ្ញ បកតន្ទុន អញ្ញមញ្ញ
អន្ទុកយា ន កិត្តាវ ចារិកសិកេន កិត្តុជា សកិត្តុកា
អាកសា អកិត្តុកោ អាកសោ ក អជាកសោ ក តន្ទុញោ
អញ្ញមញ្ញ បកតន្ទុន អញ្ញមញ្ញ អន្ទុកយា ន កិត្តាវ
ចារិកសិកេន កិត្តុជា សកិត្តុកា អជាកសា អកិត្តុកោ
អាកសោ តន្ទុញោ អញ្ញមញ្ញ បកតន្ទុន អញ្ញមញ្ញ
អន្ទុកយា ន កិត្តាវ ចារិកសិកេន កិត្តុជា
សកិត្តុកា អជាកសា អកិត្តុកោ អជាកសោ តន្ទុញោ

បារិវាសិកក្ខន្ធក វត្តរបស់ភិក្ខុអ្នកនៅបរិវាស

[៣៦៤] ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុជាអាគន្តុកត្រូវប្រាប់ដល់អាគន្តុកភិក្ខុផងគ្នា ត្រូវប្រាប់ក្នុងថ្ងៃឧបោសថ ត្រូវប្រាប់ក្នុងថ្ងៃបវារណា បើមានជម្ងឺ (មិនអាចនឹងទៅបាន) ត្រូវបម្រើទៅប្រាប់ក៏បាន ។

[៣៦៥] ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាស[១]ដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អនាវាស[២]ដែលគ្មានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អនាវាស

---

១ អាវាសបានដល់ទីសេនាសនៈដែលគេធ្វើសម្រាប់នៅ ។ ២ អនាវាសបានដល់រោងសម្រាប់ទុកអម្បោស រោងសម្រាប់ទុកឧស រោងទឹក បន្ទប់នឹងក្លោងទ្វារជាដើម ។

អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អនាវាសា អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា អភិក្ខុកោ អាវាសោ គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា អភិក្ខុកោ អនាវាសោ គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ។

(៣២៦) ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អនាវាសោ គន្តព្វោ

ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ។

(៣២៦) ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ គឺអាវាសណាដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមានភិក្ខុទេ គឺអនាវាស

## បារិវាសិកក្ខន្ធកេ បារិវាសិកវត្តំ

យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុកោ អាវាសោ គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុកោ អនាវាសោ គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ គន្តព្វោ យត្ថស្សុ ភិក្ខូ

ណាដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុទេ គឺអាវាសឬអនាវាសណាដែលមានភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ គឺអាវាសណាដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមានភិក្ខុទេ គឺអនាវាសណាដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុទេ គឺអាវាសឬអនាវាសណាដែលមានភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ គឺអាវាសណាដែលមាន

នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អនាវាសោ គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ។

- (៣២៧) គន្តព្វោ ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុំ គន្តព្វោ ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អនាវាសោ យត្ថស្សុ ភិក្ខូ ស-មានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុំ គន្តព្វោ ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា សភិក្ខុកោ អាវាសោ វា អនាវាសោ វា

ភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមានភិក្ខុទេ គឺអនាវាសណាដែលមានភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវចេញចាកអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុទេ គឺអាវាសឬអនាវាសណាដែលមានភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ។

(៣២៧) ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុបាន គឺអាវាសណាដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសណាអាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមានភិក្ខុបាន គឺអនាវាសណាដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អនាវាសណាអាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុ

## បារិវាសិកក្ខន្ធកេ បារិវាសិកវត្តំ

យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ គន្តព្វោ ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុកោ អាវាសោ យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ គន្តព្វោ ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុកោ អនាវាសោ យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ គន្តព្វោ ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ គន្តព្វោ ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ គន្តព្វោ ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា

បាន គឺអាវាសឬអនាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសឬអនាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុបាន គឺអាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមានភិក្ខុបាន គឺអនាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អនាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុបាន គឺអាវាសឬអនាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អា-វាសឬអនាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុត្រូវចេញចាកអាវាសឬអនាវាសដែលមានភិក្ខុទៅកាន់អាវាសដែលមានភិក្ខុបាន គឺអាវាសណា ដែលមានភិក្ខុមានសំ-វាសស្មើគ្នា ហើយដឹងថា អាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុត្រូវចេញចាកអាវាស

អនាវាសា វា សភិក្ខុកោ អនាវាសោ យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ គន្តព្វោ ភិក្ខវេ បារិវាសិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ ។

(៣២៨) ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា បកតត្តេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អនាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អាវាសេ វា អនាវាសេ វា វត្ថព្វំ បកតត្តំ ភិក្ខុំ ទិស្វា អាសនា វុដ្ឋាតព្វំ បកតត្តោ ភិក្ខុ អាសនេន និមន្តេតព្វោ ន បកតត្តេន ភិក្ខុនា សទ្ធឹ ឯកាសនេ និសីទិតព្វំ ន នីចេ អាសនេ និសិន្នេ ឧច្ចេ អាសនេ និសីទិតព្វំ ន ឆមាយំ និសិន្នេ អាសនេ និសីទិតព្វំ ន ឯកចង្កមេ ចង្កមិតព្វំ ន នីចេ ចង្កមេ ចង្កមន្តេ ឧច្ចេ ចង្កមេ ចង្កមិតព្វំ ន ឆមាយំ ចង្កមន្តេ ចង្កមេ ចង្កមិតព្វំ ។

ឬអនាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមានភិក្ខុបាន គឺអនាវាសណាដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អនាវាសណាអាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិ-វាសិកភិក្ខុត្រូវចេញចាកអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុបាន គឺអាវាសឬអនាវាសណាដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសឬអនាវាសណាអាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ។

(៣៦៨) ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវនៅក្នុងអាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាសឬអនាវាសដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុជាបក-តត្តទេ ឃើញភិក្ខុជាបកតត្តហើយត្រូវក្រោកចាកអាសន ត្រូវនិមន្តភិក្ខុជាបកតត្តដោយអាសន (របស់ខ្លួន) មិនត្រូវអង្គុយលើអាសនមួយជាមួយនឹងភិក្ខុជាបកតត្ត កាលបើភិក្ខុជាបកតត្តអង្គុយលើអាសនទាប មិនត្រូវអង្គុយលើអាសនខ្ពស់ កាលបើភិក្ខុជាបកតត្តអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសន មិនត្រូវចង្ក្រមក្នុងទីចង្ក្រមមួយ (ជាមួយនឹងភិក្ខុជាបកតត្ត) កាលបើភិក្ខុជាបកតត្តចង្ក្រមក្នុងទីចង្ក្រមទាប មិនត្រូវចង្ក្រមក្នុងទីចង្ក្រមខ្ពស់ កាលបើភិក្ខុជាបកតត្តចង្ក្រមលើផែនដី មិនត្រូវចង្ក្រមក្នុងទីចង្ក្រមឡើយ ។

[៣២៩] ន ភិក្ខវេ បារិវាសិកេន ភិក្ខុនា បារិវាសិកេន វុឌ្ឍតរេន ភិក្ខុនា សទ្ធឹ ។ បេ ។ មូលាយ បដិកស្សនារហេន ភិក្ខុនា សទ្ធឹ ។ បេ ។ មានត្តារហេន ភិក្ខុនា សទ្ធឹ ។ បេ ។ មានត្តចារិកេន ភិក្ខុនា សទ្ធឹ ។ បេ ។ អព្ភានារហេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អនាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អាវាសេ វា អនាវាសេ វា វត្ថព្វំ ន ឯកាសនេ និសីទិតព្វំ ន នីចេ អាសនេ និសិន្នេ ឧច្ចេ អាសនេ និសីទិតព្វំ ន ឆមាយំ និសិន្នេ អាសនេ និសីទិតព្វំ ន ឯកចង្កមេ ចង្កមិតព្វំ ន នីចេ ចង្កមេ ចង្កមន្តេ ឧច្ចេ ចង្កមេ ចង្កមិតព្វំ ន ឆមាយំ ចង្កមន្តេ ចង្កមេ ចង្កមិតព្វំ ។

[៣៣០] បារិវាសិកចតុត្ថោ ចេ ភិក្ខវេ បរិវាសំ ទទេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ទទេយ្យ តព្វីសោ[១] អព្ភេយ្យ អកម្មំ តំ[២] ន ច ករណីយន្តិ ។

ចតុន្នវុតិ បារិវាសិកវត្តំ និដ្ឋិតំ ។

---

១ ឱ. ម. បោត្ថកេសុ វីសោតិ បាឋោ ភវតិ ។ ២ អយំ តំសទ្ទោ ឱ. ម. បោត្ថកេសុ ន បញ្ញាយតិ ។

## បារិវាសិកក្ខន្ធក វត្តរបស់ភិក្ខុអ្នកនៅបរិវាស

(៣២៩) ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុមិនត្រូវនៅ ។បេ។ ជាមួយនឹងបារិវាសិកភិក្ខុដែលចាស់ជាងខ្លួន ជាមួយនឹងភិក្ខុដែលគួរដល់កិរិយាទាញចូលក្នុងមូលាបត្តិ ។ បេ ។ ជាមួយនឹងភិក្ខុដែលគួរដល់មានត្ត ។បេ។ ជាមួយនឹងភិក្ខុដែលប្រព្រឹត្តមានត្ត ។ បេ ។ មិនត្រូវនៅក្នុងអាវាសដែលមានដំបូលមួយ មិនត្រូវនៅក្នុងអនាវាសដែលមានដំបូលមួយ មិនត្រូវនៅក្នុងអាវាសឬអនាវាសដែលមានដំបូលមួយ ជាមួយនឹងភិក្ខុដែលគួរដល់អព្ភាន មិនត្រូវអង្គុយលើអាសនមួយ ជាមួយនឹងអព្ភានារហភិក្ខុ ( ភិក្ខុដែលគួរដល់អព្ភាន ) កាលអព្ភានារហភិក្ខុអង្គុយលើអាសនទាប មិនត្រូវអង្គុយលើអាសនខ្ពស់ កាលអព្ភានារហភិក្ខុអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសន មិនត្រូវចង្រ្កមលើទីចង្រ្កមជាមួយគ្នា កាលអព្ភានារហភិក្ខុចង្រ្កមលើទីចង្រ្កមទាប មិនត្រូវចង្រ្កមលើទីចង្រ្កមខ្ពស់ កាលអព្ភានារហភិក្ខុចង្រ្កមលើផែនដី មិនត្រូវចង្រ្កមលើទីចង្រ្កមឡើយ ។

(៣៣០) ម្នាលភិក្ខុទាំងឡាយ បើគណសង្ឃមានបារិវាសិកភិក្ខុជាគំរប់៤ ឲ្យបរិវាស ឲ្យមូលាយបដិកស្សនា (ទាញចូលមកកាន់មូលាបត្តិ) ឲ្យមានត្ត គណសង្ឃមានបារិវាសិកភិក្ខុជាគំរប់២០ ឲ្យអព្ភានកម្មនោះមិនឡើងជាកម្មផង សង្ឃមិនត្រូវធ្វើផង ។

ចប់បារិវាសិកវត្ត ៩៤ ។

[៣៣១] អថខោ អាយស្មា ឧបាលិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបាលិ ភគវន្តំ ឯតទវោច កតិ នុ ខោ ភន្តេ បារិវាសិកស្ស ភិក្ខុនោ រត្តិច្ឆេទាតិ ។ តយោ ខោ ឧបាលិ បារិវាសិកស្ស ភិក្ខុនោ រត្តិច្ឆេទា សហវាសោ វិប្បវាសោ អនារោចនា ឥមេ ខោ ឧបាលិ តយោ បារិវាសិកស្ស ភិក្ខុនោ រត្តិច្ឆេទាតិ ។

[៣៣២] តេន ខោ បន សមយេន សាវត្ថិយំ មហាភិក្ខុសង្ឃោ សន្និបតិតោ ហោតិ ។ ន សក្កោន្តិ បារិវាសិកា ភិក្ខូ បរិវាសំ សោធេតុំ ។ តេ ភិក្ខូ[១] ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បរិវាសំ និក្ខិបិតុំ ឯវញ្ច បន ភិក្ខវេ និក្ខិបិតព្វោ ។ តេន បារិវាសិកេន ភិក្ខុនា ឯកំ ភិក្ខុំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា

---

១ ឥទំ តេ ភិក្ខូតិ បទទ្វយំ ឱ. ម. បោត្ថកេសុ ន ទិស្សតិ ។

(៣៣១) គ្រានោះ ព្រះឧបាលិដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ព្រះឧបាលិដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបថ្វាយបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ការដាច់រាត្រីរបស់បារិវាសិកភិក្ខុមានប៉ុន្មាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបាលិ ការដាច់រាត្រីរបស់បារិវាសិកភិក្ខុមាន ៣ យ៉ាង គឺការនៅរួមគ្នា[១] ១ ការមិននៅរួមគ្នា[២] ១ ការមិនប្រាប់[៣] ១ ម្នាលឧបាលិ ការដាច់រាត្រីរបស់បារិវាសិកភិក្ខុមាន ៣ យ៉ាងដូច្នេះឯង ។

(៣៣២) សម័យនោះឯង ភិក្ខុសង្ឃប្រជុំគ្នាច្រើនក្នុងក្រុងសាវត្ថី ។ ពួកបារិវាសិកភិក្ខុមិនអាចនឹងជម្រះបរិវាស ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យដាក់បរិវាស ។ ម្នាលភិក្ខុទាំងឡាយ ឯបរិវាសនោះ ភិក្ខុត្រូវដាក់យ៉ាងនេះ ។ បារិវាសិកភិក្ខុនោះត្រូវចូលទៅរកភិក្ខុមួយរូប ហើយធ្វើឧត្តរាសង្គ៍ឆៀងស្មាម្ខាងអង្គុយ

---

១ គឺនៅជាមួយនឹងភិក្ខុជាបកតត្តក្នុងលំនៅដែលមានដំបូលមួយរួមគ្នា ។ ២ គឺនៅតែឯងមិនបាននៅក្នុងអាវាសដែលមានភិក្ខុជាបកតត្ត ។ ៣ គឺមិនប្រាប់ការដែលខ្លួនប្រព្រឹត្តដល់ភិក្ខុផងគ្នា មានអាគន្តុកភិក្ខុជាដើម ។

អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ បរិវាសំ និក្ខិបាមីតិ ។ និក្ខិត្តោ ហោតិ បរិវាសោ ។ វត្តំ និក្ខិបាមីតិ ។ និក្ខិត្តោ ហោតិ បរិវាសោតិ ។

(៣៣៣) តេន ខោ បន សមយេន សាវត្ថិយា ភិក្ខូ តហំ តហំ បក្កមឹសុ ។ សក្កោន្តិ[១] បារិវាសិកា ភិក្ខូ បរិវាសំ សោធេតុំ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បរិវាសំ សមាទាតុំ[២] ។ ឯវញ្ច បន ភិក្ខវេ សមាទិតព្វោ ។ តេន បារិវាសិកេន ភិក្ខុនា ឯកំ ភិក្ខុំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ បរិវាសំ សមាទិយាមីតិ ។ សមាទិន្នោ ហោតិ បរិវាសោ ។ វត្តំ សមាទិយាមីតិ ។ សមាទិន្នោ ហោតិ បរិវាសោតិ ។

បារិវាសិកវត្តំ និដ្ឋិតំ ។

---

១ យេភុយ្យេន ន សក្កោន្តីតិ បាឋោ ទិស្សតិ ។ ឯត្ថ នសទ្ទេន បដិសេធោ អយុត្តរូបោយេវ បរិវាសសមាទានស្ស សោធេតុំ សមត្ថកាលេ ភគវតា អនុជានិយមានត្តា ។ បុរតោ វត្តមានេ មានត្តសមាទានេបិ ឯសេវ នយោ ។ ២ កត្ថចិ បោត្ថកេ សមាទិតុន្តិ ។

ប្រហោងផ្គងអញ្ជលីឡើងហើយនិយាយយ៉ាងនេះថា ខ្ញុំសូមដាក់បរិវាស ។ បរិវាសបានឈ្មោះថាភិក្ខុដាក់ហើយ ។ ថាខ្ញុំសូមដាក់វត្ត ។ បរិវាសបានឈ្មោះថាភិក្ខុដាក់ហើយដែរ ។

(៣៣៣) សម័យនោះឯង ភិក្ខុទាំងឡាយចេញពីក្រុងសាវត្ថី ហើយចៀសចេញទៅក្នុងទីនោះៗ ។ ពួកបារិវាសិកភិក្ខុ រកបនឹងជម្រះបរិវាសបាន ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសមាទានបរិវាស ។ ម្នាលភិក្ខុទាំងឡាយ ឯបរិវាសនោះភិក្ខុត្រូវសមាទានយ៉ាងនេះ ។ បារិវាសិកភិក្ខុនោះត្រូវចូលទៅរកភិក្ខុមួយរូបហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាងអង្គុយប្រហោងផ្គងអញ្ជលីឡើងហើយនិយាយយ៉ាងនេះថា ខ្ញុំសូមសមាទានបរិវាស ។ បរិវាសបានឈ្មោះថាភិក្ខុសមាទានហើយ ។ ថាខ្ញុំសូមសមាទាននូវវត្ត ។ បរិវាសបានឈ្មោះថាភិក្ខុសមាទានហើយដែរ ។

**ចប់បារិវាសិកវត្ត ។**

(៣៣៤) តេន ខោ បន សមយេន មូលាយ បដិកស្សនារហា ភិក្ខូ សាទិយន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អាសនាភិហារំ សេយ្យាភិហារំ បាទោទកំ បាទបីឋំ បាទកឋលិកំ បត្តចីវរប្បដិគ្គហណំ នហានេ បិដ្ឋិបរិកម្មំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម មូលាយ បដិកស្សនារហា ភិក្ខូ សាទិយិស្សន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អាសនាភិហារំ សេយ្យាភិហារំ បាទោទកំ បាទបីឋំ បាទកឋលិកំ បត្តចីវរប្បដិគ្គហណំ នហានេ បិដ្ឋិបរិកម្មន្តិ ។ អថ ខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

(៣៣៥) អថ ខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ មូលាយ បដិកស្សនារហា ភិក្ខូ សាទិយន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ

(៣៣៤) សម័យនោះឯង ពួកភិក្ខុដែលគួរដល់មូលាយបដិកស្សនា ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ដុសជើង ការទទួលបាត្រនិងចីវរ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹករបស់ភិក្ខុជាបកតត្តទាំងឡាយ ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏ពួកភិក្ខុដែលគួរដល់មូលាយបដិកស្សនា ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ដុសជើង ការទទួលបាត្រនិងចីវរ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹករបស់ភិក្ខុទាំងឡាយជាបកតត្តសោះ ។ ទើបភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

(៣៣៥) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកមូលាយបដិកស្សនារហភិក្ខុ (ភិក្ខុដែលគួរដល់ការិយាទាញត្រឡប់មករកអាបត្តិដើម) ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម

។ បេ ។ នហានេ បិដ្ឋិបរិកម្មន្តិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ មូលាយ បដិកស្សនារហា ភិក្ខូ សាទិយិស្សន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ មូលាយ បដិកស្សនារហេន ភិក្ខុនា សាទិតព្វំ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ យោ សាទិយេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ មូលាយ បដិកស្សនារហានំ ភិក្ខូនំ មិថុ យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ ។ អនុជានាមិ ភិក្ខវេ មូលាយ បដិកស្សនារហានំ ភិក្ខូនំ បញ្ច យថាវុឌ្ឍំ ឧបោសថំ បវារណំ វស្សិកសាដិកំ ឱណោជនំ ភត្តញ្ច ។

។បេ។ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹករបស់ពួកភិក្ខុជាបកតត្តទាំងឡាយ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមូលាយបដិកស្សនារហភិក្ខុមិនសមបើនឹងត្រេកអរនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹករបស់ពួកភិក្ខុជាបកតត្តទេ ។ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់សំដែងធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹករបស់ពួកភិក្ខុជាបកតត្តទេ ភិក្ខុណាត្រេកអរ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹកដល់ពួកមូលាយបដិកស្សនារហភិក្ខុតាមលំដាប់ចាស់ (ខ្ចី) បាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបោសថ ១ បវារណា ១ ការទទួលវស្សិកសាដក ១ ការលះបង់ភត្ត ១ ការទទួលភត្ត ១ ទាំង ៥ យ៉ាង ដល់ពួកមូលាយបដិកស្សនារហភិក្ខុ តាមលំដាប់ចាស់ (ខ្ចី) បាន ។

តេនហិ ភិក្ខវេ មូលាយ បដិកស្សនារហានំ ភិក្ខូនំ វត្តំ បញ្ញាបេស្សាមិ យថា មូលាយ បដិកស្សនារហេហិ ភិក្ខូហិ វត្តិតព្វំ ។

(៣៣៦) មូលាយ បដិកស្សនារហេន ភិក្ខវេ ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ ន ភិក្ខុនោវាទកសម្មុតិ សាទិតព្វា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វា យាយ អាបត្តិយា មូលាយ បដិកស្សនារហោ ហោតិ សា អាបត្តិ ន អាបជ្ជិតព្វា អញ្ញា វា តាទិសិកា តតោ វា បាបិដ្ឋតរា កម្មំ ន គរហិតព្វំ កម្មិកា ន គរហិតព្វា ន បកតត្តស្ស ភិក្ខុនោ ឧបោសថោ ឋបេតព្វោ ន បវារណា ឋបេតព្វា ន សវចនីយំ កាតព្វំ ន អនុវាទោ បដ្ឋបេតព្វោ ន ឱកាសោ ការេតព្វោ ន ចោទេតព្វោ ន សារេតព្វោ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វំ ។

(៣៣៧) ន ភិក្ខវេ មូលាយ បដិកស្សនារហេន ភិក្ខុនា បកតត្តស្ស ភិក្ខុនោ បុរតោ គន្តព្វំ ន បុរតោ

ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្តដល់ពួកមូលាយ-បដិកស្សនារហភិក្ខុ តាមទំនងដែលពួកមូលាយបដិកស្សនារហភិក្ខុត្រូវប្រព្រឹត្តតាម ។

(៣៣៦) ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុត្រូវប្រព្រឹត្តវត្តដោយប្រពៃ ។ ឯការប្រព្រឹត្តវត្តដោយប្រពៃក្នុងមូលាយបដិ-កស្សនានោះដូច្នេះ គឺមូលាយបដិកស្សនារហភិក្ខុមិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើ(ខ្លួន) មិនត្រូវទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឃបានសន្មតហើយក៏មិនត្រូវប្រដៅភិក្ខុនី ភិក្ខុដែលគួរដល់កិរិយាទាញមករកអាបត្តិដើមចំពោះអាបត្តិណា មិនគួរត្រូវអាបត្តិនោះទៀត ឬអាបត្តិដទៃដែលប្រហែលនឹងអាបត្តិនោះឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណាដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ(ក្នុងអធិករណ៍នោះ) មិនត្រូវទទួលនាទីជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទ មិនត្រូវរំលឹក មិនត្រូវប្រកបពួកភិក្ខុ(ឲ្យឈ្លោះ)នឹងពួកភិក្ខុផងគ្នា ។

(៣៣៧) ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវដើរមុន មិនត្រូវអង្គុយមុនភិក្ខុជាបកតត្តឡើយ ឱកាសឯណាជាទីបំផុត

និសីទិតព្វំ យោ ហោតិ សង្ឃស្ស អាសនបរិយន្តោ
សេយ្យាបរិយន្តោ វិហារបរិយន្តោ សោ តស្ស បទាតព្វោ
តេន ច សោ សាទិតព្វោ ។ ន ភិក្ខវេ មូលាយ បដិ-
កស្សនារហេន ភិក្ខុនា បកតត្តេន ភិក្ខុនា បុរេស-
មណេន វា បច្ឆាសមណេន វា កុលានិ ឧបសង្កមិ-
តព្វានិ ន អារញ្ញិកង្គំ សមាទិតព្វំ ន បិណ្ឌបាតិកង្គំ
សមាទិតព្វំ ន ច តប្បច្ចយា បិណ្ឌបាតោ នីហារា-
បេតព្វោ មា មំ ជានឹសូតិ ។

(៣៣៨) ន ភិក្ខវេ មូលាយ បដិកស្សនារហេន
ភិក្ខុនា សភិក្ខុកា អាវាសា អភិក្ខុកោ អាវាសោ
គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន
ភិក្ខវេ មូលាយ បដិកស្សនារហេន ភិក្ខុនា សភិក្ខុ-
កា អាវាសា អភិក្ខុកោ អនាវាសោ គន្តព្វោ អញ្ញត្រ
បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មូលាយ
បដិកស្សនារហេន ភិក្ខុនា សភិក្ខុកា អាវាសា
អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ
បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មូលាយ

នៃទីអគ្គិយ ជាទីបំផុតនៃទីដេក ជាទីបំផុតនៃវិហារជារបស់សង្ឃ សង្ឃត្រូវប្រគល់ឲ្យទីឧកាសនោះ ដល់មូលាយបដិកស្សនារហភិក្ខុនោះ មួយវិញទៀត ភិក្ខុនោះត្រូវត្រេកអរនឹងទីឧកាសនោះ ។ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ (មិនត្រូវធ្វើ) បកតត្តភិក្ខុឲ្យជាបុរេសមណៈ ឬបច្ឆាសមណៈចូលទៅកាន់ត្រកូលទាំងឡាយឡើយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវសមាទានអារញ្ញិកធុតង្គ មិនត្រូវសមាទានបិណ្ឌបាតិកធុតង្គ មិនត្រូវឲ្យគេនាំបង្ហាន់បិណ្ឌបាតមក (ដើម្បីខ្លួន) ព្រោះបច្ច័យនោះដោយគិតថា ជនទាំងឡាយកុំដឹង (រឿង) អញឡើយ ។

(៣៣៨) ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ

បដិកស្សនារហេន ភិក្ខុនា សភិក្ខុកា អនាវាសា
អភិក្ខុកោ អាវាសោ គន្តព្វោ អញ្ញត្រ បកតត្តេន
អញ្ញត្រ អន្តរាយា ន ភិក្ខវេ មូលាយ បដិកស្សនារ-
ហេន ភិក្ខុនា សភិក្ខុកា អនាវាសា អភិក្ខុកោ
អនាវាសោ គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ
អន្តរាយា ន ភិក្ខវេ មូលាយ បដិកស្សនារហេន
ភិក្ខុនា សភិក្ខុកា អនាវាសា អភិក្ខុកោ អាវាសោ
វា អនាវាសោ វា គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ
អន្តរាយា ន ភិក្ខវេ មូលាយ បដិកស្សនារហេន
ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា អភិក្ខុ-
កោ អាវាសោ គន្តព្វោ ។ បេ ។ អភិក្ខុកោ អនាវាសោ
គន្តព្វោ ។ បេ ។ អភិក្ខុកោ អាវាសោ វា អនាវាសោ
វា គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ។

(៣៣៩) ន ភិក្ខវេ មូលាយ បដិកស្សនារហេន
ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ
គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ

ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវចេញចាកអាវាស ឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ ។ បេ ។ ទៅកាន់អនាវាសដែលមិនមានភិក្ខុទេ ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ។

[៣៣៩] ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ គឺអាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមាន

បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មូលាយ បដិកស្សនារហេន ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មូលាយ បដិកស្សនារហេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មូលាយ បដិកស្សនារហេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ។

ភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយ-បដិកស្សនារហភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អនា-វាសដែលមានភិក្ខុទេ ។ បេ ។ មិនត្រូវទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុទេ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ ។ បេ ។ មិនត្រូវទៅកាន់អនា-វាសដែលមានភិក្ខុទេ ។ បេ ។ មិនត្រូវទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុទេ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំង-ឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ ។ បេ ។ មិនត្រូវទៅកាន់អនាវាសដែលមានភិក្ខុទេ ។ បេ ។ មិនត្រូវទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុទេ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ។

(៣៤០) គន្តព្វោ ភិក្ខវេ មូលាយ បដិកស្សនារហេន ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ ។បេ។ សភិក្ខុកោ អនាវាសោ ។បេ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ គន្តព្វោ ភិក្ខវេ មូលាយ បដិកស្សនារហេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុកោ អាវាសោ ។បេ។ សភិក្ខុកោ អនាវាសោ ។បេ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ គន្តព្វោ ភិក្ខវេ មូលាយ បដិកស្សនារហេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ ។បេ។ សភិក្ខុកោ អនាវាសោ ។បេ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ ។

[៣៤០] ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនាភិក្ខុ គួរចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុបាន ។ បេ ។ ទៅកាន់អនាវាសដែលមានភិក្ខុបាន ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុបាន គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនាភិក្ខុ គួរចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុបាន ។ បេ ។ ទៅកាន់អនាវាសដែលមានភិក្ខុបាន ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនាភិក្ខុ គួរចេញចាកអាវាស ឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុបាន ។ បេ ។ ទៅកាន់អនាវាសដែលមានភិក្ខុបាន ។ បេ ។ ទៅកាន់អាវាស ឬអនាវាសដែលមានភិក្ខុ គឺអាវាស ឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ក្នុងថ្ងៃនេះបាន ។

(៣៤១) ន ភិក្ខវេ មូលាយ បដិកស្សនារហេន ភិក្ខុនា បកតត្តេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អនាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អាវាសេ វា អនាវាសេ វា វត្ថព្វំ បកតត្តំ ភិក្ខុំ ទិស្វា អាសនា វុដ្ឋាតព្វំ បកតត្តោ ភិក្ខុ អាសនេន និមន្តេតព្វោ ន បកតត្តេន ភិក្ខុនា សទ្ធឹ ឯកាសនេ និសីទិតព្វំ ន នីចេ អាសនេ និសិន្នេ ឧច្ចេ អាសនេ និសីទិតព្វំ ន ឆមាយំ និសិន្នេ អាសនេ និសីទិតព្វំ ន ឯកចង្កមេ ចង្កមិតព្វំ ន នីចេ ចង្កមេ ចង្កមន្តេ ឧច្ចេ ចង្កមេ ចង្កមិតព្វំ ន ឆមាយំ ចង្កមន្តេ ចង្កមេ ចង្កមិតព្វំ ។

(៣៤២) ន ភិក្ខវេ មូលាយ បដិកស្សនារហេន ភិក្ខុនា បារិវាសិកេន ភិក្ខុនា សទ្ធឹ ។បេ។ មូលាយ បដិកស្សនារហេន វុឌ្ឍតរេន ភិក្ខុនា សទ្ធឹ ។បេ។ មានត្តារហេន ភិក្ខុនា សទ្ធឹ ។បេ។ មានត្តចារិកេន ភិក្ខុនា សទ្ធឹ ។បេ។ អព្ភានារហេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អនាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អាវាសេ វា អនាវាសេ វា វត្ថព្វំ

## បារិវាសិកក្ខន្ធក វត្តរបស់មូលាយបដិកស្សនារហភិក្ខុ

(៣៤១) ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុមិនត្រូវនៅក្នុងអាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាសឬអនាវាសដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុជាបកតត្ត ឃើញភិក្ខុជាបកតត្ត (ដើរមក) ត្រូវក្រោកឡើងចាកអាសន ត្រូវនិមន្តភិក្ខុជាបកតត្តដោយអាសន មិនត្រូវអង្គុយលើអាសនមួយ ជាមួយនឹងភិក្ខុជាបកតត្ត កាលបើភិក្ខុជាបកតត្តអង្គុយលើអាសនទាប មិនត្រូវអង្គុយលើអាសនខ្ពស់ទេ កាលបើភិក្ខុជាបកតត្តអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនទេ មិនត្រូវចង្ក្រមលើទីចង្ក្រមជាមួយគ្នា កាលបើភិក្ខុជាបកតត្តចង្ក្រមលើទីចង្ក្រមទាប មិនត្រូវចង្ក្រមលើទីចង្ក្រមខ្ពស់ កាលបើភិក្ខុជាបកតត្តចង្ក្រមលើផែនដី មិនត្រូវចង្ក្រមលើទីចង្ក្រមទេ ។

(៣៤២) ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវនៅជាមួយនឹងបារិវាសិកភិក្ខុទេ ។ បេ ។ មិនត្រូវនៅជាមួយនឹងមូលាយបដិកស្សនារហភិក្ខុដែលចាស់ជាងខ្លួនទេ ។ បេ ។ មិនត្រូវនៅជាមួយនឹងមានត្តារហភិក្ខុ (ភិក្ខុគួរដល់មានត្ត) ទេ ។ បេ ។ មិនត្រូវនៅជាមួយនឹងមានត្តចារិកភិក្ខុ (ភិក្ខុដែលប្រព្រឹត្តមានត្ត) ទេ ។ បេ ។ មិនត្រូវនៅក្នុងអាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬអនាវាសដែលមានដម្បូលមួយ

ន ឯកាសនេ និសីទិតព្វំ ន នីចេ អាសនេ និសិន្នេ ឧច្ចេ អាសនេ និសីទិតព្វំ ន ឆមាយំ និសិន្នេ អាសនេ និសីទិតព្វំ ន ឯកចង្កមេ ចង្កមិតព្វំ ន នីចេ ចង្កមេ ចង្កមន្តេ ឧច្ចេ ចង្កមេ ចង្កមិតព្វំ ន ឆមាយំ ចង្កមន្តេ ចង្កមេ ចង្កមិតព្វំ ។

(៣៤៣) មូលាយ បដិកស្សនារហចតុត្ថោ ចេ ភិក្ខវេ បរិវាសំ ទទេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ទទេយ្យ តព្វីសោ អព្ភេយ្យ អកម្មំ តំ ន ច ករណីយន្តិ ។

មូលាយ បដិកស្សនារហវត្តំ និដ្ឋិតំ ។

(៣៤៤) តេន ខោ បន សមយេន មានត្តារហា ភិក្ខូ សាទិយន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម មានត្តារហា ភិក្ខូ សាទិយិស្សន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិ-

ជាមួយគ្នានឹងអព្ភានារហភិក្ខុ (ភិក្ខុដែលគួរដល់អព្ភាន) មិនត្រូវអង្គុយលើអាសនជាមួយគ្នា កាលបើភិក្ខុជាបកតត្តអង្គុយលើអាសនទាប មិនត្រូវអង្គុយលើអាសនខ្ពស់ទេ កាលបើភិក្ខុជាបកតត្តអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនទេ មិនត្រូវចង្រ្កមលើទីចង្រ្កមជាមួយគ្នា កាលបើភិក្ខុជាបកតត្តចង្រ្កមលើទីចង្រ្កមទាប មិនត្រូវចង្រ្កមលើទីចង្រ្កមខ្ពស់ទេ កាលបើភិក្ខុជាបកតត្តចង្រ្កមលើផែនដី មិនត្រូវចង្រ្កមលើទីចង្រ្កមទេ ។

(៣៤៣) ម្នាលភិក្ខុទាំងឡាយ បើគណសង្ឃមានមូលាយបដិកស្សនារហភិក្ខុជាគំរប់ ៤ ឲ្យបរិវាស ឲ្យមូលាយបដិកស្សនា ឲ្យមានត្ត គណសង្ឃមានមូលាយបដិកស្សនារហភិក្ខុនោះជាគំរប់ ២០ ឲ្យអព្ភាន កម្មនោះមិនឡើងជាកម្មផង សង្ឃមិនត្រូវធ្វើផង ។

ចប់វត្តរបស់មូលាយបដិកស្សនារហភិក្ខុ ។

(៣៤៤) សម័យនោះឯង ពួកមានត្តារហភិក្ខុទទួលត្រេកអរនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹករបស់បកតត្តភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកមានត្តារហភិក្ខុ មិនសមបើនឹងទទួលត្រេកអរនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការ

កម្មន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ មានត្តារហា ភិក្ខូ សាទិយន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មន្តិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ មានត្តារហា ភិក្ខូ សាទិយិស្សន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ មានត្តារហេន ភិក្ខុនា សាទិតព្វំ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ យោ សាទិយេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ មានត្តារហានំ ភិក្ខូនំ មិថុ យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ ។ អនុជានាមិ ភិក្ខវេ

ដុសក្អែលខ្នងក្នុងវេលាស្រង់ទឹកនៃបកតត្តភិក្ខុទាំងឡាយសោះ ៗ ទើបភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកមានត្តារហភិក្ខុទទួលត្រេកអរនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹករបស់បកតត្តភិក្ខុទាំងឡាយ ពិតមែនឬ ៗ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ៗ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុទាំងឡាយមិនសមបើនឹងទទួលត្រេកអរនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលក្នុងវេលាស្រង់ទឹករបស់បកតត្តភិក្ខុទាំងឡាយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ លុះទ្រង់បន្ទោសរួចហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុមិនត្រូវត្រេកអរនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹករបស់បកតត្តភិក្ខុទាំងឡាយទេ ភិក្ខុណាត្រេកអរត្រូវអាបត្តិទុក្កដ ៗ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹកដល់មានត្តារហភិក្ខុទាំងឡាយ តាមលំដាប់ចាស់ (ខ្ចី) បាន ៗ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត

មានត្តារហានំ ភិក្ខូនំ បញ្ច យថាវុឌ្ឍំ ឧបោសថំ បវារណំ វស្សិកសាដិកំ ឱណោជនំ ភត្តញ្ច ។ តេន-ហិ ភិក្ខវេ មានត្តារហានំ ភិក្ខូនំ វត្តំ បញ្ញាបេស្សាមិ យថា មានត្តារហេហិ ភិក្ខូហិ វត្តិតព្វំ ។

(៣៨៥) មានត្តារហេន ភិក្ខវេ ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេ-តព្វោ ន ភិក្ខុនោវាទកសម្មតិ សាទិតព្វា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វា យាយ អាបត្តិយា មានត្តា-រហោ ហោតិ សា អាបត្តិ ន អាបជ្ជិតព្វា អញ្ញា វា តាទិសិកា តតោ វា បាបិដ្ឋតរា កម្មំ ន គរហិតព្វំ កម្មិកា ន គរហិតព្វា ន បកតត្តស្ស ភិក្ខុនោ ឧបោសថោ ឋបេតព្វោ ន បវារណា ឋបេតព្វា ន សវចនីយំ កាតព្វំ ន អនុវាទោ បដ្ឋបេតព្វោ ន ឱកាសោ ការេតព្វោ ន ចោទេតព្វោ ន សារេតព្វោ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វំ ។

នូវទោសថ១ បវារណា ១ ការទទួលវស្សិកសាដិក១ ការលះបង់កត្ថ១ ការទទួលកត្ថ ១ ទាំង៥ យ៉ាង ដល់មានត្តារហភិក្ខុទាំងឡាយ តាមលំដាប់ចាស់(ខ្ចី) ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្ត ដល់ពួកមានត្តារហភិក្ខុតាមទំនងដែលមានត្តារហភិក្ខុទាំងឡាយត្រូវប្រ-ព្រឹត្តតាម ។

(៣៨៥) ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុត្រូវប្រព្រឹត្តវត្ត ដោយប្រពៃ ឯការប្រព្រឹត្តវត្តដោយប្រពៃក្នុងមានត្តនោះដូច្នេះ គឺមានត្តា-រហភិក្ខុមិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី បើសង្ឃបានសន្មតហើយក៏មិនត្រូវទៅប្រដៅភិក្ខុនីទាំងឡាយ ភិក្ខុដែលគួរដល់មានត្តព្រោះអាបត្តិណា មិនគប្បីឲ្យត្រូវអាបត្តិនោះ ឬអាបត្តិដទៃប្រហែលនឹងអាបត្តិមុននោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណា (ដល់បកតត្តភិក្ខុ) មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ(ក្នុងអធិករ-ណនោះ) មិនត្រូវទទួលនាទីជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទ មិនត្រូវរំលឹក មិនត្រូវប្រកបពួកភិក្ខុ(ឲ្យឈ្លោះ)នឹងពួកភិក្ខុឡើយ ។

## បារិវាសិកក្ខន្ធកេ មានត្តារហវត្តំ

(៣៤៦) ន ភិក្ខវេ មានត្តារហេន ភិក្ខុនា បកតត្តស្ស ភិក្ខុនោ បុរតោ គន្តព្វំ ន បុរតោ និសីទិតព្វំ យោ ហោតិ សង្ឃស្ស អាសនបរិយន្តោ សេយ្យាបរិយន្តោ វិហារបរិយន្តោ សោ តស្ស បទាតព្វោ តេន ច សោ សាទិតព្វោ ។ ន ភិក្ខវេ មានត្តារហេន ភិក្ខុនា បកតត្តេន ភិក្ខុនា បុរេសមណេន វា បច្ឆាសមណេន វា កុលានិ ឧបសង្កមិតព្វានិ ន អារញ្ញិកង្គំ សមាទិតព្វំ ន បិណ្ឌបាតិកង្គំ សមាទិតព្វំ ន ច តប្បច្ចយា បិណ្ឌបាតោ នីហរាបេតព្វោ មា មំ ជានឹសូតិ ។

(៣៤៧) មានត្តារហេន[១] ភិក្ខវេ ភិក្ខុនា អាគន្តុកេន អារោចេតព្វំ អាគន្តុកស្ស អារោចេតព្វំ ឧបោសថេ អារោចេតព្វំ បវារណាយ អារោចេតព្វំ ទេវសិកំ អារោចេតព្វំ សចេ គិលានោ ហោតិ ទូតេនបិ អារោចាបេតព្វំ[២] ។

(៣៤៨) ន ភិក្ខវេ មានត្តារហេន ភិក្ខុនា សភិក្ខុកា អាវាសា អភិក្ខុកោ អាវាសោ គន្តព្វោ អញ្ញត្រ

---

១ ឱ. មានត្តចារិកេន ។ ២ ឱ. អារោចេតព្វំ ។

## បារិវាសិកក្ខន្ធក វត្តរបស់មានត្តារហភិក្ខុ

[៣៤៦] ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុមិនត្រូវដើរមុន មិនត្រូវអង្គុយខាងមុខបកតត្តភិក្ខុឡើយ ឱកាសឯណាជាទីបំផុតនៃទីអង្គុយ ទីដេកនិងវិហាររបស់សង្ឃ សង្ឃត្រូវប្រគល់ឲ្យទីឱកាសនោះដល់មានត្តារហភិក្ខុនោះ មួយទៀតមានត្តារហភិក្ខុនោះត្រូវត្រេកអរទីឱកាសដែលសង្ឃប្រគល់ឲ្យនោះ ។ ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុមិនត្រូវផ្ញើបកតត្តភិក្ខុឲ្យជាបុរេសមណ ឬបច្ឆាសមណចូលទៅកាន់ត្រកូលទាំងឡាយឡើយ មានត្តារហភិក្ខុមិនត្រូវសមាទានអារញ្ញិកធុតង្គ មិនត្រូវសមាទានបិណ្ឌបាតិកធុតង្គ មួយទៀតមិនត្រូវឲ្យគេនាំបង្ហាន់បិណ្ឌបាតមក (ដើម្បីខ្លួន) ព្រោះបច្ច័យនោះ ដោយគិតថា ជនទាំងឡាយកុំដឹងអាត្មាអញឡើយ ។

[៣៤៧] ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុជាអាគន្តុកត្រូវប្រាប់ (ដល់ភិក្ខុទាំងឡាយក្នុងវត្ត) ត្រូវប្រាប់ដល់អាគន្តុកភិក្ខុ (ដែលមកដល់កន្លែងខ្លួន) ត្រូវប្រាប់ក្នុងថ្ងៃឧបោសថ ត្រូវប្រាប់ក្នុងថ្ងៃបវារណា ត្រូវប្រាប់រាល់ថ្ងៃ បើមានជម្ងឺ (មិនអាចនឹងទៅបាន) ត្រូវឲ្យទូតប្រាប់ (ជំនួសខ្លួន) ក៏បាន ។

[៣៤៨] ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមាន

បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មានត្តារហេន ភិក្ខុនា សភិក្ខុកា អាវាសា អភិក្ខុកោ អនាវាសោ គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មានត្តារហេន ភិក្ខុនា សភិក្ខុកា អាវាសា អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មានត្តារហេន ភិក្ខុនា សភិក្ខុកា អនាវាសា អភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។ អភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មានត្តារហេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា អភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។ អភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ។

(៣៤៩) ន ភិក្ខវេ មានត្តារហេន ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។

ភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តាហោភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តាហោភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តាហោភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ ។ បេ ។ ទៅកាន់អនាវាសដែលមិនមានភិក្ខុទេ ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តាហោភិក្ខុមិនត្រូវចេញចាកអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ ។ បេ ។ ទៅកាន់អនាវាសដែលមិនមានភិក្ខុទេ ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ។

(៣៤៩) ម្នាលភិក្ខុទាំងឡាយ មានត្តាហោភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ ។ បេ ។

សភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មានត្តារហេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មានត្តារហេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ។

(៣៤០) គន្តព្វោ ភិក្ខវេ មានត្តារហេន ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ ។ បេ ។ សភិក្ខុកោ អនាវាសោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា

ទៅកាន់អនាវាសដែលមានភិក្ខុ ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុទេ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំង-ឡាយ មានត្តារហភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ ។ បេ ។ ទៅកាន់អនាវាសដែលមានភិក្ខុ ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុទេ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុមិនត្រូវចេញចាកអាវាសឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ ។ បេ ។ ទៅកាន់អនាវាសដែលមានភិក្ខុទេ ។ បេ ។ ទៅកាន់អាវាសឬអនា-វាសដែលមានភិក្ខុទេ គឺអាវាសឬអនាវាសណាដែលមានភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ។

(៣៩០) ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុគួរចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុ ។ បេ ។ ទៅកាន់អនាវាសដែលមានភិក្ខុ ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា

យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ គន្តព្វោ ភិក្ខវេ
មានត្តារហេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុ-
កោ អាវាសោ ។បេ។ សភិក្ខុកោ អនាវាសោ ។បេ។
សភិក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ
ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ
គន្តុន្តិ គន្តព្វោ ភិក្ខវេ មានត្តារហេន ភិក្ខុនា សភិក្ខុ-
កា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវា-
សោ ។បេ។ សភិក្ខុកោ អនាវាសោ ។បេ។ សភិ-
ក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ
សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ
គន្តុន្តិ ។

(៣៨១) ន ភិក្ខវេ មានត្តារហេន ភិក្ខុនា បកត-
ត្តេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាវាសេ វត្ថព្វំ ន ឯ-
កច្ឆន្នេ អនាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អាវាសេ វា
អនាវាសេ វា វត្ថព្វំ បកតត្តំ ភិក្ខុំ ទិស្វា អាសនា
វុដ្ឋាតព្វំ បកតត្តោ ភិក្ខុ អាសនេន និមន្តេតព្វោ ន
បកតត្តេន ភិក្ខុនា សទ្ធឹ ឯកាសនេ និសីទិតព្វំ

អាវាសឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មានត្ដារហភិក្ខុគួរចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុ ។ បេ ។ ទៅកាន់អនាវាសដែលមានភិក្ខុ ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មានត្ដារហ-ភិក្ខុគួរចេញចាកអាវាស ឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុ ។ បេ ។ ទៅកាន់អនាវាសដែលមានភិក្ខុ ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុ គឺអាវាសឬអនាវាសណាដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ក្នុងថ្ងៃនេះបាន ។

(៣៩១) ម្នាលភិក្ខុទាំងឡាយ មានត្ដារហភិក្ខុមិនត្រូវនៅក្នុងអា-វាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាសឬអនាវាសដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុជាបកតត្តទេ ឃើញភិក្ខុជាបកតត្តហើយ ត្រូវក្រោកចាកអាសន ត្រូវនិមន្តភិក្ខុជាបកតត្តដោយអាសន មិនត្រូវអង្គុយលើអាសនមួយជាមួយនឹងភិក្ខុ

ន នីចេ អាសនេ និសិន្នេ ឧច្ចេ អាសនេ និសីទិតព្វំ ន ឆមាយំ និសិន្នេ អាសនេ និសីទិតព្វំ ន ឯកចង្កមេ ចង្កមិតព្វំ ន នីចេ ចង្កមេ ចង្កមន្តេ ឧច្ចេ ចង្កមេ ចង្កមិតព្វំ ន ឆមាយំ ចង្កមន្តេ ចង្កមេ ចង្កមិតព្វំ ។

(៣៨២) ន ភិក្ខវេ មានត្តារហេន ភិក្ខុនា បារិវាសិកេន ភិក្ខុនា សទ្ធឹ ។ បេ ។ មូលាយ បដិកស្សនារហេន ភិក្ខុនា សទ្ធឹ ។ បេ ។ មានត្តារហេន វុឌ្ឍតរេន ភិក្ខុនា សទ្ធឹ ។ បេ ។ មានត្តចារិកេន ភិក្ខុនា សទ្ធឹ ។ បេ ។ អព្ភានារហេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អនាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អាវាសេ វា អនាវាសេ វា វត្ថព្វំ ន ឯកាសនេ និសីទិតព្វំ ន នីចេ អាសនេ និសិន្នេ ឧច្ចេ អាសនេ និសីទិតព្វំ ន ឆមាយំ និសិន្នេ អាសនេ និសីទិតព្វំ ន ឯកចង្កមេ ចង្កមិតព្វំ ន នីចេ ចង្កមេ ចង្កមន្តេ ឧច្ចេ ចង្កមេ ចង្កមិតព្វំ ន ឆមាយំ ចង្កមន្តេ ចង្កមេ ចង្កមិតព្វំ ។

ជាបកតត្ត កាលបើភិក្ខុជាបកតត្តអង្គុយលើអាសនទាប មិនត្រូវអង្គុយលើអាសនខ្ពស់ កាលបើភិក្ខុជាបកតត្តអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសន មិនត្រូវចង្ក្រមលើទីចង្ក្រមជាមួយគ្នា កាលបើភិក្ខុជាបកតត្តចង្ក្រមលើទីចង្ក្រមទាប មិនត្រូវចង្ក្រមលើទីចង្ក្រមខ្ពស់ កាលបើភិក្ខុជាបកតត្តចង្ក្រមលើផែនដី មិនត្រូវចង្ក្រមលើទីចង្ក្រម ។

(៣៤២) ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុមិនត្រូវនៅជាមួយនឹងបារិវាសិកភិក្ខុ ។ បេ ។ ជាមួយនឹងមូលាយបដិកស្សនារហភិក្ខុ ។ បេ ។ ជាមួយនឹងមានត្តារហភិក្ខុដែលចាស់ជាងខ្លួន ។ បេ ។ ជាមួយនឹងមានត្តចារិកភិក្ខុ ។ បេ ។ មិនត្រូវនៅក្នុងអាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាសឬអនាវាសដែលមានដម្បូលមួយ ជាមួយនឹងអព្ភានារហភិក្ខុ មិនត្រូវអង្គុយលើអាសនជាមួយគ្នា កាលបើអព្ភានារហភិក្ខុអង្គុយលើអាសនទាប មិនត្រូវអង្គុយលើអាសនខ្ពស់ កាលបើអព្ភានារហភិក្ខុអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសន មិនត្រូវចង្ក្រមលើទីចង្ក្រមជាមួយគ្នា កាលបើអព្ភានារហភិក្ខុចង្ក្រមលើទីចង្ក្រមទាប មិនត្រូវចង្ក្រមលើទីចង្ក្រមខ្ពស់ កាលបើអព្ភានារហភិក្ខុចង្ក្រមលើផែនដី មិនត្រូវចង្ក្រមលើទីចង្ក្រម ។

(៣៨៣) មានត្តារហចតុត្ថោ ចេ ភិក្ខវេ បរិវាសំ ទទេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ទទេយ្យ ឥត្ថីសោ អព្ភេយ្យ អកម្មំ តំ ន ច ករណីយន្តិ ។

**មានត្តារហវត្តំ និដ្ឋិតំ ។**

(៣៨៤) តេន ខោ បន សមយេន មានត្តចារិកា ភិក្ខូ សាទិយន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ អាសនាភិហារំ សេយ្យាភិហារំ បាទោទកំ បាទបីឋំ បាទកឋលិកំ បត្តចីវរបដិគ្គហណំ នហានេ បិដ្ឋិបរិកម្មំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម មានត្តចារិកា ភិក្ខូ សាទិយិស្សន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

(៣៨៥) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ

(៣៩៣) ម្នាលភិក្ខុទាំងឡាយ បើគណសង្ឃមានមានត្តារហភិក្ខុជាគំរប់៤ ឲ្យបរិវាស ឲ្យមូលាយបដិកស្សនា ឲ្យមានត្ត គណសង្ឃមានមានត្តារហភិក្ខុនោះជាគំរប់ ២០ ឲ្យអព្ភាន កម្មនោះមិនឡើងជាកម្មផង សង្ឃមិនត្រូវធ្វើផង ។

ចប់វត្តរបស់មានត្តារហភិក្ខុ ។

(៣៩៤) សម័យនោះឯង ពួកមានត្តចារិកភិក្ខុ ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រនិងចីវរ ការដុសក្អែលខ្នងក្នុងវេលាងូតទឹកនៃបកតត្តភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏ពួកមានត្តចារិកភិក្ខុត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយដូច្នោះ ទើបភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។

(៣៩៥) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ

សច្ចំ កិរ ភិក្ខវេ មានត្តចារិកា ភិក្ខូ សាទិយន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មន្តិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ មានត្តចារិកា ភិក្ខូ សាទិយិស្សន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ នេតំ ភិក្ខវេ អប្ប-សន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ មានត្តចារិកេន ភិក្ខុនា សាទិតព្វំ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ យោ សាទិ-យេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ មានត្តចារិកានំ ភិក្ខូនំ មិថុ យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ ។ អនុជានាមិ ភិក្ខវេ មានត្តចារិកានំ ភិក្ខូនំ បញ្ច យថាវុឌ្ឍំ ឧបោ-សថំ បវារណំ វស្សិកសាដិកំ ឱណោជនំ ភត្តញ្ច ។

## បារិវាសិកក្ខន្ធក វត្តរបស់ភិក្ខុអ្នកប្រព្រឹត្តមានត្ត

ឮថាពួកមានត្តចារិកភិក្ខុ ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមានត្តចារិកភិក្ខុមិនសមបើនឹងត្រេកអរអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ លុះទ្រង់បន្ទោសរួចហើយទ្រង់ធ្វើធម្មីកថាហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុមិនត្រូវត្រេកអរអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹករបស់ពួកភិក្ខុជាបកតត្តឡើយ ភិក្ខុណាត្រេកអរ ត្រូវអាបត្តិទុក្កដ ៕ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាស្រង់ទឹកដល់មានត្តចារិកភិក្ខុទាំងឡាយ តាមលំដាប់ចាស់(ខ្ចី) ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបោសថ១ បវារណា១ ការទទួលសំពត់វស្សិកសាដិក១ ការលះបង់ភត្ត១ ការទទួលភត្ត១

តេនហិ ភិក្ខវេ មានត្តចារិកានំ ភិក្ខូនំ វត្តំ បញ្ញាបេស្សាមិ យថា មានត្តចារិកេហិ ភិក្ខូហិ វត្តិតព្វំ ។

(៣៨៦) មានត្តចារិកេន ភិក្ខវេ ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ ន ភិក្ខុនោវាទកសម្មុតិ សាទិតព្វា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វា យាយ អាបត្តិយា សង្ឃេន មានត្តំ ទិន្នំ ហោតិ សា អាបត្តិ ន អាបជ្ជិតព្វា អញ្ញា វា តាទិសិកា តតោ វា បាបិដ្ឋតរា កម្មំ ន គរហិតព្វំ កម្មិកា ន គរហិតព្វា ន បកតត្តស្ស ភិក្ខុនោ ឧបោសថោ ឋបេតព្វោ ន បវារណា ឋបេតព្វា ន សវចនីយំ កាតព្វំ ន អនុវាទោ បដ្ឋបេតព្វោ ន ឱកាសោ ការេតព្វោ ន ចោទេតព្វោ ន សារេតព្វោ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វំ ។

(៣៨៧) ន ភិក្ខវេ មានត្តចារិកេន ភិក្ខុនា បកតត្តស្ស ភិក្ខុនោ បុរតោ គន្តព្វំ ន បុរតោ និសីទិតព្វំ យោ ហោតិ សង្ឃស្ស អាសនបរិយន្តោ

ទាំង៩យ៉ាង ដល់មានត្តចារិកភិក្ខុតាមលំដាប់ចាស់(ខ្ចី) ។ ម្នាលភិក្ខុទាំង-ឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្តដល់ពួកមានត្តចារិកភិក្ខុ តាមទំនងដែលមានត្តចារិកភិក្ខុត្រូវប្រព្រឹត្ត ។

(៣៩៦) ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុត្រូវប្រព្រឹត្តវត្តដោយប្រពៃ ។ ឯការប្រព្រឹត្តវត្តដោយប្រពៃក្នុងមានត្តនោះដូច្នេះ គឺមានត្តចារិកភិក្ខុ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើ មិនត្រូវទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឃសន្មតហើយក៏មិនត្រូវប្រដៅភិក្ខុនី សង្ឃឲ្យមានត្តបំពោះអាបត្តិណា មិនគប្បីត្រូវអាបត្តិនោះទៀត ឬអាបត្តិដទៃដែលប្រហែលនឹងអាបត្តិនោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណាដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ) មិនត្រូវទទួលនាទីជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទ មិនត្រូវរំលឹក មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ។

(៣៩៧) ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវដើរមុន មិនត្រូវអង្គុយមុខភិក្ខុជាបកតត្តឡើយ ឱកាសឯណាជាទីបំផុតនៃអាសន

សេយ្យាបរិយន្តោ វិហារបរិយន្តោ សោ តស្ស បទាតព្វោ តេន ច សោ សាទិតព្វោ ។ ន ភិក្ខវេ មានត្តចារិកេន ភិក្ខុនា បកតត្តេន ភិក្ខុនា បុរេសមណេន វា បច្ឆាសមណេន វា កុលានិ ឧបសង្កមិតព្វានិ ន អារញ្ញិកង្គំ សមាទិតព្វំ ន បិណ្ឌបាតិកង្គំ សមាទិតព្វំ ន ច តប្បច្ចយា បិណ្ឌបាតោ នីហរាបេតព្វោ មា មំ ជានឹសូតិ ។

(៣៤៨) មានត្តចារិកេន ភិក្ខវេ ភិក្ខុនា អាគន្តុកេន អារោចេតព្វំ អាគន្តុកស្ស អារោចេតព្វំ ឧបោសថេ អារោចេតព្វំ បវារណាយ អារោចេតព្វំ ទេវសិកំ អារោចេតព្វំ សចេ គិលានោ ហោតិ ទូតេនបិ អារោចាបេតព្វំ ។

(៣៤៩) ន ភិក្ខវេ មានត្តចារិកេន ភិក្ខុនា សភិក្ខុកា អាវាសា អភិក្ខុកោ អាវាសោ គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មានត្តចារិកេន ភិក្ខុនា សភិក្ខុកា អាវាសា អនាវាសោ គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ

ជាទីបំផុតនៃទីដេក ជាទីបំផុតនៃវិហាររបស់សង្ឃ សង្ឃត្រូវប្រគល់ឱកាសនោះដល់ភិក្ខុនោះ ឯភិក្ខុនោះត្រូវត្រេកអរចំពោះទីឱកាសនោះ ។ ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវធ្វើភិក្ខុជាបកតត្តឲ្យជាបុរេសមណ ឬបច្ឆាសមណចូលទៅកាន់ត្រកូលទាំងឡាយឡើយ មិនត្រូវសមាទានអារញ្ញិកធុតង្គ មិនត្រូវសមាទានបិណ្ឌបាតិកធុតង្គ មួយទៀតមិនត្រូវឲ្យគេនាំចង្ហាន់បិណ្ឌបាតមក (ដើម្បីខ្លួន) ព្រោះមុច្ឆ័យនោះដោយគិតថា ជនទាំងឡាយកុំដឹងអាត្មាអញឡើយ ។

(៣៥៨) ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុជាអាគន្តុក ត្រូវប្រាប់ (ដល់ភិក្ខុក្នុងអាវាសដែលខ្លួនទៅដល់) ត្រូវប្រាប់ដល់អាគន្តុកភិក្ខុ (ដែលមកដល់ទីកន្លែងខ្លួន) ត្រូវប្រាប់ក្នុងថ្ងៃឧបោសថ ត្រូវប្រាប់ក្នុងថ្ងៃបវារណា ត្រូវប្រាប់រាល់ថ្ងៃ បើមានជម្ងឺត្រូវប្រើបម្រើទៅប្រាប់ក៏បាន ។

(៣៥៩) ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ

មានត្តចារិកេន ភិក្ខុនា សភិក្ខុកា អាវាសា អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មានត្តចារិកេន ភិក្ខុនា សភិក្ខុកា អនាវាសា អភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។ អភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ មានត្តចារិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា អភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។ អភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ អភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។

(៣៦០) ន ភិក្ខវេ មានត្តចារិកេន ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ

មានត្ថបារិកភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្ថបារិកភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុទៅកាន់អាវាសដែលមិនមានភិក្ខុទេ ។ បេ ។ ទៅកាន់អនាវាសដែលមិនមានភិក្ខុទេ ។ បេ ។ ទៅកាន់អាវាស ឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្ថបារិកភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ ។ បេ ។ ទៅកាន់អនាវាសដែលមិនមានភិក្ខុទេ ។ បេ ។ ទៅកាន់អាវាស ឬអនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ។

(៣៦០) ម្នាលភិក្ខុទាំងឡាយ មានត្ថបារិកភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ ។ បេ ។ ទៅកាន់អនាវាសដែលមានភិក្ខុទេ ។ បេ ។ ទៅកាន់អាវាស ឬអនាវាសដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ

មានត្តចារិកេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។ ន ភិក្ខវេ មានត្តចារិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អនាវាសោ គន្តព្វោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា គន្តព្វោ យត្ថស្សុ ភិក្ខូ នានាសំវាសកា អញ្ញត្រ សង្ឃេន អញ្ញត្រ អន្តរាយា ។

(៣៦១) គន្តព្វោ ភិក្ខវេ មានត្តចារិកេន ភិក្ខុនា សភិក្ខុកា អាវាសា សភិក្ខុកោ អាវាសោ ។ បេ ។ សភិក្ខុកោ អនាវាសោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ គន្តព្វោ ភិក្ខវេ មានត្តចារិកេន ភិក្ខុនា សភិក្ខុកា អនាវាសា សភិក្ខុកោ អាវាសោ ។ បេ ។ សភិក្ខុកោ អនាវាសោ ។ បេ ។

## បារិវាសិកក្ខន្ធក វត្តរបស់ភិក្ខុអ្នកប្រព្រឹត្តមានត្ត

មានត្តចារិកភិក្ខុមិនត្រូវចេញចាកអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ ។ បេ ។ ទៅកាន់អនាវាសដែលមានភិក្ខុទេ ។ បេ ។ ទៅកាន់អាវាស ឬអនាវាសដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុមិនត្រូវចេញចាកអាវាស ឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុទេ ។ បេ ។ ទៅកាន់អនាវាសដែលមានភិក្ខុទេ ។ បេ ។ ទៅកាន់អាវាស ឬអនាវាសដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេង ៗ គ្នា វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ។

(៣៦១) ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ គួរចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុបាន ។បេ។ ទៅកាន់អនាវាសដែលមានភិក្ខុបាន ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុបាន គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុគួរចេញចាកអនាវាសដែលមានភិក្ខុ ទៅកានអាវាសដែលមានភិក្ខុ ។បេ។ ទៅកាន់អនាវាសដែលមានភិក្ខុ ។បេ។

សភិក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ គន្តព្វោ ភិក្ខវេ មានត្តចារិកេន ភិក្ខុនា សភិក្ខុកា អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ ។ បេ ។ សភិក្ខុកោ អនាវាសោ ។ បេ ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ ។

(៣៦២) ន ភិក្ខវេ មានត្តចារិកេន ភិក្ខុនា បកតត្តេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អនាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អាវាសេ វា អនាវាសេ វា វត្ថព្វំ បកតត្តំ ភិក្ខុំ ទិស្វា អាសនា វុដ្ឋាតព្វំ បកតត្តោ ភិក្ខុ អាសនេន និមន្តេតព្វោ ន បកតត្តេន ភិក្ខុនា សទ្ធឹ ឯកាសនេ និសីទិតព្វំ ន នីចេ អាសនេ និសិន្នេ ឧច្ចេ អាសនេ និសីទិតព្វំ ន ឆមាយំ និសិន្នេ អាសនេ និសីទិតព្វំ ន ឯកចង្កមេ

ទៅកាន់អាវាសបុរអនាវាសដែលមានភិក្ខុបាន គឺអាវាសបុរអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសបុរអនាវាសណា អាត្មាអញអាចនឹងទៅឲ្យដល់ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មានគូបារិកភិក្ខុគួរចេញចាកអាវាស បុរអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុបាន ។បេ។ ទៅកាន់អនាវាសដែលមានភិក្ខុ ។បេ។ ទៅកាន់អាវាសបុរអនាវាសដែលមានភិក្ខុបាន គឺអាវាសបុរអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសបុរអនាវាសណា អាត្មាអញអាចនឹងទៅឲ្យដល់ក្នុងថ្ងៃនេះបាន ។

[៣៦២] ម្នាលភិក្ខុទាំងឡាយ មានគូបារិកភិក្ខុមិនត្រូវនៅក្នុងអាវាសដែលមានដំបូលមួយ មិនត្រូវនៅក្នុងអនាវាសដែលមានដំបូលមួយ មិនត្រូវនៅក្នុងអាវាសបុរអនាវាសដែលមានដំបូលមួយ ជាមួយនឹងភិក្ខុជាបកតត្ត បើឃើញភិក្ខុជាបកតត្តហើយត្រូវក្រោកចាកអាសនៈ ត្រូវនិមន្តភិក្ខុជាបកតត្តដោយអាសនៈ មិនត្រូវអង្គុយលើអាសនៈមួយ ជាមួយនឹងភិក្ខុជាបកតត្ត កាលបើភិក្ខុជាបកតត្តអង្គុយលើអាសនៈទាប មិនត្រូវអង្គុយលើអាសនៈខ្ពស់ កាលបើភិក្ខុជាបកតត្តអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនៈទេ មិនត្រូវចង្រ្កមលើទីចង្រ្កមជាមួយគ្នា កាលបើភិក្ខុជាបកតត្ត

## បារិវាសិកក្ខន្ធកេ មានត្តចារិកវត្តំ

ចង្កមិតព្វំ ន នីចេ ចង្កមេ ចង្កមន្តេ ឧច្ចេ ចង្កមេ ចង្កមិតព្វំ ន ឆមាយំ ចង្កមន្តេ ចង្កមេ ចង្កមិតព្វំ ។

(៣៦៣) ន ភិក្ខវេ មានត្តចារិកេន ភិក្ខុនា បារិវាសិកេន ភិក្ខុនា សទ្ធឹ ។បេ។ មូលាយ បដិកស្សនារហេន ភិក្ខុនា សទ្ធឹ ។បេ។ មានត្តារហេន ភិក្ខុនា សទ្ធឹ ។បេ។ មានត្តចារិកេន វុឌ្ឍតរេន ភិក្ខុនា សទ្ធឹ ។បេ។ អព្ភានារហេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អនាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អាវាសេ វា អនាវាសេ វា វត្ថព្វំ ន ឯកាសនេ និសីទិតព្វំ ន នីចេ អាសនេ និសិន្នេ ឧច្ចេ អាសនេ និសីទិតព្វំ ន ឆមាយំ និសិន្នេ អាសនេ និសីទិតព្វំ ន ឯកចង្កមេ ចង្កមិតព្វំ ន នីចេ ចង្កមេ ចង្កមន្តេ ឧច្ចេ ចង្កមេ ចង្កមិតព្វំ ន ឆមាយំ ចង្កមន្តេ ចង្កមេ ចង្កមិតព្វំ ។

(៣៦៤) មានត្តចារិកចតុត្ថោ ចេ ភិក្ខវេ បរិវាសំ ទទេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ទទេយ្យ តវីសោ អព្ភេយ្យ អកម្មំ តំ ន ច ករណីយន្តិ ។

## បារិវាសិកក្ខន្ធក វត្តរបស់ភិក្ខុអ្នកប្រព្រឹត្តមានត្ត

ចង្ក្រមលើទីចង្ក្រមទាប មិនត្រូវចង្ក្រមលើទីចង្ក្រមខ្ពស់ឡើយ កាលបើភិក្ខុជាបកតត្តចង្ក្រមលើផែនដី មិនត្រូវចង្ក្រមលើទីចង្ក្រមឡើយ ។

[៣៦៣] ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុមិនត្រូវនៅជាមួយនឹងបារិវាសិកភិក្ខុ ។ បេ ។ ជាមួយនឹងមូលាយបដិកស្សនារហភិក្ខុ ។ បេ ។ ជាមួយនឹងមានត្តារហភិក្ខុ ។ បេ ។ ជាមួយនឹងមានត្តចារិកភិក្ខុដែលចាស់ជាងខ្លួន ។ បេ ។ មិនត្រូវនៅក្នុងអាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាសឬអនាវាសដែលមានដម្បូលមួយ ជាមួយនឹងអព្ភានារហភិក្ខុ មិនត្រូវអង្គុយលើអាសនជាមួយគ្នា កាលបើអព្ភានារហភិក្ខុអង្គុយលើអាសនទាប មិនត្រូវអង្គុយលើអាសនខ្ពស់ កាលបើអព្ភានារហភិក្ខុអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសន មិនត្រូវចង្ក្រមលើទីចង្ក្រមជាមួយគ្នា កាលបើអព្ភានារហភិក្ខុចង្ក្រមលើទីចង្ក្រមទាប មិនត្រូវចង្ក្រមលើទីចង្ក្រមខ្ពស់ កាលបើអព្ភានារហភិក្ខុចង្ក្រមលើផែនដី មិនត្រូវចង្ក្រមលើទីចង្ក្រមឡើយ ។

[៣៦៤] ម្នាលភិក្ខុទាំងឡាយ បើគណសង្ឃមានមានត្តចារិកភិក្ខុជាគំរប់ ៤ ឲ្យបរិវាស ឲ្យមូលាយបដិកស្សនា ឲ្យមានត្ត គណសង្ឃមានមានត្តចារិកភិក្ខុនោះជាគំរប់ ២០ ឲ្យអព្ភាន កម្មនោះមិនឡើងជាកម្មផង សង្ឃមិនត្រូវធ្វើផង ។

[៣៦៥] អថខោ អាយស្មា ឧបាលិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបាលិ ភគវន្តំ ឯតទវោច កតិ នុ ខោ ភន្តេ មានត្តចារិកស្ស ភិក្ខុនោ រត្តិច្ឆេទាតិ ។ ចត្តារោ ខោ ឧបាលិ មានត្តចារិកស្ស ភិក្ខុនោ រត្តិច្ឆេទា សហវាសោ វិប្បវាសោ អនារោចនា ឩនេ គណេ ចរតិ[១] ឥមេ ខោ ឧបាលិ ចត្តារោ មានត្តចារិកស្ស ភិក្ខុនោ រត្តិច្ឆេទាតិ ។

[៣៦៦] តេន ខោ បន សមយេន សាវត្ថិយំ មហាភិក្ខុសង្ឃោ សន្និបតិតោ ហោតិ ។ ន សក្កោន្តិ មានត្តចារិកា ភិក្ខូ មានត្តំ សោធេតុំ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មានត្តំ និក្ខិបិតុំ ។ ឯវញ្ច បន ភិក្ខវេ និក្ខិបិតព្វំ ។ តេន មានត្តចារិកេន ភិក្ខុនា ឯកំ ភិក្ខុំ ឧបសង្ក-

---

១ ឩនោគណេន ចរតីតិបិ ឩនោគណោ ចរតីតិបិ បាឋោ ទិស្សតិ ។ ឩ. ហោត្ថកេ ឩនេ គណេ ចរណន្តិ បាឋោ បន អាគតោ ។

(៣៦៥) គ្រានោះ ព្រះឧបាលិដ៏មានអាយុចូលទៅគាល់ព្រះដ៏-មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះឧបាលិដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ការដាច់រាត្រីរបស់មានត្តចារិកភិក្ខុមានប៉ុន្មាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបាលិ ការដាច់រាត្រីរបស់មានត្តចារិកភិក្ខុមាន៤យ៉ាងគឺ ការនៅរួមគ្នា[១] ១ ការមិននៅរួមគ្នា[២] ១ ការមិនប្រាប់[៣] ១ ភិក្ខុនោះប្រព្រឹត្តមានត្តក្នុងពួកបកតត្តភិក្ខុមិនគ្រប់ចំនួន[៤] ១ ម្នាលឧបាលិ ការដាច់រាត្រីរបស់មានត្តចារិកភិក្ខុមាន ៤ យ៉ាងនេះឯង ។

(៣៦៦) សម័យនោះ ភិក្ខុសង្ឃប្រជុំគ្នាច្រើនក្នុងក្រុងសាវត្ថី ។ ពួកមានត្តចារិកភិក្ខុមិនអាចជំរះមានត្តបាន ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតឲ្យដាក់មានត្តបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវដាក់មានត្តយ៉ាងនេះ ។ មានត្តចារិកភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុ១រូប

---

១ អដ្ឋកថា ថា គឺនៅក្នុងទីមានដម្បូលមួយជាមួយនឹងភិក្ខុជាបកតត្ត ។ ២ នៅតែម្នាក់ឯង គឺនៅក្នុងទីដែលគ្មានសង្ឃជាគ្នា ។ ៣ គឺមិនប្រាប់ ថាខ្លួនជាមានត្តចារិកភិក្ខុ ដល់អាគន្តុកភិក្ខុជាដើម ។ ៤ គឺមិនគ្រប់ចំនួនសង្ឃតាំងពី ៤ រូបឡើងទៅ ។

មិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ មានត្តំ និក្ខិបាមីតិ ។ និក្ខិត្តំ ហោតិ មានត្តំ ។ វត្តំ និក្ខិបាមីតិ ។ និក្ខិត្តំ ហោតិ មានត្តន្តិ ។

(៣៦៧) តេន ខោ បន សមយេន សាវត្ថិយា ភិក្ខូ តហឹ តហឹ បក្កមឹសុ ។ សក្កោន្តិ[១] មានត្តចារិកា ភិក្ខូ មានត្តំ សោធេតុំ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មានត្តំ សមាទិយិតុំ ។ ឯវញ្ច បន ភិក្ខវេ សមាទាតព្វំ ។ តេន មានត្តចារិកេន ភិក្ខុនា ឯកំ ភិក្ខុំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ មានត្តំ សមាទិយាមីតិ ។ សមាទិន្នំ ហោតិ មានត្តំ ។ វត្តំ សមាទិយាមីតិ ។ សមាទិន្នំ ហោតិ មានត្តន្តិ ។

មានត្តចារិកវត្តំ និដ្ឋិតំ ។

---

១ យេភុយ្យេន ន សក្កោន្តីតិ បាឋោ ទិស្សតិ ។

## បារិវាសិកក្ខន្ធក វត្តរបស់ភិក្ខុអ្នកប្រព្រឹត្តមានត្ត

ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង អង្គុយប្រហោងផ្គងអញ្ជលីឡើងនិយាយយ៉ាងនេះថា ខ្ញុំសូមដាក់នូវមានត្ត ។ មានត្តឈ្មោះថាភិក្ខុបានដាក់ហើយ ។ ថាខ្ញុំសូមដាក់វត្ត ។ មានត្តក៏ឈ្មោះថាភិក្ខុបានដាក់ហើយដែរ ។

(៣៦៧) សម័យនោះ ភិក្ខុទាំងឡាយចេញអំពីក្រុងសាវត្ថី ទៅកាន់ទីនោះៗ ។ មានត្តចារិកភិក្ខុទាំងឡាយ ក៏អាចជំរះនូវមានត្តបាន ។ ភិក្ខុទាំងអម្បាលនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសមាទានមានត្ត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវសមាទានយ៉ាងនេះ ។ មានត្តចារិកភិក្ខុនោះត្រូវចូលទៅរកភិក្ខុ ១ រូបហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាងអង្គុយប្រហោងផ្គងអញ្ជលីឡើងនិយាយយ៉ាងនេះថា ខ្ញុំសូមសមាទានមានត្ត ។ មានត្តឈ្មោះថាភិក្ខុបានសមាទានហើយ ។ ថាខ្ញុំសូមសមាទានវត្ត មានត្តឈ្មោះថាភិក្ខុបានសមាទានហើយដែរ ។

ចប់វត្តរបស់មានត្តចារិកភិក្ខុ ។

(៣៦៨) តេន ខោ បន សមយេន អព្ភានារហា ភិក្ខូ សាទិយន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អព្ភានារហា ភិក្ខូ សាទិយិស្សន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

(៣៦៩) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ អព្ភានារហា ភិក្ខូ សាទិយន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មន្តិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ អព្ភានារហា ភិក្ខូ សាទិយិស្សន្តិ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។ បេ ។ នហានេ បិដ្ឋិបរិកម្មំ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ

(៣៦៨) សម័យនោះ ពួកអញ្ញនារហភិក្ខុ ត្រេកអរនឹងអភិវាទន-កម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយ ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកអញ្ញនារហភិក្ខុ មិនសមបើត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយសោះ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

(៣៦៩) ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាអញ្ញនារហភិក្ខុទាំងឡាយត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ អញ្ញនារហ-ភិក្ខុទាំងឡាយមិនសមបើនឹងត្រេកអរអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះ-ថ្លាទេ ។បេ។ លុះទ្រង់បន្ទោសហើយ ទើបទ្រង់ធ្វើធម្មីកថាត្រាស់ហៅ

## បារិវាសិកក្ខន្ធកេ អព្ភានារហវត្តំ

ន ភិក្ខវេ អព្ភានារហេន ភិក្ខុនា សាទិតព្វំ បកតត្តានំ ភិក្ខូនំ អភិវាទនំ បច្ចុដ្ឋានំ ។បេ។ នហានេ បិដ្ឋិបរិកម្មំ យោ សាទិយេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ អព្ភានារហានំ ភិក្ខូនំ មិថុ យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ ។បេ។ នហានេ បិដ្ឋិបរិកម្មំ ។ អនុជានាមិ ភិក្ខវេ អព្ភានារហានំ ភិក្ខូនំ បញ្ច យថាវុឌ្ឍំ ឧបោសថំ បវារណំ វស្សិកសាដិកំ ឱណោជនំ ភត្តំ ។ តេនហិ ភិក្ខវេ អព្ភានារហានំ ភិក្ខូនំ វត្តំ បញ្ញាបេស្សាមិ យថា អព្ភានារហេហិ ភិក្ខូហិ វត្តិតព្វំ ។

[៣៧០] អព្ភានារហេន ភិក្ខវេ ភិក្ខុនា សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ ។បេ។ យថា មូលាយបដិកស្សនារហស្ស វត្តំ តថា មានត្តារហស្ស ច មានត្តចារិកស្ស ច អព្ភានារហស្ស ច តិណ្ណំ ឯកសទិសំ វេទិតព្វំ ។បេ។ ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វំ ។

ភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អព្ភានារហភិក្ខុមិនត្រូវត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយ ភិក្ខុឯណាត្រេកអរ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអភិវាទនកម្ម បច្ចុដ្ឋានកម្ម ។បេ។ ការដុសក្អែលខ្នងក្នុងវេលាងូតទឹកដល់អព្ភានារហភិក្ខុទាំងឡាយ តាមលំដាប់ចាស់ (ខ្ចី) ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបោសថ ១ បវារណា ១ ការទទួលសំពត់វស្សិកសាដក ១ ការលះបង់ភត្ត ១ ការទទួលភត្ត ១ ទាំង ៥ យ៉ាងដល់អព្ភានារហភិក្ខុទាំងឡាយ តាមលំដាប់ចាស់ (ខ្ចី) ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះតថាគតនឹងបញ្ញត្តវត្តដល់ពួកអព្ភានារហភិក្ខុ តាមទំនងដែលអព្ភានារហភិក្ខុទាំងឡាយត្រូវប្រព្រឹត្ត ។

[៣៧០] ម្នាលភិក្ខុទាំងឡាយ អព្ភានារហភិក្ខុត្រូវប្រព្រឹត្តវត្តដោយប្រពៃ ឯការប្រព្រឹត្តវត្តដោយប្រពៃក្នុងអព្ភាននោះដូច្នេះ គឺអព្ភានារហភិក្ខុមិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើ ។បេ។ វត្តរបស់មូលាយបដិកស្សនារហភិក្ខុដូចម្តេចមិញ វត្តរបស់មានត្តារហភិក្ខុ មានត្តចារិកភិក្ខុ អព្ភានារហភិក្ខុ ទាំង ៣ ពួកក៏មានសេចក្តីដូចគ្នាយ៉ាងនោះដែរ បណ្ឌិតគប្បីឲ្យពិស្តារចុះ ។បេ។ មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា ។

[៣៧១] ន ភិក្ខវេ អព្ភានារហេន ភិក្ខុនា បកតត្តស្ស ភិក្ខុនោ បុរតោ គន្តព្វំ ន បុរតោ និសីទិតព្វំ យោ ហោតិ សង្ឃស្ស អាសនបរិយន្តោ សេយ្យាបរិយន្តោ វិហារបរិយន្តោ សោ តស្ស បទាតព្វោ តេន ច សោ សាទិតព្វោ ។ ន ភិក្ខវេ អព្ភានារហេន ភិក្ខុនា បកតត្តេន ភិក្ខុនា បុរេសមណេន វា បច្ឆាសមណេន វា កុលានិ ឧបសង្កមិតព្វានិ ន អារញ្ញិកង្គំ សមាទិតព្វំ ន បិណ្ឌបាតិកង្គំ សមាទិតព្វំ ន ច តប្បច្ចយា បិណ្ឌបាតោ នីហរាបេតព្វោ មា មំ ជានឹសូតិ ។

[៣៧២] ន ភិក្ខវេ អព្ភានារហេន ភិក្ខុនា សភិក្ខុកា អាវាសា អភិក្ខុកោ អាវាសោ គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា ន ភិក្ខវេ អព្ភានារហេន ភិក្ខុនា សភិក្ខុកា អាវាសា អភិក្ខុកោ អនាវាសោ គន្តព្វោ អញ្ញត្រ បកតត្តេន អញ្ញត្រ អន្តរាយា យថា ហេដ្ឋា តថា វិត្ថារេតព្វំ ។បេ។ គន្តព្វោ ភិក្ខវេ អព្ភានារហេន ភិក្ខុនា សភិក្ខុកា អាវាសា

(៣៧១) ម្នាលភិក្ខុទាំងឡាយ អព្ភានារហភិក្ខុមិនត្រូវដើរមុន មិនត្រូវអង្គុយមុខភិក្ខុជាបកតត្តឡើយ ទីឱកាសឯណាដែលជាទីបំផុតនៃអាសន ជាទីបំផុតនៃទីដេក ជាទីបំផុតនៃវិហាររបស់សង្ឃ ៗ ត្រូវប្រគល់ឲ្យទីឱកាសនោះដល់ភិក្ខុនោះ ភិក្ខុនោះសោតក៏ត្រូវត្រេកអរនឹងទីឱកាសនោះដែរ ៗ ម្នាលភិក្ខុទាំងឡាយ អព្ភានារហភិក្ខុ(មិនត្រូវធ្វើ)ភិក្ខុជាបកតត្តឲ្យជាបុរេសមណ ឬបច្ឆាសមណ ចូលទៅកាន់ត្រកូលទាំងឡាយឡើយ អព្ភានារហភិក្ខុមិនត្រូវសមាទានអារញ្ញិកធុតង្គ មិនត្រូវសមាទានបិណ្ឌបាតិកធុតង្គ មួយវិញទៀតមិនត្រូវឲ្យគេនាំចង្ហាន់បិណ្ឌបាតមក (ដើម្បីខ្លួន) ព្រោះបច្ច័យនោះដោយគិតថា ជនទាំងឡាយកុំដឹង (រឿង) អាត្មាអញឡើយ ៗ

(៣៧២) ម្នាលភិក្ខុទាំងឡាយ អព្ភានារហភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកុតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ អព្ភានារហភិក្ខុមិនត្រូវចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ បណ្ឌិតគប្បីឲ្យពិស្តារតាមន័យដែលមានហើយខាងក្រោមចុះ ៗ បេ ៗ ម្នាលភិក្ខុទាំងឡាយ អព្ភានារហភិក្ខុគួរចេញចាកអាវាសដែលមានភិក្ខុ ៗ បេ ៗ

## បារិវាសិកក្ខន្ធកេ អព្ភានារហវត្តំ

។បេ។ អនាវាសា ។បេ។ អាវាសា វា អនាវាសា វា សភិក្ខុកោ អាវាសោ ។បេ។ សភិក្ខុកោ អនាវាសោ ។បេ។ សភិក្ខុកោ អាវាសោ វា អនាវាសោ វា យត្ថស្សុ ភិក្ខូ សមានសំវាសកា យំ ជញ្ញា សក្កោមិ អជ្ជេវ គន្តុន្តិ ។

(៣៧៣) ន ភិក្ខវេ អព្ភានារហេន ភិក្ខុនា បកតត្តេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អនាវាសេ វត្ថព្វំ ន ឯកច្ឆន្នេ អាវាសេ វា អនាវាសេ វា វត្ថព្វំ បកតត្តំ ភិក្ខុំ ទិស្វា អាសនា វុដ្ឋាតព្វំ បកតត្តោ ភិក្ខុ អាសនេន និមន្តេតព្វោ ន បកតត្តេន ភិក្ខុនា សទ្ធឹ ឯកាសនេ និសីទិតព្វំ ន នីចេ អាសនេ និសិន្នេ ឧច្ចេ អាសនេ និសីទិតព្វំ ន ឆមាយំ និសិន្នេ អាសនេ និសីទិតព្វំ ន ឯកចង្កមេ ចង្កមិតព្វំ ន នីចេ ចង្កមេ ចង្កមន្តេ ឧច្ចេ ចង្កមេ ចង្កមិតព្វំ ន ឆមាយំ ចង្កមន្តេ ចង្កមេ ចង្កមិតព្វំ ។

(៣៧៤) ន ភិក្ខវេ អព្ភានារហេន ភិក្ខុនា បារិវា-សិកេន ភិក្ខុនា សទ្ធឹ ។បេ។ មូលាយ បដិកស្សនា-

ចាកអនាវាស ។ បេ ។ ចាកអាវាសឬអនាវាស ទៅកាន់អាវាសដែលមានភិក្ខុ ។ បេ ។ ចាកអនាវាសដែលមានភិក្ខុ ។ បេ ។ ទៅកាន់អាវាសឬអនាវាសដែលមានភិក្ខុ គឺអាវាសឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ក្នុងថ្ងៃនេះបាន ។

(៣៧៣) ម្នាលភិក្ខុទាំងឡាយ អព្ភានារហភិក្ខុមិនត្រូវនៅក្នុងអាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាសឬអនាវាសដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុជាបកតត្ត ឃើញភិក្ខុជាបកតត្តហើយ ត្រូវក្រោកចាកអាសន ត្រូវនិមន្តភិក្ខុជាបកតត្តដោយអាសន មិនត្រូវអង្គុយលើអាសនមួយជាមួយនឹងភិក្ខុជាបកតត្ត កាលបើភិក្ខុជាបកតត្តអង្គុយលើអាសនទាប មិនត្រូវអង្គុយលើអាសនខ្ពស់ឡើយ កាលបើភិក្ខុជាបកតត្តអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសន មិនត្រូវបង្ក្រមលើទីបង្ក្រមជាមួយគ្នា កាលបើភិក្ខុជាបកតត្តបង្ក្រមលើទីបង្ក្រមទាប មិនត្រូវបង្ក្រមលើទីបង្ក្រមខ្ពស់ កាលបើភិក្ខុជាបកតត្តបង្ក្រមលើផែនដី មិនត្រូវបង្ក្រមលើទីបង្ក្រមឡើយ ។

(៣៧៤) ម្នាលភិក្ខុទាំងឡាយ អព្ភានារហភិក្ខុមិនត្រូវនៅជាមួយនឹងបារិវាសិកភិក្ខុ ។ បេ ។ ជាមួយនឹងមូលាយបដិកស្សនារហ-

រហេន ភិក្ខុនា សទ្ធឹ ។បេ។ មានត្តារហេន ភិក្ខុនា សទ្ធឹ ។បេ។ មានត្តចារិកេន ភិក្ខុនា សទ្ធឹ ។បេ។ អព្ភានារហេន វុឌ្ឍតរេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ អាកាសេ វត្ថព្វំ ន ឯកច្ឆន្នេ អនាកាសេ វត្ថព្វំ ន ឯកច្ឆន្នេ អាកាសេ វា អនាកាសេ វា វត្ថព្វំ ន ឯកាសនេ និសីទិតព្វំ ន នីចេ អាសនេ និសិន្នេ ឧច្ចេ អាសនេ និសីទិតព្វំ ន ឆមាយំ និសិន្នេ អាសនេ និសីទិតព្វំ ន ឯកចង្កមេ ចង្កមិតព្វំ ន នីចេ ចង្កមេ ចង្កមន្តេ ឧច្ចេ ចង្កមេ ចង្កមិតព្វំ ន ឆមាយំ ចង្កមន្តេ ចង្កមេ ចង្កមិតព្វំ ។

(៣៧៨) អព្ភានារហចតុត្ថោ ចេ ភិក្ខវេ បរិវាសំ ទទេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ទទេយ្យ តំវីសោ អព្ភេយ្យ អកម្មំ តំ ន ច ករណីយន្តិ ។

អព្ភានារហវត្តំ និដ្ឋិតំ ។

បារិវាសិកក្ខន្ធកំ និដ្ឋិតំ ទុតិយំ ។

ឥមស្មឹ ខន្ធកេ វត្ថូ បញ្ច ។

ភិក្ខុ ។ បេ ។ ជាមួយនឹងមានត្តារហភិក្ខុ ។ បេ ។ ជាមួយនឹងមានត្តចារិកភិក្ខុ ។ បេ ។ មិនត្រូវនៅក្នុងអាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាសដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាសឬអនាវាសដែលមានដម្បូលមួយជាមួយនឹងអព្ភានារហភិក្ខុដែលចាស់ជាងខ្លួន មិនត្រូវអង្គុយលើអាសនជាមួយគ្នា (កាលបើអព្ភានារហភិក្ខុដែលចាស់ជាងខ្លួន) អង្គុយលើអាសនទាប (អព្ភានារហភិក្ខុដែលខ្ចីជាង) មិនត្រូវអង្គុយលើអាសនខ្ពស់ កាលបើអព្ភានារហភិក្ខុអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសន មិនត្រូវបង្ក្រមលើទីបង្ក្រមជាមួយគ្នា កាលបើអព្ភានារហភិក្ខុបង្ក្រមលើទីបង្ក្រមទាប មិនត្រូវបង្ក្រមលើទីបង្ក្រមខ្ពស់ កាលបើអព្ភានារហភិក្ខុបង្ក្រមលើផែនដី មិនត្រូវបង្ក្រមលើទីបង្ក្រមឡើយ ។

(១៧៨) ម្នាលភិក្ខុទាំងឡាយ បើគណសង្ឃមានអព្ភានារហភិក្ខុជាគំរប់ ៤ ឲ្យបរិវាស ឲ្យមូលាយបដិកស្សនា ឲ្យមានត្ត គណសង្ឃមានអព្ភានារហភិក្ខុនោះជាគំរប់ ២០ ឲ្យអព្ភាន កម្មនោះមិនឡើងជាកម្មផង សង្ឃមិនត្រូវធ្វើផង ។

ចប់វត្តរបស់អព្ភានារហភិក្ខុ ។

ចប់បារិវាសិកក្ខន្ធក ជាគំរប់ ២ ។

ក្នុងខន្ធកនេះមាន ៥ រឿង ។

តស្សុក្ខានំ

(៣៧៦) បារិវាសិកា សាទិយន្តិ
បកតត្តានំ ភិក្ខូនំ(១)
អភិវាទនំ បច្ចុដ្ឋានំ
អញ្ជលិកម្មំ សាមីចិំ
អាសនំ(២) សេយ្យាភិហារំ
បាទោទកំ បាទបីឋំ
បាទកថលិកំ
បត្តចីវរបដិគ្គហណំ
នហានេ បិដ្ឋិបរិកម្មំ
ឧជ្ឈាយន្តិ បេសលា(៣) ។
ទុក្កដំ សាទិយន្តស្ស
មិថុ បញ្ច យថាវុឌ្ឍំ(៤)
ឧបោសថំ បវារណំ

---

១ ឱ. ម. បារិវាសិកា សាទេន្តិ បកតត្តេ ភិក្ខុនា ។ ២ ឱ. អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិសាមិយំ អាសនំ ។ ម. អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិសាមិចិយំ អាសនំ ' ៣ ឱ. ម. សេយ្យាភិហារំ បាទោទកំ បាទបីឋំ បាទកថលិកំ បត្តំ នហានេ បរិកម្មំ ឧជ្ឈាយន្តិ ច បេសលា ។ ៤ ឱ. ម. បញ្ច បុនាបរេ ។

## បារិវាសិកក្ខន្ធក ឧទ្ទានគាថា

ឧទ្ទាននៃបារិវាសិកក្ខន្ធកនោះ គឺ

(៣៧៦) បារិវាសិកភិក្ខុទាំងឡាយ តែងត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រនឹងចីវរ ការដុសក្អែលខ្នងក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយ ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ក៏ពោលទោស ៗ អាបត្តិទុក្កដមានដល់បារិវាសិកភិក្ខុដែលត្រេកអរ(នូវអភិវាទនកម្មជាដើមនោះ) ទ្រង់អនុញ្ញាតឧបោសថ ១ បវារណា ១

វស្សិកា ញ្ញាវណោជនំ

កត្តំ[១] សម្មា បវត្តនា

បកតត្តេន គច្ឆរេ[២]

យោ ច ហោតិ បរិយត្តោ

ន បុរេ បច្ឆា សមណេន[៣]

អរញ្ញំ បិណ្ឌនីហាកោ

អាគន្តុកោ ឧបោសថេ

បវារណា ច ទូតេន

គន្តព្វោ ច សកិច្ចកោ[៤]

ឯកច្ឆន្នេ ន វត្ថព្វំ

ន ធមាយំ និស្សដ្ឋិតេ[៥]

អាសនេ នីចេ ចង្កមេ

---

១ ឱ. ម. វស្សិកោណោជភោជនំ ។ ២ ឱ. ម. សម្មា ច វត្តនា តត្ថ បកតត្តស្ស គច្ឆនំ ។ ៣ ឱ. ម. យោ ច ហោតិ បរិយត្តោ បុរេ បច្ឆា តត្ថេវ ច ។ ៤ ឱ. ម បវារណា ច ទូតោ ច គន្តព្វញ្ញ សកិច្ចកេ ។ ៥ ឱ. ម. ឯកច្ឆន្នេ ច វុដ្ឋានំ តត្ថេវ ច និមន្តយេ ។

ការទទួលសំពត់វស្សិកសាដិក១ ការលះបង់ភត្ត១ ការទទួលភត្ត១ ទាំង៥យ៉ាងដល់គ្នានឹងគ្នាតាមលំដាប់ចាស់ខ្ចី ការប្រព្រឹត្តិវត្តដោយប្រពៃ (របស់ពួកបារិវាសិកភិក្ខុ) បារិវាសិកភិក្ខុទៅជាមួយនឹងបកតត្តភិក្ខុបាន ឱកាសឯណាដែលជាទីបំផុត (នៃសេនាសន បារិវាសិកភិក្ខុគួរត្រេកអរនឹងឱកាសជាទីបំផុតនៃសេនាសនទោះ)បាន បារិវាសិកភិក្ខុមិនត្រូវធ្វើបកតត្តភិក្ខុឲ្យជាបុរេសមណ ឬបច្ឆាសមណ មិនត្រូវសមាទានអារញ្ញិកធុតង្គ នឹងបិណ្ឌបាតិកធុតង្គ នឹងឲ្យនាំបិណ្ឌបាតមក ត្រូវប្រាប់វត្តដល់អាគន្តុកភិក្ខុ ត្រូវប្រាប់វត្តក្នុងថ្ងៃឧបោសថ ក្នុងថ្ងៃបវារណា (បើមានជម្ងឺ) នឹងប្រើបម្រើទៅប្រាប់ក៏បាន មួយទៀតបារិវាសិកភិក្ខុទៅកាន់អាវាសដែលមានភិក្ខុបាន មិនត្រូវនៅក្នុងអាវាស ឬអនាវាសដែលមានដម្បូលមួយ កាលបើភិក្ខុជាបកតត្តអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសន កាលបើភិក្ខុជាបកតត្តចង្ក្រមលើទីចង្ក្រមទាប ( មិនត្រូវចង្ក្រមលើទីចង្ក្រមខ្ពស់ )

## បារិវាសិកក្ខន្ធកេ ឧទ្ទានគាថា

ឆមាយំ ចង្កមេ ន ច(១)
វុឌ្ឍតរេន អកម្មំ
រត្តិច្ឆេទា(២) ច សោធនា
និក្ខិបនំ សមាទានំ
ញាតព្វំ បារិវាសិកា(៣)
មូលាយ មានត្តារហា
តថា មានត្តចារិកា
អព្ភានារហកា ចាបិ
សម្ពុទ្ធនយតោ បុន(៤) ។
បារិវាសិកានំ(៥) តយោ
ចតុ មានត្តចារិកេ
ន សមេន្តិ រត្តិច្ឆេទា(៦)
មានត្តេសុ ច ទិវាសិកំ(៧) ។
ទ្វេ កម្មា សទិសា សេសា
តយោ កម្មា សមានតាតិ(៨) ។

---

១ ឱ. ម. អាសនេ នីចចង្កមេ ឆមាយ ចង្កមេ ន ច ។ ២ ឱ. ម. រត្តិច្ឆេទោ ។ ៣ ឱ. ម. និក្ខិបនំ សមាទានំ វត្តំ ភ បារិវាសិកេ ។ ៤ ឱ. អព្ភានារហោ យោ ចាបិ សម្ពុទ្ធំ នយតោ បុន ។ ៥ ឱ. ម. បារិវាសិកេសុ ។ ៦ ឱ. ម. សមន្តិ រត្តិច្ឆេទេសុ ។ ៧ ឱ. ម. ទេវសិ ។ ៨ ឱ. ម. សមាសមាតិ ។

## បារិវាសិកក្ខន្ធក ឧទ្ទានគាថា

កាលបើភិក្ខុជាបកតត្តបង្ក្រីមលើផែនដី (មិនត្រូវបង្ក្រីម) លើទីបង្ក្រីមឡើយ មិនត្រូវនៅរួមនឹងបារិវាសិកភិក្ខុដែលចាស់ជាងខ្លួន កម្មដែលមានបារិវាសិកភិក្ខុជាគំរប់ ៤ មិនឡើងជាកម្ម ទ្រង់សំដែងការដាច់រាត្រីនឹងការដម្រះបរិវាស ទ្រង់អនុញ្ញាតការដាក់វត្តនឹងការសមាទានវត្តទាំងនេះ បារិវាសិកភិក្ខុត្រូវដឹងរាល់គ្នា សូម្បីមូលាយបដិកស្សនារហភិក្ខុ មានត្តារហភិក្ខុ មានត្តចារិកភិក្ខុ អព្ភានារហភិក្ខុ ក៏គប្បីដឹងតាមន័យដែលផ្សេង ៗ គ្នាយ៉ាងនេះចុះ ។ ការដាច់រាត្រីទាំងឡាយរបស់បា-រិវាសិកភិក្ខុមាន ៣ របស់មានត្តចារិកភិក្ខុមាន ៤ មិនស្មើគ្នាមួយទៀតភិក្ខុប្រព្រឹត្តមានត្ត ត្រូវប្រាប់វត្តសព្វថ្ងៃ ៗ ។ កម្មទាំងពីរជាកម្មប្រហែល ៗ គ្នា កម្មទាំង ៣ ដែលសេសសល់ក៏ស្មើគ្នា ៗ ។

# សមុច្ចយក្ខន្ធកំ

(៣៧៧) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧទាយិ ឯកំ អាបត្តឹ អាបន្នោ ហោតិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អប្បដិច្ឆន្នំ ។ សោ ភិក្ខូនំ អារោចេសិ អហំ អាវុសោ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អប្បដិច្ឆន្នំ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ តេ ភិក្ខូ[1] ភគវតោ ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ ឧទាយិស្ស ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ ទេតុ ។

(៣៧៨) ឯវញ្ច បន ភិក្ខវេ ទាតព្វំ ។ តេន ភិក្ខវេ ឧទាយិនា ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ

---

១ តេ ភិក្ខូតិ បទទ្វយំ ឱរោបិយរោមបោត្ថកេសុ ន ទិស្សតិ ។

# សមុច្ចយក្ខន្ធក

(៣៧៧) សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ វេលានោះឯង ឧទាយិដ៏មានអាយុត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ[១] តែមិនបានបិទបាំងទេ ។ ឧទាយិភិក្ខុនោះប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទេ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះនាំយកសេចក្តីនុះទៅក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះសង្ឃចូរឲ្យមានត្ត ៦ រាត្រីដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលមិនបានបិទបាំងទុក ។

(៣៧៨) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះចូលទៅរកសង្ឃហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើងហើយពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ

---

១ អាបត្តិប្រកបដោយចិត្តក្លែង ហៅថា សញ្ចេតនិក ការញុំាងទឹកសុក្កឲ្យឃ្លាតចេញ ហៅថា សុក្កវិសដ្ឋិ ។

អប្បដិច្ឆន្នំ សោហំ ភន្តេ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចាមិ ។ អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អប្បដិច្ឆន្នំ ទុតិយម្បិ សោហំ ភន្តេ[១] សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចាមិ ។ អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អប្បដិច្ឆន្នំ តតិយម្បិ សោហំ ភន្តេ[២] សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចាមីតិ ។

[៣៧៩] ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧទាយិ ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អប្បដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧទាយិស្ស

១ ឱ. ទុតិយម្បិ ភន្តេ ។ ម. សោហំ ទុតិយម្បិ ភន្តេ ។ ២ ឱ. តតិយម្បិ ភន្តេ ។ ម. សោហំ តតិយម្បិ ភន្តេ ។

## សមុច្ចយក្ខន្ធក ការឲ្យមានត្ត

បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះមកសូមមានត្ត ៦ រាត្រីនឹងសង្ឃ ចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះមកសូមមានត្ត៦រាត្រីនឹងសង្ឃជាគំរប់ពីរដងទៀត ចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលមិនបានបិទបាំងទុក ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះមកសូមមានត្ត ៦ រាត្រីនឹងសង្ឃ ចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក ។

(៣៧៩) ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ឧទាយិភិក្ខុនោះមកសូមមានត្ត៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគួរឲ្យ

អព្ភានកម្មរបស់ឧទាយិភិក្ខុគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង ។បេ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង ។បេ។ ឧទាយិភិក្ខុសង្ឃបានធ្វើអព្ភានកម្មរួចហើយ អព្ភានកម្មនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំរឿងនេះទុកដោយអាការស្ងៀមយ៉ាងនេះ ។

(៤១៥) សម័យនោះឯង ឧទាយិដ៏មានអាយុត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ (កន្លះខែ) ។ ឧទាយិភិក្ខុនោះបានប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច ។ ពួកភិក្ខុនោះក៏នាំយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះចូរសង្ឃឲ្យបក្ខបរិវាស (បរិវាសកន្លះខែ) ដល់ឧទាយិភិក្ខុចំពោះអាបត្តិមួយឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ។

[៤១៦] ឯវញ្ច បន ភិក្ខវេ ទាតព្ពោ ។ តេន ភិក្ខវេ ឧទាយិនា ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ សោហំ ភន្តេ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្ពោ តតិយម្បិ យាចិតព្ពោ ។

[៤១៧] ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្ពោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧទាយី ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ

(៤១៦) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវខាយភិក្ខុនោះចូលទៅរកសង្ឃហើយធ្វើខត្តរាសង្គចៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះសូមបក្ខបរិវាសនឹងសង្ឃចំពោះអាបត្តិ១ឈ្មោះសញ្ចេតនិក-សុក្កវិសដ្ឋិដែលបិទបាំងទុក១បក្ខ ។ ត្រូវខាយភិក្ខុនោះសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង ។

(៤១៧) ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតខាយភិក្ខុនេះត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ ខាយភិក្ខុនោះមកសូមបក្ខបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បី

សង្ឃោ ឧទាយិស្ស ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧទាយិ ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ យាចតិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ ទេតិ ។ យស្សាយស្មតោ ខមតិ ឧទាយិស្ស ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ ទិន្នោ សង្ឃេន ឧទាយិស្ស ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ

ឲ្យបក្ខបរិវាសដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ១ បក្ខចុះ ។ នេះជាពាក្យផ្តៀងសង្ឃ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិហើយបិទបាំងទុក ១ បក្ខ ឧទាយិភិក្ខុនោះមកសូមបក្ខបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ១ បក្ខ ។ សង្ឃក៏ឲ្យបក្ខបរិវាសដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ១ បក្ខ ។ ការឲ្យបក្ខបរិវាសដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ១ បក្ខ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង ។ បេ ។ សង្ឃបានឲ្យបក្ខបរិវាសដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ឈ្មោះ

សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសោ ខមតិ
សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៦១៨) សោ បរិវសន្តោ អន្តរា ឯកំ អាបត្តឹ
អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ ។
សោ ភិក្ខូនំ អារោចេសិ អហំ អាវុសោ ឯកំ អាបត្តឹ
អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ
សោហំ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ
សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ យាចឹ
តស្ស មេ សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ
សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ អទាសិ
សោហំ បរិវសន្តោ អន្តរា ឯកំ អាបត្តឹ អាបជ្ជឹ
សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ កថំ នុ ខោ
មយា បដិបជ្ជិតព្ពន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោ-
ចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ ឧទាយឹ ភិក្ខុំ
អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិ-
សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិ-
ត្វា បុរិមាយ អាបត្តិយា សមោធានបរិវាសំ ទេតុ ។

សញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខហើយ ការឲ្យបក្ខបរិវាសនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំសេចក្តីនេះទុកដោយអាការស្ងៀមយ៉ាងនេះ ។

(៤១៨) ឧទាយិភិក្ខុនោះកំពុងនៅបរិវាស ក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ ។ ឧទាយិភិក្ខុនោះបានប្រាប់ដល់ពួកភិក្ខុថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ ខ្ញុំនោះសូមបក្ខបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ សង្ឃឲ្យបក្ខបរិវាសដល់ខ្ញុំនោះចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ខ្ញុំនោះកំពុងនៅបរិវាសក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច ។ ភិក្ខុទាំងនោះក៏នាំយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះចូរសង្ឃទាញឧទាយិភិក្ខុមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ហើយសឹមឲ្យសមោធានបរិវាស (បរិវាសដែលប្រជុំអាបត្តិ) ចំពោះអាបត្តិខាងដើមចុះ ។

(៤១៩) ឯវញ្ច បន ភិក្ខវេ មូលាយ បដិកស្សិតព្វោ ។ តេន ភិក្ខវេ ឧទាយិនា ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បក្ខប្បដិច្ឆន្នំ សោហំ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ យាចឹ តស្ស មេ សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ អទាសិ សោហំ បរិវសន្តោ អន្តរា ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ សោហំ ភន្តេ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។

## សមុច្ចយក្ខន្ធក ការសូមមូលាយបដិកស្សនា

(៤១៩) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញឧទាយិភិក្ខុមកដាក់ក្នុងមូលាបត្តិយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើងពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក ១ បក្ខ ខ្ញុំនោះសូមបក្ខបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ សង្ឃឲ្យបក្ខបរិវាសដល់ខ្ញុំនោះចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក១បក្ខ ខ្ញុំនោះកំពុងនៅបរិវាសក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក ៥ ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើនខ្ញុំនោះសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ។ ត្រូវឧទាយិភិក្ខុសូមជាគំរប់ពីរដងផង សូមជាគំរប់បីដងផង ។

(៤២០) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ
ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧទាយិ
ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ
បក្ខប្បដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេ-
តនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ
យាចិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ ឯកិស្សា
អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្ប-
ដិច្ឆន្នាយ បក្ខបរិវាសំ អទាសិ ។ សោ បរិវសន្តោ អន្តរា
ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចា-
ហប្បដិច្ឆន្នំ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា
សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ
មូលាយ បដិកស្សនំ យាចតិ ។ យទិ សង្ឃស្ស
បត្តកល្លំ សង្ឃោ ឧទាយឹ ភិក្ខុំ អន្តរា ឯកិស្សា
អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្ប-
ដិច្ឆន្នាយ មូលាយ បដិកស្សេយ្យ ។ ឯសា ញត្តិ ។
សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧទាយិ ភិក្ខុ ឯកំ
អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ

(៤២០) ភិក្ខុអ្នកឆ្លាសប្រតិពលត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ ឧទាយិភិក្ខុនោះបានសូមបក្ខបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ។ សង្ឃក៏បានឲ្យបក្ខបរិវាសដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ។ ឧទាយិភិក្ខុនោះកំពុងនៅបរិវាស ក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៤ ថ្ងៃ ឧទាយិភិក្ខុនោះសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៤ ថ្ងៃ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីទាញឧទាយិភិក្ខុមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៤ ថ្ងៃ ។ នេះជាពាក្យផ្ទៀងសង្ឃ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ

សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ យាចិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ អទាសិ ។ សោ បរិវសន្តោ អន្តរា ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ យាចតិ ។ សង្ឃោ ឧទាយឹ ភិក្ខុំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សតិ ។ យស្សាយស្មតោ ខមតិ ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនា សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ បដិកស្សិតោ សង្ឃេន ឧទាយិ ភិក្ខុ អន្តរា ឯកិស្សា អាបត្តិយា

## សមុច្ចយក្ខន្ធក មូលាយបដិកស្សនា

ឧទាយិភិក្ខុនោះបានសូមបក្ខបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ។ សង្ឃក៏បានឲ្យបក្ខបរិវាសដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ។ ឧទាយិភិក្ខុនោះកំពុងនៅបរិវាស ក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក ៥ ថ្ងៃ ឥឡូវ ឧទាយិភិក្ខុនោះសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ ។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ។ ការទាញឧទាយិភិក្ខុមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង ។ បេ ។ សង្ឃបានទាញឧទាយិភិក្ខុមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ

សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤២១) ឯវញ្ច បន ភិក្ខវេ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។ តេន ភិក្ខវេ ឧទាយិនា ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ សោហំ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ យាចឹ តស្ស មេ សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ អទាសិ សោហំ បរិវសន្តោ អន្តរា ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ សោហំ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ

ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃហើយ ការទាញនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំសេចក្តីនេះទុកដោយអាការស្ងៀមយ៉ាងនេះ ។

[៤២១] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសមោធានបរិវាស ចំពោះអាបត្តិមុនយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឲ្យភិក្ខុនោះចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក ១ បក្ខ ខ្ញុំនោះសូមបក្ខបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ សង្ឃឲ្យបក្ខបរិវាសដល់ខ្ញុំនោះចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ខ្ញុំនោះកំពុងនៅបរិវាស ក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ ខ្ញុំនោះសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិក-

យាចិ តំ មំ សង្ឃោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេ-
តនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ
បដិកស្សិ សោហំ ភន្តេ សង្ឃំ អន្តរា ឯកិស្សា
អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហ-
ប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ
យាចាមីតិ ។ ទុតិយម្បិ យាចិតព្វោ តតិយម្បិ
យាចិតព្វោ ។

(៤២២) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ
ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧទាយិ
ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ
បក្ខប្បដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេ-
តនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ
យាចិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ ឯកិស្សា
អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិ-
ច្ឆន្នាយ បក្ខបរិវាសំ អទាសិ ។ សោ បរិវសន្តោ
អន្តរា ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ

សុក្កវិសដ្ឋិដែលបិទបាំងទុក ៤ ថ្ងៃ សង្ឃទាញខ្ញុំនោះមកដាក់ក្នុងមូលា-
បត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំង
ទុក ៤ ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះមកសូមសមោធានបរិវាសនឹង
សង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំង
ទុក ៤ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។ ឧទាយិភិក្ខុគប្បីសូមជាគំរប់ពីរ
ដងផង គប្បីសូមជាគំរប់បីដងផង ។

(៤២២) ភិក្ខុអ្នកឆ្លាសប្រតិពលគប្បីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃ
ដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះត្រូវអាបត្តិ ១ ឈ្មោះ
សញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ ឧទាយិភិក្ខុនោះបានសូម
បក្ខបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែល
បិទបាំងទុក ១ បក្ខ ។ សង្ឃក៏បានឲ្យបក្ខបរិវាសដល់ឧទាយិភិក្ខុចំពោះ
អាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ។ ឧទា-
យិភិក្ខុនោះកំពុងនៅបរិវាសក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិក-

បញ្ចាហប្បដិច្ឆន្នំ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ យាចិ ។ សង្ឃោ ឧទាយឹ ភិក្ខុំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិ-សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិ ។ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧទាយិ ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេ-តនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បញ្ចាហបរិវាសំ យាចិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ ឯកិស្សា

សុក្កវិសដ្ឋិ ហើយបិទបាំងទុក ៥ ថ្ងៃ ឧទាយិភិក្ខុនោះបានសូមការទាញមក ដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិក-សុក្កវិសដ្ឋិ ដែលបិទបាំងទុក ៥ ថ្ងៃ ។ សង្ឃក៏បានទាញឧទាយិភិក្ខុមក ដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក ៥ ថ្ងៃ ។ ឧទាយិភិក្ខុនោះមកសូមសមោធានបរិវាសនឹង សង្ឃ ចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទ បាំងទុក ៥ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។ បើកម្មមានកាលគួរដល់សង្ឃ ហើយ សង្ឃគប្បីឲ្យសមោធានបរិវាសដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ ១ ក្នុង ចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ នឹងចំពោះ អាបត្តិខាងដើម ។ នេះជាពាក្យផ្តៀងសង្ឃ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិក-សុក្កវិសដ្ឋិ ហើយបិទបាំងទុក ១ បក្ខ ឧទាយិភិក្ខុនោះបានសូមបក្ខបរិវាស នឹងសង្ឃ ចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំង ទុក ១ បក្ខ ។ សង្ឃក៏បានឲ្យបក្ខបរិវាសដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ ១

អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ អទាសិ ។ សោ បរិវសន្តោ អន្តរា ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ យាចិ ។ សង្ឃោ ឧទាយឹ ភិក្ខុំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិ ។ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ យាចតិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ ទេតិ ។ យស្សាយស្មតោ ខមតិ ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសស្ស ទានំ

ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ។ ឧទាយិភិក្ខុនោះកំពុងនៅបរិវាសក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ ឧទាយិភិក្ខុនោះបានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ ។ សង្ឃក៏បានទាញឧទាយិភិក្ខុមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ។ ឧទាយិភិក្ខុនោះមកសូមសមោធានបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃនឹងចំពោះអាបត្តិខាងដើម ។ សង្ឃក៏បានឲ្យសមោធានបរិវាស ដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។ ការឲ្យសមោធានបរិវាសដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម គាប់ចិត្តដល់លោក

សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ ទិន្នា សង្ឃេន ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធា-នបរិវាសោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៦២៣) សោ បរិវុត្ថបរិវាសោ មានត្តារហោ អន្តរា ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហ-ប្បដិច្ឆន្នំ ។ សោ ភិក្ខូនំ អារោចេសិ អហំ អាវុសោ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ ។ បេ ។ សោហំ បរិវុត្ថបរិវាសោ មានត្តារហោ អន្តរា ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្ប-ដិច្ឆន្នំ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ

ដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង ។ បេ ។ សង្ឃបានឲ្យសមោធានបរិវាសដល់ឧទាយិ-ភិក្ខុចំពោះអាបត្តិ ១ កងនោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ការឲ្យនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំសេចក្តីនេះទុកដោយអាការស្ងៀមយ៉ាងនេះ ។

(៤២៣) ឧទាយិភិក្ខុនោះបាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ ១ កងនោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ ។ ឧទាយិភិក្ខុនោះបានប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិហើយបិទបាំងទុក ១ បក្ខ ។ បេ ។ ខ្ញុំនោះនៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ ១ កងនោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច ។ ភិក្ខុទាំងនោះក៏នាំយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃទាញ

ឧទាយឹ ភិក្ខុំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិត្វា បុរិមាយ អាបត្តិយា សមោធានបរិវាសំ ទេតុ ។

(៤២៤) ឯវញ្ច បន ភិក្ខវេ មូលាយ បដិកស្សិតព្វោ ។ បេ ។

(៤២៥) ឯវញ្ច បន ភិក្ខវេ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។ បេ ។ ទេតិ ។ បេ ។ ទិន្នោ សង្ឃេន ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤២៦) សោ បរិវុត្ថបរិវាសោ ភិក្ខូនំ អារោចេសិ អហំ អាវុសោ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ ។ បេ ។ សោហំ បរិវុត្ថបរិវាសោ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ ឧទាយិស្ស ភិក្ខុនោ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ ទេតុ ។

ឧទាយិភិក្ខុមកដាក់កន្លងមូលាបត្តិចំពោះអាបត្តិ ១ កន្លងនោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ហើយសឹមឲ្យសមោធានបរិវាសចំពោះអាបត្តិខាងដើមចុះ ។

(៤៦៤) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញមកដាក់កន្លងមូលាបត្តិយ៉ាងនេះ ។ បេ ។

(៤៦៥) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសមោធានបរិវាសចំពោះអាបត្តិខាងដើមយ៉ាងនេះ ។ បេ ។ សង្ឃឲ្យ ។ បេ ។ សង្ឃបានឲ្យសមោធានបរិវាសដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ កន្លងនោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ការឲ្យសមោធានបរិវាសនោះគាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំសេចក្តីនេះទុកដោយអាការស្ងៀមយ៉ាងនេះ ។

(៤៦៦) ឧទាយិភិក្ខុនោះបាននៅបរិវាសរួចហើយ ក៏ប្រាប់ដល់ពួកភិក្ខុថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ។ បេ ។ ខ្ញុំបាននៅបរិវាសរួចហើយ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៀត ។ ភិក្ខុទាំងនោះក៏នាំយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះចូរសង្ឃឲ្យមានត្ត៦រាត្រីដល់ឧទាយិភិក្ខុចំពោះអាបត្តិទាំង ៣ចុះ ។

(៤២៧) ឯវញ្ច បន ភិក្ខវេ ទាតព្វំ ។ តេន ភិក្ខវេ ឧទាយិនា ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ ។ បេ ។ សោហំ ភន្តេ បរិវុត្ថបរិវាសោ សង្ឃំ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វំ តតិយម្បិ យាចិតព្វំ ។

(៤២៨) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧទាយិ ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ ។ បេ ។ បរិវុត្ថបរិវាសោ សង្ឃំ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧទាយិស្ស ភិក្ខុនោ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧទាយិ ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ ។ បេ ។

(៤២៧) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាងថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើងពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ ។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះបាននៅបរិវាសរួចហើយ ឥឡូវមកសូមមានត្ត ៦ រាត្រីនឹងសង្ឃចំពោះអាបត្តិទាំង ៣ ។ ឧទាយិភិក្ខុនោះត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង ។

(៤២៨) ភិក្ខុអ្នកឆ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ ។បេ។ ឧទាយិភិក្ខុនោះបាននៅបរិវាសរួចហើយ ឥឡូវមកសូមមានត្ត ៦ រាត្រីនឹងសង្ឃចំពោះអាបត្តិទាំង ៣ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវឲ្យមានត្ត ៦ រាត្រីដល់ឧទាយិភិក្ខុចំពោះអាបត្តិទាំង៣ចុះ ។ នេះជាពាក្យផ្តៀងសង្ឃ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ ។បេ។

សោ បរិវុត្ថបរិវាសោ សង្ឃំ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ យាចតិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ ទេតិ ។ យស្សាយស្មតោ ខមតិ ឧទាយិស្ស ភិក្ខុនោ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ ទិន្នំ សង្ឃេន ឧទាយិស្ស ភិក្ខុនោ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤២៩) សោ មានត្តំ ចរន្តោ អន្តរា ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ ។ សោ ភិក្ខូនំ អារោចេសិ អហំ អាវុសោ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បក្ខប្បដិច្ឆន្នំ ។ បេ ។ សោហំ មានត្តំ ចរន្តោ អន្តរា ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ តេ ភិក្ខូ ភគវតោ

ឧទាយិភិក្ខុនោះបាននៅបរិវាសរួចហើយ មកសូមមានត្ត ៦ រាត្រីនឹងសង្ឃ ចំពោះអាបត្តិទាំង ៣ ។ សង្ឃក៏ឲ្យមានត្ត ៦ រាត្រីដល់ឧទាយិភិក្ខុចំពោះ អាបត្តិទាំង ៣ ។ ការឲ្យមានត្ត ៦ រាត្រីដល់ឧទាយិភិក្ខុចំពោះអាបត្តិទាំង ៣ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បី ស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុ អង្គនោះគប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង ។ បេ ។ សង្ឃបានឲ្យមានត្ត ៦ រាត្រី ដល់ឧទាយិភិក្ខុចំពោះអាបត្តិទាំង ៣ ហើយ ការឲ្យមានត្តនោះគាប់ចិត្តដល់ សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ ។

(៤៦៩) ឧទាយិភិក្ខុនោះកំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ ១ ក្នុង ចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ហើយបិទបាំងទុក ៥ ថ្ងៃ ។ ឧទាយិភិក្ខុ នោះបានប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះ សញ្ចេតនិកសុក្កវិស្សដ្ឋិ ហើយបិទបាំងទុក ១ បក្ខ ។ បេ ។ ខ្ញុំនោះកំពុងប្រ- ព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ហើយ បិទបាំងទុក ៥ ថ្ងៃ តើខ្ញុំត្រូវប្រព្រឹត្តដូចម្តេច ។ ភិក្ខុទាំងនោះក៏នាំយក

ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ ឧទាយិំ ភិក្ខុំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិត្វា បុរិមាយ អាបត្តិយា សមោធានបរិវាសំ ទត្វា ឆារត្តំ មានត្តំ ទេតុ ។

(៤៣០) ឯវញ្ច បន ភិក្ខវេ មូលាយ បដិកស្សិតព្វោ ។ បេ ។

(៤៣១) ឯវញ្ច បន ភិក្ខវេ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។ បេ ។

(៤៣២) ឯវញ្ច បន ភិក្ខវេ ឆារត្តំ មានត្តំ ទាតព្វំ ។ បេ ។ ទេតិ ។ បេ ។ ទិន្នំ សង្ឃេន ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤៣៣) សោ ចិណ្ណមានត្តោ អព្ភានារហោ អន្តរា ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ ។ សោ ភិក្ខូនំ អារោចេសិ អហំ អាវុសោ

សេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះចូរសង្ឃទាញឧទាយិភិក្ខុមកដាក់ក្នុងមូលា-បត្តិចំពោះអាបត្តិ ១ គ្នុងបន្ទោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ហើយឲ្យសមោធានបរិវាសចំពោះអាបត្តិខាងដើម ហើយសិមឲ្យមានត្ត ៦ រាត្រីចុះ ។

(៤៣០) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញមកដាក់ក្នុងមូលា-បត្តិយ៉ាងនេះ ។ បេ ។

(៤៣១) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសមោធានបរិវាសចំពោះអាបត្តិខាងដើមយ៉ាងនេះ ។ បេ ។

(៤៣២) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យមានត្ត ៦ រាត្រីយ៉ាងនេះ ។ បេ ។ សង្ឃឲ្យ ។ បេ ។ សង្ឃបានឲ្យមានត្ត ៦ រាត្រីដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ គ្នុងបន្ទោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ការឲ្យមានត្តនោះគាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំរឿងនេះទុកដោយអាការស្ងៀមយ៉ាងនេះ ។

(៤៣៣) ឧទាយិភិក្ខុនោះបានសន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ ១ គ្នុងបន្ទោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ ។ ឧទាយិភិក្ខុនោះបានប្រាប់ដល់ភិក្ខុទាំងឡាយថា

ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បក្ខប្បដិច្ឆន្នំ ។ បេ ។ សោហំ ចិណ្ណមានត្តោ អព្ភានារហោ អន្តរា ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ កថំ នុខោ មយា បដិបជ្ជិតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ ឧទាយឹ ភិក្ខុំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិត្វា បុរិមាយ អាបត្តិយា សមោធានបរិវាសំ ទេតុ ឆារត្តំ មានត្តំ ទេតុ ។

(៤៣៤) ឯវញ្ច បន ភិក្ខវេ មូលាយ បដិកស្សិតព្វោ ។ បេ ។

(៤៣៥) ឯវញ្ច បន ភិក្ខវេ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។ បេ ។

(៤៣៦) ឯវញ្ច បន ភិក្ខវេ ឆារត្តំ មានត្តំ ទាតព្វំ ។ បេ ។ ទេតិ ។ បេ ។ ទិន្នំ សង្ឃេន ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ

## សមុច្ចយក្ខន្ធក មូលាយបដិកស្សនា

ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក ១ បក្ខ ។ បេ ។ ខ្ញុំនោះសន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក ៥ ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច ។ ភិក្ខុទាំងនោះក៏នាំយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃទាញ ុ ទាយភិក្ខុមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ហើយឲ្យសមោធានបរិវាសចំពោះអាបត្តិខាងដើម ហើយសឹមឲ្យមានត្ត ៦ រាត្រីចុះ ។

(៤៣៤) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញមកដាក់ក្នុងមូលាបត្តិយ៉ាងនេះ ។ បេ ។

(៤៣៥) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសមោធានបរិវាសចំពោះអាបត្តិខាងដើមយ៉ាងនេះ ។ បេ ។

(៤៣៦) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យមានត្ត ៦ រាត្រីយ៉ាងនេះ ។ បេ ។ ឲ្យ ។ បេ ។ សង្ឃក៏បានឲ្យមានត្ត ៦ រាត្រីដល់ ុ ទាយភិក្ខុចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ

សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៥៣៧) សោ ចិណ្ណមានត្តោ ភិក្ខូនំ អារោចេសិ អហំ អាវុសោ ឯកំ អាបជ្ជឹ អាបត្តឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ ។បេ។ សោហំ ចិណ្ណមា-នត្តោ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ ឧទាយឹ ភិក្ខុំ អព្ភេតុ ។

(៥៣៨) ឯវញ្ច បន ភិក្ខវេ អព្ភេតព្វោ ។ តេន ភិក្ខវេ ឧទាយិនា ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេ-តនិកំ សុក្កវិសដ្ឋឹ បក្ខប្បដិច្ឆន្នំ សោហំ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ យាចឹ តស្ស មេ

ការឲ្យមានត្តនោះគាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំសេចក្តីនេះទុកដោយអាការស្ងៀមយ៉ាងនេះ ។

(៤៣៧) ឧទាយិភិក្ខុនោះបានសន្សំមានត្តរួចហើយ ក៏ប្រាប់ដល់ពួកភិក្ខុថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក ១ បក្ខ ។ បេ ។ ខ្ញុំនោះសន្សំមានត្តរួចហើយ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៀត ។ ភិក្ខុទាំងនោះក៏នាំយកសេចក្តីនុះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃធ្វើអព្ភានកម្មដល់ឧទាយិភិក្ខុចុះ ។

(៤៣៨) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យអព្ភានកម្មយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើងពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក ១ បក្ខ ខ្ញុំនោះសូមបក្ខបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំង

## សមុច្ចយក្ខន្ធកេ អត្ថយោជនា

សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ អទាសិ សោហំ បរិវសន្តោ អន្តរា ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ សោហំ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ យាចឹ តំ មំ សង្ឃោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិ សោហំ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ យាចឹ តស្ស មេ សង្ឃោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ អទាសិ សោហំ បរិវុត្ថបរិវាសោ មានត្តារហោ អន្តរា ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ សោហំ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេត-

## សមុច្ចយក្ខន្ធក ការសូមអព្ភានកម្ម

ទុក ១ បក្ខ សង្ឃក៏បានឲ្យបក្ខបរិវាសដល់ខ្ញុំនោះចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក១បក្ខ ខ្ញុំនោះកំពុងនៅបរិវាសក៏ត្រូវអាបត្តិ១ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ ខ្ញុំនោះបានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ សង្ឃក៏បានទាញខ្ញុំនោះមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ខ្ញុំនោះបានសូមសមោធានបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម សង្ឃក៏បានឲ្យសមោធានបរិវាសដល់ខ្ញុំនោះចំពោះអាបត្តិ១ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ខ្ញុំនោះបាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ ខ្ញុំនោះបានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិក-

និកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ យាចឹ តំ មំ សង្ឃោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិ សោហំ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ យាចឹ តស្ស មេ សង្ឃោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ អទាសិ សោហំ បរិវុត្ថបរិវាសោ សង្ឃំ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ យាចឹ តស្ស មេ សង្ឃោ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ អទាសិ សោហំ មានត្តំ ចរន្តោ អន្តរា ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ សោហំ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ យាចឹ

សុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ សង្ឃបានទាញខ្ញុំនោះមកដាក់ក្នុងមូលា-បត្តិចំពោះអាបត្តិ១ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះបានសូមសមោធានបរិវាសនឹងសង្ឃចំពោះអាបត្តិ១ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ នឹងចំពោះអាបត្តិ ១ ខាងដើម សង្ឃក៏បានឲ្យសមោធានបរិវាសដល់ខ្ញុំនោះចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ខ្ញុំនោះបាននៅបរិវាសរួចហើយ ក៏សូមមានត្ត ៦ រាត្រីនឹងសង្ឃទៀតចំពោះអាបត្តិទាំង ៣ ខ្ញុំនោះកំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ ខ្ញុំនោះបានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ

តំ មំ សង្ឃោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិ-
កាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ
បដិកស្សិ សោហំ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា
សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ
បុរិមាយ អាបត្តិយា សមោធានបរិវាសំ យាចិំ តស្ស មេ
សង្ឃោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ
សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិ-
យា សមោធានបរិវាសំ អទាសិ សោហំ បរិវុត្ថបរិវា-
សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេ-
តនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ ឆារត្តំ
មានត្តំ យាចិំ តស្ស មេ សង្ឃោ អន្តរា ឯកិស្សា
អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចា-
ហប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ អទាសិ សោហំ
ចិណ្ណមានត្តោ អព្ភានារហោ អន្តរា ឯកំ អាបត្តឹ
អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ
សោហំ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិ-
កាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ

សមុច្ចយក្ខន្ធក ការសូមអព្ភានកម្ម

សង្ឃបានទាញខ្ញុំនោះមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះបានសូមសមោធានបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ទឹងចំពោះអាបត្តិខាងដើម សង្ឃក៏បានឲ្យសមោធានបរិវាសដល់ខ្ញុំចំពោះអាបត្តិ១ក្នុងចន្លោះឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ ទឹងចំពោះអាបត្តិខាងដើម ខ្ញុំនោះនៅបរិវាសរួចហើយ បានសូមមានត្ត ៦ រាត្រីនឹងសង្ឃទៀត ចំពោះអាបត្តិ១ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ សង្ឃបានឲ្យមានត្ត ៦ រាត្រីដល់ខ្ញុំនោះចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ខ្ញុំបានសន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ ខ្ញុំនោះបានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ

បដិកស្សនំ យាចឹ តំ មំ សង្ឃោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិ សោហំ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ យាចឹ តស្ស មេ សង្ឃោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ អទាសិ សោហំ បរិវុត្ថបរិវាសោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចឹ តស្ស មេ សង្ឃោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ អទាសិ សោហំ ភន្តេ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វំ តតិយម្បិ យាចិតព្វំ ។

សង្ឃបានទាញខ្ញុំនោះមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះបានសូមសមោធានបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ នឹងចំពោះអាបត្តិខាងដើម សង្ឃបានឲ្យសមោធានបរិវាសដល់ខ្ញុំនោះចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ខ្ញុំនោះបាននៅបរិវាសរួចហើយបានសូមមានត្ត ៦ រាត្រីនឹងសង្ឃទៀតចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ សង្ឃបានឲ្យមានត្ត៦រាត្រីដល់ខ្ញុំនោះចំពោះអាបត្តិ១ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះបានសន្សំមានត្តរួចហើយ ឥឡូវមកសូមអព្ភានកម្មនឹងសង្ឃ ។ ទុតិយភិក្ខុត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង ។

## សមុច្ចយក្ខន្ធកេ អដ្ឋកំ

(៦៣៩) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឧទាយិ ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បក្ខប្បដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ យាចិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បក្ខប្បដិច្ឆន្នាយ បក្ខបរិវាសំ អទាសិ ។ សោ បរិវសន្តោ អន្តរា ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ យាចិ ។ សង្ឃោ ឧទាយឹ ភិក្ខុំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិ ។ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ យាចិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ

(៤៣៩) ភិក្ខុអ្នកឆ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ១ បក្ខ ឧទាយិភិក្ខុនោះបានសូមបក្ខបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ៗ សង្ឃក៏បានឲ្យបក្ខបរិវាសដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ១ បក្ខ ៗ ឧទាយិភិក្ខុនោះកំពុងនៅបរិវាស ក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ ឧទាយិភិក្ខុនោះបានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ៗ សង្ឃក៏បានទាញឧទាយិភិក្ខុមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ៗ ឧទាយិភិក្ខុនោះបានសូមសមោធានបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក ៥ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ៗ សង្ឃក៏បានឲ្យសមោធាន.

អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ អទាសិ ។ សោ បរិវុត្ថបរិវាសោ មានត្តារហោ អន្តរា ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ ។ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ យាចិ ។ សង្ឃោ ឧទាយឹ ភិក្ខុំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិ ។ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ យាចិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ អទាសិ ។ សោ

បរិវាសដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ក្តីនោះ ឈ្មោះសញ្ចេតនិកសុក្កវិ-
សដ្ឋិដែលបិទបាំងទុក៥ថ្ងៃនឹងចំពោះអាបត្តិខាងដើម ។ ឧទាយិភិក្ខុនោះបាន
នៅបរិវាសរួចហើយ គួរដល់មានត្តក៏ត្រូវអាបត្តិ ១ ក្តីនោះ ឈ្មោះសញ្ចេ-
តនិកសុក្កវិសដ្ឋិហើយបិទបាំងទុក ៥ ថ្ងៃ ។ ឧទាយិភិក្ខុនោះបានសូមការទាញ
មកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្តីនោះ ឈ្មោះសញ្ចេត-
និកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ។ សង្ឃក៏ទាញឧទាយិភិក្ខុមកដាក់
ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្តីនោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែល
បិទបាំងទុក ៥ ថ្ងៃ ។ ឧទាយិភិក្ខុនោះបានសូមសមោធានបរិវាសនឹងសង្ឃ
ចំពោះអាបត្តិ ១ ក្តីនោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក
៥ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។ សង្ឃក៏បានឲ្យសមោធានបរិវាសដល់
ឧទាយិភិក្ខុចំពោះអាបត្តិ ១ ក្តីនោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែល
បិទបាំងទុក ៥ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។ ឧទាយិភិក្ខុនោះបាននៅ

បរិវុត្ថបរិវាសោ សង្ឃំ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ យាចិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ អទាសិ ។ សោ មានត្តំ ចរន្តោ អន្តរា ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ យាចិ ។ សង្ឃោ ឧទាយឹ ភិក្ខុំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិ ។ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ យាចិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ អទាសិ ។ សោ បរិវុត្ថបរិវាសោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា

បរិវាសរួចហើយ ក៏សូមមានត្ត៦រាត្រីនឹងសង្ឃទៀតចំពោះអាបត្តិទាំង៣ ។ សង្ឃក៏បានឲ្យមានត្ត៦រាត្រីដល់ឧទាយិភិក្ខុចំពោះអាបត្តិទាំង៣ ។ ឧទាយិភិក្ខុនោះកំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះបានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ។ សង្ឃក៏បានទាញឧទាយិភិក្ខុមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ ។ ឧទាយិភិក្ខុនោះបានសូមសមោធានបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។ សង្ឃក៏បានឲ្យសមោធានបរិវាសដល់ឧទាយិភិក្ខុចំពោះអាបត្តិ១ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិដែលបិទបាំងទុក៥ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។ ឧទាយិភិក្ខុនោះបាននៅបរិវាសរួចហើយ ក៏បានសូមមានត្ត៦រាត្រីនឹងសង្ឃទៀតចំពោះអាបត្តិ១ក្នុងចន្លោះ

សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ អទាសិ ។ សោ ចិណ្ណមានត្តោ អព្ភានារហោ អន្តរា ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សនំ យាចិ ។ សង្ឃោ ឧទាយឹ ភិក្ខុំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ មូលាយ បដិកស្សិ ។ សោ សង្ឃំ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ យាចិ ។ សង្ឃោ ឧទាយិស្ស ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ បុរិមាយ អាបត្តិយា សមោធានបរិវាសំ អទាសិ ។ សោ បរិវុត្ថបរិវាសោ សង្ឃំ អន្តរា ឯកិស្សា

ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ៤ ថ្ងៃ ។ សង្ឃក៏បានឲ្យមានត្ត ៦ រាត្រីដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ៤ ថ្ងៃ ។ ឧទាយិភិក្ខុនោះបានសន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិហើយបិទបាំងទុក ៤ ថ្ងៃ ឧទាយិភិក្ខុនោះបានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ៤ ថ្ងៃ ។ សង្ឃក៏បានទាញឧទាយិភិក្ខុមកដាក់ក្នុងមូលាបត្តិចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ៤ ថ្ងៃ ។ ឧទាយិភិក្ខុនោះបានសូមសមោធានបរិវាសនឹងសង្ឃចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ៤ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។ សង្ឃក៏បានឲ្យសមោធានបរិវាសដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ៤ ថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។ ឧទាយិភិក្ខុនោះបាននៅបរិវាសរួចហើយ ក៏បានសូមមានត្ត ៦ រាត្រីនឹងសង្ឃទៀតចំពោះ

## សមុច្ចយក្ខន្ធកេ អព្ភានំ

អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា បញ្ចាហ-
បដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចិ ។ សង្ឃោ ឧទាយិស្ស
ភិក្ខុនោ អន្តរា ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ
សុក្កវិសដ្ឋិយា បញ្ចាហប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ
អទាសិ ។ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ ។
យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧទាយឹ ភិក្ខុំ
អព្ភេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ
អយំ ឧទាយិ ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ
សុក្កវិសដ្ឋឹ បញ្ចាហប្បដិច្ឆន្នំ ។ បេ ។ សោ ចិណ្ណមានត្តោ
សង្ឃំ អព្ភានំ យាចតិ ។ សង្ឃោ ឧទាយឹ ភិក្ខុំ
អព្ភេតិ ។ យស្សាយស្មតោ ខមតិ ឧទាយិស្ស ភិក្ខុនោ
អព្ភានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។
ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ
វទាមិ ។ បេ ។ អព្ភិតោ សង្ឃេន ឧទាយិ ភិក្ខុ ខមតិ
សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

សុក្កវិសដ្ឋិ សមត្តា

## សមុច្ចយក្ខន្ធក អព្ភានកម្ម

អាបត្តិ១ ក្នុងបន្ទោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក ៤ថ្ងៃ ។ សង្ឃក៏បានឲ្យមានត្ត ៦ រាត្រីដល់ឧទាយិភិក្ខុចំពោះអាបត្តិ ១ ក្នុងបន្ទោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិដែលបិទបាំងទុក៤ថ្ងៃ ។ ឧទាយិភិក្ខុនោះ បានប្រព្រឹត្តមានត្តរួចហើយ មកសូមអព្ភានកម្មនឹងសង្ឃ ។ បើកម្មមាន កាលគួរដល់សង្ឃហើយ សង្ឃត្រូវឲ្យអព្ភានកម្មដល់ឧទាយិភិក្ខុ ។ នេះជា ពាក្យផ្តៀងសង្ឃ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិត ឧទាយិភិក្ខុនេះត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិហើយបិទបាំងទុក ១បក្ខ ។ បេ ។ ឧទាយិភិក្ខុនោះបានប្រព្រឹត្តមានត្តរួចហើយ មកសូម អព្ភានកម្មនឹងសង្ឃ ។ សង្ឃក៏បានឲ្យអព្ភានកម្មដល់ឧទាយិភិក្ខុ ។ អព្ភានកម្មរបស់ឧទាយិភិក្ខុ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោក ដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា ទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង ។ បេ ។ សង្ឃបានឲ្យអព្ភានកម្មដល់ឧទាយិភិក្ខុ អព្ភានកម្មនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំសេចក្តីនេះទុកដោយ អាការស្ងៀមយ៉ាងនេះ ។

ចប់អំពើដែលធ្វើទឹកសុក្កឲ្យឃ្លាតចេញ ។

(៤៤០) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ
សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបន្នោ ហោតិ
ឯកា អាបត្តិ ឯកាហប្បដិច្ឆន្នា ឯកា អាបត្តិ ទ្វីហប្ប-
ដិច្ឆន្នា ឯកា អាបត្តិ តីហប្បដិច្ឆន្នា ឯកា អាបត្តិ ចតូ-
ហប្បដិច្ឆន្នា ឯកា អាបត្តិ បញ្ចាហប្បដិច្ឆន្នា ឯកា
អាបត្តិ ឆាហប្បដិច្ឆន្នា ឯកា អាបត្តិ សត្តាហប្បដិច្ឆន្នា
ឯកា អាបត្តិ អដ្ឋាហប្បដិច្ឆន្នា ឯកា អាបត្តិ នវាហ-
ប្បដិច្ឆន្នា ឯកា អាបត្តិ ទសាហប្បដិច្ឆន្នា ។ សោ
ភិក្ខូនំ អារោចេសិ អហំ អាវុសោ សម្ពហុលា សង្ឃា-
ទិសេសា អាបត្តិយោ អាបជ្ជឹ ឯកា អាបត្តិ ឯកាហ-
ប្បដិច្ឆន្នា ។ បេ ។ ឯកា អាបត្តិ ទសាហប្បដិច្ឆន្នា
កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ តេ ភិក្ខូ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ តស្ស
ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិ ទសាហប្បដិច្ឆន្នា
តស្ស អគ្ឃេន សមោធានបរិវាសំ ទេតុ ។

(៤៤១) ឯវញ្ច បន ភិក្ខវេ ទាតព្វោ ។ តេន
ភិក្ខវេ ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ

(៤៤០) សម័យនោះឯង ភិក្ខុ ១ រូប ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ ១ បិទបាំងទុក ១ ថ្ងៃ អាបត្តិ ១ បិទបាំងទុក ២ ថ្ងៃ អាបត្តិ ១ បិទបាំងទុក ៣ ថ្ងៃ អាបត្តិ ១ បិទបាំងទុក ៤ ថ្ងៃ អាបត្តិ ១ បិទបាំងទុក ៥ ថ្ងៃ អាបត្តិ ១ បិទបាំងទុក ៦ ថ្ងៃ អាបត្តិ ១ បិទបាំងទុក ៧ ថ្ងៃ អាបត្តិ ១ បិទបាំងទុក ៨ ថ្ងៃ អាបត្តិ ១ បិទបាំងទុក ៩ ថ្ងៃ អាបត្តិ ១ បិទបាំងទុក ១០ ថ្ងៃ ។ ភិក្ខុនោះបានប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ ១ បិទបាំងទុក ១ ថ្ងៃ ។ បេ ។ អាបត្តិ ១ បិទបាំងទុក ១០ ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច ។ ភិក្ខុទាំងនោះក៏នាំយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ បណ្តាអាបត្តិទាំងនោះ អាបត្តិណាដែលភិក្ខុនោះបិទបាំងទុក ១០ ថ្ងៃ សង្ឃត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះ តាមដំរៃ[1] អាបត្តិនោះ ។

(៤៤១) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះចូលទៅរកសង្ឃហើយធ្វើឧត្តរាសង្គ

---

១ គឺតាមចំនួនថ្ងៃដែលបិទបាំងក្រោយបង្អស់ ។

ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ ឯកា អាបត្តិ ឯកាហប្បដិច្ឆន្នា ។ បេ ។ ឯកា អាបត្តិ ទសាហប្បដិច្ឆន្នា សោហំ ភន្តេ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិ ទសាហប្បដិច្ឆន្នា តស្សា អគ្ឃេន សមោធានបរិវាសំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វោ តតិយម្បិ យាចិតព្វោ ។

(៤៤២) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិ ឯកា អាបត្តិ ឯកាហប្បដិច្ឆន្នា ។ បេ ។ ឯកា អាបត្តិ ទសាហប្បដិច្ឆន្នា សោ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិ ទសាហប្បដិច្ឆន្នា តស្សា អគ្ឃេន សមោធានបរិវាសំ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិ ទសាហប្បដិច្ឆន្នា តស្សា អគ្ឃេន សមោធាន-

## សមុច្ចយក្ខន្ធក ការឲ្យសមោធានបរិវាសតាមតម្លៃអាបត្តិ

ចៀងស្មាម្ខាងថ្វាយបង្គំបាទាព្ទុកភិក្ខុចាស់ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើងពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំបានត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ ១ បិទបាំងទុក ១ ថ្ងៃ ។ បេ ។ អាបត្តិ ១ បិទបាំងទុក ១០ ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន បណ្តាអាបត្តិទាំងនោះ អាបត្តិណាដែលបិទបាំងទុក ១០ ថ្ងៃ ខ្ញុំសូមសមោធានបរិវាសនឹងសង្ឃតាមតម្លៃអាបត្តិនោះ ៗ ភិក្ខុនោះត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង ។

(៤៤២) ភិក្ខុអ្នកឆ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនេះមានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃាទិ-សេសជាច្រើន អាបត្តិ ១ បិទបាំងទុក ១ ថ្ងៃ ។ បេ ។ អាបត្តិ ១ បិទបាំងទុក ១០ ថ្ងៃ បណ្តាអាបត្តិទាំងនោះ អាបត្តិណាដែលបិទបាំងទុក ១០ ថ្ងៃ ភិក្ខុនោះសូមសមោធានបរិវាសនឹងសង្ឃតាមតម្លៃអាបត្តិនោះ ៗ បើកម្មមានកាលគួរដល់សង្ឃហើយ បណ្តាអាបត្តិទាំងនោះ អាបត្តិណាដែលបិទបាំងទុក ១០ ថ្ងៃ សង្ឃត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុមានឈ្មោះដូច្នេះ

បរិវាសំ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិ ឯកា អាបត្តិ ឯកាហប្បដិច្ឆន្នា ។ បេ ។ ឯកា អាបត្តិ ទសាហប្បដិច្ឆន្នា សោ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិ ទសាហប្បដិច្ឆន្នា តស្សា អគ្ឃេន សមោធានបរិវាសំ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិ ទសាហប្បដិច្ឆន្នា តស្សា អគ្ឃេន សមោធានបរិវាសំ ទេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិ ទសាហប្បដិច្ឆន្នា តស្សា អគ្ឃេន សមោធានបរិវាសស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ ទិន្នោ សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិ ទសាហប្បដិច្ឆន្នា តស្សា អគ្ឃេន សមោធានបរិវាសោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

តាមដម្លៃអាបត្តិនោះចុះ ។ នេះជាពាក្យផ្តៀងសង្ឃ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតភិក្ខុនេះមានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ១ បិទបាំងទុក១ថ្ងៃ ។បេ។ អាបត្តិ១ បិទបាំងទុក ១០ថ្ងៃ បណ្តាអាបត្តិទាំងនោះ អាបត្តិណាដែលបិទបាំងទុក ១០ថ្ងៃ ភិក្ខុនោះសូមសមោធានបរិវាសនឹងសង្ឃ តាមដម្លៃអាបត្តិនោះៗ បណ្តាអាបត្តិទាំងនោះ អាបត្តិណាដែលបិទបាំងទុក ១០ថ្ងៃ សង្ឃឲ្យសមោធានបរិវាសដល់ភិក្ខុមានឈ្មោះដូច្នេះ តាមដម្លៃអាបត្តិនោះ ៗ បណ្តាអាបត្តិទាំងនោះ អាបត្តិណាដែលបិទបាំងទុក ១០ថ្ងៃ ការឲ្យសមោធានបរិវាសដល់ភិក្ខុមានឈ្មោះដូច្នេះ តាមដម្លៃអាបត្តិនោះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង ។បេ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង ។បេ។ បណ្តាអាបត្តិទាំងនោះ អាបត្តិណាដែលបិទបាំងទុក ១០ថ្ងៃ សង្ឃបានឲ្យសមោធានបរិវាសដល់ភិក្ខុឈ្មោះដូច្នេះ តាមដម្លៃអាបត្តិនោះហើយ ការឲ្យសមោធានបរិវាសនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំសេចក្តីនេះទុកដោយអាការស្ងៀមយ៉ាងនេះ ។

## សមុច្ចយក្ខន្ធកេ អគ្ឃេន សមោធានបរិវាសទានំ

[៤៤៣] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបន្នោ ហោតិ ឯកា អាបត្តិ ឯកាហប្បដិច្ឆន្នា ទ្វេ អាបត្តិយោ ទ្វីហប្បដិច្ឆន្នាយោ(១) តិស្សោ អាបត្តិយោ តីហប្បដិច្ឆន្នាយោ ចតស្សោ អាបត្តិយោ ចតូហប្បដិច្ឆន្នាយោ បញ្ច អាបត្តិយោ បញ្ចាហប្បដិច្ឆន្នាយោ ឆ អាបត្តិយោ ឆាហប្បដិច្ឆន្នាយោ សត្ត អាបត្តិយោ សត្តាហប្បដិច្ឆន្នាយោ អដ្ឋ អាបត្តិយោ អដ្ឋាហប្បដិច្ឆន្នាយោ នវ អាបត្តិយោ នវាហប្បដិច្ឆន្នាយោ ទស អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ ។ សោ ភិក្ខូនំ អារោចេសិ អហំ អាវុសោ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ ឯកា អាបត្តិ ឯកាហប្បដិច្ឆន្នា ។បេ។ ទស អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ តស្ស ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិយោ សព្វចិរប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសំ ទេតុ ។

---

១ ឱ. ទ្វីហប្បដិច្ឆន្នា ។

(៤៤៣) សម័យនោះឯង ភិក្ខុ ១ រូប ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ ១ បិទបាំងទុក ១ ថ្ងៃ អាបត្តិ ២ បិទបាំងទុក ២ ថ្ងៃ អាបត្តិ ៣ បិទបាំងទុក ៣ ថ្ងៃ អាបត្តិ ៤ បិទបាំងទុក ៤ ថ្ងៃ អាបត្តិ ៥ បិទបាំងទុក ៥ ថ្ងៃ អាបត្តិ ៦ បិទបាំងទុក ៦ ថ្ងៃ អាបត្តិ ៧ បិទបាំងទុក ៧ ថ្ងៃ អាបត្តិ ៨ បិទបាំងទុក ៨ ថ្ងៃ អាបត្តិ ៩ បិទបាំងទុក ៩ ថ្ងៃ អាបត្តិ ១០ បិទបាំងទុក ១០ ថ្ងៃ ។ ភិក្ខុនោះបានប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ ១ បិទបាំងទុក ១ ថ្ងៃ ។ បេ ។ អាបត្តិ ១០ បិទបាំងទុក ១០ ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច ។ ភិក្ខុទាំងនោះក៏នាំយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ បណ្តាអាបត្តិទាំងនោះ អាបត្តិណាដែលបិទបាំងទុកយូរជាងអាបត្តិទាំងអស់ សង្ឃគួរឲ្យសមោធានបរិវាសដល់ភិក្ខុនោះ តាមដម្លៃអាបត្តិទាំងនោះចុះ ។

មាសំ សរតិ ។ តស្ស ឯវំ ហោតិ អហំ ខោ ទ្វេ សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ ទ្វេមាសប្បដិច្ឆន្នាយោ ឯកំ មាសំ សរឹ ឯកំ មាសំ ន សរឹ សោហំ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ យំ មាសំ សរឹ តំ មាសំ បរិវាសំ យាចឹ តស្ស មេ សង្ឃោ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ យំ មាសំ សរឹ តំ មាសំ បរិវាសំ អទាសិ សោហំ បរិវសន្តោ ឥតរម្បិ មាសំ សរាមិ យន្នូនាហំ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ឥតរម្បិ មាសបរិវាសំ យាចេយ្យន្តិ ។ សោ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ឥតរម្បិ មាសបរិវាសំ យាចតិ ។ តស្ស សង្ឃោ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ឥតរម្បិ មាសបរិវាសំ ទេតិ ។ តេន ភិក្ខវេ ភិក្ខុនា បុរិមំ ឧបាទាយ ទ្វេ មាសា បរិវសិតព្វា ។

(៤៦២) ឥធ បន ភិក្ខវេ ភិក្ខុ ទ្វេ សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ ទ្វេមាសប្បដិច្ឆន្នាយោ ឯកំ មាសំ និព្វេមតិកោ ឯកំ មាសំ វេមតិកោ ។ សោ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ យំ មាសំ និព្វេមតិកោ

១ខែទៀត ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែបានរលឹកឃើញ ១ខែ រលឹកមិនឃើញ ១ខែ អាត្មាអញនោះរលឹកឃើញខែណា ក៏សូមបរិវាស ១ខែ នោះនឹងសង្ឃចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ អាត្មាអញរលឹកឃើញខែណា សង្ឃក៏បានឲ្យបរិវាស ១ខែនោះដល់អាត្មាអញនោះចំពោះអាបត្តិទាំង២ដែលបិទបាំងទុក២ខែ អាត្មាអញនោះកំពុងនៅបរិវាស ក៏ស្រាប់តែរលឹកឃើញ១ខែទៀត បើដូច្នោះគួរតែអាត្មាអញសូមបរិវាស១ខែទៀតនឹងសង្ឃចំពោះអាបត្តិទាំង២ដែលបិទបាំងទុក២ខែ ។ ភិក្ខុនោះក៏សូមបរិវាស ១ខែទៀតនឹងសង្ឃចំពោះអាបត្តិទាំង ២ដែលបិទបាំងទុក ២ខែ ។ សង្ឃក៏បានឲ្យបរិវាស ១ខែទៀត ដល់ភិក្ខុនោះចំពោះអាបត្តិទាំង២ដែលបិទបាំងទុក២ខែ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះនៅបរិវាស ២ខែដោយកប់យកខែខាងដើមផង ។

(៤៦២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេស ២ ហើយបិទបាំងទុក ២ ខែ តែឥតមានសេចក្តីសង្ស័យ ១ ខែ មានសេចក្តីសង្ស័យ ១ ខែ ។ ភិក្ខុនោះឥតមានសេចក្តីសង្ស័យខែណា

តំ មាសំ បរិវាសំ យាចតិ ។ តស្ស សង្ឃោ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ យំ មាសំ និព្ពេមតិកោ តំ មាសំ បរិវាសំ ទេតិ ។ សោ បរិវសន្តោ ឥតរម្បិ មាសំ និព្ពេមតិកោ ហោតិ ។ តស្ស ឯវំ ហោតិ អហំ ខោ ទ្វេ សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ ទ្វេមាសប្បដិច្ឆន្នាយោ ឯកំ មាសំ និព្ពេមតិកោ ឯកំ មាសំ វេមតិកោ សោហំ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ យំ មាសំ និព្ពេមតិកោ តំ មាសំ បរិវាសំ យាចឹ តស្ស មេ សង្ឃោ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ យំ មាសំ និព្ពេមតិកោ តំ មាសំ បរិវាសំ អទាសិ សោហំ បរិវសន្តោ ឥតរម្បិ មាសំ និព្ពេមតិកោ យន្នូនាហំ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ឥតរម្បិ មាសបរិវាសំ យាចេយ្យន្តិ ។ សោ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ឥតរម្បិ មាសបរិវាសំ យាចតិ ។ តស្ស សង្ឃោ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ឥតរម្បិ មាសបរិវាសំ ទេតិ ។ តេន ភិក្ខវេ ភិក្ខុនា បុរិមំ ឧបាទាយ ទ្វេ មាសា បរិវសិតព្វា ។

ក៏សូមបរិវាស ១ ខែនោះនឹងសង្ឃចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ ៗ ភិក្ខុនោះឥតមានសេចក្តីសង្ស័យខែណា សង្ឃក៏ឲ្យបរិវាស ១ ខែនោះដល់ភិក្ខុនោះចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ ៗ ភិក្ខុនោះកំពុងនៅបរិវាសក៏ស្រាប់តែមានសេចក្តីសង្ស័យក្នុងខែ ១ ទៀត ៗ ភិក្ខុនោះមានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញត្រូវអាបត្តិសង្ឃាទិសេស ២ ហើយបិទបាំងទុក ២ ខែ តែឥតមានសេចក្តីសង្ស័យ ១ ខែ មានសេចក្តីសង្ស័យ ១ ខែ អាត្មាអញនោះឥតមានសេចក្តីសង្ស័យខែណា ក៏សូមបរិវាស ១ ខែនោះនឹងសង្ឃចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ អាត្មាអញឥតមានសេចក្តីសង្ស័យខែណា សង្ឃក៏ឲ្យបរិវាស ១ ខែនោះដល់អាត្មាអញនោះចំពោះអាបត្តិទាំង២ដែលបិទបាំងទុក២ខែ អាត្មាអញនោះកំពុងនៅបរិវាសក៏ស្រាប់តែអស់សេចក្តីសង្ស័យក្នុងខែ ១ ទៀត បើដូច្នោះគួរតែអាត្មាអញសូមបរិវាស ១ ខែទៀតនឹងសង្ឃចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ ៗ ភិក្ខុនោះក៏សូមបរិវាស ១ ខែទៀតនឹងសង្ឃចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ ៗ សង្ឃក៏ឲ្យបរិវាស ១ ខែទៀតដល់ភិក្ខុនោះចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ ៗ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះនៅបរិវាស ២ ខែដោយរាប់យកខែខាងដើមផង ៗ

(១៦៣) ឥធ បន ភិក្ខវេ ភិក្ខុ ទ្វេ សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ ទ្វេមាសប្បដិច្ឆន្នាយោ ឯកា មាសោ ជានប្បដិច្ឆន្នា ឯកា មាសោ អជានប្បដិច្ឆន្នា ។ សោ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ យាចតិ ។ តស្ស សង្ឃោ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ ទេតិ ។ តស្ស បរិវសន្តស្ស អញ្ញោ ភិក្ខុ អាគច្ឆតិ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ បណ្ឌិតោ វិយត្តោ មេធាវី លជ្ជី កុក្កុច្ចកោ សិក្ខាកាមោ ។ សោ ឯវំ វទេតិ កឹ អយំ អាវុសោ ភិក្ខុ អាបន្នោ កិស្សាយំ ភិក្ខុ បរិវសតីតិ ។ តេ ឯវំ វទេន្តិ អយំ អាវុសោ ភិក្ខុ ទ្វេ សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិ ទ្វេមាសប្បដិច្ឆន្នាយោ ឯកា មាសោ ជានប្បដិច្ឆន្នា ឯកា មាសោ អជានប្បដិច្ឆន្នា សោ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ យាចិ តស្ស សង្ឃោ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ អទាសិ តាយោ អយំ អាវុសោ ភិក្ខុ អាបន្នោ តាសាយំ ភិក្ខុ បរិវសតីតិ ។

(៤៦៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេស ២ ហើយបិទបាំងទុក ២ ខែ តែខែ ១ ភិក្ខុដឹងហើយបិទបាំងទុក ខែ ១ ទៀតភិក្ខុមិនដឹងហើយបិទបាំងទុក ។ ភិក្ខុនោះក៏សូមទេ្វមាសបរិវាស នឹងសង្ឃចំពោះអាបត្តិទាំង២ដែលបិទបាំងទុក២ខែ ។ សង្ឃក៏ឲ្យទេ្វមាសបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិទាំង២ដែលបិទបាំងទុក២ខែ ។ កាលភិក្ខុនោះកំពុងនៅបរិវាស ក៏ស្រាប់តែមានភិក្ខុដទៃជាពហុស្សុត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត ឆ្លៀវឆ្លាស មានប្រាជ្ញា មានសេចក្តីខ្មាសបាប មានសេចក្តីរអែង មានការប្រាថ្នានូវសិក្ខា បានមកដល់ ។ ភិក្ខុនោះសួរយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះត្រូវអាបត្តិអ្វី ភិក្ខុនេះនៅបរិវាសចំពោះអាបត្តិអ្វី ។ ភិក្ខុទាំងនោះឆ្លើយយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះត្រូវអាបត្តិសង្ឃាទិសេស ២ ហើយបិទបាំងទុក ២ ខែ តែខែ១ភិក្ខុនោះដឹងហើយបិទបាំងទុក ខែ ១ ទៀតភិក្ខុនោះមិនដឹងហើយបិទបាំងទុក ភិក្ខុនោះបានសូមទេ្វមាសបរិវាសនឹងសង្ឃចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ សង្ឃក៏បានឲ្យទេ្វមាសបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ នែអាវុសោ ភិក្ខុនេះត្រូវអាបត្តិទាំងនោះ ភិក្ខុនេះនៅបរិវាសចំពោះអាបត្តិទាំងនោះ ។

សោ ឯវំ វទេតិ យ្វាយំ អាវុសោ មាសោ ជានប្បដិច្ឆន្នោ ធម្មិកំ តស្ស មាសស្ស បរិវាសទានំ ធម្មតា រុហតិ យោ ច ខ្វាយំ អាវុសោ មាសោ អជានប្បដិច្ឆន្នោ អធម្មិកំ តស្ស មាសស្ស បរិវាសទានំ អធម្មតា ន រុហតិ ឯតស្ស(១) អាវុសោ មាសស្ស ភិក្ខុ មានត្តារហោតិ ។

(៤៦៤) ឥធ បន ភិក្ខវេ ភិក្ខុ ទ្វេ សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ ទ្វេមាសប្បដិច្ឆន្នាយោ ឯកោ មាសោ សរមានប្បដិច្ឆន្នោ ឯកោ មាសោ អសរមានប្បដិច្ឆន្នោ ។ សោ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ យាចតិ ។ តស្ស សង្ឃោ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ ទេតិ ។ តស្ស បរិវសន្តស្ស អញ្ញោ ភិក្ខុ អាគច្ឆតិ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ បណ្ឌិតោ វិយត្តោ មេធាវី លជ្ជី កុក្កុច្ចកោ សិក្ខាកាមោ ។ សោ ឯវំ វទេតិ កឹ អយំ អាវុសោ ភិក្ខុ អាបន្នោ កិស្សាយំ ភិក្ខុ បរិវសតីតិ ។ តេ ឯវំ វទេន្តិ អយំ អាវុសោ

១ មរម្មពោត្ថកេ ឯកស្សាតិ បាឋោ អាគតោ ។

ភិក្ខុជាបណ្ឌិតនោះសួរយ៉ាងនេះថា នែអាវុសោ ខែណាដែលភិក្ខុដឹង ហើយបិទបាំងទុក ការឲ្យបរិវាស ១ ខែនោះឈ្មោះថាប្រកបដោយធម៌ ក៏ដុះឡើងតាមសភាវធម៌ នែអាវុសោ មួយវិញទៀត ខែណាដែលភិក្ខុមិនដឹង ហើយបិទបាំងទុក ការឲ្យបរិវាស ១ ខែនោះឈ្មោះថាមិនប្រកបដោយធម៌ មិនដុះឡើងព្រោះមិនត្រូវតាមសភាវធម៌ នែអាវុសោ ភិក្ខុគួរដល់មានត្ត តែ ១ ខែនេះឯង ។

(៤៦៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេស ២ ហើយបិទបាំងទុក ២ ខែ តែខែ ១ ភិក្ខុនោះរលឹកឃើញ ហើយបិទបាំងទុក ខែ ១ ទៀតភិក្ខុនោះរលឹកមិនឃើញហើយបិទបាំងទុក ។ ភិក្ខុនោះក៏សូមទេ្វមាសបរិវាសនឹងសង្ឃចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ ។ សង្ឃក៏ឲ្យទេ្វមាសបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ ។ កាលភិក្ខុនោះកំពុងនៅបរិវាស ក៏ស្រាប់តែមានភិក្ខុដទៃជាពហុស្សុត ចេះចាំគង់គម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត ឈ្លៀវឆ្លាស មានប្រាជ្ញា មានសេចក្តីខ្មាសបាប មានសេចក្តីរអៀស មានការប្រាថ្នានូវសិក្ខា បានមកដល់ ។ ភិក្ខុជាបណ្ឌិតនោះក៏សួរយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះត្រូវអាបត្តិអ្វី ភិក្ខុនេះនៅបរិវាសចំពោះអាបត្តិអ្វី ។ ភិក្ខុទាំងនោះឆ្លើយយ៉ាងនេះថា នែ

ភិក្ខុ ទ្វេ សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិ ទ្វេមាសប្បដិច្ឆន្នាយោ ឯកោ មាសោ សរមានប្បដិច្ឆន្នោ ឯកោ មាសោ អសរមានប្បដិច្ឆន្នោ សោ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ យាចិ តស្ស សង្ឃោ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ អទាសិ តាយោ អយំ អាវុសោ ភិក្ខុ អាបន្នោ តាសាយំ ភិក្ខុ បរិវសតីតិ ។ សោ ឯវំ វទេតិ យ្វាយំ អាវុសោ មាសោ សរមានប្បដិច្ឆន្នោ ធម្មិកំ តស្ស មាសស្ស បរិវាសទានំ ធម្មតា រូហតិ យោ ច ខ្វាយំ អាវុសោ មាសោ អសរមានប្បដិច្ឆន្នោ អធម្មិកំ តស្ស មាសស្ស បរិវាសទានំ អធម្មតា ន រូហតិ ឯកស្ស អាវុសោ មាសស្ស ភិក្ខុ មានត្តារហោតិ ។

(៤៦៥) ឥធ បន ភិក្ខវេ ភិក្ខុ ទ្វេ សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ ទ្វេមាសប្បដិច្ឆន្នាយោ ឯកោ មាសោ និព្វេមតិកប្បដិច្ឆន្នោ ឯកោ មាសោ វេមតិកប្បដិច្ឆន្នោ ។ សោ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ យាចតិ ។ សង្ឃោ តស្ស ទ្វិន្នំ អាបត្តីនំ

អាវុសោ ភិក្ខុនេះត្រូវអាបត្តិសង្ឃាទិសេស ២ ហើយបិទបាំងទុក ២ ខែ តែខែ ១ ភិក្ខុនោះរលឹកឃើញហើយបិទបាំងទុក ខែ ១ ទៀត ភិក្ខុនោះរលឹកមិនឃើញហើយបិទបាំងទុក ភិក្ខុនោះបានសូមទ្វេមាសបរិវាសនឹងសង្ឃចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ សង្ឃក៏បានឲ្យទ្វេមាស-បរិវាសដល់ភិក្ខុនោះចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ នែអាវុសោ ភិក្ខុនេះត្រូវអាបត្តិទាំងនោះ ភិក្ខុនេះនៅបរិវាសចំពោះអាបត្តិទាំងនោះ ៗ ភិក្ខុជាបណ្ឌិតនោះក៏ពោលយ៉ាងនេះថា នែអាវុសោ ខែណាដែលភិក្ខុរលឹកឃើញហើយបិទបាំងទុក ការឲ្យបរិវាស ១ ខែ នោះឈ្មោះថាប្រកបដោយធម៌ ក៏ដុះឡើងតាមសភាវធម៌ នែអាវុសោ ម្យ៉ាងទៀត ខែណាដែលភិក្ខុនោះរលឹកមិនឃើញហើយបិទបាំងទុក ការឲ្យបរិវាស ១ ខែនោះឈ្មោះថាមិនប្រកបដោយធម៌ មិនបានដុះឡើងព្រោះមិនត្រូវតាមសភាវធម៌ នែអាវុសោ ភិក្ខុគួរដល់មានត្តតែ ១ ខែនេះឯង ៗ

(៤៦៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិ-សេស ២ ហើយបិទបាំងទុក២ខែ តែខែ១ភិក្ខុនោះឥតមានសេចក្តីសង្ស័យហើយបិទបាំងទុក ខែ១ទៀតភិក្ខុនោះមានសេចក្តីសង្ស័យហើយបិទបាំងទុក ៗ ភិក្ខុនោះក៏សូមទ្វេមាសបរិវាសនឹងសង្ឃចំពោះអាបត្តិទាំង២ដែលបិទបាំងទុក២ខែ ៗ សង្ឃក៏ឲ្យទ្វេមាសបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិ,

ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ ទេតិ ។ តស្ស បរិវសន្តស្ស អញ្ញោ ភិក្ខុ អាគច្ឆតិ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ បណ្ឌិតោ វិយត្តោ មេធាវី លជ្ជី កុក្កុច្ចកោ សិក្ខាកាមោ ។ សោ ឯវំ វទេតិ កឹ អយំ អាវុសោ ភិក្ខុ អាបន្នោ កិស្សាយំ ភិក្ខុ បរិវសតីតិ ។ តេ ឯវំ វទន្តិ អយំ អាវុសោ ភិក្ខុ ទ្វេ សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិ ទ្វេមាសប្បដិច្ឆន្នាយោ ឯកោ មាសោ និព្វេមតិកប្បដិច្ឆន្នោ ឯកោ មាសោ វេមតិកប្បដិច្ឆន្នោ សោ សង្ឃំ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ យាចិ តស្ស សង្ឃោ ទ្វិន្នំ អាបត្តីនំ ទ្វេមាសប្បដិច្ឆន្នានំ ទ្វេមាសបរិវាសំ អទាសិ តាយោ អយំ អាវុសោ ភិក្ខុ អាបន្នោ តាសាយំ ភិក្ខុ បរិវសតីតិ ។ សោ ឯវំ វទេតិ យ្វាយំ អាវុសោ មាសោ និព្វេមតិកប្បដិច្ឆន្នោ ធម្មិកំ តស្ស មាសស្ស បរិវាសទានំ ធម្មត្តា រូហតិ យោ ច ខ្វាយំ អាវុសោ មាសោ វេមតិកប្បដិច្ឆន្នោ

ទាំង ២ ដែលបិទបាំងទុក ២ ខែ ។ កាលភិក្ខុនោះកំពុងនៅបរិវាសក៏ស្រាប់តែមានភិក្ខុដទៃជាពហុស្សុត ចេះចាំគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត ឈ្លៀវឈ្លាស មានប្រាជ្ញា មានសេចក្ដីខ្មាសបាប មានសេចក្ដីរអែង នឹងមានការប្រាថ្នានូវសិក្ខា បានមកដល់ ។ ភិក្ខុជាបណ្ឌិតនោះក៏សួរយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះត្រូវអាបត្តិអ្វី ភិក្ខុនេះនៅបរិវាសចំពោះអាបត្តិអ្វី ។ ភិក្ខុទាំងនោះក៏ឆ្លើយយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះត្រូវអាបត្តិសង្ឃាទិសេស ២ ហើយបិទបាំងទុក ២ ខែ តែខែ ១ ភិក្ខុនោះឥតមានសេចក្ដីសង្ស័យហើយបិទបាំងទុក ខែ ១ ទៀតភិក្ខុនោះមានសេចក្ដីសង្ស័យហើយបិទបាំងទុក ភិក្ខុនោះបានសូមទ្វេមាសបរិវាសនឹងសង្ឃចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិទាំង ២ ដែលបិទបាំងទុក ២ ខែ នែអាវុសោ ភិក្ខុនេះត្រូវអាបត្តិទាំងនោះ ភិក្ខុនេះនៅបរិវាសចំពោះអាបត្តិទាំងនោះ ។ ភិក្ខុជាបណ្ឌិតនោះក៏ពោលយ៉ាងនេះថា នែអាវុសោ ខែណាដែលភិក្ខុនោះឥតមានសេចក្ដីសង្ស័យហើយបិទបាំងទុក ការឲ្យបរិវាស ១ ខែនោះឈ្មោះថាប្រកបដោយធម៌ ក៏ដុះឡើងតាមសភាវធម៌ នែអាវុសោ ម្យ៉ាងទៀត ខែណាដែលភិក្ខុនោះមានសេចក្ដីសង្ស័យហើយបិទបាំងទុក

អធម្មិកំ តស្ស មាសស្ស បរិវាសទានំ អធម្មត្តា ន រូហតិ ឯកស្ស អាវុសោ មាសស្ស ភិក្ខុ មានត្តារហោ ហោតិ ។

[៤៦៦] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបន្នោ ហោតិ ។ សោ(១) អាបត្តិបរិយន្តំ ន ជានាតិ រត្តិបរិយន្តំ ន ជានាតិ អាបត្តិបរិយន្តំ ន សរតិ រត្តិបរិយន្តំ ន សរតិ អាបត្តិបរិយន្តេ វេមតិកោ រត្តិបរិយន្តេ វេមតិកោ ។ សោ ភិក្ខូនំ អារោចេសិ អហំ អាវុសោ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ អាបត្តិបរិយន្តំ ន ជានាមិ រត្តិបរិយន្តំ ន ជានាមិ អាបត្តិបរិយន្តំ ន សរាមិ រត្តិបរិយន្តំ ន សរាមិ អាបត្តិបរិយន្តេ វេមតិកោ រត្តិបរិយន្តេ វេមតិកោ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ តេនហិ ភិក្ខវេ សង្ឃោ តស្ស ភិក្ខុនោ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ ទេតុ ។

---

១ ឱ. ម. ពោត្ថកេសុ សោសទ្ទោ ន ទិស្សតិ ។

ការឲ្យបរិវាស ១ ខែនោះឈ្មោះថាមិនប្រកបដោយធម៌ មិនបានដុះឡើង ព្រោះមិនត្រូវតាមសភាវធម៌ នែអាវុសោ ភិក្ខុគួរផ្តល់មានត្តតែ ១ ខែនេះឯង ។

[៤៦៦] សម័យនោះឯង មានភិក្ខុ ១ រូបត្រូវអាបត្តិសង្ឃាទិសេសជាច្រើន[១] ។ ភិក្ខុនោះមិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី មានសេចក្តីសង្ស័យក្នុងទីកំណត់អាបត្តិ ទាំងមានសេចក្តីសង្ស័យក្នុងទីកំណត់រាត្រី ។ ភិក្ខុនោះបានប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយមិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី មានសេចក្តីសង្ស័យក្នុងទីកំណត់អាបត្តិ ទាំងមានសេចក្តីសង្ស័យក្នុងទីកំណត់រាត្រី តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច ។ ភិក្ខុទាំងនោះក៏នាំយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃគួរឲ្យសុទ្ធន្តបរិវាស[២] (បរិវាសមានសេចក្តីស្អាតជាទីបំផុត) ដល់ភិក្ខុនោះចំពោះអាបត្តិទាំងនោះចុះ ។

---

១ ទីនេះសំដៅយកតែត្រឹមអាបត្តិសង្ឃាទិសេស ៣ ។ ២ បរិវាសមានបរិសុទ្ធិជាទីបំផុតនោះ ប្រៀបដូចជាភិក្ខុមួយរូបបួសបាន ៧ ខែ តែ ៣ ខែខាងដើមភិក្ខុនោះនឹកឃើញថាខ្លួនបរិសុទ្ធ ឥតមានត្រូវអាបត្តិសង្ឃាទិសេស ៤ ខែខាងចុងភិក្ខុនោះដឹងខ្លះ សង្ស័យខ្លះ ថាខ្លួនមិនបរិសុទ្ធ តែមិនដឹងកំណត់អាបត្តិនឹងកំណត់រាត្រីជាដើម ត្រូវធ្វើបរិវាស ៤ ខែ គឺរាប់ថ្ងៃឲ្យទល់នឹងថ្ងៃដែលបរិសុទ្ធ ហៅថា សុទ្ធន្តបរិវាស ។

## សមុច្ចយក្ខន្ធកេ សុទ្ធន្តបរិវាសទាន់

(៤៦៧) ឯវញ្ច បន ភិក្ខវេ ទាតព្វោ ។ តេន ភិក្ខវេ ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ អាបត្តិបរិយន្តំ ន ជានាមិ រត្តិបរិយន្តំ ន ជានាមិ អាបត្តិបរិយន្តំ ន សរាមិ រត្តិបរិយន្តំ ន សរាមិ អាបត្តិបរិយន្តេ វេមតិកោ រត្តិបរិយន្តេ វេមតិកោ សោហំ ភន្តេ សង្ឃំ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វោ តតិយម្បិ យាចិតព្វោ ។

(៤៦៨) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិ អាបត្តិបរិយន្តំ ន ជានាតិ រត្តិបរិយន្តំ ន ជានាតិ អាបត្តិបរិយន្តំ ន សរតិ រត្តិបរិយន្តំ ន សរតិ អាបត្តិបរិយន្តេ វេមតិកោ រត្តិបរិយន្តេ វេមតិកោ សោ សង្ឃំ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ យាចតិ ។ យទិ សង្ឃស្ស

## សមុច្ចយក្ខន្ធក ការឲ្យសុទ្ធន្តបរិវាស

(៤៦៧) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង សំពះបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយមិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី មានសេចក្តីសង្ស័យក្នុងទីកំណត់អាបត្តិ ទាំងមានសេចក្តីសង្ស័យក្នុងទីកំណត់រាត្រី បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះសូមសុទ្ធន្តបរិវាសនឹងសង្ឃចំពោះអាបត្តិទាំងនោះ ៗ ភិក្ខុនោះត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង ៗ

(៤៦៨) ត្រូវភិក្ខុអ្នកឆ្លាសប្រតិពលផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតភិក្ខុនេះមានឈ្មោះដូច្នេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយមិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី មានសេចក្តីសង្ស័យក្នុងទីកំណត់អាបត្តិ ទាំងមានសេចក្តីសង្ស័យក្នុងទីកំណត់រាត្រី ភិក្ខុនោះក៏សូមសុទ្ធន្តបរិវាសនឹងសង្ឃចំពោះអាបត្តិទាំងនោះ ៗ បើ

បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិ អាបត្តិបរិយន្តំ ន ជានាតិ រត្តិបរិយន្តំ ន ជានាតិ អាបត្តិបរិយន្តំ ន សរតិ រត្តិបរិយន្តំ ន សរតិ អាបត្តិបរិយន្តេ វេមតិកោ រត្តិបរិយន្តេ វេមតិកោ សោ សង្ឃំ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ ទេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ ទិន្នោ សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

កម្មមានកាលគួរដល់សង្ឃហើយ សង្ឃគួរឲ្យសុទ្ធន្តបរិវាសដល់ភិក្ខុមានឈ្មោះដូច្នេះចំពោះអាបត្តិទាំងនោះ នេះជាពាក្យផ្តៀងសង្ឃ ៗ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតភិក្ខុនេះមានឈ្មោះដូច្នេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយមិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី មានសេចក្តីសង្ស័យក្នុងទីកំណត់អាបត្តិ ទាំងមានសេចក្តីសង្ស័យក្នុងទីកំណត់រាត្រី ភិក្ខុនោះក៏សូមសុទ្ធន្តបរិវាសនឹងសង្ឃចំពោះអាបត្តិទាំងនោះ ៗ សង្ឃឲ្យសុទ្ធន្តបរិវាសដល់ភិក្ខុមានឈ្មោះដូច្នេះចំពោះអាបត្តិទាំងនោះ ៗ ការឲ្យសុទ្ធន្តបរិវាសដល់ភិក្ខុមានឈ្មោះដូច្នេះចំពោះអាបត្តិទាំងនោះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម បើមិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ៗ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង ៗ បេ ៗ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង ៗ បេ ៗ សុទ្ធន្តបរិវាសសង្ឃបានឲ្យដល់ភិក្ខុមានឈ្មោះដូច្នេះចំពោះអាបត្តិទាំងនោះហើយ ការឲ្យសុទ្ធន្តបរិវាសនោះគាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ៗ ខ្ញុំសូមចាំសេចក្តីនេះទុកដោយអាការស្ងៀមយ៉ាងនេះ ៗ

(៤២៩) ឯវញ្ច(១) ខោ ភិក្ខវេ សុទ្ធន្តបរិវាសោ ទាតព្វោ ។
ឯវំ បរិវាសោ ទាតព្វោ ។ កទញ្ច ភិក្ខវេ សុទ្ធន្តបរិវាសោ
ទាតព្វោ ។ អាបត្តិបរិយន្តំ ន ជានាតិ រត្តិបរិយន្តំ ន
ជានាតិ អាបត្តិបរិយន្តំ ន សរតិ រត្តិបរិយន្តំ ន សរតិ
អាបត្តិបរិយន្តេ វេមតិកោ រត្តិបរិយន្តេ វេមតិកោ សុទ្ធន្ត-
បរិវាសោ ទាតព្វោ ។ អាបត្តិបរិយន្តំ ជានាតិ រត្តិបរិយន្តំ
ន ជានាតិ អាបត្តិបរិយន្តំ សរតិ រត្តិបរិយន្តំ ន សរតិ
អាបត្តិបរិយន្តេ និព្វេមតិកោ រត្តិបរិយន្តេ វេមតិកោ
សុទ្ធន្តបរិវាសោ ទាតព្វោ ។ អាបត្តិបរិយន្តំ ឯកច្ចំ
ជានាតិ ឯកច្ចំ ន ជានាតិ រត្តិបរិយន្តំ ន ជានាតិ
អាបត្តិបរិយន្តំ ឯកច្ចំ សរតិ ឯកច្ចំ ន សរតិ រត្តិបរិយន្តំ
ន សរតិ អាបត្តិបរិយន្តេ ឯកច្ចេ វេមតិកោ ឯកច្ចេ
និព្វេមតិកោ រត្តិបរិយន្តេ វេមតិកោ សុទ្ធន្តបរិវាសោ ទា-
តព្វោ ។ អាបត្តិបរិយន្តំ ន ជានាតិ រត្តិបរិយន្តំ ឯកច្ចំ
ជានាតិ ឯកច្ចំ ន ជានាតិ អាបត្តិបរិយន្តំ ន សរតិ

---

១ ឱ. ម. បោត្ថកេសុ ចសទ្ទោ ន ទិស្សតិ ។

## សមុច្ចយក្ខន្ធក សុទ្ធន្តបរិវាស

[៤៦៩] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសុទ្ធន្តបរិវាសយ៉ាងនេះ ។ សង្ឃត្រូវឲ្យបរិវាសយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសុទ្ធន្តបរិវាសដូចម្តេចខ្លះ ។ (បើ) ភិក្ខុមិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី សង្ស័យក្នុងទីកំណត់អាបត្តិ ទាំងសង្ស័យក្នុងទីកំណត់រាត្រី ហើយសង្ឃត្រូវឲ្យសុទ្ធន្តបរិវាសចុះ ។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិ តែមិនដឹងទីកំណត់រាត្រី រលឹកឃើញទីកំណត់អាបត្តិ តែរលឹកមិនឃើញទីកំណត់រាត្រី មិនសង្ស័យក្នុងទីកំណត់អាបត្តិ តែសង្ស័យក្នុងទីកំណត់រាត្រី សង្ឃក៏ត្រូវឲ្យសុទ្ធន្តបរិវាសដែរ ។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិខ្លះ មិនដឹងខ្លះ ទាំងមិនដឹងទីកំណត់រាត្រី រលឹកឃើញទីកំណត់អាបត្តិខ្លះ រលឹកមិនឃើញខ្លះ ទាំងរលឹកមិនឃើញទីកំណត់រាត្រី សង្ស័យក្នុងទីកំណត់អាបត្តិខ្លះ មិនសង្ស័យខ្លះ សង្ស័យតែត្រង់ទីកំណត់រាត្រី ហើយសង្ឃក៏ត្រូវឲ្យសុទ្ធន្តបរិវាសដែរ ។ (បើ) ភិក្ខុមិនដឹងទីកំណត់អាបត្តិ តែដឹងទីកំណត់រាត្រីខ្លះ មិនដឹងខ្លះ រលឹកមិនឃើញទីកំណត់អាបត្តិ

រត្តិបរិយន្តំ ឯកាហំ សរតិ ឯកាហំ ន សរតិ អាបត្តិបរិយន្តេ វេមតិកោ រត្តិបរិយន្តេ ឯកាហេ វេមតិកោ ឯកាហេ និព្វេមតិកោ សុទ្ធន្តបរិវាសោ ទាតព្វោ ។ អាបត្តិបរិយន្តំ ជានាតិ រត្តិបរិយន្តំ ឯកាហំ ជានាតិ ឯកាហំ ន ជានាតិ អាបត្តិបរិយន្តំ សរតិ រត្តិបរិយន្តំ ឯកាហំ សរតិ ឯកាហំ ន សរតិ អាបត្តិបរិយន្តេ និព្វេមតិកោ រត្តិបរិយន្តេ ឯកាហេ វេមតិកោ ឯកាហេ និព្វេមតិកោ សុទ្ធន្តបរិវាសោ ទាតព្វោ ។ អាបត្តិបរិយន្តំ ឯកាហំ ជានាតិ ឯកាហំ ន ជានាតិ រត្តិបរិយន្តំ ឯកាហំ ជានាតិ ឯកាហំ ន ជានាតិ អាបត្តិបរិយន្តំ ឯកាហំ សរតិ ឯកាហំ ន សរតិ រត្តិបរិយន្តំ ឯកាហំ សរតិ ឯកាហំ ន សរតិ អាបត្តិបរិយន្តេ ឯកាហេ វេមតិកោ ឯកាហេ និព្វេមតិកោ រត្តិបរិយន្តេ ឯកាហេ វេមតិកោ ឯកាហេ និព្វេមតិកោ សុទ្ធន្តបរិវាសោ ទាតព្វោ ។ ឯវំ ខោ ភិក្ខវេ សុទ្ធន្តបរិវាសោ ទាតព្វោ ។

តែរលឹកឃើញទីកំណត់រាត្រីខ្លះ រលឹកមិនឃើញខ្លះ សង្ស័យក្នុងទីកំណត់អាបត្តិ ទាំងសង្ស័យក្នុងទីកំណត់រាត្រីខ្លះ មិនសង្ស័យខ្លះ សង្ឃក៏ឲ្យសុទ្ធន្តបរិវាសដែរ ។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិ ទាំងដឹងទីកំណត់រាត្រីខ្លះ មិនដឹងខ្លះ រលឹកឃើញទីកំណត់អាបត្តិខ្លះ ទាំងរលឹកឃើញទីកំណត់រាត្រីខ្លះ រលឹកមិនឃើញខ្លះ មិនសង្ស័យក្នុងទីកំណត់អាបត្តិ តែសង្ស័យក្នុងទីកំណត់រាត្រីខ្លះ មិនសង្ស័យខ្លះ សង្ឃក៏ត្រូវឲ្យសុទ្ធន្តបរិវាសដែរ ។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិខ្លះ មិនដឹងខ្លះ ដឹងទីកំណត់រាត្រីខ្លះ មិនដឹងខ្លះ រលឹកឃើញទីកំណត់អាបត្តិខ្លះ រលឹកមិនឃើញខ្លះ រលឹកឃើញទីកំណត់រាត្រីខ្លះ រលឹកមិនឃើញខ្លះ សង្ស័យក្នុងទីកំណត់អាបត្តិខ្លះ មិនសង្ស័យខ្លះ សង្ស័យក្នុងទីកំណត់រាត្រីខ្លះ មិនសង្ស័យខ្លះ សង្ឃក៏ត្រូវឲ្យសុទ្ធន្តបរិវាសដែរ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃក៏ត្រូវឲ្យសុទ្ធន្តបរិវាសយ៉ាងនេះឯង ។

## សមុច្ចយក្ខន្ធកេ សុទ្ធន្តបរិវាសោ

[៤៧០] កតមោ ច ភិក្ខវេ បរិវាសោ ទាតព្វោ ។ អាបត្តិបរិយន្តំ ជានាតិ រត្តិបរិយន្តំ ជានាតិ អាបត្តិបរិយន្តំ សរតិ រត្តិបរិយន្តំ សរតិ អាបត្តិបរិយន្តេ និព្វេមតិកោ រត្តិបរិយន្តេ និព្វេមតិកោ បរិវាសោ ទាតព្វោ ។ អាបត្តិបរិយន្តំ ន ជានាតិ រត្តិបរិយន្តំ ជានាតិ អាបត្តិបរិយន្តំ ន សរតិ រត្តិបរិយន្តំ សរតិ អាបត្តិបរិយន្តេ វេមតិកោ រត្តិបរិយន្តេ និព្វេមតិកោ បរិវាសោ ទាតព្វោ ។ អាបត្តិបរិយន្តំ ឯកច្ចំ ជានាតិ ឯកច្ចំ ន ជានាតិ រត្តិបរិយន្តំ ជានាតិ អាបត្តិបរិយន្តំ ឯកច្ចំ សរតិ ឯកច្ចំ ន សរតិ រត្តិបរិយន្តំ សរតិ អាបត្តិបរិយន្តេ ឯកច្ចេ វេមតិកោ ឯកច្ចេ និព្វេមតិកោ រត្តិបរិយន្តេ និព្វេមតិកោ បរិវាសោ ទាតព្វោ ។ ឯវំ ខោ ភិក្ខវេ បរិវាសោ ទាតព្វោ ។

### បរិវាសោ និដ្ឋិតោ ។

[៤៧១] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បរិវសន្តោ វិព្ភមិ ។ សោ បុន បច្ចាគន្ត្វា ភិក្ខូ ឧបសម្បទំ យាចិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

## សមុច្ចយក្ខន្ធក សុទ្ធន្តបរិវាស

(៤៧០) ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសដូចម្តេច ។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិ ទាំងដឹងទីកំណត់រាត្រី រលឹកឃើញទីកំណត់អាបត្តិ ទាំងរលឹកឃើញទីកំណត់រាត្រី មិនសង្ស័យក្នុងទីកំណត់អាបត្តិ ទាំងមិនសង្ស័យក្នុងទីកំណត់រាត្រី សង្ឃត្រូវឲ្យបរិវាសចុះ ។ (បើ) ភិក្ខុមិនដឹងទីកំណត់អាបត្តិ តែដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ តែរលឹកឃើញទីកំណត់រាត្រី សង្ស័យក្នុងទីកំណត់អាបត្តិ តែមិនសង្ស័យក្នុងទីកំណត់រាត្រី សង្ឃក៏ត្រូវឲ្យបរិវាសដែរ ។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិខ្លះ មិនដឹងខ្លះ ដឹងតែទីកំណត់រាត្រី រលឹកឃើញទីកំណត់អាបត្តិខ្លះ រលឹកមិនឃើញខ្លះ រលឹកឃើញតែទីកំណត់រាត្រី សង្ស័យក្នុងទីកំណត់អាបត្តិខ្លះ មិនសង្ស័យខ្លះ មិនសង្ស័យតែត្រង់ទីកំណត់រាត្រី សង្ឃក៏ត្រូវឲ្យបរិវាសដែរ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស យ៉ាងនេះឯង ។

ចប់បរិវាស ។

(៤៧១) សម័យនោះឯង មានភិក្ខុ ១ រូបកំពុងនៅបរិវាស ក៏ស្រាប់តែសឹកចេញទៅ ។ បុរសនោះបានត្រឡប់មកសូមឧបសម្បទានឹងភិក្ខុទាំងឡាយវិញ ។ ភិក្ខុទាំងនោះក៏នាំយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។

[៤៧២] ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ វិព្ភមតិ ។ វិព្ភន្តកស្ស ភិក្ខវេ បរិវាសោ ន រូហតិ ។ សោ ចេ បុន ឧបសម្បជ្ជតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ អវសេសោ បរិវសិតព្វោ ។

[៤៧៣] ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ សាមណេរោ ហោតិ ។ សាមណេរស្ស ភិក្ខវេ បរិវាសោ ន រូហតិ ។ សោ ចេ បុន ឧបសម្បជ្ជតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ អវសេសោ បរិវសិតព្វោ ។

(៤៧២) ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាសហើយសឹកចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ បរិវាសរបស់ភិក្ខុដែលសឹកចេញទៅហើយ មិនបានលូតលាស់ឡើងទេ ។ បើបុគ្គលនោះត្រឡប់មកបួសវិញទៀត ការដែលឲ្យបរិវាសអំពីមុនដល់ភិក្ខុនោះ ក៏នៅនឹងដដែល ។ បរិវាសណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ ឯបរិវាសដែលសល់ ភិក្ខុនោះត្រូវនៅទៀតចុះ ។

(៤៧៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាសហើយក៏ប្តូរខ្លួនជាសាមណេរវិញ ។ ម្នាលភិក្ខុទាំងឡាយ ឯបរិវាសរបស់សាមណេរនោះ ក៏មិនបានលូតលាស់ឡើងទេ ។ បើសាមណេរនោះមកបួសជាភិក្ខុវិញ ការដែលឲ្យបរិវាសពីមុនដល់ភិក្ខុនោះ ក៏នៅនឹងដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ ឯបរិវាសដែលសល់ ភិក្ខុនោះត្រូវនៅទៀតចុះ ។

(៤៧៤) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ ឧម្មត្តកោ ហោតិ ។ ឧម្មត្តកស្ស ភិក្ខវេ បរិវាសោ ន រូហតិ ។ សោ ចេ បុន អនុម្មត្តកោ ហោតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ អវសេសោ បរិវសិតព្វោ ។

(៤៧៥) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ ខិត្តចិត្តោ ហោតិ ។ ខិត្តចិត្តស្ស ភិក្ខវេ បរិវាសោ ន រូហតិ ។ សោ ចេ បុន អខិត្តចិត្តោ ហោតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ អវសេសោ បរិវសិតព្វោ ។

(៤៧៦) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ វេទនដ្ដោ ហោតិ ។ វេទនដ្ដស្ស ភិក្ខវេ បរិវាសោ ន រូហតិ ។

## សមុច្ចយក្ខន្ធក បរិវាសរបស់ភិក្ខុឆ្កួតជាដើមមិនលូតលាស់ឡើង

(៤៧៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាសហើយក៏ទៅជាមនុស្សឆ្កួត ។ ម្នាលភិក្ខុទាំងឡាយ បរិវាសរបស់ភិក្ខុដែលឆ្កួត មិនបានលូតលាស់ឡើងទេ ។ បើភិក្ខុនោះបាត់ឆ្កួតទៅវិញហើយ ការឲ្យបរិវាសពីមុនដល់ភិក្ខុនោះ ក៏នៅទីដដែល ។ បរិវាសណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ ឯបរិវាសដែលសល់ ភិក្ខុនោះត្រូវនៅទៀតចុះ ។

(៤៧៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាសហើយក៏មានចិត្តរវើរវាយ ។ ម្នាលភិក្ខុទាំងឡាយ ឯបរិវាសរបស់ភិក្ខុដែលមានចិត្តរវើរវាយ មិនបានលូតលាស់ឡើងទេ ។ បើភិក្ខុនោះបាត់រវើរវាយចិត្តទៅវិញហើយ ការឲ្យបរិវាសពីមុនដល់ភិក្ខុនោះក៏នៅទីដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុនោះបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ ឯបរិវាសដែលសល់ ភិក្ខុនោះត្រូវនៅទៀតចុះ ។

(៤៧៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាសហើយក៏មានទុក្ខវេទនាគ្របសង្កត់ ។ ម្នាលភិក្ខុទាំងឡាយ បរិវាសរបស់ភិក្ខុដែលមានទុក្ខវេទនាគ្របសង្កត់ មិនបានលូតលាស់ឡើងទេ ។

សោ ចេ បុន អនវជ្ជោ ហោតិ តស្ស តថេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ អវសេសោ បរិវសិតព្វោ ។

(៤៧៧) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ អាបត្តិយា អទស្សនេ ឧក្ខិបិយតិ ។ ឧក្ខិត្តកស្ស ភិក្ខវេ បរិវាសោ ន រុហតិ ។ សោ ចេ បុន ឱសារិយតិ តស្ស តថេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ អវសេសោ បរិវសិតព្វោ ។

(៤៧៨) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ អាបត្តិយា អប្បដិកម្មេ ឧក្ខិបិយតិ ។ ឧក្ខិត្តកស្ស ភិក្ខវេ បរិវាសោ ន រុហតិ ។ សោ ចេ បុន ឱសារិយតិ តស្ស តថេវ

បើភិក្ខុនោះត្រឡប់ជាឥតមានទុក្ខវេទនាគ្របសង្កត់វិញហើយ  ការឲ្យបរិ-វាសពីមុនដល់ភិក្ខុនោះក៏នៅនឹងដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយក៏ឈ្មោះថានៅល្អហើយ ។ បរិវាសដែលសល់ ភិក្ខុនោះត្រូវនៅទៀតចុះ ។

(៤៧៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិ-វាស ហើយសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិ ។ ម្នាលភិក្ខុទាំងឡាយបរិវាសរបស់ភិក្ខុដែលសង្ឃលើកវត្ត មិនបានលូតលាស់ឡើងទេ ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសារណកម្ម (បានឲ្យលាទោសចេញ) វិញហើយការឲ្យបរិវាសពីមុនដល់ភិក្ខុនោះ ក៏នៅនឹងដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ បរិវាសដែលសល់ ភិក្ខុនោះត្រូវនៅទៀតចុះ ។

(៤៧៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាសហើយសង្ឃលើកវត្តព្រោះមិនបានសំដែងអាបត្តិចេញ ។ ម្នាលភិក្ខុទាំង-ឡាយ បរិវាសរបស់ភិក្ខុដែលសង្ឃលើកវត្ត មិនបានលូតលាស់ឡើងទេ ។ បើភិក្ខុនោះសង្ឃបានធ្វើឱសារណកម្មវិញហើយ ការឲ្យបរិវាស

បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ អវសេសោ បរិវសិតព្វោ ។

(៦៧៩) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិបិយតិ ។ ឧក្ខិត្តកស្ស ភិក្ខវេ បរិវាសោ ន រូហតិ ។ សោ ចេ បុន ឱសារិយតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ អវសេសោ បរិវសិតព្វោ ។

(៦៨០) ឥធ បន ភិក្ខវេ ភិក្ខុ មូលាយ បដិកស្សនារហោ វិព្ភមតិ ។ វិព្ភន្តកស្ស ភិក្ខវេ មូលាយ បដិកស្សនា ន រូហតិ ។ សោ ចេ បុន ឧបសម្បជ្ជតិ តស្ស

ពីមុនដល់ភិក្ខុនោះក៏នៅទឹងដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ បរិវាសដែលសល់ ភិក្ខុនោះត្រូវនៅទៀតចុះ ។

(៤៧៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាសហើយ ស្រាប់តែសង្ឃលើកវត្តព្រោះមិនបានលះបង់ទិដ្ឋិលាមកចេញ ។ ម្នាលភិក្ខុទាំងឡាយ បរិវាសរបស់ភិក្ខុដែលសង្ឃលើកវត្ត មិនបានលុតលាស់ឡើងទេ ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសារណកម្មវិញហើយ ការឲ្យបរិវាសពីមុនដល់ភិក្ខុនោះ ក៏នៅទឹងដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ ឯបរិវាសដែលសល់ ភិក្ខុនោះត្រូវនៅទៀតចុះ ។

(៤៨០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះគួរនឹងទាញមកដាក់ក្នុងមូលាបត្តិហើយ ក៏ស្រាប់តែសឹកចេញទៅ ។ ការទាញភិក្ខុដែលសឹកចេញទៅ មកដាក់ក្នុងមូលាបត្តិ មិនបានលុតលាស់ឡើងទេ ។ បើបុគ្គលនោះត្រឡប់មកបួសវិញទៀត ការឲ្យបរិវាសពីមុនដល់ភិក្ខុនោ

តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ ។

[៤៨១] ឥធ បន ភិក្ខវេ ភិក្ខុ មូលាយ បដិកស្សនារហោ សាមណេរោ ហោតិ ។ បេ ។ ឧម្មត្តកោ ហោតិ ។ បេ ។ ខិត្តចិត្តោ ហោតិ ។ បេ ។ វេទនដ្ដោ ហោតិ ។ បេ ។ អាបត្តិយា អទស្សនេ ឧក្ខិបិយតិ ។ បេ ។ អាបត្តិយា អប្បដិកម្មេ ឧក្ខិបិយតិ ។ បេ ។ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិបិយតិ ។ ឧក្ខិត្តកស្ស ភិក្ខវេ មូលាយ បដិកស្សនា ន រូហតិ ។ សោ ចេ បុន ឱសារិយតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ ។

ក៏នៅទឹងដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ ភិក្ខុនោះ សង្ឃត្រូវទាញមកដាក់ក្នុងមូលាបត្តិ ។

(៤៨១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះគួរនឹងទាញមកដាក់ក្នុងមូលាបត្តិហើយ ក៏ប្តូរខ្លួនជាសាមណេរវិញ ។បេ។ ក៏ត្រឡប់ទៅជាឆ្កួត ។បេ។ ត្រឡប់ទៅជាមានចិត្តរវើរវាយ ។បេ។ ត្រឡប់ជាមានទុក្ខវេទនាគ្របសង្កត់ ។បេ។ សង្ឃលើកវត្តព្រោះមិនឃើញអាបត្តិ ។បេ។ សង្ឃលើកវត្តព្រោះមិនបានសំដែងអាបត្តិ ។បេ។ សង្ឃលើកវត្តព្រោះមិនបានលះបង់ទិដ្ឋិលាមកចេញ ។ ម្នាលភិក្ខុទាំងឡាយ ការទាញភិក្ខុដែលសង្ឃលើកវត្តមកដាក់ក្នុងមូលាបត្តិ មិនបានល្អគ្រលាស់ឡើងទេ ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសារណកម្មវិញហើយ ការឲ្យបរិវាសពីមុនដល់ភិក្ខុនោះ ក៏នៅទឹងដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ ឯភិក្ខុនោះ សង្ឃត្រូវទាញមកដាក់ក្នុងមូលាបត្តិចុះ ។

(៤៨២) ឥធ បន ភិក្ខវេ ភិក្ខុ មានត្តារហោ វិព្ភមតិ ។ វិព្ភន្តកស្ស ភិក្ខវេ មានត្តចារំ ន រូហតិ ។ សោ ចេ បុន ឧបសម្បជ្ជតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ តស្ស ភិក្ខុនោ មានត្តំ ទាតព្វំ ។

(៤៨៣) ឥធ បន ភិក្ខវេ ភិក្ខុ មានត្តារហោ សាមណេរោ ហោតិ ។ បេ ។ ឧម្មត្តកោ ហោតិ ។ បេ ។ ខិត្តចិត្តោ ហោតិ ។ បេ ។ វេទនដ្ដោ ហោតិ ។ បេ ។ អាបត្តិយា អទស្សនេ ឧក្ខិបិយតិ ។ បេ ។ អាបត្តិយា អប្បដិកម្មេ ឧក្ខិបិយតិ ។ បេ ។ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិបិយតិ ។ ឧក្ខិត្តកស្ស ភិក្ខវេ មានត្តចារំ ន រូហតិ ។ សោ ចេ បុន ឱសារិយតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។

(៤៨២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះគួរដល់មានត្ត ហើយ ក៏ត្រឡប់សឹកទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ ការឲ្យមានត្តដល់បុគ្គលដែលសឹកចេញ មិនបានលូតលាស់ឡើងទេ ។ បើបុគ្គលនោះត្រឡប់មកបួសវិញ ការឲ្យបរិវាសពីមុនដល់ភិក្ខុនោះ ក៏នៅទីដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុនោះនៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ សង្ឃត្រូវឲ្យមានត្តដល់ភិក្ខុនោះចុះ ។

(៤៨៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះគួរដល់មានត្ត ហើយ ក៏ប្តូរខ្លួនទៅជាសាមណេរវិញ ។បេ។ ត្រឡប់ទៅជាឆ្កួត ។បេ។ ត្រឡប់ជាមានចិត្តរវើរវាយ ។ បេ ។ ត្រឡប់ជាមានទុក្ខវេទនាគ្របសង្កត់ ។ បេ ។ សង្ឃលើកវត្តព្រោះមិនឃើញអាបត្តិ ។ បេ ។ សង្ឃលើកវត្តព្រោះមិនបានសំដែងអាបត្តិ ។ បេ ។ សង្ឃលើកវត្តព្រោះមិនបានលះបង់ទិដ្ឋិលាមកចេញ ។ ម្នាលភិក្ខុទាំងឡាយ ការឲ្យមានត្តដល់ភិក្ខុដែលសង្ឃលើកវត្ត មិនបានលូតលាស់ឡើងទេ ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសា-រណកម្មវិញហើយ ការឲ្យបរិវាសពីមុនដល់ភិក្ខុនោះ ក៏នៅទីដដែល ។

យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ តស្ស ភិក្ខុនោ មានត្តំ ទាតព្វំ ។

(៤៨៤) ឥធ បន ភិក្ខវេ ភិក្ខុ មានត្តំ ចរន្តោ វិព្ភមតិ ។ វិព្ភន្តកស្ស ភិក្ខវេ មានត្តចរិយា ន រូហតិ ។ សោ ចេ បុន ឧបសម្បជ្ជតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ យំ មានត្តំ ទិន្នំ សុទិន្នំ ។ យំ មានត្តំ ចិណ្ណំ សុចិណ្ណំ ។ អវសេសំ ចរិតព្វំ ។

(៤៨៥) ឥធ បន ភិក្ខវេ ភិក្ខុ មានត្តំ ចរន្តោ សាមណេរោ ហោតិ ។ បេ ។ ឧម្មត្តកោ ហោតិ ។ បេ ។ ខិត្តចិត្តោ ហោតិ ។ បេ ។ វេទនដ្ដោ ហោតិ ។ បេ ។ អាបត្តិយា អទស្សនេ ឧក្ខិបិយតិ ។ បេ ។ អាបត្តិយា អប្បដិកម្មេ ឧក្ខិបិយតិ ។ បេ ។ បាបិកាយ

បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ សង្ឃត្រូវឲ្យមានត្តដល់ភិក្ខុនោះចុះ ។

(៤៨៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងប្រព្រឹត្តមានត្តហើយក៏ស្រាប់តែសឹកចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ ការប្រព្រឹត្តិមានត្តរបស់ភិក្ខុដែលសឹកចេញទៅ មិនបានលូតលាស់ឡើងទេ ។ បើបុគ្គលនោះត្រឡប់មកបួសវិញទៀត ការឲ្យបរិវាសពីមុនដល់ភិក្ខុនោះ ក៏នៅទីដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ មានត្តឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ មានត្តឯណាដែលភិក្ខុបានសន្សំរួចហើយ ក៏ឈ្មោះថាសន្សំល្អហើយ ។ មានត្តដែលសល់ ភិក្ខុនោះត្រូវប្រព្រឹត្តទៅទៀតចុះ ។

(៤៨៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងប្រព្រឹត្តមានត្តហើយក៏ប្តូរខ្លួនទៅជាសាមណេរ ។បេ។ ត្រឡប់ទៅជាឆ្កួត ។បេ។ ត្រឡប់ទៅជាមានចិត្តរវើរវាយ ។បេ។ ត្រឡប់ជាមានទុក្ខវេទនាគ្របសង្កត់ ។បេ។ សង្ឃលើកវត្តព្រោះមិនឃើញអាបត្តិ ។បេ។ សង្ឃលើកវត្តព្រោះមិនសំដែងអាបត្តិ ។បេ។ សង្ឃលើកវត្តព្រោះមិនលះបង់ទិដ្ឋិលាមក

ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិបិយតិ ។ ឧក្ខិត្តកស្ស ភិក្ខវេ មានត្តចរិយា ន រូហតិ ។ សោ ចេ បុន ឱសារិយតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ យំ មានត្តំ ទិន្នំ សុទិន្នំ ។ យំ មានត្តំ ចិណ្ណំ សុចិណ្ណំ ។ អវសេសំ ចរិតព្វំ ។

(៤៨៦) ឥធ បន ភិក្ខវេ ភិក្ខុ អព្ភានារហោ វិព្ភមតិ ។ វិព្ភន្តកស្ស ភិក្ខវេ អព្ភានំ ន រូហតិ ។ សោ ចេ បុន ឧបសម្បជ្ជតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ យំ មានត្តំ ទិន្នំ សុទិន្នំ ។ យំ មានត្តំ ចិណ្ណំ សុចិណ្ណំ ។ សោ ភិក្ខុ អព្ភេតព្វោ ។

ចេញ ។ ម្នាលភិក្ខុទាំងឡាយ ការប្រព្រឹត្តិមានត្តរបស់ភិក្ខុដែលសង្ឃលើកវត្ត មិនបានលូតលាស់ឡើងទេ ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសារណៈកម្មវិញហើយ ការឲ្យបរិវាសពីមុនដល់ភិក្ខុនោះ ក៏នៅនឹងដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ មានត្តឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ មានត្តឯណាដែលភិក្ខុបានសន្សំរួចហើយ ក៏ឈ្មោះថាសន្សំល្អហើយ ។ មានត្តដែលសល់នៅ ភិក្ខុនោះត្រូវប្រព្រឹត្តតទៅទៀតចុះ ។

(៤៨៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះគួរដល់អព្ភានកម្មហើយ ក៏ស្រាប់តែសឹកចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ អព្ភានកម្មរបស់ភិក្ខុដែលសឹកចេញ មិនបានលូតលាស់ឡើងទេ ។ បើបុគ្គលនោះត្រឡប់មកបួសវិញ ការឲ្យបរិវាសពីមុនដល់ភិក្ខុនោះ ក៏នៅនឹងដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ មានត្តឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ មានត្តឯណាដែលភិក្ខុបានសន្សំរួចហើយ ក៏ឈ្មោះថាសន្សំល្អហើយ ។ ភិក្ខុនោះសង្ឃត្រូវឲ្យអព្ភានកម្មចុះ ។

[៤៨៧] ឥធ បន ភិក្ខវេ ភិក្ខុ អព្ភានារហោ សាមណេរោ ហោតិ ។ បេ ។ ឧម្មត្តកោ ហោតិ ។ បេ ។ ខិត្តចិត្តោ ហោតិ ។ បេ ។ វេទនដ្ដោ ហោតិ ។ បេ ។ អាបត្តិយា អទស្សនេ ឧក្ខិបិយតិ ។ បេ ។ អាបត្តិយា អប្បដិកម្មេ ឧក្ខិបិយតិ ។ បេ ។ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិបិយតិ ។ ឧក្ខិត្តកស្ស ភិក្ខវេ អព្ភានំ ន រូហតិ ។ សោ ចេ បុន ឱសារិយតិ តស្ស តទេវ បុរិមំ បរិវាសទានំ ។ យោ បរិវាសោ ទិន្នោ សុទិន្នោ ។ យោ បរិវុត្ថោ សុបរិវុត្ថោ ។ យំ មានត្តំ ទិន្នំ សុទិន្នំ ។ យំ មានត្តំ ចិណ្ណំ សុចិណ្ណំ ។ សោ ភិក្ខុ អព្ភេតព្ពោ ។

ចត្តាឡីសកំ សមត្តំ ។

[៤៨៨] ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិ-មាណាយោ (១) អប្បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្ពោ ។

---

១ ឱ. បរិមាណា ។

(៤៨៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវដល់អព្ភានកម្ម ហើយ ក៏ប្តូរខ្លួនទៅជាសាមណេរ ។ បេ ។ ត្រឡប់ទៅជាឆ្កួត ។ បេ ។ ត្រឡប់ទៅជាមានចិត្តរវើរវាយ ។ បេ ។ ត្រឡប់ទៅជាមានទុក្ខវេទនាគ្របសង្កត់ ។ បេ ។ សង្ឃលើកវត្តព្រោះមិនឃើញអាបត្តិ ។ បេ ។ សង្ឃលើកវត្តព្រោះមិនសំដែងអាបត្តិ ។ បេ ។ សង្ឃលើកវត្តព្រោះមិនលះបង់ទិដ្ឋិលាមកចេញ ។ ម្នាលភិក្ខុទាំងឡាយ អព្ភានកម្មរបស់ភិក្ខុដែលសង្ឃលើកវត្ត មិនបានលូតលាស់ឡើងទេ ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសារណកម្មវិញហើយ ការឲ្យបរិវាសពីមុនដល់ភិក្ខុនោះ ក៏នៅគង់ដដែល ។ បរិវាសឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ បរិវាសឯណាដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថានៅល្អហើយ ។ មានត្តឯណាដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថាឲ្យល្អហើយ ។ មានត្តឯណាដែលភិក្ខុបានសន្សំរួចហើយ ក៏ឈ្មោះថាសន្សំល្អហើយ ។ ភិក្ខុនោះសង្ឃត្រូវឲ្យអព្ភានកម្មចុះ ។

ចប់ការចំនួន ៤០ ។

(៤៨៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់បាន តែមិនបានបិទបាំងទុក ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិវិញ ។

(៤៨៩) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិមាណាយោ បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ យថាបដិច្ឆន្នានញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

(៤៩០) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិមាណាយោ បដិច្ឆន្នាយោបិ អប្បដិច្ឆន្នាយោបិ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ យថាបដិច្ឆន្នានញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

(៤៩១) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ អបរិមាណាយោ អប្បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ ។

## សមុច្ចយក្ខន្ធក (សង្ឃត្រូវឲ្យ) សមោធានបរិវាសចំពោះអាបត្តិខាងដើម

(៤៨៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់បាន ហើយបិទបាំងទុក ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ ទឹងចំពោះអាបត្តិខាងដើម ។

(៤៩០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់បាន តែបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ ទឹងចំពោះអាបត្តិខាងដើម ។

(៤៩១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនរាប់មិនបាន តែមិនបានបិទបាំងទុក ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ ។

(៤៩២) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ អបរិមាណាយោ បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ យថាបដិច្ឆន្នញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

(៤៩៣) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ អបរិមាណាយោ បដិច្ឆន្នាយោបិ អប្បដិច្ឆន្នាយោបិ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ យថាបដិច្ឆន្នញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

(៤៩៤) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិមាណាយោបិ អបរិមាណាយោបិ អប្បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ ។

(៤៩៥) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិមា-

(៤៩២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាសហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនកប់មិនបានហើយបិទបាំងទុក ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិរួចហើយត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។

(៤៩៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនកប់មិនបាន តែបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិរួចហើយត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិដែលបិទបាំងទុកប៉ុន្មានថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។

(៤៩៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួរកប់បានខ្លះ កប់មិនបានខ្លះ តែមិនបានបិទបាំងទុក ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ ។

(៤៩៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួរកប់

ណាយោបិ អបរិមាណាយោបិ បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ យថាបដិច្ឆន្នាញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

(៤៩៦) ឥធ បន ភិក្ខវេ ភិក្ខុ បរិវសន្តោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិមា-ណាយោបិ អបរិមាណាយោបិ បដិច្ឆន្នាយោបិ អប្ប-ដិច្ឆន្នាយោបិ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ យថាបដិច្ឆន្នាញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

(៤៩៧) ឥធ បន ភិក្ខវេ ភិក្ខុ មានត្តារហោ ។ បេ ។

(៤៩៨) ឥធ បន ភិក្ខវេ ភិក្ខុ មានត្តំ ចរន្តោ ។ បេ ។

(៤៩៩) ឥធ បន ភិក្ខវេ ភិក្ខុ អព្ភានារហោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិ-មាណាយោ អប្បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ ។

បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុក ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។

(៤៩៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ បិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។

(៤៩៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះគួរដល់មានត្ត ។ បេ ។

(៤៩៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកំពុងប្រព្រឹត្តមានត្ត ។ បេ ។

(៤៩៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះគួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់បានតែមិនបានបិទបាំងទុក ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ ។

(៥០០) ឥធ បន ភិក្ខវេ ភិក្ខុ មានត្តារហោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិមាណាយោ បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ យថាបដិច្ឆន្នានញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

(៥០១) ឥធ បន ភិក្ខវេ ភិក្ខុ មានត្តារហោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិមាណាយោ បដិច្ឆន្នាយោបិ អប្បដិច្ឆន្នាយោបិ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ យថាបដិច្ឆន្នានញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

(៥០២) ឥធ បន ភិក្ខវេ ភិក្ខុ មានត្តារហោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ អបរិមាណាយោ អប្បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ ។

(៥០៣) ឥធ បន ភិក្ខវេ ភិក្ខុ មានត្តារហោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ អបរិមាណាយោ បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ

(៥០០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះគួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់បាន ហើយបិទបាំងទុក ៗ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ នឹងចំពោះអាបត្តិខាងដើម ៗ

(៥០១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះគួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនរាប់បាន តែបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ ៗ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ រួចហើយឲ្យសមោធានបរិវាសដល់ភិក្ខុនោះ ចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ នឹងចំពោះអាបត្តិខាងដើម ៗ

(៥០២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះគួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនរាប់មិនបាន តែមិនបានបិទបាំងទុក ៗ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ ៗ

(៥០៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនរាប់មិនបាន ហើយបិទបាំងទុក ៗ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ

បដិកស្សិតព្វោ យថាបដិច្ឆន្នញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

(៨០៤) ឥធ បន ភិក្ខវេ ភិក្ខុ អព្ភានារហោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ អបរិមាណាយោ បដិច្ឆន្នាយោបិ អប្បដិច្ឆន្នាយោបិ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ យថាបដិច្ឆន្នញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

(៨០៥) ឥធ បន ភិក្ខវេ ភិក្ខុ អព្ភានារហោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិមាណាយោបិ អបរិមាណាយោបិ អប្បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ ។

(៨០៦) ឥធ បន ភិក្ខវេ ភិក្ខុ អព្ភានារហោ អន្តរា សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិមាណាយោបិ អបរិមាណាយោបិ បដិច្ឆន្នាយោ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ យថាបដិច្ឆន្នញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

រួចហើយត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះ ចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។

(៤០៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនរាប់មិនបាន តែបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។

(៤០៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ តែមិនបានបិទបាំងទុក ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ ។

(៤០៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុក ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ នឹងចំពោះអាបត្តិខាងដើម ។

(៥០៧) ឥធ បន ភិក្ខវេ ភិក្ខុ អញ្ញាណារហោ អន្តក សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ បរិមាណាយោបិ អបរិមាណាយោបិ បដិច្ឆន្នាយោបិ អប្បដិច្ឆន្នាយោបិ ។ សោ ភិក្ខុ មូលាយ បដិកស្សិតព្វោ យថាបដិច្ឆន្នានញ្ចស្ស អាបត្តីនំ បុរិមាយ អាបត្តិយា សមោធានបរិវាសោ ទាតព្វោ ។

ឆត្តឹសកំ សមត្តំ ។

(៥០៨) ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិត្វា អប្បដិច្ឆាទេត្វា វិព្ភមតិ ។ សោ បុន ឧបសម្បន្នោ តា អាបត្តិយោ ន ឆាទេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ មានត្តំ ទាតព្វំ ។

(៥០៩) ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃា-ទិសេសា អាបត្តិយោ អាបជ្ជិត្វា អប្បដិច្ឆាទេត្វា វិព្ភម-តិ ។ សោ បុន ឧបសម្បន្នោ តា អាបត្តិយោ ឆាទេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បច្ឆិមស្មឹ អាបត្តិក្ខន្ធេ យថាប-ដិច្ឆន្នេ បរិវាសំ ទត្វា មានត្តំ ទាតព្វំ ។

(៩០៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះគួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ តែបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ ។ សង្ឃត្រូវទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាសដល់ភិក្ខុនោះចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ ទាំងចំពោះអាបត្តិខាងដើម ។

ចប់ភារចំនួន ១៦ ។

(៩០៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែមិនបានបិទបាំងទុក ក៏សឹកចេញទៅ ។ បុគ្គលនោះត្រឡប់មកបួសវិញ ហើយក៏មិនបានបិទបាំងអាបត្តិទាំងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យមានត្តដល់ភិក្ខុនោះតែម្តងចុះ ។

(៩០៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែមិនបានបិទបាំងទុក ក៏សឹកចេញទៅ ។ បុគ្គលនោះត្រឡប់មកបួសវិញ ហើយក៏បិទបាំងទុកអាបត្តិទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសចំពោះក្នុងអាបត្តិដែលភិក្ខុបិទបាំងទុកខាងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្តដល់ភិក្ខុនោះ ។

[៤១០] ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិត្វា បដិច្ឆាទេត្វា វិព្ភមតិ ។ សោ បុន ឧបសម្បន្នោ តា អាបត្តិយោ ន ឆាទេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមស្មឹ អាបត្តិក្ខន្ធេ យថាបដិច្ឆន្នេ បរិវាសំ ទត្វា មានត្តំ ទាតព្វំ ។

[៤១១] ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិត្វា បដិច្ឆាទេត្វា វិព្ភមតិ ។ សោ បុន ឧបសម្បន្នោ តា អាបត្តិយោ ឆាទេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមស្មិញ្ច បច្ឆិមស្មិញ្ច អាបត្តិក្ខន្ធេ យថាបដិច្ឆន្នេ បរិវាសំ ទត្វា មានត្តំ ទាតព្វំ ។

[៤១២] ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ ។ តស្ស ហោន្តិ អាបត្តិយោ បដិច្ឆន្នាយោបិ អប្បដិច្ឆន្នាយោបិ ។ សោ វិព្ភមិត្វា បុន ឧបសម្បន្នោ យា អាបត្តិយោ បុព្វេ ឆាទេសិ តា អាបត្តិយោ បច្ឆា ន ឆាទេតិ យា អាបត្តិយោ បុព្វេ ន ឆាទេសិ តា អាបត្តិយោ បច្ឆា

(៤១០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយបិទបាំងទុក ក៏សឹកចេញទៅ ។ លុះបុគ្គលនោះត្រឡប់មកបួសវិញ ហើយបេក៏មិនបានបិទបាំងទុកអាបត្តិទាំងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសចំពោះកងអាបត្តិដែលភិក្ខុបិទបាំងទុកពីមុនប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្តដល់ភិក្ខុនោះ ។

(៤១១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយបិទបាំងទុក ក៏សឹកចេញទៅ ។ លុះបុគ្គលនោះត្រឡប់មកបួសវិញ ក៏បិទបាំងអាបត្តិទាំងនោះទុកទៀត ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសចំពោះកងអាបត្តិដែលភិក្ខុបិទបាំងទុកទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្តដល់ភិក្ខុនោះចុះ ។

(៤១២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ។ តែអាបត្តិទាំងនោះភិក្ខុនោះបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ ។ ភិក្ខុនោះសឹកចេញទៅ ហើយក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណាដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសខាងក្រោយក៏ត្រឡប់ជាមិនបិទបាំងពួកអាបត្តិនោះវិញ ពួកអាបត្តិណាដែលខ្លួនមិនបានបិទបាំងទុកពីមុន ដល់មកបួសខាងក្រោយ ក៏នៅតែមិនបិទបាំងទុកពួកអាបត្តិ

ន ជានាតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមស្មឹ[១] អាបត្តិក្ខន្ធេ យថាបដិច្ឆន្នេ បរិវាសំ ទត្វា មានត្តំ ទាតព្វំ ។

(៤១៣) ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ ។ តស្ស ហោន្តិ អាបត្តិយោ បដិច្ឆន្នាយោបិ អប្បដិច្ឆន្នាយោបិ ។ សោ វិព្ភមិត្វា បុន ឧបសម្បន្នោ យា អាបត្តិយោ បុព្វេ ជានេសិ តា អាបត្តិយោ បច្ឆា ន ជានាតិ យា អាបត្តិយោ បុព្វេ ន ជានេសិ តា អាបត្តិយោ បច្ឆា ជានាតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមស្មិញ្ច បច្ឆិមស្មិញ្ច អាបត្តិក្ខន្ធេ យថាបដិច្ឆន្នេ បរិវាសំ ទត្វា មានត្តំ ទាតព្វំ ។

(៤១៤) ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ ។ តស្ស ហោន្តិ អាបត្តិយោ បដិច្ឆន្នាយោបិ អប្បដិច្ឆន្នាយោបិ ។ សោ វិព្ភមិត្វា បុន ឧបសម្បន្នោ យា អាបត្តិយោ បុព្វេ

---

១ ឱ. បុរិមស្មិញ្ច បច្ឆិមស្មិញ្ច ។

នោះដដែល ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសចំពោះគង់អាបត្តិដែលភិក្ខុបិទបាំងទុកពីមុនប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្តដល់ភិក្ខុនោះចុះ ។

(៩១៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ។ តែអាបត្តិទាំងនោះភិក្ខុនោះបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ ។ ភិក្ខុនោះសឹកចេញទៅហើយក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណាដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយក៏ត្រឡប់ជាមិនបិទបាំងពួកអាបត្តិនោះទុកវិញ ពួកអាបត្តិណាដែលខ្លួនមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយក៏ត្រឡប់ជាបិទបាំងពួកអាបត្តិនោះទុកវិញ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសចំពោះគង់អាបត្តិដែលភិក្ខុបិទបាំងទុកទាំងមុនទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្តដល់ភិក្ខុនោះចុះ ។

(៩១៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ។ តែអាបត្តិទាំងនោះភិក្ខុបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ ។ ភិក្ខុនោះសឹកចេញទៅហើយក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា

ជានេសិ តា អាបត្តិយោ បច្ឆា ជានេតិ យា អាបត្តិយោ បុព្វេ ន ជានេសិ តា អាបត្តិយោ បច្ឆា ន ជានេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមស្មិញ្ច បច្ឆិមស្មិញ្ច អាបត្តិក្ខន្ធេ យថាបដិច្ឆន្នេ បរិវាសំ ទត្វា មានត្តំ ទាតព្វំ ។

(៥១៥) ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ ។ តស្ស ហោន្តិ អាបត្តិយោ បដិច្ឆន្នាយោបិ អប្បដិច្ឆន្នាយោបិ ។ សោ វិព្ភមិត្វា បុន ឧបសម្បន្នោ យា អាបត្តិយោ បុព្វេ ជានេសិ តា អាបត្តិយោ បច្ឆា ជានេតិ យា អាបត្តិយោ បុព្វេ ន ជានេសិ តា អាបត្តិយោ បច្ឆា ជានេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមស្មិញ្ច បច្ឆិមស្មិញ្ច អាបត្តិក្ខន្ធេ យថាបដិច្ឆន្នេ បរិវាសំ ទត្វា មានត្តំ ទាតព្វំ ។

(៥១៦) ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ ឯកច្ចា អាបត្តិយោ ជានាតិ ឯកច្ចា អាបត្តិយោ ន ជានាតិ យា

ដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយក៏បិទបាំងពួកអាបត្តិនោះទុកទៀត ពួកអាបត្តិណាដែលខ្លួនមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយក៏មិនបានបិទបាំងពួកអាបត្តិនោះទុកទៀត ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសចំពោះកងអាបត្តិដែលភិក្ខុបិទបាំងទុកទាំងមុនទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្តដល់ភិក្ខុនោះចុះ ។

(៤១៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ។ តែអាបត្តិទាំងនោះភិក្ខុនោះបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ ។ ភិក្ខុនោះសឹកចេញទៅហើយក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណាដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយក៏ឈ្មោះថាបិទបាំងពួកអាបត្តិនោះទុកទៀត ពួកអាបត្តិណាដែលខ្លួនមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយក៏ត្រឡប់ជាបិទបាំងពួកអាបត្តិនោះទុកវិញ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសចំពោះកងអាបត្តិដែលបិទបាំងទុកទាំងមុនទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្តដល់ភិក្ខុនោះចុះ ។

(៤១៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ ស្គាល់

អាបត្តិយោ ជានាតិ តា អាបត្តិយោ ឆាទេតិ យា អាបត្តិយោ ន ជានាតិ តា អាបត្តិយោ ន ឆាទេតិ ។ សោ វិព្ភមិត្វា បុន ឧបសម្បន្នោ យា អាបត្តិយោ បុព្វេ ជានិត្វា ឆាទេសិ តា អាបត្តិយោ បច្ឆា ជានិត្វា ន ឆាទេតិ យា អាបត្តិយោ បុព្វេ អជានិត្វា ន ឆាទេសិ តា អា-បត្តិយោ បច្ឆា ជានិត្វា ន ឆាទេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមស្មឹ អាបត្តិក្ខន្ធេ យថាបដិច្ឆន្នេ បរិវាសំ ទត្វា មានត្តំ ទាតព្វំ ។

(៥១៧) ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ ឯកច្ចា អាបត្តិយោ ជានាតិ ឯកច្ចា អាបត្តិយោ ន ជានាតិ យា អាបត្តិយោ ជានាតិ តា អាបត្តិយោ ឆាទេតិ យា អាបត្តិយោ ន ជានាតិ តា អាបត្តិយោ ន ឆាទេតិ ។ សោ វិព្ភមិត្វា បុន ឧបសម្បន្នោ យា អាបត្តិយោ បុព្វេ ជានិត្វា ឆាទេសិ តា អាបត្តិយោ បច្ឆា ជានិត្វា ន ឆាទេតិ យា អាបត្តិយោ បុព្វេ អជានិត្វា ន ឆាទេសិ

អាបត្តិណា ក៏បិទបាំងអាបត្តិនោះទុក មិនស្គាល់អាបត្តិណា ក៏មិនបានបិទបាំងអាបត្តិនោះទុកទេ ។ ភិក្ខុនោះសឹកចេញទៅហើយក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណាដែលខ្លួនស្គាល់ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយក៏មិនបិទបាំងពួកអាបត្តិដែលខ្លួនស្គាល់នោះទុក ពួកអាបត្តិណាដែលខ្លួនមិនស្គាល់ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយក៏ត្រឡប់ជាស្គាល់ ហើយមិនបានបិទបាំងពួកអាបត្តិនោះទុក ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសចំពោះកងអាបត្តិដែលភិក្ខុបិទបាំងទុកពីមុនប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្តដល់ភិក្ខុនោះចុះ ។

(៥១៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ ស្គាល់ពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក មិនស្គាល់ពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកទេ ។ ភិក្ខុនោះសឹកចេញទៅហើយក៏ត្រឡប់មកបួសវិញ ស្គាល់ពួកអាបត្តិណាដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយក៏ត្រឡប់ជាមិនបិទបាំងអាបត្តិដែលស្គាល់នោះទុក មិនស្គាល់ពួកអាបត្តិណាដែលមិនបានបិទបាំងទុកពីមុន ដល់មក

តា អាបត្តិយោ បច្ឆា ជានិត្វា ឆាទេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមស្មិញ្ច បច្ឆិមស្មិញ្ច អាបត្តិក្ខន្ធេ យថាប-ដិច្ឆន្នេ បរិវាសំ ទត្វា មានត្តំ ទាតព្វំ ។

(៨១៨) ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជតិ ឯកច្ចា អាបត្តិយោ ជានាតិ ឯកច្ចា អាបត្តិយោ ន ជានាតិ យា អាបត្តិ-យោ ជានាតិ តា អាបត្តិយោ ឆាទេតិ យា អាបត្តិយោ ន ជានាតិ តា អាបត្តិយោ ន ឆាទេតិ ។ សោ វិព្ភមិត្វា បុន ឧបសម្បន្នោ យា អាបត្តិយោ បុព្វេ ជានិត្វា ឆាទេសិ តា អាបត្តិយោ បច្ឆា ជានិត្វា ឆាទេតិ យា អាបត្តិយោ បុព្វេ អជានិត្វា ន ឆាទេសិ តា អាបត្តិយោ បច្ឆា ជានិត្វា ន ឆាទេតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមស្មិញ្ច បច្ឆិមស្មិញ្ច អាបត្តិក្ខន្ធេ យថាបដិច្ឆន្នេ បរិវាសំ ទត្វា មានត្តំ ទាតព្វំ ។

(៨១៩) ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃា-ទិសេសា អាបត្តិយោ អាបជ្ជតិ ឯកច្ចា អាបត្តិយោ ជា-នាតិ ឯកច្ចា អាបត្តិយោ ន ជានាតិ យា អាបត្តិយោ

